មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង
ក្រសួងទេសចរណ៍ និងមជ្ឈមណ្ឌលឯកសារកម្ពុជា



**ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង**
**តំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម**

គ្រីស្តូហ្វ័រ ឌៀរីង និង បណ្ឌិត លី សុខឃាង
ប្រែសម្រួលជាភាសាខ្មែរ សុភ័ក្រ្ត ភាណា

# សៀវភៅណែនាំ
# សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង
ក្រសួងទេសចរណ៍ និងមជ្ឈមណ្ឌលឯកសារកម្ពុជា



## ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែងៈ
## តំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម

គ្រីស្តូហ្វ័រ ឌៀរីង និង បណ្ឌិត លី សុខឃាង
ប្រែសម្រួលជាភាសាខ្មែរ សុភ័ក្រ ភាណា

# សៀវភៅណែនាំ
# សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍

# Esovk karBitedIn, karcgcaMy ytulFm’ mCÄm NÐDÉk ßrkmÉa karcgcaMy ytulFm’

«...សង្គមមួយមិនអាចស្គាល់ខ្លួនឯងបានទេប្រសិនបើសង្គមនោះមិនមានការចងចាំច្បាស់លាស់អំពីប្រវត្តិសាស្ត្ររបស់ខ្លួន» -- ឆាំង យុ

ប្រអប់សំបុត្រលេខ១១១០ ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ៖ (៨៨៥) ២៣ ២១១ ៨៧៥, (៨៨៥) ១២ ៩០៥ ៥៩៥
ទូរសារលេខ៖ (៨៨៥) ២៣ ២១០ ៣៥៨
អ៊ីមែល៖ dccam@online.com.kh

ជាមួយនឹងអនាគតរបស់តុលាការខ្មែរក្រហម ដែលកាត់ក្តីត្រឹមតែមេដឹកនាំជាន់ខ្ពស់នៃខ្មែរក្រហមមួយចំនួនតូច ព្រមទាំងប្រជាជនប្រមាណជាង៧០% ជាអ្នកដែលកើតក្រោយរបបប្រល័យពូជសាសន៍របស់ខ្មែរក្រហម កម្ពុជាកំពុងតែឈានទៅដល់ចំណុចផ្លាស់ប្តូរយ៉ាងសំខាន់។ នៅជ្រុងម្ខាងប្រជាជនកម្ពុជាកំពុងតែប្រឈមមុខនឹងការបាត់បង់ការយល់ដឹង និងការចងចាំ ដែលឈានដល់ការទទួលយកអតីតកាលដ៏ជូរចត់នៃរបបខ្មែរក្រហម។ ចំណែកនៅឯជ្រុងម្ខាងទៀត ប្រទេសកម្ពុជាដែលកំពុងតែធ្វើសកលភាវូបនីយកម្មដ៏ឆាប់រហ័ស ត្រូវតែខិតខំជម្នះឧបសគ្គថ្មីៗនៃការសម្រេចឲ្យបាននូវការរីកលូតលាស់ប្រកបដោយនិរន្តរភាពបូរណភាពប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។

**ដៃគូ**

គេហទំព័រឃ្លាំមើលការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម | www.cambodiatribunal.org
វិទ្យាស្ថានស្លឹករឹត | www.cambodiasri.org
Zaha Hadid Architects | www.zaha-hadid.com
Genocide Watch | www.genocidewatch.com

**សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍**

ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ តំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម
គ្រីស្តូហ្វ័រ ឌៀរីង និងបណ្ឌិត លី សុខឃាង

ប្រែសម្រួលដោយ៖ បណ្ឌិត លី សុខឃាង និង សុភ័ក្ត្រ ភាណា

១) កម្ពុជា-ប្រវត្តិសាស្ត្រ-សិទ្ធិមនុស្ស-ការអប់រំ
២) កម្ពុជា-នយោបាយនិងរដ្ឋាភិបាល-១៩៧៥-១៩៧៩
៣) កម្ពុជា-ប្រវត្តិសាស្ត្រ-១៩៧៥-១៩៧៩

ជំនួយទ្រទ្រង់សម្រាប់គម្រោង ត្រូវបានផ្តល់ឲ្យដោយទីភ្នាក់ងារស្វីសដើម្បីកិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍ រួមជាមួយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ។

ទស្សនៈដែលឆ្លុះបញ្ចាំងនៅក្នុងសៀវភៅ គឺជាគំនិតរបស់អ្នកនិពន្ធ ដែលមិនបង្ហាញពីជំហររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ។
រក្សាសិទ្ធិ ឆ្នាំ២០១៧ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងទេសចរណ៍។

រក្សាសិទ្ធិគ្រប់យ៉ាង។ មិនមានផ្នែកណាមួយនៃសៀវភៅ អាចបោះពុម្ពឡើងវិញ ឬប្រើប្រាស់ក្នុងទម្រង់ ឬក្នុងមធ្យោបាយណាមួយ ដែលរួមមានការថតចម្លងការកត់ត្រា ឬការថតទុកនៅក្នុងប្រព័ន្ធផ្ទុកព័ត៌មានផ្សេងៗ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកបោះពុម្ពបានឡើយ។

គំនិតរចនាសៀវភៅ និងគំនិតសិល្បៈ៖ ឆាំង យុ
កុំព្យូទ័រការី៖ គឹម សុវណ្ណដានី

ISBN: 978-9924-9078-1-7
បោះពុម្ពនៅកម្ពុជា



បណ្ឌិត លី សុខឃាង កំពុងធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រអន្លង់វែងទៅកាន់សិស្សបំពេញទស្សនកិច្ចសិក្សានៅអន្លង់វែង។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

# អារម្ភកថា

សៀវភៅប្រៀបបានទៅនឹងមនុស្ស នៅក្នុងន័យមួយដែលថា ជាញឹកញាប់ យើងតែងតែផ្សារភ្ជាប់សៀវភៅទៅនឹងកន្លែងដាក់លាក់មួយ។ ឧទាហរណ៍ សៀវភៅសាសនាមានការពេញនិយមនៅកន្លែងគោរពប្រតិបត្តិសាសនា សៀវភៅសិក្សាក្រាស់ៗស្ថិតនៅក្នុងសាលារៀន និងបណ្ណាល័យ សៀវភៅប្រលោមលោកខ្លីៗ ជាទូទៅស្ថិតនៅជាមួយអ្នកធ្វើការក្នុងការិយាល័យ និងអ្នកធ្វើដំណើរសម្រាប់អានពេលទំនេរពីកិច្ចការ ឬពេលធ្វើដំណើរ។ សៀវភៅផ្តល់ព័ត៌មានបណ្តុះគំនិត និងជំរុញលើកទឹកចិត្តអ្នកអាន។ សៀវភៅគឺជាគ្រាប់ពូជនៃក្តីស្រមៃរបស់យើង និងជាមេរៀនមួយដែលយើងបានបំភ្លេច ខណៈពេលបច្ចេកវិទ្យាទំនើបៗកំពុងរីកដុះដាលគ្មានទីបញ្ចប់។ ខ្ញុំយល់ឃើញថា វាជារឿងល្អមួយដែលអ្នកនិពន្ធយកស្ថានភាពនៃទីកន្លែងមកពិចារណា ជាពិសេសនៅពេលដែលអ្នកនិពន្ធពិតជាចង់ផ្សារភ្ជាប់ការងាររបស់ខ្លួនទៅនឹងអ្នកអាន។

យើងស្រមៃឃើញមនុស្សកំពុងតែអានសៀវភៅនៅជិតទីតាំងប្រវត្តិសាស្ត្រ ឬនៅក្នុងថ្នាក់រៀន មិនឆ្ងាយប៉ុន្មានពីតំបន់អន្លង់វែង និងប្រជាជនដែលរស់នៅក្នុងតំបន់។ ទីតាំងមានលក្ខណៈសមស្រប ពីព្រោះអ្នកនិពន្ធមានចេតនាផ្តោតទៅលើភាពជាមនុស្សរបស់ចលនាខ្មែរក្រហម។

ការនិពន្ធដែលផ្តោតទៅលើមនុស្ស ជាជាងក្រុមនៃមនុស្ស ស្ថានភាព និងព្រឹត្តិការណ៍មានគុណសម្បត្តិ និងគុណវិបត្តិ។ គុណសម្បត្តិនៃការនិពន្ធ គឺបានបង្ហាញអំពីភាពស្មុគស្មាញនៃមនសិការបស់មនុស្ស នៅក្នុងអំឡុងពេលនៃសង្គ្រាម អំពើឃោរឃៅ និងភាពចលាចលនៅក្នុងសង្គម។ គុណវិបត្តិនៃវិធីសាស្ត្រនិពន្ធ គឺយើងត្រូវបានដាក់ឲ្យប្រឈមទៅនឹងការពិតដ៏លំបាកទទួលយកមួយ ដែលថាជនដៃដល់ក៏មានមុខមាត់ជាមនុស្សដូចយើង។

អំពើឧក្រិដ្ឋកម្មទាំងអស់ត្រូវបានប្រព្រឹត្តឡើងដោយមនុស្ស វាប្រហែលជាលំបាកសម្រាប់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម ពីព្រោះវាហួសពីអ្វីដែលជនរងគ្រោះអាចស្រមៃឃើញ។ ជាធម្មជាតិ ជនរងគ្រោះចង់កាត់ផ្តាច់ទំនាក់ទំនងពីជនដៃដល់ អ្នកសមគំនិត និងក្រុមគ្រួសាររបស់ជនដៃដល់ចេញពីសង្គមទាំងមូល។ ការឆ្លើយតបហាក់ដូចជាការផ្តល់តម្លៃដ៏អាក្រក់មួយ ដែលសង្គមត្រូវតែសងត្រឡប់មកវិញ នៅពេលធ្វើដំណើរទៅមុខ។ ទោះជាយ៉ាងនេះក្តី នៅក្នុងដំណើរវែងឆ្ងាយទៅមុខ ទង្វើបែបនេះមិនមែនជាចម្លើយសម្រាប់សង្គមកម្ពុជាទេ។ ដើម្បីឲ្យប្រទេសកម្ពុជាធ្វើដំណើរទៅមុខយើងត្រូវប្រឈមមុខទៅនឹងការពិតដ៏លំបាកដែលថា ខ្មែរក្រហមក៏ជាមនុស្សដូចយើងគ្រប់គ្នា។

ប្រសិនបើប្រវត្តិសាស្ត្រ នឹងត្រូវក្លាយទៅជាមគ្គុទ្ទេសក៍ប្រកបដោយប្រសិទ្ធភាព និងពិតប្រាកដមួយសម្រាប់អនាគត យើងត្រូវតែទទួលស្គាល់តម្រូវការដែលគ្មានទីបញ្ចប់នៅក្នុងការសិក្សាពីគ្រប់ទិដ្ឋភាពទាំងអស់ នៃអតីតកាលរបស់យើង រួមទាំងអតីតកាលប្រកបដោយភាពស្មុគស្មាញ និងពិបាកបកស្រាយផង។ យុត្តិធម៌នឹងមិនអាចកើតឡើងមានបានទេ នៅក្នុងស្ថានភាពដែលគ្មានការយល់ដឹង ការអត់ឱន និងការផ្សះផ្សា នឹងកើតមានពិតប្រាកដ ប្រសិនបើយើងសុខចិត្តទទួលស្គាល់គ្នាជាមនុស្សទៅវិញទៅមក។

សៀវភៅ «សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍»នឹងចូលរួមចំណែកដើម្បីសម្រេចឲ្យបាននូវស្មារតីទាំងនេះ។ ប៉ុន្តែសៀវភៅនេះគ្រាន់តែជាចំណែកតូចមួយ នៅក្នុងការតស៊ូ ស្វែងរកយុត្តិធម៌ទូលំទូលាយមួយនៅក្នុងប្រទេសកម្ពុជា។ យើងត្រូវការការចាប់ផ្តើម ដើម្បីស្វែងរកទីបញ្ចប់មួយប្រសិនបើមាន។ ទោះបីជាតំបន់អន្លង់វែងមានសន្តិភាពជិត២០ឆ្នាំយ៉ាងណាក៏ដោយ ក៏យើងត្រូវចងចាំថា សន្តិភាព និងយុត្តិធម៌ត្រូវដើរទន្ទឹមគ្នា ដើម្បីឲ្យសង្គមមួយធ្វើដំណើរទៅមុខបាន។ ជោគវាសនារបស់ប្រទេសកម្ពុជាអាស្រ័យទៅលើការទទួលស្គាល់ និងការឲ្យតម្លៃទៅលើការពិត ក្នុងនាមជាបុគ្គល ជាសហគមន៍ និងជាប្រទេសជាតិមួយទាំងមូល។

**ឯកឧត្តម បណ្ឌិត ថោង ខុន**
រដ្ឋមន្ត្រីក្រសួងទេសចរណ៍
ប្រធានគណៈកម្មការអន្តរក្រសួង
ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង



ឯកឧត្តមបណ្ឌិត ថោង ខុន (នៅជួរមុខទីបួនរាប់ពីខាងឆ្វេង) រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ធ្វើជាអធិបតីក្នុងកិច្ចប្រជុំដែលត្រូវបានប្រារព្ធឡើងនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ នៅក្នុងសាលាខេត្តឧត្តរមានជ័យ។ មានវត្តមាននៅក្នុងកិច្ចប្រជុំគឺ អភិបាលខេត្តឧត្តរមានជ័យ ឯកឧត្តម ស ថាវី (នៅជួរមុខទីបី រាប់ពីខាងឆ្វេង) និងតំណាងរបស់ក្រសួងមន្ទីរផ្សេងៗនិងមជ្ឈមណ្ឌលឯកសារកម្ពុជា។ បន្ទាប់ពីបានស្តាប់ឯកឧត្តម ស ថាវី ធ្វើបទបង្ហាញពីរបាយការណ៍ខ្លីស្តីពីទីតាំងប្រវត្តិសាស្ត្រទាំងដប់បួននៅក្នុងសហគមន៍អន្លង់វែងមក ឯកឧត្តមបណ្ឌិត ថោង ខុន បានផ្តល់វេទិកាជូនដល់ មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោក វ៉ាន់ថាន់ ពៅដារ៉ា (នៅជួរមុខខាងស្តាំ) នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា បានថ្លែងអំណរគុណចំពោះ ឯកឧត្តមបណ្ឌិត ថោង ខុន និងគណៈកម្មការទាំងឡាយដែលបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការគ្រប់គ្រង និងអភិវឌ្ឍតំបន់អន្លង់វែង។ បន្ទាប់មកទៀត បណ្ឌិត លី សុខឃាង (នៅជួរទីពីរនិងទីពីររាប់ពីខាងឆ្វេង) នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានចាប់ផ្តើមបទបង្ហាញដោយបង្ហៃការយកចិត្តទុកដាក់របស់អ្នកមានវត្តមានទៅកាន់កិច្ចការដែលត្រូវបានផ្តល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយគណៈកម្មាការអន្តរក្រសួង ព្រមជាមួយនឹងសមិទ្ធផល និងផែនការនាពេលអនាគតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ប្រភពព័ត៌មានៈ ក្រសួងទេសចរណ៍។

# មាតិកា


មាតិកា ៦

រប្រៀបប្រើប្រាស់សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ៨

ហេតុផលក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ១០

ទស្សនវិជ្ជានៃសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍អំពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង ១២

ជំពូកទី១៖ បទបង្ហាញ គន្លឹះណែនាំ និងសកម្មភាពបង្រៀន ១៧

ផ្នែកទី១៖ សេចក្តីផ្តើម ១៧

ផ្នែកទី២៖ បទបង្ហាញបែបប្រវត្តិសាស្ត្រ ១៩

បទបង្ហាញទី១៖ ប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា ១៩

បទបង្ហាញទី២៖ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ២៥

បទបង្ហាញទី៣៖ ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ ផ្នែកទី១ ៣០

បទបង្ហាញទី៤៖ ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ ផ្នែកទី២ ៣៦

ជំពូកទី២៖ ការរៀបរាប់សាច់រឿង ៤៥

ផ្នែកទី១៖ សេចក្តីផ្តើម ៤៥

ផ្នែកទី២៖ សាច់រឿងស្តីពីអន្លង់វែង មុនពេលនៃការងើបឡើងរបស់ខ្មែរក្រហម ៤៧

ផ្នែកទី៣៖ សាច់រឿងស្តីពីអន្លង់វែងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ៥១

ផ្នែកទី៤៖ សាច់រឿងស្តីពីការរត់គេចខ្លួន បន្លាស់ទី និងការរស់រានមានជីវិតក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ៥៤

ផ្នែកទី៥៖ សាច់រឿងស្តីពីជម្លោះនិងការរស់រានមានជីវិត (១៩៧៩ ~ ១៩៨៩) ៥៨

ផ្នែកទី៦៖ សាច់រឿងស្តីពីជីវិតនៅក្នុងមូលដ្ឋានយោធាខ្មែរក្រហម (១៩៧៩ ~ ១៩៨៩) ៦២

ផ្នែកទី៧៖ សាច់រឿងស្តីពីការវិលត្រឡប់របស់ខ្មែរក្រហមមកអន្លង់វែង ៦៥

ផ្នែកទី៨៖ សាច់រឿងស្តីពី តាម៉ុក នៅតំបន់អន្លង់វែង ៦៧

ផ្នែកទី៩៖ សាច់រឿងស្តីពីការពិនិត្យមើលតំបន់អន្លង់វែងឡើងវិញ ៦៩

ជំពូកទី៣៖ ទីតាំងប្រវត្តិសាស្ត្រ ៧៣

ផ្នែកទី១៖ សេចក្តីផ្តើម ៧៣

ផ្នែកទី២៖ ទីតាំងប្រវត្តិសាស្ត្រ ៧៣

ជំពូកទី៤៖ ផែនការបង្រៀន ៩៣

ផ្នែកទី១៖ សេចក្តីណែនាំ ៩៣

ផ្នែកទី២៖ ផែនការបង្រៀន ៩៣

ប្រធានបទទី១៖ ប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា ៩៣

ប្រធានបទទី២៖ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ៩៥

ប្រធានបទទី៣៖ ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី ១) ៩៨

ប្រធានបទទី៤៖ ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី ២) ១០១

ជំពូកទី៥៖ កម្រងសំណួរចម្លើយ ១០៧

សំណួរ និងចម្លើយ នៅក្នុងមេរៀនស្តីពីប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា ១០៧

សំណួរ និងចម្លើយ នៅក្នុងមេរៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១០៨

សំណួរ និងចម្លើយ នៅក្នុងមេរៀនស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ ផ្នែកទី១ ១០៩

សំណួរ និងចម្លើយ នៅក្នុងមេរៀនស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ ផ្នែកទី២ ១១០

ផែនទីបង្ហាញផ្លូវនៅស្រុកអន្លង់វែង ១១១

# របៀបប្រើប្រាស់សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍

សៀវភៅណែនាំមគ្គុទ្ទេសក៍ទេសចរណ៍ គឺជាឧបករណ៍សម្រាប់អ្នកបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ និងគ្រូបង្រៀន ដើម្បីប្រើប្រាស់នៅក្នុងសិក្ខាសាលា ក៏ដូចជាឯកសារយោងសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ និងគ្រូបង្រៀន នៅក្នុងកិច្ចការប្រចាំថ្ងៃរបស់ខ្លួន។ ជំពូក និងសកម្មភាពនីមួយៗក្នុងសៀវភៅ រៀបរាប់តាមលំដាប់លំដោយចាប់តាំងពីទិដ្ឋភាព និងសាច់រឿងប្រវត្តិសាស្ត្រទូទៅ រហូតដល់ប្រធានបទជាក់លាក់ផ្សេងៗទាក់ទងទៅនឹងវិជ្ជាជីវៈណាមួយ។ បន្ថែមលើនេះទៀត សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ លើកកម្ពស់ការយល់ដឹងជាមូលដ្ឋានស្តីពីប្រវត្តិសាស្ត្រជាតិ និងសហគមន៍អន្លង់វែង មុននឹងផ្តោតទៅលើសាច់រឿងរបស់បុគ្គលមួយចំនួន ស្ថិតនៅក្នុងបរិបទប្រវត្តិសាស្ត្រ។ សាច់រឿងនៅក្នុងសៀវភៅ មានភាពដូចគ្នានឹងសាច់រឿងក្នុងសៀវភៅប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង។ សៀវភៅមគ្គុទ្ទេសក៍ទេសចរណ៍ គឺជាឧបករណ៍ដែលមានភាពជាក់លាក់ សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ប្រើប្រាស់ព័ត៌មានដែលពាក់ព័ន្ធនឹងទីតាំងមួយចំនួននៅអន្លង់វែង ថែមទាំងមានជំពូកមួយផ្តោតលើការបង្កើតផែនការបង្រៀនសម្រាប់គ្រូបង្រៀនទៀតផង។ សរុបមក សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ និពន្ធឡើងក្នុងគោលបំណងសម្របសម្រួលដល់សិក្ខាសាលា ដែលជួយឲ្យមគ្គុទ្ទេសក៍ទេសចរណ៍ ឬគ្រូបង្រៀន ប្រើប្រាស់ទៅតាមតម្រូវការបែបវិជ្ជាជីវៈជាក់លាក់រៀងៗខ្លួន និងជាឯកសារយោង។ ខណៈដែលមគ្គុទ្ទេសក៍ទេសចរណ៍ និងគ្រូបង្រៀន ត្រូវបានលើកទឹកចិត្តឲ្យព្យាយាមរៀនសូត្រ (បើចាំបាច់ទន្ទេញឲ្យចាំ) នូវរាល់ខ្លឹមសារសង្ខេប និងសាច់រឿងប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង យើងខ្ញុំយល់ថា សិក្ខាសាលាដែលមានរយៈពេលមួយសប្តាហ៍ គឺមិនគ្រប់គ្រាន់ដើម្បីសម្រេចគោលដៅទេ។ ដូច្នេះ មគ្គុទ្ទេសក៍ទេសចរណ៍ និងគ្រូបង្រៀន គឺត្រូវបានលើកទឹកចិត្តឲ្យប្រើប្រាស់សៀវភៅណែនាំជាគោល និងអានរំឭកឡើងវិញជារៀងរាល់ថ្ងៃ ដើម្បីបង្កើនសមត្ថភាពក្នុងការសម្របសម្រួលដល់ក្រុមទេសចរ ឬថ្នាក់រៀន ស្តីពីរបបខ្មែរក្រហម។ សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ដឹកនាំអ្នកសម្របសម្រួលសិក្ខាសាលា និងជាឯកសារយោងសម្រាប់សិក្ខាកាមប្រើប្រាស់នាពេលអនាគត។







រូបខាងឆ្វេង៖ ប្រាសាទព្រះវិហារ មានទីតាំងនៅជិតព្រំដែនថៃ ដែលមានចម្ងាយប្រមាណជា៨៥គីឡូម៉ែត្រពីទិសខាងកើតនៃស្រុកអន្លង់វែង។

រូបខាងលើ៖ ប្រាសាទកោះកេរ្តិ៍ ដែលមានចម្ងាយប្រមាណ ១៦០គីឡូម៉ែត្រពីទិសអាគ្នេយ៍នៃស្រុកអន្លង់វែង។

រូបខាងស្តាំ៖ ប្រាសាទអង្គរវត្ត ដែលមានចម្ងាយប្រមាណ១២៤គីឡូម៉ែត្រពីទិសខាងត្បូងនៃស្រុកអន្លង់វែង។

ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

# ហេតុផលក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម

បេសកកម្មមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាការលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងផលប៉ះពាល់មកលើជីវិតប្រចាំថ្ងៃ។ គម្រោងស្តីពី«ការអប់រំពីអំពើប្រល័យពូជសាសន៍» គឺជាគម្រោងស្នូលមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើឡើងជំរុញឲ្យមានការជាសះស្បើយយុត្តិធម៌ ការផ្សះផ្សា និងលទ្ធិប្រជាធិបតេយ្យ នៅក្នុងប្រទេសកម្ពុជា។ សៀវភៅគោលសំខាន់មួយដែលត្រូវបានប្រើប្រាស់ក្នុងគម្រោងមានចំណងជើងថា៖ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»។ សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ សៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» និងសៀវភៅ «ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង» គឺជាឯកសារគន្លឹះដើម្បីប្រើប្រាស់ក្នុងគម្រោងស្តីពីការអប់រំពីអំពើប្រល័យពូជសាសន៍។


ជនរងគ្រោះនៃរបបខ្មែរក្រហមអានកាសែត នៅដើមទសវត្សរ៍ឆ្នាំ១៩៨០។ ដោយសារជនរងគ្រោះភាគច្រើនមិនចេះអក្សរ កាសែតភាគច្រើនបោះពុម្ពជារូបភាព បង្ហាញពីការដួលរលំនៃរបបខ្មែរក្រហម និងកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងនឹងការត្រឡប់មកវិញនៃរបបខ្មែរក្រហម។ ប្រព័ន្ធផ្សព្វផ្សាយមានតួនាទីយ៉ាងសំខាន់ក្នុងការនាំសារពីរដ្ឋាភិបាលនិងសមរភូមិមកជូនប្រជាជន។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

### ហេតុអ្វីបានជាយើងត្រូវបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ?
### ហេតុអ្វីបានជាយើងត្រូវបង្រៀនប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង?

របបកម្ពុជាប្រជាធិបតេយ្យ (និងប្រវត្តិនៃចលនាខ្មែរក្រហម) ផ្តល់ឱកាសដ៏សំខាន់មួយក្នុងការពិនិត្យមើលឡើងវិញ បែបគុរកោសល្យចំពោះបញ្ហាសីលធម៌មូលដ្ឋាន។ ការចោទសួរទៅលើខ្លឹមសារប្រវត្តិសាស្ត្រ ផ្តល់លទ្ធផលជាមេរៀនដ៏សំខាន់មួយចំនួនសម្រាប់ការអង្កេតទៅលើឥរិយាបថរបស់មនុស្ស មនោគមន៍វិជ្ជា ជំនឿ និងយុត្តិធម៌។ មិនតែប៉ុណ្ណោះទៀតសោត វានឹងលើកទឹកចិត្តសិស្សានុសិស្សឲ្យគិតពិចារណាអំពីផលប៉ះពាល់របស់ប្រវត្តិសាស្ត្រទៅលើជីវភាពប្រចាំថ្ងៃរបស់ខ្លួនទៀតផង។

បច្ចុប្បន្ន ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) កំពុងបង្រៀននៅតាមសាលារៀននៅក្នុងប្រទេសកម្ពុជា ដោយប្រើប្រាស់សៀវភៅគោលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានចំណងជើងថា «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»។ ខណៈពេលដែលការដាក់បញ្ចូលប្រវត្តិសាស្ត្រសហគមន៍អន្លង់វែងទៅក្នុងកម្មវិធីសិក្សា គឺជាសមិទ្ធផលដ៏ល្អមួយ នៅមានប្រវត្តិសាស្ត្រមួយចំនួនធំទៀតដែលត្រូវការការទទួលស្គាល់ និងការដឹងឮពីសំណាក់សាធារណជន ជាពិសេសប្រវត្តិសាស្ត្រនៃចលនាខ្មែរក្រហមមុនពេលឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ និងប្រវត្តិសាស្ត្រខ្មែរក្រហមបន្ទាប់ពីដួលរលំនៅក្នុងឆ្នាំ១៩៧៩។ សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ និងសៀវភៅ «ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង»ព្យាយាមតភ្ជាប់សម័យកាល «មុន» និង «ក្រោយ» ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើសម័យកាលក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារមានជាប់ទាក់ទងនឹងសហគមន៍អន្លង់វែង ។

អន្លង់វែងធ្លាប់ជាស្រុកដ៏ស្ងាត់ជ្រងំ និងមានសារៈសំខាន់ផ្នែកប្រវត្តិសាស្ត្រតិចតួចបើគិតត្រឹមឆ្នាំ១៩៧៩។ ក្រោយឆ្នាំ១៩៧៩ ជាពិសេសក្រោយឆ្នាំ១៩៨៩ នៅពេលកងទ័ពវៀតណាមបានដកចេញពីប្រទេសកម្ពុជា តំបន់នៅជុំវិញអន្លង់វែងក៏មានភាពលេចធ្លោឡើង និងក្លាយជាតំបន់តស៊ូដ៏សំខាន់មួយរបស់ខ្មែរក្រហម។ ស្រុកអន្លង់វែងស្ថិតនៅជាប់ជួរភ្នំដងរែក និងព្រំដែនកម្ពុជា-ថៃ ដែលជាកត្តាដ៏សំខាន់ដល់ការសម្រេចចិត្តរបស់ខ្មែរក្រហមក្នុងការបង្កើតមូលដ្ឋានយោធា។ នៅពេលដែលចលនាខ្មែរក្រហមចុះទន់ខ្សោយ (ដោយសារជម្លោះផ្ទៃក្នុង ការដកថយរបស់កងទ័ព និងភាពឯកោខាងផ្នែកនយោបាយ ឬសេដ្ឋកិច្ច) សមត្ថភាពក្នុងការគ្រប់គ្រងភូមិសាស្ត្រក៏បានចុះថយ។ អន្លង់វែងក្លាយជាតំបន់តស៊ូចុងក្រោយរបស់ចលនាខ្មែរក្រហម និងជាច្រកដ៏សំខាន់នៃចុងបញ្ចប់របស់ចលនាខ្មែរក្រហម។

### សំណួរទាក់ទងនឹងមូលហេតុ

គោលបំណងនៃការបង្រៀនប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង គឺដើម្បីរួមចំណែកដល់ការស្វែងយល់របស់ទេសចរ ឬសិស្សានុសិស្ស និងជំរុញឲ្យមានការគិតស៊ីជម្រៅ ក៏ដូចជាការរីកលូតលាស់របស់បុគ្គលម្នាក់ៗ។ មគ្គុទ្ទេសក៍ទេសចរណ៍ និងគ្រូបង្រៀន គួរពិចារណាអំពីមូលហេតុនៃការបង្រៀនប្រវត្តិសាស្ត្រ (ជាពិសេសប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង) នៅពេលរៀបចំក្រុមទស្សនកិច្ចសិក្សា ឬការបង្រៀនទាក់ទងនឹងប្រធានបទប្រវត្តិសាស្ត្រនៃសហគមន៍អន្លង់វែង។ មុនពេលសម្រេចថានឹងត្រូវបង្រៀនអំពីអ្វី និងយ៉ាងដូចម្តេច មគ្គុទ្ទេសក៍ទេសចរណ៍ (ក៏ដូចជាគ្រូបង្រៀន) ត្រូវពិចារណាជាមុននូវសំណួរខាងក្រោម៖

- ហេតុអ្វីបានជាអ្នកត្រូវរៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម?
- តើប្រវត្តិសាស្ត្រអាចធ្វើឲ្យអ្នកយល់ដឹងថាតើអ្នកជានរណា អ្នកអាចក្លាយជាអ្វីយ៉ាងដូចម្តេចខ្លះ ?
- តើមេរៀនសំខាន់ៗអ្វីខ្លះ ដែលអ្នកអាចរៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហម?
- តើការបង្កើនការយល់ដឹងអំពីប្រវត្តិសាស្ត្រ ជួយមនុស្សឲ្យបង្កើននូវទស្សនវិស័យស្តីពីរបៀបដែលបញ្ហា ឬហេតុការណ៍កើតឡើងនៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា (ឬនៅក្នុងសង្គមក្រោយជម្លោះ) យ៉ាងដូចម្តេចខ្លះ? បានរួមចំណែកដល់ការធ្លាក់ចុះតម្លៃសីលធម៌ និងយុត្តិធម៌សង្គមយ៉ាងដូចម្តេចខ្លះ?
- តើការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមជួយតភ្ជាប់ទំនាក់ទំនងរវាងសិស្ស ឬយុវជន ជាមួយនិងរៀមច្បងយ៉ាងដូចម្តេច?
- តើការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះដល់ការយោគយល់ និងភាពអាណិតអាសូរ?
- តើការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមជួយលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជាយ៉ាងដូចម្តេចខ្លះ?

នៅពេលដែលមគ្គុទ្ទេសក៍ទេសចរណ៍ (ឬគ្រូបង្រៀន) ចំណាយពេលវេលាពិចារណាមូលហេតុនៃដំណើរទស្សនកិច្ច (ឬមេរៀន) អំពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង អ្នកនឹងអាចជ្រើសរើសខ្លឹមសារនៃប្រវត្តិសាស្ត្រដែលឆ្លើយតបទៅនឹងការចាប់អារម្មណ៍របស់ទេសចរ ឬសិស្សានុសិស្សនូវការយល់ដឹងច្បាស់លាស់មួយ។

មនុស្សភាគច្រើនចាប់អារម្មណ៍យ៉ាងខ្លាំងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ពីព្រោះមានការលើកឡើងអំពីបញ្ហាយុត្តិធម៌ ការចុះសម្រុងគ្នា ការស្តាប់បង្គាប់ ភាពភ័យខ្លាច និងភាពឈឺចាប់ ដែលមនុស្សគ្រប់គ្នាបានជួបប្រទះ ឬឃើញដោយផ្ទាល់ភ្នែកនៅក្នុងជីវភាពប្រចាំថ្ងៃ។ មនុស្សគ្រប់រូបអាចមានការចាប់អារម្មណ៍ ពីវិសាលភាពដ៏ធំធេងនៃអំពើឃោរឃៅ និងអមនុស្សធម៌ទៅលើមនុស្សជាតិដែលបានកើតឡើងនាពេលថ្មីៗកន្លងមក។ ប្រជាជនកម្ពុជាអាចនឹងត្រូវបានលើកទឹកចិត្តឲ្យសួរសំណួរនៅតាមគេហដ្ឋាន និងអាចមានចំណាប់អារម្មណ៍ក្នុងការយកបទពិសោធន៍របស់សាច់ញាតិខ្លួនទៅដាក់ក្នុងបរិបទប្រវត្តិសាស្ត្រដែលមានភាពទូលំទូលាយ។

# ទស្សនវិជ្ជានៃសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍អំពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង

សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ បានរៀបចំឡើង ដើម្បីជួយសម្រួលដល់មគ្គុទ្ទេសក៍ទេសចរណ៍ក្នុងកិច្ចការអប់រំទេសចរអំពីទីតាំងនានានៅស្រុកអន្លង់វែង។ ក្រៅពីបម្រើជាឯកសារយោង សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ក៏ព្យាយាមជួយសម្រួលដល់គ្រូបង្រៀននៅតាមវិទ្យាល័យ (ចាប់ពីថ្នាក់ទី៩ ដល់ថ្នាក់ទី១២) ឬថ្នាក់មធ្យមសិក្សា ក្នុងការប្រើប្រាស់សៀវភៅស្ដីពី «ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង»។

ជាការពិតណាស់ មគ្គុទ្ទេសក៍ទេសចរណ៍ និងគ្រូបង្រៀន មានភាពស្រដៀងគ្នាច្រើនទាក់ទងនឹងការអប់រំសាធារណជន ផ្ទុយទៅវិញក៏មានភាពខុសគ្នាមួយចំនួនដែរ។ គ្រូបង្រៀនតម្រូវឲ្យមានចំណេះទាក់ទងនឹងការព្យាករទុកជាមុន រចនាសម្ព័ន្ធ និងផែនការលម្អិតអំពីអ្វីដែលត្រូវបង្រៀន។ សៀវភៅណែនាំគ្រូបង្រៀនរៀបចំឡើងតាមរបៀបជាមេរៀន ដោយមានវត្ថុបំណង បទដ្ឋាន សកម្មភាព ខ្លឹមសារ និងសំណួរដែលមានស្រាប់។

ចំណែកឯមគ្គុទ្ទេសក៍ទេសចរណ៍វិញត្រូវការឯកសារយោង ដែលអាចបត់បែនទៅតាមការចង់បានរបស់ភ្ញៀវ។ ខណៈដែលគ្រូបង្រៀនអាចដឹងជាមុនអំពីវត្ថុបំណងសិស្សនៅក្នុងថ្នាក់ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវតែឆ្លើយតបទៅនឹងកាលវិភាគរបស់ភ្ញៀវ ដែលធ្វើទស្សនកិច្ចនៅតាមទីតាំងជាក់លាក់មួយចំនួន។ ជារឿយៗ មគ្គុទ្ទេសក៍ទេសចរណ៍ធ្វើការដោយមានការព្យាករទុកជាមុនបានតិចតួចបំផុតទៅតាមកាលវិភាគ ការយល់ដឹងរបស់ភ្ញៀវទេសចរ និងការលំបាកមួយចំនួនក្នុងការទាក់ទងជាមួយភ្ញៀវ។ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវជៀសវាងក្នុងការគ្របដណ្ដប់ទៅលើបទពិសោធន៍នៃទស្សនកិច្ចទាំងមូល។ ទេសចរកម្រធ្វើទស្សនកិច្ចដោយចង់បានត្រឹមតែព័ត៌មានមួយមុខណាស់ ដោយអ្នកទេសចរអាចអានសៀវភៅដោយខ្លួនឯងបាន។ ទេសចរផ្ដល់តម្លៃខ្លាំងទៅលើបទពិសោធន៍ជីវិត ដែលទទួលបានពីការទាក់ទងផ្ទាល់ជាមួយមជ្ឈដ្ឋានជុំវិញជាជាងការធ្វើបទបង្ហាញរបស់មគ្គុទ្ទេសក៍ទេសចរណ៍។

ការបំពេញនូវរាល់សេចក្ដីត្រូវការរបស់មគ្គុទ្ទេសក៍ទេសចរណ៍ និងគ្រូបង្រៀន ក្នុងពេលព្រមគ្នាឲ្យបានគ្រប់ជ្រុងជ្រោយ គឺមិនអាចទៅរួចទេ ដោយមានក្ដីបារម្ភថា ការតម្រូវទៅតាមក្រុមណាមួយ នឹងធ្វើឲ្យសៀវភៅណែនាំមគ្គុទ្ទេសក៍ទេសចរណ៍មិនអាចប្រើប្រាស់បានសម្រាប់ក្រុមផ្សេងទៀត។ ដោយយល់ឃើញបែបនេះ ទើបអ្នកនិពន្ធរៀបរៀងសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ឲ្យមានទម្រង់ដូចទៅនឹង«តារាងវ៉ែន» ដែលផ្សំឡើងពីរង្វង់ត្រួតស៊ីគ្នាចាប់ពីពីរឡើងទៅ ប្រើដើម្បីបង្ហាញអំពីទំនាក់ទំនងរវាងទស្សនៈពីរ ថែមទាំងមានសារៈសំខាន់ណាស់សម្រាប់ការពិនិត្យមើលនូវភាពស្រដៀងគ្នា និងភាពខុសគ្នា។

ជាញឹកញាប់ «តារាងវ៉ែន» គឺប្រើដើម្បីបង្កលទ្ធភាពឲ្យសិស្សានុសិស្សអាចរៀបចំគំនិត ឬការដកស្រង់សម្ដីពីក្នុងអត្ថបទ មុនពេលសរសេរអត្ថបទតែងសេចក្ដីបែបប្រៀបធៀប ឬមតិផ្ទុយ។ សកម្មភាពនេះ បង្កលទ្ធភាពឲ្យសិស្សានុសិស្សអាចរៀបចំភាពស្រដៀងគ្នា និងភាពខុសគ្នា ដែលអាចមើលឃើញ។




ប្រសិនបើយើងចង់បង្ហាញពីភាពស្រដៀងគ្នា និងភាពខុសគ្នារវាងគ្រូបង្រៀននិងមគ្គុទ្ទេសក៍ទេសចរណ៍ «តារាងវ៉ែន»អាចមានទម្រង់ដូចខាងក្រោម៖




ភាពស្រដៀងគ្នាអាចរាប់បញ្ចូលនៅក្នុងខ្លឹមសារប្រវត្តិសាស្ត្រ ការពិភាក្សា និងបច្ចេកទេសនៃការរៀបរាប់សាច់រឿង។ ខណៈដែលគ្រូបង្រៀននិងមគ្គុទ្ទេសក៍ទេសចរណ៍មានភាពស្រដៀងគ្នានៅត្រង់ខ្លឹមសារនៃការបង្រៀនប្រវត្តិសាស្ត្រអន្លង់វែង គឺគ្មានអ្វីគួរឲ្យសង្ស័យទេ ដោយសារតែការនិយាយយោងទៅតាមហេតុការណ៍ ទស្សនៈ និងបុគ្គលិកលក្ខណៈ នៅពេលពិភាក្សាអំពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែងមានភាពដូចគ្នា។ ទោះជាយ៉ាងណាក៏ដោយ ប្រភេទនៃការពិភាក្សា និងរបៀបនៃការនិយាយសាច់រឿង ត្រូវការការពន្យល់បន្ថែម ដោយសារតែវិធីសាស្ត្រទាំងពីរនេះជាវិធីសាស្ត្រអប់រំគោលនៅក្នុងសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍។

ការពិភាក្សាអាចពិពណ៌នាថា គឺជាគ្រឹះដ៏សំខាន់សម្រាប់ការអប់រំ ដោយសារមិនត្រឹមតែតម្រូវឲ្យមានការត្រិះរិះពិចារណាតែប៉ុណ្ណោះទេ ថែមទាំងមានលទ្ធភាពបង្កើតឲ្យមានគំនិតដែលស៊ីជម្រៅទៀតផង។

*គ្មានការពិភាក្សា គឺគ្មានការទំនាក់ទំនង គ្មានទំនាក់ទំនង គឺអាចគ្មានការអប់រំពិតប្រាកដ[១] ។*

ការពិភាក្សាដើរតួយ៉ាងសំខាន់មួយសម្រាប់គ្រូបង្រៀន និងមគ្គុទ្ទេសក៍ទេសចរណ៍អាចប្រើប្រាស់ក្នុងការបំពេញការងារ។

តើការពិភាក្សាជាអ្វី ? នៅពេលដែលយើងនិយាយអំពី«ការពិភាក្សា» យើងមិនត្រឹមតែសំដៅលើការសន្ទនាតែមួយប៉ុណ្ណោះទេ យើងថែមទាំងសំដៅលើទំនាក់ទំនងរបស់ការពិភាក្សាជាមួយសកម្មភាព និងការឆ្លុះបញ្ចាំងទៀតផង។ ការពិភាក្សាអាចមានអត្ថន័យជាប់ពាក់ព័ន្ធទៅនឹងនយោបាយ។ គ្រូបង្រៀន ឬមគ្គុទ្ទេសក៍ទេសចរណ៍ អាចប្រើការពិភាក្សាដើម្បីស្វែងយល់អំពីខ្លួនឯង តាមរយៈការផ្លាស់ប្តូរ គំនិតយោបល់ ការពិភាក្សាមិនមានន័យថា គ្រូបង្រៀនមានតួនាទីត្រឹមតែផ្តល់ព័ត៌មានទៅឲ្យសិស្សានុសិស្ស ដើម្បីផ្តល់ចំណេះដឹងតែប៉ុណ្ណោះទេ និងក៏មិនមានន័យថា មគ្គុទ្ទេសក៍ទេសចរណ៍ផ្តល់ព័ត៌មានឲ្យភ្ញៀវទេសចរដែរ។ ទាំងគ្រូបង្រៀន និងមគ្គុទ្ទេសក៍ទេសចរណ៍រំពឹងថានឹងមានការឆ្លើយតបទៅវិញទៅមក។ ការពិភាក្សាត្រូវតែចាប់ផ្តើមដោយការទទួលស្គាល់ថា ពាក្យពេចន៍ទាំងឡាយអាចជាឧបករណ៍ដ៏មានប្រសិទ្ធភាព ក្នុងការកែប្រែការយល់ឃើញរបស់មនុស្សម្នាក់។ ការសន្ទនាជាមួយអ្នកដទៃក៏អាចជាបទពិសោធន៍ដែលធ្វើឲ្យមនុស្សម្នាក់មានការផ្លាស់ប្តូរដែរ។

ឧទាហរណ៍ នៅពេលដែលមគ្គុទ្ទេសក៍ទេសចរណ៍ពន្យល់ភ្ញៀវពីហេតុការណ៍ប្រវត្តិសាស្ត្រដែលពាក់ព័ន្ធនឹងទីតាំងណាមួយក្នុងអំឡុងពេលទស្សនកិច្ច វាមិនត្រឹមតែផ្តល់ព័ត៌មានតែប៉ុណ្ណោះទេ ប៉ុន្តែក៏បង្ហាញពីសិទ្ធិក្នុងការបញ្ចេញមតិដោយសេរីលើប្រធានជាក់លាក់អំពីប្រវត្តិសាស្ត្រដែរ។ ទោះជាយ៉ាងណាក្តី សកម្មភាពនៃការបង្ហាញទស្សនៈផ្ទាល់ខ្លួនមិនមែនជាគោលដៅចុងក្រោយទេ ផ្ទុយទៅវិញការពិភាក្សាទៅលើប្រធានបទជាក់លាក់ណាមួយរបស់មគ្គុទ្ទេសក៍ទេសចរណ៍ គួរតែជាមធ្យោបាយមួយសម្រាប់អ្នកដទៃធ្វើការពិចារណានិងផ្តល់ទស្សនៈផ្ទាល់ខ្លួនត្រឡប់មកវិញ។ ការពិភាក្សាអំពីប្រវត្តិសាស្ត្រគឺជាគោលដៅធំបំផុត ពីព្រោះតែការពិភាក្សាអាចពង្រឹងវប្បធម៌នៃការសួរនាំ ឆ្លុះបញ្ចាំង និងគ្រប់ដំណើរការ ដែលជាគោលការណ៍មូលដ្ឋានឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ។ ឯនៅក្នុងថ្នាក់រៀនវិញ នៅពេលដែលគ្រូបង្រៀនសួរសិស្សអំពីគំនិតទាក់ទងនឹងរឿងរ៉ាវ ហេតុការណ៍ ឬប្រធានបទណាមួយ គ្រូបង្រៀនមិនត្រឹមតែផ្តល់ឲ្យសិស្សនូវឱកាសដើម្បីសួរដេញដោលអំពីប្រវត្តិសាស្ត្រតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសួរអំពីខ្លួនឯង សង្គម និងពិភពលោកទៀតផង។ ការបញ្ចេញមតិផ្ទាល់ខ្លួនស្តីពីប្រវត្តិសាស្ត្រអាចជាមូលដ្ឋាន ដើម្បីបញ្ចេញមតិរបស់ខ្លួនទៅលើប្រធានបទផ្សេងៗទៀតដែលកំពុងកើតឡើងក្នុងពេលបច្ចុប្បន្ន។ តាមរយៈការជជែកពិភាក្សាជាប្រចាំ គ្រូបង្រៀនអាចលើកកម្ពស់ការឲ្យតម្លៃទៅលើបុគ្គលទាំងឡាយនៅក្នុងសង្គម និងលក្ខណៈពិសេសរបស់បុគ្គលម្នាក់ៗ។

ការនិយាយសាច់រឿង មានតួនាទីសំខាន់ក្នុងការលើកយកហេតុការណ៍ប្រវត្តិសាស្ត្រដាក់ក្នុងបរិបទមួយ ដែលមនុស្សម្នាក់ៗអាចយល់បាន។ ឧទាហរណ៍ វាជាការពិបាកសម្រាប់បុគ្គលម្នាក់ៗក្នុងការស្វែងយល់អំពីលក្ខណៈធម្មជាតិនៃអំពើប្រល័យពូជសាសន៍ នៅពេលពិភាក្សាពីបញ្ហានេះនៅកម្រិតថ្នាក់ជាតិ ប៉ុន្តែនៅពេលដែលយើងពិពណ៌នាពីអំពើប្រល័យពូជសាសន៍តាមបទពិសោធន៍របស់ជនរងគ្រោះម្នាក់វិញ វិសាលភាពនៃបទឧក្រិដ្ឋកម្ម និងការជាប់ពាក់ព័ន្ធរបស់មនុស្សជាតិនឹងមានភាពច្បាស់លាស់ភ្លាម។ ការនិយាយសាច់រឿងដើរតួនាទីយ៉ាងសំខាន់ ក្នុងការពន្យល់អំពីតួនាទីរបស់បុគ្គលម្នាក់ៗនៅក្នុងប្រវត្តិសាស្ត្រ និងថាតើបទពិសោធន៍របស់បុគ្គលម្នាក់ៗកាលពីអតីតកាលអាចឆ្លុះបញ្ចាំង និងស្វែងយល់ពីបញ្ហានានា ដែលកំពុងជួបប្រទះនៅពេលបច្ចុប្បន្ន និងបញ្ហាដែលអាចកើតមាននាពេលអនាគត។

នៅពេលដែលការពិភាក្សា និងការនិយាយសាច់រឿង អាចជាការបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក (សាច់រឿងដែលបង្កឲ្យមានការគិតពិចារណា និងលើកទឹកចិត្តឲ្យមានការសួរសំណួរនិងការជជែកដេញដោល) មិនមែនជាសកម្មភាពដែលងាយស្រួលអនុវត្តទេ។ សិល្បៈនៃការសន្ទនា និងការនិយាយសាច់រឿងពឹងផ្អែកមួយផ្នែកធំទៅលើជំនាញសង្គម និងសមត្ថភាពគ្រូបង្រៀន ឬមគ្គុទ្ទេសក៍ទេសចរណ៍ម្នាក់ៗក្នុងការទំនាក់ទំនង ដែលអាចផុសចេញពីបុគ្គលិកលក្ខណៈបុគ្គលម្នាក់ៗផ្ទាល់។ ខណៈដែលបុគ្គលខ្លះមានសមត្ថភាពពីធម្មជាតិក្នុងការសម្របសម្រួលការសន្ទនា ឬការនិយាយសាច់រឿងបានយ៉ាងល្អ មនុស្សភាគច្រើនត្រូវការការអនុវត្ត និងត្រូវការគ្រូបង្រៀន ដើម្បីបង្កើតវិធីសាស្ត្រសម្រាប់ធ្វើការសម្របសម្រួល និងបទបង្ហាញប្រកបដោយប្រសិទ្ធភាព។ សរុបមក នៅពេលដែលសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ផ្តល់គំនិតអប់រំសិស្សានុសិស្ស និងសាធារណជនតាមរយៈសាច់រឿងនិងការសន្ទនា ប៉ុន្តែមិនអាចកែប្រែទម្លាប់បង្រៀន និងជំនាញសង្គមរបស់បុគ្គលបានឡើយ។

ដូចគ្នាទៅនឹងជំនាញដទៃទៀត សមត្ថភាពក្នុងការជូនដំណឹង លើកទឹកចិត្តឲ្យមានការពិភាក្សា និងនិយាយសាច់រឿងអាចត្រូវការការអនុវត្តជាប្រចាំ។ គ្រូបង្រៀន និងមគ្គុទ្ទេសក៍ទេសចរណ៍ គួរតែអនុវត្តដោយខ្លួនឯង និងរៀនពីគ្នាទៅវិញទៅមក បើទោះបីជាមានផែនការបង្រៀនល្អយ៉ាងណាក៏ដោយ។

ជំពូកទី១នៃសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ គឺជាបណ្តុំខ្លឹមសារប្រវត្តិសាស្ត្រសង្ខេប ដើម្បីសម្រួលដល់ការផ្តល់ព័ត៌មានប្រវត្តិសាស្ត្រដ៏ពេញលេញគ្រប់ជ្រុងជ្រោយដល់សិស្សានុសិស្ស និងភ្ញៀវទេសចរ។ នៅក្នុងជំពូកទី២ មានសាច់រឿងមួយចំនួនទាក់ទងនឹងសម័យកាលនៃប្រវត្តិសាស្ត្រ និងប្រធានបទដើម្បីផ្សារភ្ជាប់បទពិសោធន៍មនុស្សម្នាក់ៗជាមួយកាលបរិច្ឆេទ និងហេតុការណ៍ប្រវត្តិសាស្ត្រនានា។ ជំពូកទី៣ ភាគច្រើនផ្តោតលើការធ្វើទស្សនកិច្ចនៅតាមទីតាំងប្រវត្តិសាស្ត្រ និងសម្រួលដល់ការយល់ដឹងរបស់អ្នកអានចំពោះទីតាំងប្រវត្តិសាស្ត្រ ដើម្បីអាចធ្វើបទបង្ហាញអំពីទីតាំងក្នុងអំឡុងពេលធ្វើដំណើរទស្សនកិច្ច។ ជំពូកទី៤ បានងាកចេញពីអាជីពជាមគ្គុទ្ទេសក៍ទេសចរណ៍ ដោយផ្តោតពិសេសទៅលើសេចក្តីត្រូវការរបស់គ្រូបង្រៀននៅក្នុងមជ្ឈដ្ឋានថ្នាក់រៀន។ ការរៀបចំមេរៀន គ្រូបង្រៀនតម្រូវឲ្យប្រើប្រាស់ឧបករណ៍ក្នុងជំពូកទី១ និងជំពូកទី២ ដើម្បីសម្រេចនូវសកម្មភាព ឬមេរៀនទៅដល់សិស្សានុសិស្ស។ ជាចុងក្រោយ ជំពូកទី៥ផ្តល់ចម្លើយពាក្យគន្លឹះទៅនឹងសំណួរនៅក្នុងមេរៀននៃជំពូកទី៤។

មគ្គុទ្ទេសក៍ទេសចរណ៍ និងគ្រូបង្រៀន មិនបានរំពឹងឲ្យចងចាំដោយលម្អិតអំពីព័ត៌មានប្រវត្តិសាស្ត្រនៅក្នុងសៀវភៅនោះទេ ទោះបីជាការចងចាំលម្អិតត្រូវបានលើកទឹកចិត្តក៏ដោយ។ សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ បានផ្តល់យោបល់មួយចំនួនទៅលើសកម្មភាព ដែលគួរតែជ្រើសរើសនិងសម្របតាមអត្ថន័យដ៏សមស្របបំផុតទៅនឹងចំណាប់អារម្មណ៍របស់សិស្សានុសិស្ស ឬភ្ញៀវទេសចរ។ អ្នកអានត្រូវបានលើកទឹកចិត្តឲ្យសាកសួរក្រសួងទេសចរណ៍និងក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការណែនាំបន្ថែមលើមេរៀន សំណួរ និងឯកសារយោងទាក់ទងនឹងទេសចរណ៍។

[១] គរុកោសល្យអំពីអ្នករងការគាបសង្កត់, ទំព័រ ៩២-៩៣, (២០១១)



ហាជី ស្លូពីយ៉ាន ប្រធានសហគមន៍មូស្លីមចាម រំឭកពីបទពិសោធន៍គាត់ និងការតស៊ូរបស់ប្រជាជនចាមនៅសម័យខ្មែរក្រហម (១៩៧៥-១៩៧៩)។ ដោយសារតែមានវប្បធម៌ ភាសា និងសាសនាខុសប្លែកពីប្រជាជនកម្ពុជាភាគច្រើន ហាជី ស្លូពីយ៉ាន ត្រូវបានអញ្ជើញឲ្យចូលរួមនិយាយចែករំលែកបទពិសោធទៅកាន់សិក្ខាកាមទាំង១០០នាក់ នៅក្នុងសិក្ខាសាលាស្តីពីការអប់រំពីអំពើប្រល័យពូជសាសន៍ ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅខេត្តបាត់ដំបង កាលពីខែមេសា ឆ្នាំ២០១៦។ មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសិក្ខាសាលាជាច្រើនទាំងថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ស្របពេលជាមួយនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលនៅសេសសល់រួមមាន នួន ជា និង ខៀវ សំផន។

# ជំពូកទី១
# បទបង្ហាញ គន្លឹះណែនាំ និងសកម្មភាពបង្រៀន

## ផ្នែកទី១៖ សេចក្តីផ្តើម

មិនថាការបង្រៀនប្រវត្តិសាស្ត្រនៅក្នុងថ្នាក់រៀន ឬការដឹកនាំដំណើរទស្សនកិច្ចនៅតាមទីតាំងប្រវត្តិសាស្ត្រនានានោះទេ អ្នកសម្របសម្រួលត្រូវចាប់ផ្តើមជាមួយនឹងសេចក្តីផ្តើមជានិច្ច[២]។ សេចក្តីផ្តើម មិនត្រឹមតែមានតួនាទីសំខាន់ក្នុងការផ្តល់នូវការយល់ដឹងមូលដ្ឋាន អំពីអ្វីដែលយើងនឹងពិភាក្សាតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយវាស់ស្ទង់ការយល់ដឹងសិស្សានុសិស្ស ឬភ្ញៀវទេសចរទៅលើប្រធានបទទៀតផង។ មិនថាអ្នកអានជាមគ្គុទ្ទេសក៍ទេសចរណ៍ ឬគ្រូបង្រៀន សេចក្តីផ្តើមអាចជួយសិស្សានុសិស្ស ឬភ្ញៀវទេសចរ ឲ្យឈានទៅរករបៀបគារវកិច្ច ព្រមទាំងអាចជួយដល់អ្នកសម្របសម្រួលក្នុងការបើកផ្លូវបន្តទៅកាន់ប្រធានបទផ្សេងៗទៀត។

សេចក្តីផ្តើមធ្វើបានតាមវិធីច្រើនយ៉ាង។ ឧទាហរណ៍ អ្នកសម្របសម្រួលអាចចោទសំណួរទូទៅមួយទៅកាន់អ្នកស្តាប់ដូចខាងក្រោម៖

> «តើអ្នកបានដឹងអ្វីខ្លះពីតំបន់អន្លង់វែង?»
> «តើអ្នកបានដឹងអ្វីខ្លះពីរបបខ្មែរក្រហម?»
> «តើមាននរណាដឹងអំពីទំនាក់ទំនងរវាងតំបន់អន្លង់វែងនិងរបបខ្មែរក្រហមដែរឬទេ?»

សំណួរទូទៅខាងលើ អាចជួយឲ្យអ្នកសម្របសម្រួលវាស់ស្ទង់អំពីការយល់ដឹងសិស្សានុសិស្ស ឬភ្ញៀវទេសចរចាប់តាំងពីដំបូង និងជួយលើកទឹកចិត្តឲ្យសិស្សានុសិស្ស ឬភ្ញៀវទេសចរចែកក្នុងការរំលែកចំណេះដឹងគ្នាទៅវិញទៅមក។ អ្នកសម្របសម្រួលគួរសួរសំណួរក្នុងពេលទស្សនកិច្ច ឬក្នុងថ្នាក់រៀន ដោយសារការសួរសំណួរអនុញ្ញាតឲ្យសិស្សានុសិស្ស ឬភ្ញៀវទេសចរ ពិភាក្សា គិតពិចារណា និងចែករំលែកគំនិត ដែលជាខ្លឹមសារៈសំខាន់នៃការរៀនសូត្រ។ ម្យ៉ាងវិញទៀត ប្រសិនបើសិស្សានុសិស្ស ឬភ្ញៀវទេសចរមានការយល់ដឹងតិចតួច ឬគ្មានការយល់ដឹងទាល់តែសោះអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ឬប្រវត្តិសាស្ត្រអន្លង់វែង អ្នកសម្របសម្រួលអាចលើកយកប្រធានបទមកធ្វើបទបង្ហាញខ្លីៗអំពីប្រវត្តិសាស្ត្រដែលពាក់ព័ន្ធ។

បទបង្ហាញផ្នែកប្រវត្តិសាស្ត្រ គឺជាឧបករណ៍ដ៏សំខាន់ ជួយដល់សិស្សានុសិស្ស ឬភ្ញៀវទេសចរឲ្យស្វែងយល់ពីការពិតនិងកាលបរិច្ឆេទផ្នែកប្រវត្តិសាស្ត្រជាមូលដ្ឋាន ដែលទាក់ទងនឹងប្រធានបទជាក់លាក់ ឬទីតាំងប្រវត្តិសាស្ត្រណាមួយ។ ការផ្តល់បទបង្ហាញខ្លីៗអំពីប្រវត្តិសាស្ត្រមានសារៈសំខាន់ណាស់សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍។ មគ្គុទ្ទេសក៍ទេសចរណ៍ជួយឲ្យភ្ញៀវទេសចរផ្សារភ្ជាប់ប្រវត្តិសាស្ត្រតំបន់អន្លង់វែង ជាមួយប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងពិភពលោក។ អ្វីដែលសំខាន់ គឺអ្នកសម្របសម្រួលមិនអាចចាប់ផ្តើមនិយាយសាច់រឿង ឬការសន្ទនា ដោយគ្មានការសន្និដ្ឋានថា សិស្សានុសិស្ស ឬភ្ញៀវទេសចរយ៉ាងហោចមានការយល់ដឹងអំពីប្រវត្តិសាស្ត្រដែលពាក់ព័ន្ធក្នុងកម្រិតណាមួយបានឡើយ។ ដូច្នេះ ខណៈពេលដែលមគ្គុទ្ទេសក៍ទេសចរណ៍ ឬគ្រូបង្រៀនត្រូវបានលើកទឹកចិត្តឲ្យប្រើប្រាស់សំណួរដើម្បីវាស់ស្ទង់ការយល់ដឹងរបស់សិស្សានុសិស្ស ឬភ្ញៀវទេសចរ ការផ្តល់បទបង្ហាញខ្លី (ជាពិសេសនៅពេលចាប់ផ្តើម) ក៏មានសារៈសំខាន់ ដែលបានដើរតួនាទីជាមូលដ្ឋានគ្រឹះសម្រាប់ឲ្យអ្នកស្តាប់ប្រើប្រាស់នៅមេរៀនក្រោយៗទៀត។

[២] មានពាក្យជាច្រើនដែលយើងអាចប្រើប្រាស់ដើម្បីបញ្ជាក់អំពី«សេចក្តីផ្តើម» ដូចជា ការលេងល្បែងកម្សាន្ត ការបណ្តុះគំនិតទុកជាមុន និងការលើកទឹកចិត្ត ប៉ុន្តែដើម្បីធ្វើឲ្យមានភាពស៊ីគ្នាជាមួយគោលបំណងរបស់សៀវភៅនេះ យើងនឹងប្រើប្រាស់ពាក្យ «សេចក្តីផ្តើម»។

**គន្លឹះណែនាំ**

*នៅពេលណែនាំ សិស្សានុសិស្ស ឬភ្ញៀវទេសចរ អំពីប្រធានបទប្រវត្តិសាស្ត្រជាក់លាក់ណាមួយ ជាលើកដំបូង អ្នកសម្របសម្រួលគួរតែ៖*

*(១) សួរសំណួរទៅសិស្សានុសិស្ស ឬភ្ញៀវទេសចរដើម្បីណែនាំប្រធានបទ និងវាយតម្លៃពីការយល់ដឹង។*

*(២) ត្រៀមលក្ខណៈជាស្រេចក្នុងការផ្តល់បទបង្ហាញខ្លីស្តីពីប្រវត្តិសាស្ត្រដែលពាក់ព័ន្ធ។*

វិធីសាស្ត្រដ៏មានប្រសិទ្ធភាពបំផុត ដើម្បីបង្ហាញជូននូវប្រវត្តិសាស្ត្រដ៏ស្មុគស្មាញក្នុងរយៈពេលខ្លី គឺការធ្វើបទបង្ហាញក្នុងទម្រង់ជាបទបាឋកថា។ ទោះបីជាវិធីសាស្ត្រនេះមានប្រសិទ្ធភាព ប៉ុន្តែវាមានប្រសិទ្ធិភាពតិចតួចបំផុតក្នុងការចូលរួមរបស់សិស្សានុសិស្ស ឬទេសចរ។ ដូច្នេះ អ្នកសម្របសម្រួលត្រូវបានជម្រុញឲ្យធ្វើការជ្រើសរើសឲ្យបានត្រឹមត្រូវក្នុងការប្រើប្រាស់វិធីសាស្ត្រជាទម្រង់បទបាឋកថា។ បទបាឋកថាគួរតែប្រើ ដើម្បីផ្តល់ព័ត៌មានសំខាន់ៗ នៅពេលមានប្រធានបទប្រវត្តិសាស្ត្រទូទៅជាច្រើន ដែលអ្នកសម្របសម្រួលអាចផ្តល់ជូនសិស្សានុសិស្ស ឬភ្ញៀវទេសចរបាន ប៉ុន្តែដើម្បីបង្កឲ្យមានការងាយស្រួល យើងខ្ញុំសូមផ្តល់ជូននូវខ្លឹមសារសង្ខេបបួនគឺ៖

ប្រវត្តិសាស្ត្រនៃចលនាកម្មុយនីស្តកម្ពុជា

ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ ផ្នែកទី១

ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ ផ្នែកទី២



មន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ កំពុងអង្គុយក្នុងការិយាល័យ។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

## ផ្នែកទី២៖ បទបង្ហាញបែបប្រវត្តិសាស្ត្រ

សេចក្តីសង្ខេបខាងក្រោម ផ្តល់ជាឯកសារយោង ដែលជាជំនួយក្នុងការរៀបចំបទបង្ហាញ។ នៅពេលដែលអ្នកសម្របសម្រួលមានសេរីភាពក្នុងការសិក្សា និងយកលំនាំតាមបទបង្ហាញខ្លីៗនៅក្នុងជំពូកទី១ ដើម្បីបង្កើតបទបង្ហាញរបស់ខ្លួន អ្នកសម្របសម្រួលក៏អាចបែរទៅរកគន្លឹះណែនាំដែលពាក់ព័ន្ធដើម្បីជាជំនួយ (ឧទាហរណ៍ មាតិកានៃចំណុចសំខាន់ៗ)។

### បទបង្ហាញទី១៖ ប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា

ការណែនាំ៖ សូមអានបទបង្ហាញខាងក្រោម និងគន្លឹះណែនាំ ដែលពាក់ព័ន្ធមុនពេលបន្តទៅធ្វើលំហាត់។

ពាក្យ «ខ្មែរក្រហម» គឺជាឈ្មោះដែលសម្តេចព្រះ នរោត្តម សីហនុ ដាក់ឲ្យក្រុមកុម្មុយនីស្តដែលប្រឆាំងនឹងព្រះអង្គ នៅទសវត្សរ៍ឆ្នាំ១៩៦០។ ឈ្មោះជាផ្លូវការ គឺបក្សកុម្មុយនីស្តកម្ពុជា។



សមាជិកខ្មែរក្រហមជាន់ខ្ពស់កំពុងឈរជាជួរ ដើម្បីរង់ចាំភ្ញៀវកិត្តិយស ប្រហែលជានៅឆ្នាំ ១៩៧៥។ ពីស្តាំទៅឆ្វេង៖ នួន ជា, អៀង សារី, សុន សេន, វន វ៉េត និង កុយ ធួន។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ប្រភពនៃចលនាខ្មែរក្រហម កើតចេញពីចលនាតស៊ូប្រឆាំងនឹងអាណានិគមបារាំង។ នៅក្នុងត្រីមាសចុងក្រោយនៃសតវត្សរ៍ទី១៩ និងរហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩៥០ បារាំងចាប់ផ្តើមគ្រប់គ្រងលើប្រទេសកម្ពុជា ឡាវ និងវៀតណាម។ ការគ្រប់គ្រងរបស់បារាំងទៅលើដែនដីអាណានិគម បានស្គាល់ជាទូទៅថាជាឥណ្ឌូចិនបារាំង។ ខណៈដែលទឹកចិត្តប្រឆាំងអាណានិគមកើតមានឡើងជានិច្ច ដែលពេលខ្លះផ្ទុះឡើងក្លាយជាឧទ្ទាមកម្មក្នុងរូបភាពណាមួយក៏ដោយ ក៏ចលនាប្រឆាំងអាណានិគម មិនបានសហការគ្នាឲ្យត្រឹមត្រូវទេ រហូតដល់ក្នុងទសវត្សរ៍ឆ្នាំ១៩៤០។ ចលនាខ្មែរឥស្សរៈ គឺជាចលនាប្រឆាំងបារាំង ចលនាអ្នកជាតិនិយមខ្មែរ បានកើតឡើងដោយមានការគាំទ្រពីប្រទេសថៃក្នុងឆ្នាំ១៩៤៥។ នៅពេលដែលយើងធ្វើការពិពណ៌នា ខ្មែរឥស្សរៈជាចលនាដែលគ្មានមេដឹកនាំជាគោលទេ។ តាមការពិតទៅ ចលនាខ្មែរឥស្សរៈបានបង្កើតឡើងពីសមាសភាពក្រុមផ្សេងៗគ្នាជាច្រើន ដែលមានរបៀបវារៈ និងគោលដៅនយោបាយផ្សេងៗគ្នា។ ក្រុមឥស្សរៈនៅភាគខាងលិចប្រទេសកម្ពុជា មាននិន្នាការងាកទៅរកការគាំទ្រពីប្រទេសថៃ ខណៈដែលក្រុមឥស្សរៈនៅភាគខាងកើតបានសហការ និងទទួលឥទ្ធិពលយ៉ាងខ្លាំងពីក្រុមកុម្មុយនីស្តវៀតណាម ដែលស្គាល់ថាជាវៀតមិញ។ ក្រុមកុម្មុយនីស្តវៀតណាមបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រឲ្យមានការកើតឡើងនូវចលនាកុម្មុយនីស្តកម្ពុជានៅក្នុងប្រវត្តិសាស្ត្រដំបូងរបស់ខ្លួន។

វៀតមិញ គឺជាក្រុមចម្រុះនៃកុម្មុយនីស្តវៀតណាម ដែលប្រឆាំងនឹងការគ្រប់គ្រងសាជាថ្មីរបស់បារាំងទៅលើវៀតណាម។ នៅត្រឹមឆ្នាំ១៩៤៩ ចលនាវៀតមិញទទួលការគាំទ្រពីសំណាក់ក្រុមកុម្មុយនីស្តចិន ដែលអនុញ្ញាតឲ្យចលនាវៀតមិញបង្កើនការតស៊ូ ពីជម្លោះបែបឧទ្ទាមទៅជាសង្គ្រាមមួយ។ នៅត្រឹមឆ្នាំ១៩៥០ តំបន់ឥណ្ឌូចិនរបស់បារាំង ស្ថិតក្នុងស្ថានភាពឧទ្ទាមកម្មដែលសព្វថ្ងៃយើងហៅថា សង្គ្រាមឥណ្ឌូចិនលើកទី១។ ការ

ប្រយុទ្ធគ្នាភាគច្រើននៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី១ បានកើតឡើងនៅប្រទេសវៀតណាម ប៉ុន្តែក្រុមអ្នកជាតិនិយមខ្មែរ ក៏បានតស៊ូប្រឆាំងនឹងបារាំងស្របពេលជាមួយគ្នា។ នៅឆ្នាំ១៩៥១ ក្រុមកុម្មុយនីស្តវៀតណាមបានណែនាំឲ្យមានការបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលជាក្រុមដំបូងបង្អស់ឆ្ពោះទៅកាន់បក្សកុម្មុយនីស្តកម្ពុជា (ដែលស្គាល់ថា ខ្មែរក្រហម)។ ដូចចលនាខ្មែរឥស្សរៈ គឺបានងាកទៅរកក្រុមកុម្មុយនីស្តវៀតណាមដើម្បីសុំការណែនាំ។

នៅត្រឹមឆ្នាំ១៩៥៣ ប្រទេសបារាំងបានប្រគល់ឯករាជ្យឲ្យប្រទេសកម្ពុជា នៅក្នុងសន្និសីទស្តីពីសន្តិភាពនៅទីក្រុងហ្សឺណែវ (បានបញ្ចប់ជាផ្លូវការនូវសង្គ្រាមឥណ្ឌូចិនលើកទី១ នៅឆ្នាំ១៩៥៤) វៀតណាម បែងចែកជាប្រទេសវៀតណាមកុម្មុយនីស្តខាងជើង និងវៀតណាមខាងត្បូងដែលគាំទ្រដោយលោកខាងលិច។

រយៈពេលជាច្រើនឆ្នាំ បន្ទាប់ពីសន្និសីទស្តីពីសន្តិភាពនៅទីក្រុងហ្សឺណែវ (១៩៥៥-១៩៥៩) ចលនាកុម្មុយនីស្តកម្ពុជា ចុះទន់ខ្សោយ។ ខណៈដែលការគ្រប់គ្រងរបស់អាណានិគមនិយមបារាំងបញ្ចប់នៅក្នុងប្រទេសកម្ពុជា របបគ្រប់គ្រងមិនបានជំនួសវិញ ដោយរបបលទ្ធិប្រជាធិបតេយ្យ។ ព្រះករុណា សម្តេចព្រះ នរោត្តម សីហនុ បានដាក់រាជ្យ និងក្លាយជាសម្តេចព្រះ នរោត្តម សីហនុ ដែលជាអ្នកនយោបាយ និងជានាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា។ នៅក្រោមរបបរបស់ព្រះអង្គ ក្រុមប្រឆាំងត្រូវបានគាបសង្កត់ ហើយក្រុមកុម្មុយនីស្តកម្ពុជា ដែលធ្លាប់សង្ឃឹមថានឹងមានមុខតំណែងនៅក្នុងរដ្ឋឯករាជ្យថ្មីរបស់កម្ពុជា បានបែកខ្ញាត់ខ្ញាយទៅតាមទីជនបទ។ នៅតាមទីជនបទ និងព្រៃភ្នំ ក្រុមកុម្មុយនីស្តកម្ពុជាបានត្រដររស់។

នៅខែកញ្ញា ឆ្នាំ១៩៦០ បក្សប្រជាជនបដិវត្តន៍ខ្មែរបានរៀបចំគណបក្សឡើងវិញ បង្កើតមាគ៌ានយោបាយថ្មី និងផ្លាស់ប្តូរឈ្មោះទៅជាបក្សពលករកម្ពុជា។ ទូ សាមុត ក្លាយជាលេខាបក្ស, នួន ជា ក្លាយជាអនុលេខាបក្ស និង ប៉ុល ពត ស្ថិតនៅលំដាប់ទីបី។ មានការជឿជាក់ថា ប៉ុល ពត បានក្លាយជាអនុលេខាបក្សទីពីរនៅឆ្នាំ១៩៦១។ ក្រោយពី ទូ សាមុត បានបាត់ខ្លួននៅឆ្នាំ១៩៦២ បក្សពលករកម្ពុជាបានកោះប្រជុំបន្ទាន់នៅខែកុម្ភៈ ឆ្នាំ១៩៦៣។ ការប្រជុំបានជ្រើសតាំង ប៉ុល ពត ជាលេខាបក្ស, នួន ជា នៅជាអនុលេខាដដែល។ នៅក្នុងឆ្នាំ១៩៦៥ ប៉ុល ពត បានចូលរួមក្នុងកិច្ចប្រជុំមួយចំនួនជាមួយវៀតណាមខាងជើង ចិន និងកូរ៉េខាងជើង។ នៅក្នុងឆ្នាំ១៩៦៦ បន្ទាប់ពីវិលត្រឡប់មកកាន់ប្រទេសវិញ ប៉ុល ពត បានប្តូរឈ្មោះបក្សទៅជាបក្សកុម្មុយនីស្តកម្ពុជា។ សមាជិករបស់គណៈមជ្ឈិមបក្សរួមមាន ប៉ុល ពត, នួន ជា, អៀង សារី, វន វ៉េត និង សុន សេន។ នៅតាមតំបន់ឆ្ងាយៗដែលទាហានរដ្ឋាភិបាលមិនអាចទៅដល់ ចលនាកុម្មុយនីស្តកម្ពុជាបានពង្រឹងអំណាច និងរៀបចំខ្លួនឡើងវិញដើម្បីរង់ចាំស្ថានការណ៍អំណោយផល ដែលនឹងអនុញ្ញាតឲ្យខ្លួនឡើងកាន់អំណាច។ នៅទីបំផុត ស្ថានការណ៍អំណោយផលបានមកដល់នៅឆ្នាំ១៩៧០ ដោយមានការទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីអំណាច និងការបង្កើតឡើងនូវរបប លន់ នល់។

នៅខែមីនា ឆ្នាំ១៩៧០ រដ្ឋសភាបានបោះឆ្នោតទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីព្រះប្រមុខរដ្ឋ។ ការទម្លាក់សម្តេចព្រះ នរោត្តម សីហនុ និងការបង្កើតរបប លន់ នល់ បានចាប់ផ្តើមនូវស្ថានការណ៍អំណោយផលមួយចំនួនសម្រាប់ក្រុមកុម្មុយនីស្តកម្ពុជា។ ក្រោយពីដកតំណែង ព្រះអង្គបានចាប់ដៃជាមួយអតីតសត្រូវរបស់ព្រះអង្គ គឺក្រុមកុម្មុយនីស្តកម្ពុជាឬខ្មែរក្រហម។ ព្រះអង្គនៅតែទទួលបានការគោរពគាំទ្រពីប្រជារាស្ត្រយ៉ាងខ្លាំងនៅតាមទីជនបទ។ ដូច្នេះសម្ព័ន្ធភាពរបស់ខ្មែរក្រហមជាមួយព្រះអង្គបាននាំឲ្យមានការចូលរួមកម្លាំងទ័ពថ្មីទៀត ចំពោះបុព្វហេតុកុម្មុយនីស្ត។

លើសពីនេះទៀត ការបង្កើតរបប លន់ នល់ ដែលគាំទ្រដោយលោកខាងលិច បានបង្កឲ្យកើតមានសង្គ្រាមឥណ្ឌូចិនលើកទីពីរ (ឬសង្គ្រាមវៀតណាម)។ ប្រទេសកម្ពុជាបានធ្លាក់ក្នុងសង្គ្រាមឥណ្ឌូចិនលើកទី២។ សង្គ្រាមរវាងសហរដ្ឋអាមេរិក និងវៀតណាមខាងត្បូងជាមួយនឹងក្រុមកុម្មុយនីស្តវៀតណាម និងវៀតណាមខាងជើងបានផ្ទុះឡើងនៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែន។ ក្នុងអំឡុងនៃការគ្រប់គ្រងរបស់សម្តេចព្រះ នរោត្តម សីហនុកងកម្លាំងកុម្មុយនីស្តវៀតណាមអនុញ្ញាតឲ្យប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីគាំទ្រការតស៊ូរបស់ខ្លួនប្រឆាំងនឹងអាមេរិក និងវៀតណាមខាងត្បូង។ ជាថ្នូរវិញ ក្រុមកុម្មុយនីស្តវៀតណាមបានគាំទ្រសម្តេចព្រះ នរោត្តម សីហនុ បើទោះបីជាធ្វើឲ្យប៉ះពាល់ដល់សមមិត្តរួមអាវុធរបស់ខ្លួន គឺក្រុមកុម្មុយនីស្តកម្ពុជាក៏ដោយ។ ឆ្លៀតពេលដែលរបបគាំទ្រដោយលោកខាងលិចកំពុងគ្រប់គ្រងប្រទេសកម្ពុជា កងកម្លាំងកុម្មុយនីស្តវៀតណាម ក៏បានរំកិលចូលកាន់តែជ្រៅទៅក្នុងផ្ទៃប្រទេស ដើម្បីប្រយុទ្ធជាមួយកងកម្លាំង លន់ នល់ ព្រមទាំងជួយជ្រើសរើស និងហ្វឹកហ្វឺនកងទ័ពខ្មែរក្រហម។ ជាលទ្ធផល ខ្មែរក្រហមបានពង្រីកកម្លាំងរបស់ខ្លួនពីប្រមាណ៣ពាន់នាក់នៅក្នុងឆ្នាំ១៩៧០ រហូតដល់ជាង ៤ម៉ឺននាក់ នៅឆ្នាំ១៩៧៣។ ដោយមានជំនួយពីវៀតណាម ខ្មែរក្រហមចាប់ផ្តើមវាយប្រហារកងកម្លាំងរបស់ លន់ នល់ ឲ្យបរាជ័យនៅលើសមរភូមិមួយចំនួន។

ទោះបីជាយ៉ាងណា សម្ព័ន្ធភាពរវាងវៀតណាម និងខ្មែរក្រហមមិនបិតថេរទេ។ ខណៈពេលដែលខ្មែរក្រហមបានកើតឡើងទាំងកម្លាំងប្រយុទ្ធ និងទំនុកចិត្ត ខ្លួនក៏ចាប់ផ្តើមទាមទារឲ្យកងកម្លាំងវៀតណាមចាកចេញពីប្រទេសកម្ពុជា។ នៅត្រឹមចុងឆ្នាំ១៩៧៣ វៀតណាមបានដកទ័ពចេញពីកម្ពុជាមួយភាគធំ ខ្មែរក្រហមបានទទួលខុសត្រូវទាំងស្រុងនូវរាល់សង្គ្រាមប្រឆាំងនឹងរបប លន់ នល់ ។

នៅដើមឆ្នាំ១៩៧៣ ប្រហែល៨៥ភាគរយនៃទឹកដីកម្ពុជា បានធ្លាក់ក្នុងកណ្តាប់ដៃរបស់ខ្មែរក្រហម ហើយកងទ័ព លន់ នល់ ស្ទើរតែមិនអាចការពារខ្លួនបាន។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ បន្តិចក្រោយមក បានប្រកាសពីការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ។



កិច្ចប្រជុំរវាងកុម្មុយនីស្តកម្ពុជា និងកុម្មុយនីស្តវៀតណាម។
ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

*ចំណុចសង្ខេបៗដើម្បីបញ្ចូលទៅក្នុងការធ្វើបទបង្ហាញ៖*

*១. ពាក្យ «ខ្មែរក្រហម» ជាឈ្មោះដែលសម្តេចព្រះ នរោត្តម សីហនុ ដាក់ឲ្យក្រុមកុម្មុយនីស្តប្រឆាំងនឹងព្រះអង្គនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ ឈ្មោះផ្លូវការរបស់ខ្មែរក្រហមគឺ បក្សកុម្មុយនីស្តកម្ពុជា។ ដើមកំណើតរបស់ខ្មែរក្រហម ចាប់ផ្តើមពីការតស៊ូយ៉ាងទូលំទូលាយប្រឆាំងនឹងអាណានិគមនិយមបារាំង។*

*២. ចាប់ពីត្រីមាសចុងក្រោយនៃសតវត្សរ៍ទី១៩ រហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩៥០ បារាំងបានគ្រប់គ្រងកម្ពុជា ឡាវ វៀតណាម ដែលត្រូវបានស្គាល់ថាឥណ្ឌូចិនបារាំង។*

*៣. នៅឆ្នាំ១៩៥១ ក្រុមកុម្មុយនីស្តវៀតណាមបានត្រួសត្រាយផ្លូវឲ្យបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលជាបក្សដំបូងបង្អស់ឆ្ពោះទៅក្លាយជាបក្សកុម្មុយនីស្តកម្ពុជា។*

*៤. នៅត្រឹមឆ្នាំ១៩៥៣ បារាំងបានប្រគល់ឯករាជ្យឲ្យកម្ពុជាវិញ។*

*៥. នៅខែកញ្ញា ឆ្នាំ១៩៦០ បក្សប្រជាជនបដិវត្តន៍ខ្មែរបានរៀបចំបក្សឡើងវិញ បង្កើតមាគ៌ានយោបាយថ្មី និងផ្លាស់ប្តូរឈ្មោះរបស់ខ្លួនទៅជាបក្សពលករកម្ពុជាវិញ។*

*៦. ទូ សាមុត បានក្លាយជាលេខាបក្សពលករកម្ពុជា នួន ជា មានតួនាទីជាអនុលេខាបក្ស។ ប៉ុល ពត ស្ថិតនៅលំដាប់ទីបីនៅពេលនោះ។ មានការជឿជាក់ថា ប៉ុល ពត បានក្លាយជាអនុលេខាបក្សទីពីរនៅឆ្នាំ១៩៦១។*

*៧. បន្ទាប់ពី ទូ សាមុត បានបាត់ខ្លួននៅឆ្នាំ១៩៦២ បក្សកោះប្រជុំបន្ទាន់មួយនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៦៣។ កិច្ចប្រជុំនេះបានជ្រើសតាំង ប៉ុល ពត ជាលេខាបក្ស។ នួន ជា នៅតែជាអនុលេខាដដែល។*

*៨. នៅឆ្នាំ១៩៦៦ ប៉ុល ពត បានប្តូរឈ្មោះ បក្សពលករកម្ពុជា ទៅជា បក្សកុម្មុយនីស្តកម្ពុជា។ គណៈមជ្ឈិមបក្សរួមមាន ប៉ុល ពត, នួន ជា, អៀង សារី, វន វ៉េត និង សុន សេន។*

*៩. នៅខែមីនា ឆ្នាំ១៩៧០ រដ្ឋសភាកម្ពុជាបានបោះឆ្នោតទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពីព្រះប្រមុខរដ្ឋ។ ការដកតំណែងរបស់សម្តេចព្រះ នរោត្តម សីហនុ ការបង្កើតរបប លន់ នល់ ដែលគាំទ្រដោយលោកខាងលិចនិងការបន្តសង្គ្រាមឥណ្ឌូចិនលើកទី២ បានបង្កើតឲ្យមានស្ថានការណ៍អំណោយផល ដល់ក្រុមកុម្មុយនីស្តកម្ពុជាក្នុងការដណ្តើមអំណាច។*

*១០. ដោយមានរបបដែលមានការគាំទ្រដោយលោកខាងលិចគ្រប់គ្រងប្រទេសកម្ពុជា កងកម្លាំងកុម្មុយនីស្តវៀតណាមបានចូលកាន់តែជ្រៅទៅក្នុងប្រទេសកម្ពុជា ដើម្បីប្រយុទ្ធជាមួយកងទ័ព លន់ នល់ និងជួយជ្រើសរើស និងហ្វឹកហ្វឺនកងទ័ពសម្រាប់ចលនាខ្មែរក្រហម។ សម្តេចព្រះ នរោត្តម សីហនុ ក៏បានចូលរួមក្នុងការតស៊ូរបស់ខ្មែរក្រហមក្នុងនាមជាសម្ព័ន្ធមិត្ត។*

*១១. ជាលទ្ធផលនៃកាលៈទេសៈទាំងអស់នេះ ចលនាខ្មែរក្រហមបានបង្កើនកម្លាំងកងទ័ព ពីប្រមាណ ៣ពាន់នាក់នៅឆ្នាំ១៩៧០ រហូតដល់ជាង៤ម៉ឺននាក់នៅឆ្នាំ១៩៧៣។ ដោយមានជំនួយពីវៀតណាម ខ្មែរក្រហមបានចាប់ផ្តើមមានជ័យជម្នះលើកងកម្លាំង លន់ នល់ នៅលើសមរភូមិ។*

*១២. នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ បានប្រកាសពីការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ។*

## សកម្មភាពទី១

ការណែនាំ៖ សូមអានសេចក្តីសង្ខេបបែបប្រវត្តិសាស្ត្រខាងលើ ឆ្លើយសំណួរខាងក្រោម៖

១. តើខ្មែរក្រហមទទួលបានឈ្មោះថា «ខ្មែរក្រហម» យ៉ាងដូចម្តេច? ____________________

២. តើនៅឆ្នាំ១៩៥១ វៀតណាមបានណែនាំឲ្យបង្កើតបក្សកុម្មុយនីស្តខ្មែរឈ្មោះអ្វី? ____________________

៣. តើនៅក្នុងឆ្នាំ១៩៦០ បក្សប្រជាជនបដិវត្តន៍ខ្មែររៀបចំឡើងវិញទៅជាបក្សអ្វី?

____________________________________________

៤. តើមេដឹកនាំសំខាន់ៗចំនួន៣រូបរបស់បក្សពលករកម្ពុជាមានឈ្មោះអ្វីខ្លះ?

ក. ______________ ខ. ______________ គ. ______________

៥. នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៦៣ បក្សពលករកម្ពុជាបានជ្រើសតាំង ____________________ ជាលេខាបក្ស និង ____________________ ជាអនុលេខាបក្ស។

៦. នៅឆ្នាំ១៩៦៣ ប៉ុល ពត បានប្តូរឈ្មោះបក្សពលករកម្ពុជាទៅជា ____________________?

៧. គណៈមជ្ឈិមបក្សរបស់បក្សកុម្មុយនីស្តកម្ពុជារួមមានសមាសភាពបុគ្គលចំនួន៥រូបដូចខាងក្រោម៖

ក. ______________ ខ. ______________ គ. ______________

ឃ. ______________ ង. ______________

៨. សូមរៀបរាប់ស្ថានភាពយ៉ាងហោចបី (រវាងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥) ដែលបានជួយបក្សកុម្មុយនីស្តកម្ពុជានៅក្នុងការតស៊ូដើម្បីទទួលបានអំណាចនៅកម្ពុជា៖

ក.____________________________________________

ខ.____________________________________________

គ.____________________________________________

៩. សូមរាយឈ្មោះប្រទេសមួយដែលគាំទ្រខ្មែរក្រហមក្នុងការតស៊ូប្រឆាំងនឹងរបប លន់ នល់?

____________________________________________

១០. តើមានកងទ័ពខ្មែរក្រហមចំនួនប្រហែលប៉ុន្មាននាក់ក្នុងឆ្នាំ១៩៧០?____________________

១១. តើមានកងទ័ពខ្មែរក្រហមចំនួនប្រហែលប៉ុន្មាននាក់ក្នុងឆ្នាំ១៩៧៣? ____________________

១២. តើខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញនៅពេលណា? ____________________

## សកម្មភាពទី២

ការណែនាំ៖ ជាដំបូង សូមអានសេចក្តីសង្ខេបប្រវត្តិសាស្ត្រខាងលើ។ បន្ទាប់ពីអានសេចក្តីសង្ខេបចប់ សូមបិទសៀវភៅ យកក្រដាសមួយសន្លឹករួចសរសេរព័ត៌មានឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន អំពីអ្វីដែលអ្នកអាចចាំបានពីសេចក្តីសង្ខេប។ សូមព្យាយាមសរសេរឲ្យបានយ៉ាងហោចណាស់១២ហេតុការណ៍ ឬ ១២ចំណុចខុសៗគ្នា។ បន្ទាប់ពីបានសរសេរបញ្ជីរួចរាល់ សូមបើកសៀវភៅម្តងទៀត (១) ផ្លាស់ប្តូរបញ្ជីរបស់អ្នកជាមួយដៃគូម្នាក់ដែលអាចប្រៀបធៀបបញ្ជីក្នុងគន្លឹះណែនាំ ឬ (២) ប្រៀបធៀបបញ្ជីដោយខ្លួនឯង ជាមួយបញ្ជីនៅក្នុងគន្លឹះណែនាំ។ គូសរង្វង់លើហេតុការណ៍ ឬចំណុចដែលមិនត្រឹមត្រូវ ឬដែលត្រូវកែសម្រួល។

## សកម្មភាពទី៣

ការណែនាំ៖ អ្នកត្រូវការដៃគូម្នាក់។ ដំបូង អ្នកនិងដៃគូគួរតែអានសេចក្តីសង្ខេបប្រវត្តិសាស្ត្រឡើងវិញ ដើម្បីរំឭកការចងចាំ។ បន្ទាប់ពីអ្នកទាំងពីរបានអានសេចក្តីសង្ខេបរួច សូមបិទសៀវភៅ និងយកក្រដាសមួយសន្លឹកចេញមកក្រៅ។ អ្នកទាំងពីរត្រូវផ្លាស់វេនគ្នា ដើម្បីធ្វើបទបង្ហាញពីសេចក្តីសង្ខេបយ៉ាងខ្លី (មិនលើសពី៥នាទី) អំពីប្រវត្តិសាស្ត្រខាងលើ។ នៅពេលដែលម្នាក់កំពុងធ្វើបទបង្ហាញ ម្នាក់ទៀតគួរកត់ត្រានៅលើក្រដាសដាច់ដោយឡែកមួយ។ អ្នកដែលធ្វើបទបង្ហាញគួរតែនិយាយតាមធម្មតា ប៉ុន្តែមិនលឿនពេក ដើម្បីទុកឲ្យម្នាក់ទៀតធ្វើការកត់ត្រា។ អ្នកកត់ត្រាគួរតែព្យាយាមសរសេរឲ្យបានច្រើនតាមដែលអាចធ្វើបាន និងសរសេរចំណុចទាំងឡាយណា ដែលអ្នកធ្វើបទបង្ហាញគួរលើកមកនិយាយ ក៏ប៉ុន្តែប្រហែលជាបានភ្លេច។ អ្នកកត់ត្រាក៏អាចសរសេរនូវការអង្កេតទាំងឡាយដូចជា តើអ្នកធ្វើបទបង្ហាញបាននិយាយអ្វីដែលមិនត្រឹមត្រូវ និងអាចយល់បានឬទេ។ សកម្មភាពទី៣ មានវត្ថុបំណងពីរយ៉ាងគឺ (១) អាចជួយអ្នកធ្វើបទបង្ហាញ អនុវត្តជំនាញធ្វើបទបង្ហាញជាមួយនឹងព័ត៌មានប្រវត្តិសាស្ត្រ និង (២) អាចជួយអ្នកកត់ត្រាឲ្យអនុវត្តជំនាញវាយតម្លៃ ដោយសារតែអ្នកចូលរួមអាចនឹងត្រូវវាយតម្លៃអ្នកផ្សេងទៀត នៅក្នុងពេលធ្វើបទបង្ហាញនាពេលអនាគត។

## បទបង្ហាញទី២៖ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ការណែនាំ៖ សូមអានបទបង្ហាញខាងក្រោម និងគន្លឹះណែនាំ មុនពេលបន្តទៅធ្វើលំហាត់។




ដំណើរទស្សនកិច្ចសម្ងាត់របស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នៅតំបន់រំដោះខ្មែរក្រហម នៅឆ្នាំ១៩៧៣។ នេះជាទស្សនកិច្ចលើកដំបូងរបស់សម្តេចព្រះ នរោត្តម សីហនុ (ទីពីរ រាប់ពីស្តាំ) ដែលត្រូវជាប្រមុខនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ព្រមទាំងព្រះមហេសីរបស់ទ្រង់ព្រះអង្គម្ចាស់ក្សត្រី នរោត្តម មុនីនាថ សីហនុ (ទីពីររាប់ពីឆ្វេង) មកកាន់កម្ពុជាក្រោយការធ្វើរដ្ឋប្រហារនៅ ខែមីនា ឆ្នាំ១៩៧០។ នៅក្នុងរូបនេះមាន៖ ខៀវ សំផន (ទីបីរាប់ពីឆ្វេង) និងហ៊ូ នឹម ហៅ ភាស់ (ខាងស្តាំ) ដែលក្រោយមកក្លាយជារដ្ឋមន្ត្រីក្រសួងឃោសនាការនិងព័ត៌មាន នៅក្នុងរបបខ្មែរក្រហម។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

បក្សកុម្មុយនីស្តកម្ពុជា បានព្យាយាមធ្វើបដិវត្តន៍សង្គមនិយមបែបទាន់ហន់នៅកម្ពុជា តាមរយៈកម្មវិធីកែទម្រង់បែបលទ្ធិម៉ៅនិយម និងម៉ាក្ស-លេនីននិយម។ ដើម្បីសម្រេចបានជោគជ័យ ខ្មែរក្រហមបានរៀបចំសង្គមឡើងវិញនៅលើគ្រប់វិស័យ ដោយចាប់ផ្តើមពីការជម្លៀសប្រជាជនចេញពីទីក្រុង។

នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនភាគច្រើនជម្លៀសដោយបង្ខំពីផ្ទះសម្បែងរបស់ខ្លួន ទៅកាន់តំបន់ឆ្ងាយៗនៅតាមទីជនបទ។ គោលនយោបាយនៃការជម្លៀសប្រជាជនដោយបង្ខំពីកន្លែងមួយទៅកន្លែងមួយទៀត (ការជម្លៀសដោយបង្ខំ) បង្កឲ្យមានការឈឺចាប់ និងផលប៉ះពាល់យ៉ាងខ្លាំងទៅលើប្រជាជននិងសហគមន៍។ ក្នុងរយៈពេល៤៥ខែ របបខ្មែរក្រហមបានធ្វើការជម្លៀសដោយបង្ខំជាច្រើន នៅតាមតំបន់នានា។

បន្ថែមលើនេះ រូបិយប័ណ្ណ ទីផ្សារសេរី និងទ្រព្យសម្បត្តិឯកជនបានលុបបំបាត់ចោល។ ការប្រតិបត្តិសាសនា និងវប្បធម៌ត្រូវហាមឃាត់ សាលារៀន វត្តអារាម វិហារឥស្លាម វិហារសាសនាគ្រឹស្ត និងហាងលក់ទំនិញនានាបានបិទទ្វារ ឬប្រែក្លាយទៅជាគុកជំរំកែប្រែនិងតាមការស្នើរបស់អង្គការ។មធ្យោបាយដឹកជញ្ជូនសាធារណៈ ឬឯកជនត្រូវបំបាត់ចោល សកម្មភាពកម្សាន្តផ្សេងៗត្រូវបានហាមឃាត់ជាដាច់ខាត។ ប្រជាជនត្រូវបានដកហូតសិទ្ធិមូលដ្ឋានរបស់ខ្លួន មិនត្រូវបានអនុញ្ញាតឲ្យចាកចេញពីប្រទេសទេ។ ក្រុមគ្រួសារត្រូវបានបំបែកចេញពីគ្នា ជំរំការងារត្រូវបានបង្កើតឡើង សង្គមត្រូវបានប្រែក្លាយឲ្យមានសមូហភាព។ ខ្មែរក្រហមជឿថា តាមរយៈការកែទម្រង់ទាំងស្រុង នឹងមានលទ្ធភាពបង្កើនទិន្នផលកសិកម្មក្នុងកម្រិតអតិបរមា សម្រេចបាននូវសមិទ្ធផល និងការអភិវឌ្ឍនៅក្នុងកម្រិតខ្ពស់មួយដែលមិនអាចសម្រេចបានដោយប្រើប្រាស់មធ្យោបាយផ្សេង។

រឿងរ៉ាវដែលផ្ទុយពីបានកើតឡើង គឺប្រជាជនមួយភាគធំបាត់បង់ជីវិត ដោយការអត់ឃ្លាន ការធ្វើការបាក់កម្លាំង ឬជំងឺ។ បន្ថែមពីលើនេះ ដើម្បីការពារបក្សពី«សត្រូវខាងក្នុង និងសត្រូវខាងក្រៅ»ដែលគ្រាន់តែជាការស្រមើស្រមៃមួយ និងដើម្បីដោះស្រាយការបរាជ័យយ៉ាងធំធេងនៃគោលនយោបាយកែទម្រង់ទាំងស្រុងរបស់ខ្លួន ខ្មែរក្រហមបានបង្កើតគម្រោងសន្តិសុខយ៉ាងរឹងមាំ ដែលកំណត់មុខសញ្ញាទៅលើអ្នកដែលពាក់ព័ន្ធជាមួយរបបមុន បញ្ញវន្ត អ្នកមាន និងអ្នកដែលគួរឲ្យសង្ស័យ។ ប្រជាជនត្រូវបានចាប់ខ្លួន និងជាញឹកញាប់គឺសម្លាប់ភ្លាមៗ ឬនៅក្នុងករណីខ្លះ ឃុំឃាំងនៅក្នុងគុក ឬជំរំកែប្រែដែលជាទីកន្លែងធ្វើទុក្ខទារុណកម្ម និងចុងក្រោយគឺបាត់បង់ជីវិត។ ខ្មែរក្រហមមិនស្ទាក់ស្ទើរក្នុងការប្រើប្រាស់ទារុណកម្មដ៏ឃោរឃៅបំផុត ដើម្បីធ្វើឲ្យអាម៉ាស់ ធ្វើឲ្យបាក់ទឹកចិត្ត ធ្វើឲ្យលែងមានភាពជាមនុស្ស និងកម្ទេចអ្នកដែលសង្ស័យថាជាខ្មាំងឡើយ។ របបខ្មែរក្រហមក៏មិនស្ទាក់ស្ទើរក្នុងការធ្វើយុទ្ធនាការបំភិតបំភ័យជនរងគ្រោះគ្រប់ប្រភេទ។ ស្ត្រី កុមារ និងសូម្បីតែសមាជិកដ៏ស្មោះស្ម័គ្របំផុត ក៏ទទួលរងទារុណកម្ម

និងការសម្លាប់។ ក្រុមសាសនា និងជនជាតិភាគតិចបានទទួលរងគ្រោះ ខ្មែរក្រហមមានការប្រុងប្រយ័ត្នជាពិសេសចំពោះអ្នកទាំងឡាយណាដែលមានខ្សែស្រឡាយជាវៀតណាម (ឬឲ្យតែមិនមែនជាខ្មែរ)។ គុកដ៏ឃោរឃៅបំផុត គឺមន្ទីរស-២១ ដែលមានទីតាំងនៅទីក្រុងភ្នំពេញ ជឿថាបានឃុំឃាំងមនុស្សប្រមាណ២ម៉ឺននាក់ ដែលភាគច្រើនត្រូវបានយកទៅសម្លាប់ចោល។ មានការជឿជាក់ថា មនុស្សជាង២លាននាក់បានស្លាប់ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៧០ ជម្លោះជាបន្តបន្ទាប់បានកើតឡើងរវាងវៀតណាមកុម្មុយនីស្តនិងកម្ពុជាប្រជាធិបតេយ្យ ការប្រយុទ្ធទ្រង់ទ្រាយធំបានផ្ទុះឡើងនៅក្នុងអំឡុងពាក់កណ្ដាលឆ្នាំ១៩៧៧ នៅពេលដែលកងកម្លាំងខ្មែរក្រហមបានបាញ់ផ្លោង និងវាយប្រហារខេត្តមួយចំនួនរបស់វៀតណាម។ ដោយប្រឈមមុខនឹងការឈ្លានពានកាន់តែខ្លាំងឡើង វៀតណាមបានសម្រេចចិត្តវាយបកមកវិញ កងកម្លាំងកុម្មុយនីស្តវៀតណាម បានជ្រៀតចូលក្នុងតំបន់ជាច្រើនរបស់កម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៧។ នៅត្រឹមខែមករា ឆ្នាំ១៩៧៨ កងកម្លាំងវៀតណាមបានដកថយ ប៉ុន្តែការលុកលុយបានបង្កឲ្យមានជម្លោះផ្ទៃក្នុងរវាងរបប ប៉ុល ពត និងភូមិភាគបូព៌ា ដែលមានព្រំដែនជាប់ប្រទេសវៀតណាម។ ដោយសារតែនកន្លែងមួយទៀតមានការសង្ស័យជ្រុល និងភ័យខ្លាចអំពីសកម្មភាពក្បត់ផ្ទៃក្នុង របប ប៉ុល ពត បានធ្វើសង្គ្រាមប្រឆាំងនឹងភូមិភាគបូព៌ារបស់កម្ពុជាប្រជាធិបតេយ្យ។ សង្គ្រាមនាំឲ្យមានការងើបឡើងប្រឆាំង ដោយមានការគាំទ្រពីវៀតណាម។ នៅខែមិថុនា ឆ្នាំ១៩៧៨ វៀតណាមបានចាប់ផ្ដើមទម្លាក់គ្រាប់បែកមកលើកម្ពុជាប្រជាធិបតេយ្យ។ នៅខែតុលា ឆ្នាំ១៩៧៨វៀតណាមបានចាប់ផ្ដើមរៀបចំការវាយលុកទ្រង់ទ្រាយធំ។ នៅទីបំផុត នៅចុងខែធ្នូ ឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានបើកការវាយប្រហារទ្រង់ទ្រាយធំមកលើកម្ពុជាប្រជាធិបតេយ្យ។ កងកម្លាំងវៀតណាម និងកងកម្លាំងប្រឆាំងឈ្មោះថា រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានយកប្រៀបលើកងកម្លាំងខ្មែរក្រហមដោយកម្លាំងសព្វាវុធ និងកម្លាំងទ័ពដ៏ច្រើន ដែលបានវាយប្រហារនៅតាមមុខសញ្ញាជាច្រើន។ កងកម្លាំងរបស់វៀតណាម និងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានដណ្ដើមកាន់កាប់ទីក្រុងភ្នំពេញក្នុងរយៈពេលត្រឹមតែបីសប្ដាហ៍ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ វៀតណាមបានជួយបង្កើតរបបថ្មីមួយ ឈ្មោះថា «សាធារណរដ្ឋប្រជាមានិតកម្ពុជា» ប្រកាសជាផ្លូវការនៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៩ មានសមមិត្ត ហេង សំរិន ជាប្រធានរដ្ឋ សមមិត្ត ប៉ែន សុវណ្ណ ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងសមមិត្ត ហ៊ុន សែន ជារដ្ឋមន្ត្រីក្រសួងការបរទេស។


រូបភាពសហករណ៍មួយ។ ថតដោយ ហ្គុនណា បឺយស្ត្រម ឆ្នាំ១៩៧៨, បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

## សង្ខេបមេរៀន

*ចំណុចសង្ខេបៗដែលត្រូវបញ្ចូលទៅក្នុងការធ្វើបទបង្ហាញ៖*

*១. គោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលជាបក្សរបស់ខ្មែរក្រហម គឺជាការធ្វើបដិវត្តន៍សង្គមទាន់ហន់នៅកម្ពុជាតាមរយៈការប្រើប្រាស់កម្មវិធីកែទម្រង់ទាំងស្រុងរបស់លទ្ធិម៉ៅនិយម និងម៉ាក្ស-ឡេនីន។*

*២. ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មនុស្សជាច្រើនត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះសម្បែងរបស់ ខ្លួនទៅកាន់ទីកន្លែងឆ្ងាយៗនៅឯជនបទ។*

*៣. រូបិយប័ណ្ណ ទីផ្សារសេរី និងទ្រព្យសម្បត្តិឯកជនត្រូវបានបំបាត់ចោល។*

*៤. ការប្រតិបត្តិសាសនា និងវប្បធម៌ ត្រូវបានហាមឃាត់ សាលា វត្តអារាម វិហារឥស្លាម ព្រះវិហារគ្រឹស្ត និងហាងលក់ទំនិញ ត្រូវបានបិទទ្វារ ឬប្រើប្រាស់តាមសំណើផ្សេងៗរបស់អង្គការ។*

*៥. នៅអំឡុងរបបខ្មែរក្រហមមិនមានសេវាដឹកជញ្ជូនសាធារណៈឬឯកជនទេ សកម្មភាពកម្សាន្តនានា ក៏ត្រូវបានហាមឃាត់ជាដាច់ខាត។*

*៦. ប្រជាជនត្រូវបានដកហូតសិទ្ធិមូលដ្ឋានរបស់ខ្លួន និងមិនអនុញ្ញាតឲ្យចាកចេញពីប្រទេសឡើយ។*

*៧. ខ្មែរក្រហមជឿជាក់ថា តាមរយៈការកែទម្រង់ទាំងស្រុងនេះខ្លួននឹងបង្កលទ្ធភាពធ្វើឲ្យទិន្នផលកសិកម្មមានកម្រិតអតិបរមា សម្រេចបាននូវសមិទ្ធផល និងការអភិវឌ្ឍនៅក្នុងកម្រិតខ្ពស់មួយ ដែលមិនអាចសម្រេចបានដោយប្រើប្រាស់មធ្យោបាយផ្សេងឡើយ។*

*៨. មនុស្សជាច្រើនត្រូវបានស្លាប់ដោយសារគ្រោះទុរភិក្ស ការបាក់កម្លាំង ឬជំងឺផ្សេងៗ។ មនុស្សជាច្រើនទៀត ក៏ត្រូវបានរងទារុណកម្ម និងការសម្លាប់។*

*៩. ខ្មែរក្រហមបានបង្កើតប្រព័ន្ធសន្តិសុខ ដែលកំណត់មុខសញ្ញាទៅលើអ្នកណាដែលជាប់ពាក់ព័ន្ធជាមួយរបបមុន បញ្ញវន្ត អ្នកមាន និងអ្នកដែលគួរឲ្យសង្ស័យ។*

*១០. ក្រុមសាសនា និងជនជាតិភាគតិច ក៏ទទួលរងទុក្ខខ្លាំង។*

*១១. មានការជឿជាក់ថា មនុស្សជាងពីរលាននាក់ បានស្លាប់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។*

*១២. ក្នុងអំឡុងពាក់កណ្ដាលឆ្នាំ១៩៧៧ កងកម្លាំងខ្មែរក្រហមបានបាញ់ផ្លោងនិងវាយប្រហារខេត្តមួយចំនួនរបស់វៀតណាម។ កងកម្លាំងវៀតណាមបានឆ្លើយតបវិញ ដោយវាយប្រហារទីតាំងរបស់កម្ពុជាប្រជាធិបតេយ្យជាច្រើនកន្លែងនៅឆ្នាំ១៩៧៧។ នៅទីបំផុត នៅខែមិថុនា ឆ្នាំ១៩៧៨ វៀតណាមបានចាប់ផ្ដើមទម្លាក់គ្រាប់បែកមកលើកម្ពុជាប្រជាធិបតេយ្យ។ នៅចុងខែធ្នូ ឆ្នាំ១៩៧៨ កងទ័ពវៀតណាម បានធ្វើការវាយប្រហារទ្រង់ទ្រាយធំមកលើកម្ពុជាប្រជាធិបតេយ្យ។ កងទ័ពវៀតណាមនិងកងកម្លាំងប្រឆាំង ដែលមានឈ្មោះថា រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានយកប្រៀបលើកម្លាំងខ្មែរក្រហម។ កងកម្លាំងវៀតណាម និងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានដណ្ដើមកាន់កាប់ទីក្រុងភ្នំពេញ ក្នុងរយៈពេលត្រឹមតែបីសប្ដាហ៍នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។*

## សកម្មភាពទី១

ការណែនាំ៖ ចូរអានខ្លឹមសារប្រវត្តិសាស្ត្រខាងលើ ឆ្លើយសំណួរខាងក្រោមដូចតទៅ៖

១. តើអ្នកនឹងរៀបរាប់អំពីមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាយ៉ាងដូចម្តេច?

____________________

២. តើក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនជម្លៀសដោយបង្ខំពីផ្ទះសម្បែងរបស់ខ្លួន ទៅកាន់កន្លែងណា?

____________________

៣. ចូររៀបរាប់វត្ថុដែលហាមឃាត់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យឲ្យបានយ៉ាងហោចណាស់បីយ៉ាង?

ក.____________________

ខ.____________________

គ.____________________

៤. ចូររៀបរាប់សកម្មភាពដែលហាមឃាត់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យឲ្យបានយ៉ាងហោចណាស់បីយ៉ាង?

ក.____________________

ខ.____________________

គ.____________________

៥. ត្រូវ ឬខុស៖ ប្រជាជនមានសេរីភាពក្នុងការធ្វើដំណើរក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ____________________

៦. ត្រូវ ឬខុស៖ កម្ពុជាប្រជាធិបតេយ្យបានលើកកម្ពស់សិទ្ធិមនុស្ស។ ____________________

៧. សូមរៀបរាប់មនុស្សបីប្រភេទ ដែលកំណត់ជាមុខសញ្ញា នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ៖

ក.____________________

ខ.____________________

គ.____________________

៨. តើមានប្រជាជនប៉ុន្មាននាក់បានស្លាប់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ?____________________

៩. តើអ្វីជាហេតុផលចម្បងមួយក្នុងចំណោមហេតុផលជាច្រើនទៀតដែលធ្វើឲ្យវៀតណាមវាយប្រហារមកលើកម្ពុជាប្រជាធិបតេយ្យ?

____________________

១០. តើក្នុងអំឡុងពេលណាដែលវៀតណាមចាប់ផ្តើមការវាយប្រហារទ្រង់ទ្រាយធំមកលើកម្ពុជាប្រជាធិបតេយ្យ?

____________________

## សកម្មភាពទី២

ការណែនាំ៖ ជាដំបូង សូមអានសេចក្តីសង្ខេបប្រវត្តិសាស្ត្រខាងលើ។ បន្ទាប់ពីអានសេចក្តីសង្ខេបចប់ សូមបិទសៀវភៅ យកក្រដាសមួយសន្លឹករួចសរសេរព័ត៌មានឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន អំពីអ្វីដែលអ្នកអាចចាំបានពីសេចក្តីសង្ខេប។ សូមព្យាយាមសរសេរឲ្យបានយ៉ាងហោចណាស់១២ហេតុការណ៍ ឬ ១២ចំណុចខុសៗគ្នា។ បន្ទាប់ពីបានសរសេរបញ្ជីរួចរាល់ សូមបើកសៀវភៅម្តងទៀត (១) ផ្លាស់ប្តូរបញ្ជីរបស់អ្នកជាមួយដៃគូម្នាក់ដែលអាចប្រៀបធៀបបញ្ជីក្នុងគន្លឹះណែនាំ ឬ (២) ប្រៀបធៀបបញ្ជីដោយខ្លួនឯង ជាមួយបញ្ជីនៅក្នុងគន្លឹះណែនាំ។ គូសរង្វង់លើហេតុការណ៍ ឬចំណុចដែលមិនត្រឹមត្រូវ ឬដែលត្រូវកែសម្រួល។

## សកម្មភាពទី៣

ការណែនាំ៖ អ្នកត្រូវការដៃគូម្នាក់។ ដំបូង អ្នកនិងដៃគូគួរតែអានសេចក្តីសង្ខេបប្រវត្តិសាស្ត្រឡើងវិញ ដើម្បីរំឭកការចងចាំ។ បន្ទាប់ពីអ្នកទាំងពីរបានអានសេចក្តីសង្ខេបរួច សូមបិទសៀវភៅ និងយកក្រដាសមួយសន្លឹកចេញមកក្រៅ។ អ្នកទាំងពីរត្រូវផ្លាស់វេនគ្នា ដើម្បីធ្វើបទបង្ហាញពីសេចក្តីសង្ខេបយ៉ាងខ្លី (មិនលើសពី៥នាទី) អំពីប្រវត្តិសាស្ត្រខាងលើ។ នៅពេលដែលម្នាក់កំពុងធ្វើបទបង្ហាញ ម្នាក់ទៀតគួរកត់ត្រានៅលើក្រដាសដាច់ដោយឡែកមួយ។ អ្នកដែលធ្វើបទបង្ហាញគួរតែនិយាយតាមធម្មតា ប៉ុន្តែមិនលឿនពេក ដើម្បីទុកឲ្យម្នាក់ទៀតធ្វើការកត់ត្រា។ អ្នកកត់ត្រាគួរតែព្យាយាមសរសេរឲ្យបានច្រើនតាមដែលអាចធ្វើបាន និងសរសេរចំណុចទាំងឡាយណា ដែលអ្នកធ្វើបទបង្ហាញគួរលើកមកនិយាយ ក៏ប៉ុន្តែប្រហែលជាបានភ្លេច។ អ្នកកត់ត្រាក៏អាចសរសេរនូវការអង្កេតទាំងឡាយដូចជា តើអ្នកធ្វើបទបង្ហាញបាននិយាយអ្វីដែលមិនត្រឹមត្រូវ និងអាចយល់បានឬទេ។ សកម្មភាពទី៣ មានវត្ថុបំណងពីរយ៉ាងគឺ (១) អាចជួយអ្នកធ្វើបទបង្ហាញ អនុវត្តជំនាញធ្វើបទបង្ហាញជាមួយនឹងព័ត៌មានប្រវត្តិសាស្ត្រ និង (២) អាចជួយអ្នកកត់ត្រាឲ្យអនុវត្តជំនាញវាយតម្លៃ ដោយសារតែអ្នកចូលរួមអាចនឹងត្រូវវាយតម្លៃអ្នកផ្សេងទៀត នៅក្នុងពេលធ្វើបទបង្ហាញនាពេលអនាគត។



គំនរលលាដ៍ក្បាល និងឆ្អឹងមនុស្ស ក្នុងគុកសង់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ មុនសម័យខ្មែរក្រហមទីនេះ គឺជាមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន។ ក្រោយមក ខ្មែរក្រហមបានប្រែក្លាយទៅជាមន្ទីរឃុំឃាំង។ នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ ចេតិយមួយសាងសង់នៅទីនេះដើម្បីដាក់អដ្ឋិធាតុអ្នកស្លាប់នៅរបបខ្មែរក្រហម។ ថតដោយ ដេវីឌ ហក, បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

## បទបង្ហាញទី៣៖ ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង ផ្នែកទី១

ការណែនាំ៖ សូមអានបទបង្ហាញខាងក្រោម និងគន្លឹះណែនាំ មុនពេលបន្តទៅធ្វើលំហាត់។

ស្រុកអន្លង់វែង បង្កើតឡើងជាយូរណាស់មកហើយ មុនពេលក្លាយជាតំបន់តស៊ូចុងក្រោយនៃចលនាកុម្មុយនីស្ត នៅប្រទេសកម្ពុជា។ ឆ្នាំ១៩០៧ អ្នកគូរផែនទីបារាំងបានស្គាល់សហគមន៍អន្លង់វែង នៅពេលបង្កើតព្រំដែនប្រទេសកម្ពុជាជាមួយប្រទេសជិតខាងនៅភាគខាងជើង។ មានការជឿថា ដូចសហគមន៍ដទៃទៀតដែលបង្កើតឡើងនៅតាមព្រំដែនថៃ ប្រជាជនខ្មែរដែលធ្វើដំណើរមកពីភាគខាងលើនៃប្រទេសសៀម ឬមកពីខេត្តស៊ីសាកេតដែលសព្វថ្ងៃជាខេត្តរបស់ថៃ បានចូលមកតាំងទីលំនៅក្នុងស្រុកអន្លង់វែង។



ជនភៀសខ្លួនកម្ពុជានៅជំរុំខាវអ៊ីដាង ប្រទេសថៃ កំពុងប្រមូលផ្តុំគ្នាទៅកន្លែងចែកអាហារ នៅទសវត្សរ៍ឆ្នាំ១៩៨០។ ថតដោយ ដែក ឌុនហ្វ៊ដ, បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ទាក់ទងនឹងរដ្ឋបាល តំបន់ដែលស្ថិតនៅជុំវិញអន្លង់វែងមានប្រវត្តិនៃការដណ្តើមការគ្រប់គ្រងគ្នាទៅវិញទៅមករវាងកម្ពុជា និងថៃ។ នៅចន្លោះឆ្នាំ១៨៦៧ និងឆ្នាំ១៩០៧ អន្លង់វែងស្ថិតនៅក្នុងអតីតខេត្តសៀមណាខនរបស់ថៃ ដែលតាំងពីមុនមក គឺស្ថិតនៅក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ១៨៦៣ ប្រទេសកម្ពុជាស្ថិតនៅក្រោមការការពាររបស់បារាំង ក្នុងនាមជាអាណាព្យាបាលបែបអាណានិគម ដោយសារតែការដាក់សម្ពាធពីបារាំង សៀមបានប្រគល់ខេត្តបាត់ដំបង និងសៀមរាបមកឲ្យកម្ពុជាវិញ នៅឆ្នាំ១៩០៧។



ជំរំសាយបី (Site B) នៅឆ្នាំ១៩៩៧។
ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

នៅឆ្នាំ១៩៤១ តំបន់អន្លង់វែងបានកាត់ឲ្យទៅប្រទេសថៃម្តងទៀត (អតីតរដ្ឋសៀម) បន្ទាប់ពីមានជម្លោះរយៈពេលខ្លីរវាងថៃ និងបារាំង។ នៅចន្លោះឆ្នាំ១៩៤១ និងឆ្នាំ១៩៤៦ អន្លង់វែងបានស្ថិតនៅក្នុងខេត្តប្លែកគីប៊ុនសង់ក្រោមរបស់ថៃ។ ប្រទេសថៃបានកាន់កាប់ខេត្តសៀមរាប និងបាត់ដំបង រហូតដល់ឆ្នាំ១៩៤៦ នៅពេលសន្ធិសញ្ញាព្រំដែនរវាងបារាំងនិងថៃ បានធានាឲ្យមានការប្រគល់ខេត្តមកកម្ពុជាវិញ។ ចាប់តាំងពីឆ្នាំ១៩៤៦ តំបន់អន្លង់វែងបានក្លាយជាផ្នែកមួយរបស់កម្ពុជា។

ជីវភាពប្រជាជននៅតំបន់អន្លង់វែង មិនងាយស្រួលទេ។ ដោយគ្មានផ្លូវថ្នល់ គ្មានប្រព័ន្ធទំនាក់ទំនង និងគ្មានហេដ្ឋារចនាសម្ព័ន្ធ តំបន់នៅព័ទ្ធជុំវិញអន្លង់វែងបានស្ថិតនៅក្រៅការយកចិត្តទុកដាក់របស់រដ្ឋាភិបាលសៀម និងកម្ពុជា និងស្ទើរតែគ្មានការផ្លាស់ប្តូរនៅពេលដែលបារាំងបានចូលមកដល់។

បារាំងបានបង្កើតប៉ុស្តិ៍ប៉ូលីស ឬប៉ុស្តិ៍ព្រំដែនជួរមុខតូចមួយ ក្នុងការការពារការវាយប្រហារពីចោរព្រៃ ដែលជាបញ្ហាទូទៅនៅក្នុងតំបន់។ នៅប៉ុន្មានឆ្នាំក្រោយមក លក្ខណៈដាច់ស្រយាលរបស់អន្លង់វែង បានក្លាយជាមុខសញ្ញាដ៏ងាយស្រួលសម្រាប់ការជ្រៀតចូល និងកាន់កាប់របស់ខ្មែរក្រហម។

ខ្មែរក្រហមបានកាន់កាប់តំបន់អន្លង់វែងនៅឆ្នាំ១៩៧០ ជីវភាព និងប្រពៃណីរបស់ប្រជាជនអន្លង់វែងផ្លាស់ប្តូរយ៉ាងខ្លាំង។ មនោគមន៍វិជ្ជាបដិវត្តន៍ខ្មែរក្រហមតម្រូវឲ្យប្រជាជនបោះបង់ចោលនូវវប្បធម៌ និងការប្រតិបត្តិផ្សេងៗក្នុងសហគមន៍។

បន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៥ ប្រជាជននៅអន្លង់វែងបានបន្តរស់នៅតាមផ្ទះសម្បែងរៀងៗខ្លួន ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។ ប៉ុន្តែខ្មែរក្រហមបានរៀបចំប្រជាជនអន្លង់វែងទៅជាអង្គភាពដើម្បីធ្វើកសិកម្ម កាប់ឆ្ការព្រៃ ឬធ្វើការងារពលកម្មផ្សេងៗ។ ក្នុងពេលមួយនៅឆ្នាំ១៩៧៧ ប្រជាជនជាច្រើនត្រូវបង្ខំឲ្យចាកចេញពីអន្លង់វែង និងតំបន់ជុំវិញឲ្យចូលធ្វើការតាមសហករណ៍។

ប្រជាជនភាគច្រើនជម្លៀសដោយបង្ខំទៅកាន់ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ខ្លះទៀតជម្លៀសទៅស្រុកវ៉ារិន ស្រុកស្រីស្នំ ស្រុកសំរោង និងស្រុកចុងកាល់។ ជាទូទៅតំបន់អន្លង់វែងកាន់កាប់ដោយកងទ័ពខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៧ ដល់ដើមឆ្នាំ១៩៧៩។

ប្រជាជនធ្វើដំណើរទៅកាន់ស្រុកក្រឡាញ់តាមមធ្យោបាយផ្សេងៗគ្នា អ្នកខ្លះធ្វើដំណើរតាមរទេះគោ ខណៈដែលប្រជាជនភាគច្រើនធ្វើដំណើរដោយថ្មើរជើង អ្នកខ្លះទៀតមានសំណាងដោយបានដឹកជញ្ជូនតាមឡានរបស់ខ្មែរក្រហម។

នៅស្រុកក្រឡាញ់ ប្រជាជនពីអន្លង់វែងត្រូវបង្ខំឲ្យរស់នៅតាមសហករណ៍ផ្សេងៗ និងរៀបចំជាអង្គភាពដាច់ដោយឡែកពីប្រជាជនមកពីតំបន់ផ្សេងៗទៀត។ កុមារតូចៗអាចរស់នៅជាមួយម្តាយនៅពេលយប់បាន។ នៅពេលថ្ងៃ កុមារត្រូវចូលរៀន និងកាត់ស្មៅ ដើម្បីធ្វើជីដាក់ស្រែ ប្រមូលមែកឈើ ឬដេញចាបកុំឲ្យចុះស៊ីស្រូវក្នុងស្រែ។ ប្រជាជនក៏តម្រូវឲ្យកសាងទំនប់ និងជីកប្រឡាយ។ នៅឯការដ្ឋានទំនប់ស្ពានស្រែង ស្រុកក្រឡាញ់ បានរកឃើញវាលពិឃាតមួយឈ្មោះ «ឡពិឃាត ភ្នំទ្រង់បាត»។

ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់អន្លង់វែង ប្រកបដោយភាពលំបាកលំបិន រស់នៅដោយគ្មានអាហារហូបចុកគ្រប់គ្រាន់ និងមានការសង្ស័យលើគ្នាទៅវិញទៅមក។ អ្វីក៏អាចនាំឲ្យមានការសង្ស័យបាន។ ឧទាហរណ៍ អ្នករស់រានមានជីវិតម្នាក់នៅចាំថាបានឃើញមនុស្សដឹកតាមឡានយកទៅសម្លាប់ ដោយសារតែចំណាយពេលយូរពេកនៅពេលបន្ទោបង់នៅក្នុងបន្ទប់ទឹក ឬនៅវាលស្រែ។ វាលពិឃាតនៅស្រុកក្រឡាញ់ស្ថិតនៅក្បែរឡភ្នំទ្រង់បាត។ មានការរាយការណ៍ថា មានមនុស្សរាប់រយ ឬអាចឈានទៅដល់រាប់ពាន់នាក់សម្លាប់នៅកន្លែងនោះ។

នៅចុងឆ្នាំ១៩៧៨ កងកម្លាំងវៀតណាមវាយលុកចូលកម្ពុជាប្រជាធិបតេយ្យ ដណ្តើមបានទីក្រុងភ្នំពេញ នៅក្នុងខែមករា ឆ្នាំ១៩៧៩។ ការវាយលុកចូលរបស់កងកម្លាំងវៀតណាម និងកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ធ្វើឲ្យកងទ័ព កម្មាភិបាលខ្មែរក្រហម និងប្រជាជនមានការភ័យខ្លាច បំបែកគ្នារត់គេចខ្លួនទៅក្នុងព្រៃនិងតាមបណ្តោយព្រំដែនថៃ។ អង្គភាពខ្មែរក្រហមជាច្រើនបានដាច់ទំនាក់ទំនងជាមួយខ្សែសង្វាក់បញ្ជាពីខាងលើហើយបានរត់ចោលជួរកងទ័ព។ ជាជំនួសវិញ សមាជិកខ្មែរក្រហមព្យាយាមស្វែងរកកន្លែងគេចខ្លួន។ ក្នុងអំឡុងពេលគេចខ្លួន ខ្មែរក្រហមបានជម្លៀសមនុស្សរាប់ម៉ឺននាក់ទៅជាមួយដើម្បីបន្តការតស៊ូម្តងទៀត។ ស្ថិតក្នុងដំណើរដ៏វែងឆ្ងាយ និងប្រកបដោយគ្រោះថ្នាក់ទៅកាន់ព្រំដែនថៃ យោធា និងជនស៊ីវិលភៀសខ្លួនមានស្បៀងតិចតួចណាស់ និងតែងតែស្វែងរកស្លឹកឈើ រុក្ខជាតិ និងសត្វព្រៃ ដែលប្រទះឃើញនៅតាមផ្លូវមកធ្វើជាអាហារ។ ប្រជាជនខ្លះទទួលបានអាហារនិងគ្រឿងប្រើប្រាស់ផ្សេងៗពីអ្នកភូមិ ក៏ប៉ុន្តែត្រូវបានបង្ខំឲ្យធ្វើដំណើរជាច្រើនថ្ងៃដោយគ្មានអាហារ និងទឹកបរិភោគគ្រប់គ្រាន់។ នៅក្នុងករណីខ្លះ ប្រជាជននិយាយថា បានផឹកទឹកនោមខ្លួនឯង ព្រោះមិនអាចប្រើប្រាស់ប្រភពទឹកក្នុងតំបន់បាន ដោយមានការយាមកាមពីកងកម្លាំងវៀតណាម។

មានហេតុផលជាច្រើនដែលនាំឲ្យប្រជាជនការភៀសខ្លួនទៅព្រំដែនកម្ពុជា-ថៃ។ ប្រជាជនជឿតាមការឃោសនាខ្មែរក្រហម ដែលរៀបរាប់ពីកងទ័ពវៀតណាមថាជាបិសាច។ ប្រជាជនខ្លះទៀតជឿថា ប្រទេសកម្ពុជាបានបាត់បង់ទៅវៀតណាម។ ដូច្នេះជម្រើសតែមួយគត់ គឺការចាប់ផ្តើមជីវិតថ្មីនៅប្រទេសមួយផ្សេងទៀត។ ប្រជាជនផ្សេងទៀតបានជ្រើសរើសការរត់ចេញពីប្រទេសកម្ពុជា ដោយសារខ្លួនបានដឹងថា អង្គការសហប្រជាជាតិកំពុងផ្តល់អាហារដល់ជនភៀសខ្លួននៅប្រទេសថៃ។ ប្រជាជនខ្លះទៀត គឺជាអ្នកធ្វើការឲ្យរបបកម្ពុជាប្រជាធិបតេយ្យ។

នៅពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅដើមឆ្នាំ១៩៧៩ ប្រជាជននៅអន្លង់វែងបានវិលត្រឡប់ទៅកាន់សហគមន៍របស់ខ្លួនវិញ។ ប្រជាជនបានប្រឈមមុខសាជាថ្មីជាមួយនឹងភាពលំបាក ដែលខ្លួនជាប់ផុងនៅចន្លោះកងកម្លាំងយោធាដែលប្រជែងគ្នាដើម្បីស្វែងរកការគាំទ្រ។ កងកម្លាំងខ្មែរក្រហមដែលបរាជ័យបានស្វែងរកទីជម្រកនៅលើភ្នំដងរែក ខណៈដែលកងកម្លាំងរបស់វៀតណាមនិងសាធារណរដ្ឋប្រជាមានិតកម្ពុជាបានកាន់កាប់តំបន់អន្លង់វែង។




ក្រុមគ្រួសារខ្មែរក្រហមមួយ នៅក្នុងផ្ទះរបស់ខ្លួនក្នុងជំរំមួយ នៅឆ្នាំ១៩៨៤។
ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ឧបទេសគ្រូ

*ចំណុចសង្ខេបដែលត្រូវបញ្ចូលក្នុងបទបង្ហាញ៖*

*១. នៅចន្លោះឆ្នាំ១៨៦៧ និងឆ្នាំ១៩០៧ តំបន់អន្លង់វែងស្ថិតនៅក្នុងអតីតខេត្តសៀមណាខនរបស់ថៃ ពីមុនមកអន្លង់វែងស្ថិតនៅក្នុងប្រទេសកម្ពុជា។*

*២. នៅឆ្នាំ១៨៦៣ ប្រទេសកម្ពុជាស្ថិតនៅក្រោមការការពាររបស់បារាំងក្នុងនាមជាអាណាព្យាបាល ដោយសារតែការដាក់សម្ពាធរបស់បារាំង សៀមបានប្រគល់អតីតខេត្តបាត់ដំបង និងសៀមរាប មកឲ្យកម្ពុជាវិញនៅឆ្នាំ១៩០៧។*

*៣. នៅឆ្នាំ១៩៤១ ទឹកដីនេះត្រូវបានកាត់ចូលទៅប្រទេសថៃ (អតីតសៀម) សាជាថ្មីម្តងទៀត។ នៅចន្លោះឆ្នាំ១៩៤១ និងឆ្នាំ១៩៤៦ អន្លង់វែងបានស្ថិតនៅក្នុងខេត្តប្លែកគីប៊ុនសង់ក្រោមរបស់ថៃ។*

*៤. ថៃបានប្រគល់ខេត្តបាត់ដំបងនិងសៀមរាបមកឲ្យកម្ពុជាវិញនៅឆ្នាំ១៩៤៦។*

*៥. តាមប្រវត្តិសាស្ត្រអន្លង់វែងជាតំបន់នៅឆ្ងាយដាច់ស្រយាលដែលធ្វើឲ្យតំបន់នេះក្លាយជាគោលដៅយ៉ាងងាយស្រួលសម្រាប់ក្រុមចោរព្រៃ ជាច្រើនឆ្នាំក្រោយមកទៀតក៏ជាកន្លែងសម្រាប់ការជ្រៀតចូលរបស់ក្រុមកុម្មុយនីស្ត។*

*៦. ខ្មែរក្រហមបានចូលកាន់កាប់តំបន់អន្លង់វែងនៅឆ្នាំ១៩៧០។ បន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៥ ប្រជាជននៅអន្លង់វែង បានបន្តរស់នៅតាមផ្ទះសម្បែងរបស់ខ្លួនក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។ តែទោះជាយ៉ាងណា ប្រជាជនត្រូវបានរៀបចំឲ្យចូលតាមអង្គភាពដើម្បីធ្វើកសិកម្ម កាប់ឆ្ការព្រៃ ឬការងារពលកម្មផ្សេងៗ។*

*៧. នៅក្នុងឆ្នាំ១៩៧៧ ប្រជាជនត្រូវបានបង្ខំឲ្យចាកចេញពីអន្លង់វែងនិងតំបន់ជុំវិញ ទៅកាន់ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ប្រជាជនមួយចំនួនទៀតត្រូវបានជម្លៀសទៅកាន់ស្រុកវ៉ារិន ស្រុកស្រីស្នំ ស្រុកសំរោង និងស្រុកចុងកាល់។*

*៨. ជាទូទៅតំបន់អន្លង់វែងបានក្លាយជាតំបន់ ដែលកាន់កាប់ដោយកងទ័ពខ្មែរក្រហមចាប់តាំងពីឆ្នាំ១៩៧៧ ដល់ដើមឆ្នាំ១៩៧៩។*

*៩. ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ជីវភាពរស់នៅនៅតំបន់អន្លង់វែងជួបប្រទះនឹងការលំបាកជាច្រើន។ ប្រជាជនរស់នៅ ដោយមិនមានអាហារហូបចុកគ្រប់គ្រាន់ និងសង្ស័យលើគ្នាទៅវិញទៅមក។*

*១០. នៅឯការដ្ឋានទំនប់ស្ពានស្រែង រលពិឃាតមួយត្រូវបានរកឃើញគឺ «ឡពិឃាតភ្នំទ្រង់បាត» នៅក្នុងស្រុកក្រឡាញ់។ រលពិឃាតមួយទៀតនៅស្រុកក្រឡាញ់ ត្រូវបានជឿជាក់ថាស្ថិតនៅក្បែរឡនៅភ្នំទ្រង់បាត។*

*១១. នៅចុងឆ្នាំ១៩៧៨ កងកម្លាំងវៀតណាមបានវាយចូលមកក្នុងកម្ពុជាប្រជាធិបតេយ្យ នៅខែមករា ឆ្នាំ១៩៧៩ កងកម្លាំងវៀតណាមបានទទួលជោគជ័យក្នុងការកាន់កាប់ទីក្រុងភ្នំពេញ។*

*១២. ប្រជាជនកម្ពុជាបានរត់ភៀសខ្លួនទៅព្រំដែនកម្ពុជាថៃដោយសារហេតុផលមួយចំនួន។ អ្នកខ្លះជឿថា កងទ័ពវៀតណាមគឺជាបិសាច។ អ្នកខ្លះទៀតជឿថា ជម្រើសតែមួយគត់របស់ខ្លួន គឺចាប់ផ្តើមជីវិតថ្មីនៅក្នុងប្រទេសមួយផ្សេងទៀត។ អ្នកផ្សេងទៀត បានជ្រើសរើសយកការភៀសខ្លួនចេញពីប្រទេសកម្ពុជា ដោយសារតែខ្លួនដឹងថា អង្គការសហប្រជាជាតិ កំពុងផ្តល់អាហារដល់ជនភៀសខ្លួននៅប្រទេសថៃ។ អ្នកខ្លះទៀត ធ្លាប់ជាអ្នកធ្វើការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។*

## សកម្មភាពទី១

ការណែនាំ៖ សូមអានសេចក្តីសង្ខេបប្រវត្តិសាស្ត្រខាងលើ ឆ្លើយសំណួរខាងក្រោម៖

១. តើនៅចន្លោះឆ្នាំ១៨៦៧ និងឆ្នាំ១៩០៧ អន្លង់វែងគឺជាផ្នែកមួយនៃខេត្តណារបស់ប្រទេសថៃ?

______________________________

២. តើនៅពេលណាដែលប្រទេសកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលរបស់បារាំង? ______________________________

៣. តើនៅចន្លោះឆ្នាំ១៩០៧ និងឆ្នាំ១៩៤១ ប្រទេសណាជាអ្នកគ្រប់គ្រងតំបន់នៅជុំវិញអន្លង់វែង?

______________________________

៤. តើនៅឆ្នាំ១៩៤១ អន្លង់វែងបានក្លាយជាផ្នែកមួយនៃខេត្តណារបស់ថៃ?

______________________________

៥. តើនៅក្នុងឆ្នាំណាដែលថៃបានប្រគល់ខេត្តសៀមរាបនិងបាត់ដំបងមកឲ្យកម្ពុជាវិញ?

______________________________

៦. អន្លង់វែងត្រូវបានដឹងថាជាតំបន់ស្ថិតនៅដាច់ស្រយាល និងធ្វើឲ្យងាយកើតមាននូវបទល្មើសប្រភេទអ្វីខ្លះ?

______________________________

៧. តើនៅពេលណាដែលខ្មែរក្រហមបានកាន់កាប់តំបន់អន្លង់វែង? ______________________________

៨. នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានប្រមូលប្រជាជនឲ្យចូលទៅក្នុងសហករណ៍ តើភាគច្រើននៃតំបន់ស្ថិតនៅកន្លែងណា?

______________________________

៩. ត្រូវ ឬខុស៖ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ អាហារមានភាពសម្បូរបែប កុមារអាចចូលរៀន និងជីវិតរស់នៅមានភាពល្អប្រសើរសម្រាប់ប្រជាជននៅអន្លង់វែង។ ______________________________

១០. តើវាលពិឃាតនៅស្រុកក្រឡាញ់ឈ្មោះអ្វី? ______________________________

១១. នៅពេលដែលកងកម្លាំងវៀតណាម និងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ មនុស្សជាច្រើនបានភៀសខ្លួនទៅកាន់ប្រទេសថៃ។ ចូររៀបរាប់មូលហេតុយ៉ាងហោចណាស់បី ដែលធ្វើឲ្យប្រជាជនរត់ភៀសខ្លួនចូលទៅប្រទេសថៃ។

ក.______________________________

ខ.______________________________

គ.______________________________

## សកម្មភាពទី២

ការណែនាំ៖ ជាដំបូង សូមអានសេចក្តីសង្ខេបប្រវត្តិសាស្ត្រខាងលើ។ បន្ទាប់ពីអានសេចក្តីសង្ខេបចប់ សូមបិទសៀវភៅ យកក្រដាសមួយសន្លឹករួចសរសេរព័ត៌មានឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន អំពីអ្វីដែលអ្នកអាចចាំបានពីសេចក្តីសង្ខេប។ សូមព្យាយាមសរសេរឲ្យបានយ៉ាងហោចណាស់១២ហេតុការណ៍ ឬ ១២ចំណុចខុសៗគ្នា។ បន្ទាប់ពីបានសរសេរបញ្ជីរួចរាល់ សូមបើកសៀវភៅម្តងទៀត (១) ផ្លាស់ប្តូរបញ្ជីរបស់អ្នកជាមួយដៃគូម្នាក់ដែលអាចប្រៀបធៀបបញ្ជីក្នុងគន្លឹះណែនាំ ឬ (២) ប្រៀបធៀបបញ្ជីដោយខ្លួនឯង ជាមួយបញ្ជីនៅក្នុងគន្លឹះណែនាំ។ គូសរង្វង់លើហេតុការណ៍ ឬចំណុចដែលមិនត្រឹមត្រូវ ឬដែលត្រូវកែសម្រួល។

## សកម្មភាពទី៣

ការណែនាំ៖ អ្នកត្រូវការដៃគូម្នាក់។ ដំបូង អ្នកនិងដៃគូគួរតែអានសេចក្តីសង្ខេបប្រវត្តិសាស្ត្រឡើងវិញ ដើម្បីរំឭកការចងចាំ។ បន្ទាប់ពីអ្នកទាំងពីរបានអានសេចក្តីសង្ខេបរួច សូមបិទសៀវភៅ និងយកក្រដាសមួយសន្លឹកចេញមកក្រៅ។ អ្នកទាំងពីរត្រូវផ្លាស់វេនគ្នា ដើម្បីធ្វើបទបង្ហាញពីសេចក្តីសង្ខេបយ៉ាងខ្លី (មិនលើសពី៥នាទី) អំពីប្រវត្តិសាស្ត្រខាងលើ។ នៅពេលដែលម្នាក់កំពុងធ្វើបទបង្ហាញ ម្នាក់ទៀតគួរកត់ត្រានៅលើក្រដាសដាច់ដោយឡែកមួយ។ អ្នកដែលធ្វើបទបង្ហាញគួរតែនិយាយតាមធម្មតា ប៉ុន្តែមិនលឿនពេក ដើម្បីទុកឲ្យម្នាក់ទៀតធ្វើការកត់ត្រា។ អ្នកកត់ត្រាគួរតែព្យាយាមសរសេរឲ្យបានច្រើនតាមដែលអាចធ្វើបាន និងសរសេរចំណុចទាំងឡាយណា ដែលអ្នកធ្វើបទបង្ហាញគួរលើកមកនិយាយ ក៏ប៉ុន្តែប្រហែលជាបានភ្លេច។ អ្នកកត់ត្រាក៏អាចសរសេរនូវការអង្កេតទាំងឡាយដូចជា តើអ្នកធ្វើបទបង្ហាញបាននិយាយអ្វីដែលមិនត្រឹមត្រូវ និងអាចយល់បានឬទេ។ សកម្មភាពទី៣ មានវត្ថុបំណងពីរយ៉ាងគឺ (១) អាចជួយអ្នកធ្វើបទបង្ហាញ អនុវត្តជំនាញធ្វើបទបង្ហាញជាមួយនឹងព័ត៌មានប្រវត្តិសាស្ត្រ និង (២) អាចជួយអ្នកកត់ត្រាឲ្យអនុវត្តជំនាញវាយតម្លៃ ដោយសារតែអ្នកចូលរួមអាចនឹងត្រូវវាយតម្លៃអ្នកផ្សេងទៀត នៅក្នុងពេលធ្វើបទបង្ហាញនាពេលអនាគត។

ការណែនាំ៖ សូមអានបទបង្ហាញខាងក្រោម និងគន្លឹះណែនាំ ដែលពាក់ព័ន្ធ នៅមុនពេលធ្វើលំហាត់។

ចាប់តាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ កងកម្លាំងខ្មែរក្រហមនិងប្រជាជនដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម រស់នៅក្នុងមូលដ្ឋានយោធាខ្មែរក្រហមនៅតាមបណ្តោយព្រំដែនកម្ពុជាថៃ ឬក្នុងជំរំជនភៀសខ្លួនដទៃទៀតនៅប្រទេសថៃ។ មូលដ្ឋានយោធាខ្មែរក្រហមចម្បងចំនួនពីរ ដែលជាសម្ព័ន្ធជាមួយតំបន់អន្លង់វែង គឺភ្នំ១០០១ និងភ្នំ១០០៣ ដែលមានទីតាំងនៅតាមបណ្តោយជួរភ្នំដងរែក ភាគខាងជើង និងភាគពាយ័ព្យនៃព្រំដែនកម្ពុជា-ថៃ ហើយជាទីតាំងដ៏ពិសេសសម្រាប់ការការពារពីខ្មាំង និងការកសាងកម្លាំងប្រយុទ្ធឡើងវិញ។



អ្នកភូមិមួយចំនួនជួបជុំគ្នាដើម្បីពិភាក្សាអំពីញត្តិរបស់កងកម្លាំងរណសិរ្ស នៅឆ្នាំ១៩៨២ ដែលមានរៀបរាប់ពីបទឧក្រិដ្ឋរបស់ ប៉ុល ពត។
ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ក៏មានតំបន់តស៊ូ និងមូលដ្ឋានយោធាខ្មែរក្រហមជាច្រើនទៀត ដែលក្រោយមកបានដើរតួនាទីជាទីតាំងឈរជើងរបស់ខ្មែរក្រហម ដើម្បីវាយប្រហារនិងដណ្តើមយកតំបន់ត្រួតត្រាមកវិញ នៅក្រោយពេលដែលដឹងថាមានការចាកចេញរបស់កងទ័ពវៀតណាម ពីប្រទេសកម្ពុជានៅឆ្នាំ១៩៨៩។

បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមភាគច្រើនបានក្លាយទៅជាទ័ពឈ្លប ដោយពឹងផ្អែកលើការគាំទ្រពីបរទេស ជាពិសេសប្រទេសចិនចំពោះធនធាន និងប្រទេសថៃជាជំរំភៀសខ្លួន។ បន្ថែមពីនេះ ខណៈដែលអង្គការមនុស្សធម៌បដិសេធក្នុងការផ្តល់ជំនួយដល់កងយោធាខ្មែរក្រហម ជារឿយៗប្រជាជនដែលមិនមែនជាយោធា ពឹងផ្អែកលើអាហារ ស្បៀង និងជំនួយនៅជំរំជនភៀសខ្លួន។

កងទ័ពខ្មែរក្រហមនៅក្នុងជំរំយោធា ជារឿយៗបញ្ជូនទៅកាន់ផ្នែកខាងក្នុងនៃប្រទេសកម្ពុជា ដើម្បីបំពេញបេសកកម្មសង្គ្រាមឈ្លបដែលខ្មែរក្រហមហៅថា «សង្គ្រាមប្រជាជន»។ សង្គ្រាមឈ្លបមានលក្ខណៈពិសេស ដោយសារការប្រើប្រាស់អាវុធសម្ងាត់ និងការវាយឆ្មក់ ដកថយវិញយ៉ាងរហ័ស ដើម្បីធ្វើឲ្យកងកម្លាំងវៀតណាម និងកងកម្លាំងសាធារណរដ្ឋកម្ពុជាមានភាពរង្គោះរង្គើ។ លើសពីនេះទៅទៀត «សង្គ្រាមប្រជាជន» រួមមានការប្រមូលកម្លាំងទ័ព ការយកការណ៍ និងការបង្កើនការគាំទ្ររបស់ប្រជាជនមកលើការតស៊ូរបស់ខ្មែរក្រហម។

ប្រជាជនដែលសេសសល់នៅលើភ្នំដងរែក និងអន្លង់វែង រស់នៅដោយមានជីវភាពលំបាកលំបិន។ ប្រជាជនពិពណ៌នាជីវិតរបស់ខ្លួនថា ត្រូវផ្លាស់ប្តូរទីកន្លែងជារឿយៗ និងពោរពេញដោយភាពភ័យខ្លាច។ ការប៉ះទង្គិចគ្នារវាងកងកម្លាំងខ្មែរក្រហម និងកងកម្លាំងវៀតណាមគឺជារឿងសាមញ្ញ។ ដើម្បីធានាដល់ការការពារសហគមន៍ខ្មែរក្រហម ស្ត្រីនិងកុមារតែងតែជ្រើសរើសឲ្យបំពេញមុខងារដូចជា ដាក់អង្គប់ ចែកចាយស្បៀង ឬផលិតអាវុធជាដើម។

ស្របគ្នាទៅនឹងការដកថយរបស់កងកម្លាំងវៀតណាមនៅក្នុងឆ្នាំ១៩៨៩ ខ្មែរក្រហមធ្វើការវាយលុក ដោយក្តោបក្តាប់យកតំបន់មួយចំនួននៅក្នុងប្រទេសកម្ពុជា។ នៅចុងឆ្នាំ១៩៨៩ កងកម្លាំងខ្មែរក្រហមនៅភ្នំ១០០៣ ដែលនៅក្រោមបញ្ជារបស់ តាម៉ុក បានចាប់ផ្តើមធ្វើការវាយលុកដើម្បីកាន់កាប់តំបន់អន្លង់វែង។ ខ្មែរក្រហមបានកាន់កាប់អន្លង់វែងនៅខែធ្នូ ឆ្នាំ១៩៨៩។ តាម៉ុក ចាប់ផ្តើមចល័តប្រជាជនជាច្រើនពីជំរំមូលដ្ឋានទៅកាន់អន្លង់វែង។ នៅពេលដែលប្រជាជនចូលមករស់នៅក្នុងតំបន់អន្លង់វែង ខ្មែរក្រហមបានរៀបចំភូមិទាំងឡាយឲ្យមានការផ្សារភ្ជាប់ជាមួយនឹងអង្គភាពយោធាជាក់លាក់នីមួយៗ។ សហគមន៍អន្លង់វែង បានក្លាយជាសហគមន៍ដែលមានសមូហភាព ដោយសារប្រជាជនតែងតែពឹងផ្អែកលើគ្នាទៅវិញទៅមក។ ប្រជាជនរស់នៅក្រោមការគំរាមកំហែងពីការវាយប្រហារ ឬការបំផ្ទុះកាំភ្លើងធំ ហេតុនេះត្រូវតែត្រៀមខ្លួនរត់គេចដោយមានការ





រូបខាងលើ៖ រូបកងទ័ពខ្មែរក្រហមពីរនាក់ ដែលត្រូវបានជឿថា បានថតនៅផ្ទះរបស់ តាម៉ុក នៅជាប់មាត់បឹង។
រូបខាងក្រោម៖ យឹម ផាន់ណា និង ណុប សុជាត នៅប្រាសាទអង្គរវត្តឆ្នាំ១៩៩២។
ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។





រូបខាងលើ៖ ពិធីសមាហរណកម្មនៅអន្លង់វែងឆ្នាំ១៩៩៩។
រូបខាងក្រោម៖ ពិធីសមាហរណកម្មនៅអន្លង់វែងឆ្នាំ១៩៩៩។
ថតដោយ គង់ លី, បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ផ្តល់ដំណឹងជាមុនយ៉ាងតិចតួចបំផុត។ អន្លង់វែងត្រូវបានដណ្តើមយកមកវិញអស់មួយរយៈពេលខ្លី ដែលបណ្តាលឲ្យខ្មែរក្រហម និងក្រុមគ្រួសារត្រូវភៀសខ្លួនទៅកាន់ជំរំមូលដ្ឋាននៅតាមជួរភ្នំ។

សហគមន៍អន្លង់វែងពឹងផ្អែកយ៉ាងខ្លាំងលើការគាំទ្រ ដែលកើតចេញមកពីបញ្ជាការយោធាថ្នាក់កណ្តាល (ឈិត ជឿន) ដែលហៅថា តាម៉ុក។ តាម៉ុក មានកេរ្តិ៍ឈ្មោះអសោចខាងអំពើឃោរឃៅព្រៃផ្សៃ។ កងកម្លាំងតាម៉ុកមានតួនាទីកាប់សម្លាប់ជនស៊ីវិល និងកម្មាភិបាលខ្មែរក្រហមនៅភូមិភាគបូព៌ានៃកម្ពុជាប្រជាធិបតេយ្យ ដែលឈ្មោះថា «តាម៉ុក៖ មេពេជ្ឈឃាត»។

ផ្ទុយពីកិត្តិសព្ទខាងលើ តាម៉ុក គឺជាមនុស្សល្បីល្បាញ ដែលទទួលបានការគោរពយ៉ាងជ្រាលជ្រៅនៅក្នុងសហគមន៍អន្លង់វែង។ តាម៉ុក បានចំណាយពេលវេលាជាមួយប្រជាជនក្នុងតំបន់ និងបានអភិវឌ្ឍគម្រោងសាងសង់ជាច្រើន ដែលផ្តល់ផលប្រយោជន៍សម្រាប់សហគមន៍។

ទោះបីជាយ៉ាងណាក្តី ខណៈដែលតាម៉ុកទទួលបានជោគជ័យក្នុងការគ្រប់គ្រងសហគមន៍អន្លង់វែង ការគាំទ្រពីបរទេសចំពោះខ្មែរក្រហមចាប់ផ្តើមខ្សត់ខ្សោយ បន្ទាប់ពីវៀតណាមដកខ្លួនចេញពីប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៨៩។ មកត្រឹមឆ្នាំ១៩៩១ ខ្មែរក្រហមបានព្រមព្រៀងចុះហត្ថលេខាលើសន្ធិសញ្ញាទីក្រុងប៉ារីស ដែលតម្រូវឲ្យភាគីជម្លោះប្រតិបត្តិតាមបទឈប់បាញ់ រៀបចំប្រទេសសម្រាប់រដ្ឋធម្មនុញ្ញថ្មី និងការបោះឆ្នោតដោយសេរីនិងយុត្តិធម៌។ ក្នុងនាមជាផ្នែកមួយនៃសន្ធិសញ្ញា ភាគីទាំងអស់យល់ព្រមឲ្យកងកម្លាំងរបស់អង្គការសហប្រជាជាតិត្រួតពិនិត្យលើបទឈប់បាញ់។ ខ្មែរក្រហមបានបដិសេធមិនព្រមទម្លាក់អាវុធនិងមិនចូលរួមក្នុងការបោះឆ្នោត។ បន្ទាប់ពីការបោះឆ្នោតនៅក្នុងឆ្នាំ១៩៩៣ ការគាំទ្រពីបរទេសចំពោះខ្មែរក្រហមបានបាត់បង់អស់មួយភាគធំ ហើយចលនាខ្មែរក្រហម ដែលបានបាត់បង់អានុភាពអស់ជាច្រើនឆ្នាំបានបែកបាក់និងរួញតូច។ ការបែកបាក់ទ្រង់ទ្រាយធំដែលកើតឡើងក្នុងតំបន់តស៊ូខ្មែរក្រហមនៅម៉ាឡៃ និងប៉ៃលិន បង្ហាញអំពីការចាប់ផ្តើមនៃថ្ងៃអវសានរបស់ចលនាខ្មែរក្រហម។

សមាជិកជាន់ខ្ពស់របស់ខ្មែរក្រហម (ប៉ុល ពត, សុន សេន, នួន ជា, ខៀវ សំផន និង តាម៉ុក) ចាប់ផ្តើមមានជម្លោះ និងមានការភ័យខ្លាចពីការក្បត់គ្នាទៅវិញទៅមកកាន់តែខ្លាំងឡើង។ នៅល្ងាចថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៧ ប៉ុល ពត បានបញ្ជូនមេបញ្ជាការរបស់ខ្លួនឈ្មោះ សារឿន ឲ្យទៅសម្លាប់ សុន សេន និងភរិយាដែលកំពុងស្នាក់នៅក្នុងផ្ទះសាងសង់ដោយ តាម៉ុក។ សារឿន បានដឹកនាំយោធាដែលមានចំនួន២០ ទៅ៣០ នាក់ទៅកាន់ផ្ទះរបស់ សុន សេន នៅអំឡុងម៉ោង១១យប់ ហើយបានបាញ់សម្លាប់ សុន សេន និងភរិយា ព្រមទាំងសមាជិកគ្រួសារ។ នៅពេលទទួលបានព័ត៌មានអំពីការស្លាប់របស់ សុន សេន រួចមក តាម៉ុក ក៏បានបញ្ជាឲ្យប្រមូលផ្តុំកងកម្លាំងរបស់ខ្លួនជម្លោះផ្ទៃក្នុងរយៈពេល៥ថ្ងៃបានផ្ទុះឡើងរវាងកងកម្លាំងរបស់ តាម៉ុក និងកងកម្លាំងរបស់ ប៉ុល ពត។

បន្ទាប់ពីប្រយុទ្ធគ្នាអស់រយៈពេល៥ថ្ងៃ កងកម្លាំងរបស់ ប៉ុល ពត បានចុះចាញ់។ ប៉ុល ពត អមជាមួយនឹងមេទ័ព និងមេដឹកនាំដទៃទៀតដូចជា នួន ជា និង ខៀវ សំផន ត្រូវបានចាប់ខ្លួន។ មេទ័ពខ្លះទៀត ត្រូវបានយកទៅដាក់ក្នុងទ្រុងដែកពីរដែលសម្រាប់ដាក់សត្វខ្លា ហើយដែលយើងអាចឃើញតាំងនៅផ្ទះមាត់បឹងរបស់ តាម៉ុក សព្វថ្ងៃនេះ។

ការកាត់ទោស ប៉ុល ពត នៅចំពោះមុខ«តុលាការប្រជាជន» រៀបចំឡើងដោយខ្មែរក្រហម ប៉ុន្តែតុលាការនេះប្រៀបដូចជាការសម្តែងមួយទៅវិញ។ សកម្មភាពក្នុងសវនាការក្លែងក្លាយរួមមានប្រជាជនឡើងសូត្រមតិរបស់ខ្លួនទៅលើការដាក់ទោស ប៉ុល ពត។ នៅទីបញ្ចប់ ប៉ុល ពត ត្រូវបានកាត់ទោសឲ្យជាប់គុកមួយជីវិត ក្រោមការចាត់ចែងរបស់ តាម៉ុក។

ក្នុងអំឡុងពេលមុនការបោះឆ្នោតនៅកម្ពុជានៅឆ្នាំ១៩៩៣ ដែលបានរៀបចំឡើងដោយអង្គការសហប្រជាជាតិ មេទ័ពខ្មែរក្រហមជាច្រើនបានធ្វើការជាមួយមន្ត្រីរដ្ឋាភិបាលនៃរបបរដ្ឋកម្ពុជា បង្កើតសម្ព័ន្ធភាពដ៏ល្អ ដែលជួយសម្របសម្រួលដល់ការចរចា សម្រាប់ការធ្វើសមាហរណកម្មរួបរួមឡើងវិញនៃកងកម្លាំងខ្មែរក្រហមនៅអន្លង់វែង។

យឹម ផាន់ណា ដែលជាមេទ័ពជាន់ខ្ពស់បំផុតមួយរូបរបស់ តាម៉ុក (និងក្រោយមកក្លាយជាអភិបាលស្រុកអន្លង់វែង) បានដឹកនាំក្រុមអ្នកចរចា។ ការចរចាបានឈានដល់កិច្ចព្រមព្រៀងផ្តាច់ខ្លួនចេញពី តាម៉ុក។ នៅពេលដែលកិច្ចព្រមព្រៀងបានលេចឮដល់ តាម៉ុក ការប៉ះទង្គិចបាន

ផ្ទុះឡើងរវាងក្រុមអ្នកផ្តាច់ខ្លួននិងកងកម្លាំងស្មោះត្រង់របស់ តាម៉ុក នៅខែមីនា ឆ្នាំ១៩៩៨។ ប្រជាជនជាច្រើននៅក្នុងអន្លង់វែងមិនបានដឹងអំពីកិច្ចព្រមព្រៀងទេ ហេតុនេះនៅពេលឮសំឡេងនៃការប៉ះទង្គិច ប្រជាជនស៊ីវិលនៅក្នុងអន្លង់វែងបានរត់ភៀសខ្លួន។ ការប៉ះទង្គិចបានបន្តជាច្រើនខែ។ កងកម្លាំងរបស់ តាម៉ុក បានក្តោបក្តាប់អន្លង់វែងឡើងវិញម្តងទៀត។ ទោះបីជាយ៉ាងណាក៏ដោយ នៅទីបំផុតកងកម្លាំង តាម៉ុក ត្រូវបណ្តេញចេញពីតំបន់អន្លង់វែង ដោយការវាយប្រហាររួមគ្នាពីសំណាក់ក្រុមដែលទើបផ្តាច់ខ្លួនថ្មីៗ ជាមួយនឹងកងយោធពលខេមរភូមិន្ទកម្ពុជា។ នៅក្នុងអំឡុងពេលនៃការវាយប្រហារ ប៉ុល ពត ដែលកំពុងមានសុខភាពទន់ខ្សោយ ក៏បានស្លាប់ ដោយសារជំងឺគាំងបេះដូង។ កងកម្លាំងរបស់តាម៉ុក មិនអាចថែទាំ ប៉ុល ពត បាន ដោយសារការខ្វះអុកស៊ីសែន និងឱសថព្យាបាល។ នៅក្នុងអំឡុងពេលដែលកងកម្លាំងរបស់ តាម៉ុក កំពុងដកថយ ប៉ុល ពត បានស្លាប់នៅលើគ្រែ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ដោយមានភរិយាក្មេង និងកូនស្រីនៅក្បែរខ្លួន។ នៅរំលងពីរថ្ងៃបន្ទាប់ សាកសព ប៉ុល ពត ត្រូវបានដុតបូជាដោយប្រើសំបកកង់ឡាន។

នៅពេលក្រោយមក កងទ័ពតាម៉ុកជាច្រើនទៀតបានផ្តាច់ខ្លួនចេញ។ កងកម្លាំង តាម៉ុក កាន់តែមានភាពទន់ខ្សោយ និងបាក់ទឹកចិត្ត។ នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៩៨ ភាគីទាំងពីរបានធ្វើកិច្ចព្រមព្រៀងលើការផ្តាច់ខ្លួនចេញពីខ្មែរក្រហមនិងធ្វើការរំសាយអង្គភាពខ្មែរក្រហមទាំងមូល។ នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ ពិធីសមាហរណកម្មរួបរួមជាផ្លូវការមួយបានរៀបចំឡើងនៅអន្លង់វែង។ ដំបូង តាម៉ុក ត្រូវឃុំខ្លួននៅក្នុងផ្ទះ តែទីបំផុតត្រូវចាប់ខ្លួន និងបញ្ជូនទៅកាន់គុកយោធានៅក្នុងទីក្រុងភ្នំពេញ ដែលជាទីតាំងរង់ចាំទទួលការកាត់ទោស។ តាម៉ុក ជាប់ឃុំអស់រយៈពេលប្រាំពីរឆ្នាំ លើកលែងតែពេលទៅកាន់មន្ទីរពេទ្យ ហើយទទួលមរណៈភាពនៅ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ក្នុងពេលមានអាយុ ៨០ឆ្នាំ។ សព តាម៉ុក បានបញ្ជូនទៅអន្លង់វែងវិញ និងប្រារព្ធបុណ្យសពយ៉ាងអធិកអធម និងកសាងចេតិយដ៏ធំមួយនៅក្នុងវត្តស្រះឈូក។

*ចំណុចសង្ខេបដែលត្រូវដាក់បញ្ចូលនៅក្នុងបទបង្ហាញ៖*

១. ចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ កងកម្លាំងខ្មែរក្រហម និងប្រជាជនដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ត្រូវបានរស់នៅក្នុងមូលដ្ឋានយោធាខ្មែរក្រហមនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ឬនៅក្នុងជំរំជនភៀសខ្លួននៅក្នុងប្រទេសថៃ។ ខ្មែរក្រហមបានកាន់កាប់អន្លង់វែងជាថ្មីនៅក្នុងឆ្នាំ១៩៨៩ រហូតដល់ឆ្នាំ១៩៩៨។

២. មូលដ្ឋានយោធាខ្មែរក្រហមសំខាន់ៗចំនួនពីរនៅក្នុងតំបន់អន្លង់វែងគឺ ភ្នំ១០០១ និងភ្នំ១០០៣។

៣. បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមពឹងផ្អែកលើប្រទេសចិន ដើម្បីគាំទ្រផ្នែកសេដ្ឋកិច្ច និងពឹងផ្អែកលើប្រទេសថៃសម្រាប់ជំរំជនភៀសខ្លួន។

៤. កងទ័ពខ្មែរក្រហមតែងតែធ្វើប្រតិបត្តិការឈ្លបនៅក្នុងប្រទេសកម្ពុជា ព្រមទាំងបេសកកម្មផ្សេងទៀត ដែលគេហៅថា «សង្គ្រាមប្រជាជន»។

៥. ចំពោះប្រជាជន ដែលនៅសេសសល់លើភ្នំដងរែក ឬអន្លង់វែង មានជីវភាពលំបាកលំបិន។ ខ្មែរក្រហមដែលជាស្ត្រី និងកុមារ តែងតែជ្រើសរើសឲ្យបំពេញតួនាទីដូចជា ដាក់អង្គប់ ចែកចាយស្បៀង ឬផលិតអាវុធ។

៦. ផ្ទុយនឹងកិត្តិសព្ទពីអំពើព្រៃផ្សៃ តាម៉ុក គឺជាមនុស្សល្បីល្បាញ ដែលទទួលបានការគោរពយ៉ាងជ្រាលជ្រៅ នៅក្នុងសហគមន៍ ដោយសារតែការគាំទ្ររបស់គាត់ចំពោះអ្នករស់នៅអន្លង់វែង និងគម្រោងសាងសង់ផ្សេងៗ។

៧. នៅត្រឹមឆ្នាំ១៩៩១ ខ្មែរក្រហមបានព្រមព្រៀងចុះហត្ថលេខាលើសន្និសញ្ញាទីក្រុងប៉ារីស ដែលតម្រូវឲ្យភាគីទាំងសងខាងអនុវត្តតាមបទឈប់បាញ់ រៀបចំរដ្ឋធម្មនុញ្ញថ្មីមួយសម្រាប់ប្រទេសនិងការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ ខ្មែរក្រហមបានបដិសេធក្នុងការទម្លាក់អាវុធ និងមិនចូលរួមនៅក្នុងការបោះឆ្នោត។

៨. ការគាំទ្រពីបរទេសចំពោះខ្មែរក្រហមត្រូវបានបាត់បង់មួយភាគធំបន្ទាប់ពីការបោះឆ្នោតនៅក្នុងឆ្នាំ១៩៩៣ ចលនាខ្មែរក្រហមដែលបានបាត់បង់អានុភាពអស់ជាច្រើនឆ្នាំ ត្រូវបានបែកបាក់និងរួញតូច។

៩. សមាជិកជាន់ខ្ពស់ខ្មែរក្រហម (ប៉ុល ពត, សុន សេន, នួន ជា, ខៀវ សំផន, និង តាម៉ុក) ចាប់ផ្តើមមានជម្លោះជាមួយគ្នាទៅវិញទៅមក។

១០. ប៉ុល ពត បានចេញបញ្ជាឲ្យកងកម្លាំងរបស់ខ្លួនទៅសម្លាប់ សុន សេន។ ដើម្បីជាការសងសឹក កងកម្លាំងរបស់ តាម៉ុក បានវាយប្រហារលើកងកម្លាំងរបស់ ប៉ុល ពត ដែលទីបំផុតកម្លាំងរបស់ ប៉ុល ពត បានចុះចាញ់។ ប៉ុល ពត ត្រូវបានចាប់ខ្លួន និងកាត់ទោសឲ្យជាប់គុកមួយជីវិត។

១១. តាម៉ុក បានក្លាយជាមេដឹកនាំជាន់ខ្ពស់បំផុតនៃចលនាខ្មែរក្រហម បន្ទាប់ពីកងកម្លាំងរបស់ តាម៉ុក បានយកឈ្នះលើកងកម្លាំងរបស់ ប៉ុល ពត នៅចុងឆ្នាំ១៩៩៧។

១២. នៅពេលដែលកងកម្លាំងក្រោមឱវាទរបស់ តាម៉ុក ទទួលបរាជ័យ ខ្មែរក្រហមដែលនៅសេសសល់អាចការពារទីតាំងរបស់ខ្លួនបានត្រឹមតែប៉ុន្មានខែប៉ុណ្ណោះ។ នៅក្នុងខែធ្នូ ឆ្នាំ១៩៩៨ ខ្មែរក្រហមក៏យល់ព្រមបញ្ឈប់ការតស៊ូរបស់ខ្លួន។ តាម៉ុក ត្រូវបានចាប់ខ្លួន នៅទីបំផុតត្រូវបានដាក់គុកនិងបានស្លាប់ក្នុងគុក នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ទាំងកំពុងរង់ចាំការកាត់ទោស។

### សកម្មភាពសិក្សាទី ១

ការណែនាំ៖ សូមអានសេចក្តីសង្ខេបប្រវត្តិសាស្ត្រខាងលើ ឆ្លើយសំណួរខាងក្រោម៖

១. នៅចន្លោះពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ ខ្មែរក្រហមនៅតំបន់អន្លង់វែង ភាគច្រើនរស់នៅក្នុងជំរំជនភៀសខ្លួន ឬមូលដ្ឋានយោធាដែលហៅថា៖

ក.____________________

ខ.____________________

២. តើខ្មែរក្រហមបានក្តោបក្តាប់អន្លង់វែងឡើងវិញម្តងទៀត នៅក្នុងឆ្នាំណា?

៣. តើប្រទេសណាខ្លះដែលមានសារៈសំខាន់ចំពោះការបន្តសកម្មភាពរបស់ខ្មែរក្រហម?

ក.____________________

ខ.____________________

៤. តើ «សង្គ្រាម» ប្រភេទណាដែលយោធាខ្មែរក្រហមប្រើប្រាស់នៅក្នុងការតស៊ូប្រឆាំងនឹងកងកម្លាំងរបស់វៀតណាម នៅក្នុងប្រទេសកម្ពុជា?

ក.____________________

ខ.____________________

៥. ចូររៀបរាប់មុខងារសំខាន់ៗដែលស្ត្រី និងកុមារត្រូវបានចាត់តាំងឲ្យធ្វើនៅក្នុងស្រុកអន្លង់វែង យ៉ាងហោចណាស់ឲ្យបានពីរ?

ក.____________________

ខ.____________________

៦. ត្រូវ ឬខុស៖ ប៉ុល ពត ជាអ្នកគ្រប់គ្រងអន្លង់វែង។

៧. ត្រូវ ឬខុស៖ ខ្មែរក្រហមបានយល់ស្របចំពោះសន្ធិសញ្ញាទីក្រុងប៉ារីស។

៨. ត្រូវ ឬខុស៖ ខ្មែរក្រហមបានចូលរួមក្នុងការបោះឆ្នោតឆ្នាំ១៩៩៣។

៩. នៅក្នុងឆ្នាំ១៩៩៧ ប៉ុល ពត បានបញ្ជាឲ្យសម្លាប់មេបញ្ជាការខ្មែរក្រហមជាន់ខ្ពស់ម្នាក់។ តើមេបញ្ជាការដែលបានសម្លាប់ជានរណា?

____________________

១០. នៅក្នុងឆ្នាំ១៩៩៧កងកម្លាំងរបស់ប៉ុលពតនិងតាម៉ុកបានប្រយុទ្ធគ្នា។តើភាគីខាងណាជាអ្នកឈ្នះ?____________________

១១. នៅពេលណាដែលកងកម្លាំងខ្មែរក្រហមចុងក្រោយបង្អស់យល់ព្រមដកខ្លួនចេញ? (ខែ/ឆ្នាំ)____________________

១២. នៅពេលណាដែល តាម៉ុក បានស្លាប់?____________________

### សកម្មភាពទី២

ការណែនាំ៖ ជាដំបូង សូមអានសេចក្តីសង្ខេបប្រវត្តិសាស្ត្រខាងលើ។ បន្ទាប់ពីអានសេចក្តីសង្ខេបចប់ សូមបិទសៀវភៅ យកក្រដាសមួយសន្លឹករួចសរសេរព័ត៌មានឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន អំពីអ្វីដែលអ្នកអាចចាំបានពីសេចក្តីសង្ខេប។ សូមព្យាយាមសរសេរឲ្យបានយ៉ាងហោចណាស់១២ហេតុការណ៍ ឬ ១២ចំណុចខុសៗគ្នា។ បន្ទាប់ពីបានសរសេរបញ្ជីរួចរាល់ សូមបើកសៀវភៅម្តងទៀត (១) ផ្លាស់ប្តូរបញ្ជីរបស់អ្នកជាមួយដៃគូម្នាក់ដែលអាចប្រៀបធៀបបញ្ជីក្នុងគន្លឹះណែនាំ ឬ (២) ប្រៀបធៀបបញ្ជីដោយខ្លួនឯង ជាមួយបញ្ជីនៅក្នុងគន្លឹះណែនាំ។ គូសរង្វង់លើហេតុការណ៍ ឬចំណុចដែលមិនត្រឹមត្រូវ ឬដែលត្រូវកែសម្រួល។

### សកម្មភាពទី៣

ការណែនាំ៖ អ្នកត្រូវការដៃគូម្នាក់។ ដំបូង អ្នកនិងដៃគូគួរតែអានសេចក្តីសង្ខេបប្រវត្តិសាស្ត្រឡើងវិញ ដើម្បីរំឭកការចងចាំ។ បន្ទាប់ពីអ្នកទាំងពីរបានអានសេចក្តីសង្ខេបរួច សូមបិទសៀវភៅ និងយកក្រដាសមួយសន្លឹកចេញមកក្រៅ។ អ្នកទាំងពីរត្រូវផ្លាស់វេនគ្នា ដើម្បីធ្វើបទបង្ហាញពីសេចក្តីសង្ខេបយ៉ាងខ្លី (មិនលើសពី៥នាទី) អំពីប្រវត្តិសាស្ត្រខាងលើ។ នៅពេលដែលម្នាក់កំពុងធ្វើបទបង្ហាញ ម្នាក់ទៀតគួរកត់ត្រានៅលើក្រដាសដាច់ដោយឡែកមួយ។ អ្នកដែលធ្វើបទបង្ហាញគួរតែនិយាយតាមធម្មតា ប៉ុន្តែមិនលឿនពេក ដើម្បីទុកឲ្យម្នាក់ទៀតធ្វើការកត់ត្រា។ អ្នកកត់ត្រាគួរតែព្យាយាមសរសេរឲ្យបានច្រើនតាមដែលអាចធ្វើបាន និងសរសេរចំណុចទាំងឡាយណា ដែលអ្នកធ្វើបទបង្ហាញគួរលើកមកនិយាយ ក៏ប៉ុន្តែប្រហែលជាភ្លេច។ អ្នកកត់ត្រាក៏អាចសរសេរនូវការអង្កេតទាំងឡាយដូចជា តើអ្នកធ្វើបទបង្ហាញបាននិយាយអ្វីដែលមិនត្រឹមត្រូវ និងអាចយល់បានឬទេ។ សកម្មភាពទី៣ មានវត្ថុបំណងពីរយ៉ាងគឺ (១) អាចជួយអ្នកធ្វើបទបង្ហាញ អនុវត្តជំនាញធ្វើបទបង្ហាញជាមួយនឹងព័ត៌មានប្រវត្តិសាស្ត្រ និង (២) អាចជួយអ្នកកត់ត្រាឲ្យអនុវត្តជំនាញវាយតម្លៃ ដោយសារតែអ្នកចូលរួមអាចនឹងត្រូវវាយតម្លៃអ្នកផ្សេងទៀត នៅក្នុងពេលធ្វើបទបង្ហាញនាពេលអនាគត។



អ្នូម ភាព កំពុងឈរកាន់ដៃកូនស្រីរបស់គាត់ជាមួយនឹងកុមារដទៃទៀត។
ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

# ជំពូកទី២
# ការរៀបរាប់សាច់រឿង

## ផ្នែកទី១៖ សេចក្តីផ្តើម

គំនិតមួយក្នុងគោលគំនិតសំខាន់ៗបំផុតនៃការរៀបរាប់សាច់រឿងគឺ បែបផែនដែលសាច់រឿងអាចបំបែកឧបសគ្គផ្សេងៗបាន។ រឿងមួយអាចដើរតួជាយានដឹកនាំអ្នកស្តាប់ទៅកាន់ពិភពលោកថ្មីមួយ ដែលគ្មានទំនាក់ទំនងជាមួយវប្បធម៌ កាលៈទេសៈ ឬពេលវេលា។ នៅពេលដែលការពិពណ៌នាអំពីយុទ្ធនាការប្រល័យពូជសាសន៍ ឬស្ថានភាពគួរឲ្យភ័យខ្លាចរបស់អ្នកទោសនៅក្នុងជំរំពលកម្ម អាចជះឥទ្ធិពលដល់អារម្មណ៍អ្នកស្តាប់ដូច្នេះការធ្វើឡើងតាមរយៈការមើលឃើញផ្ទាល់របស់មនុស្សម្នាក់កាន់តែជះឥទ្ធិពលពិសេសចំពោះអ្នកស្តាប់ថែមទៀត។ ដោយសារសាច់រឿងអាចឲ្យយើងមើលឃើញ និងឆ្លុះបញ្ចាំងអំពីអ្វីដែលយើងនឹងជួបប្រទះខ្លួនឯងនៅក្នុងស្ថានភាពអ្នកដទៃ ថែមទាំងផ្តល់នូវឱកាសក្នុងការលុបបំបាត់ភាពលម្អៀង ការយល់ច្រឡំ និងពិសេសគឺ ការមិនអើពើ។ សាច់រឿងក៏បង្រៀនមនុស្សអំពីមេរៀនដ៏សំខាន់មួយគឺ ពិភពលោកយើងបង្កើតឡើងដោយមនុស្សដែលមានតម្រូវការ ចំណាប់អារម្មណ៍ និងក្តីសុបិនប្រហាក់ប្រហែលគ្នា។

សាច់រឿងនៅក្នុងសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ មិនតំណាងឲ្យការរៀបរាប់លម្អិតនៃសាច់រឿង និងប្រវត្តិសាស្ត្ររបស់អន្លង់វែងទេ។ អមជាមួយនឹង«សៀវភៅប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង» សៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ គឺបោះពុម្ពឡើងដើម្បីផ្តល់ជាចំណុចចាប់ផ្តើមមួយសម្រាប់ការសិក្សា និងការពិភាក្សាបន្ថែមជាមួយប្រជាជនក្នុងតំបន់អន្លង់វែងនិងសហគមន៍កម្ពុជាទូទៅ។

ការសិក្សាអំពីសាច់រឿងនៅក្នុងសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ (ឬសៀវភៅដែលស្រដៀងគ្នាមួយទៀតគឺ«សៀវភៅប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង») នឹងតម្រូវឲ្យអ្នកសិក្សាមានការប្តេជ្ញាចិត្ត។ ថ្វីបើយើងអាចផ្តល់ជាលំហាត់ និងគន្លឹះ តែរាល់ការសិក្សា គឺជាកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលម្នាក់ៗ។ ហេតុនេះប្រសិនបើអ្នកចាប់អារម្មណ៍លើការបង្រៀន ឬការផ្តល់ឲ្យនូវដំណើរទស្សនកិច្ចទៅកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង អ្នកគួរចំណាយពេលវេលាផ្ទាល់ខ្លួន ដើម្បីអាន (និងអានសាឡើងវិញឲ្យបានច្រើនដង) សាច់រឿងដែលមានក្នុងសៀវភៅ។

តើអ្នកអាចប្រើប្រាស់សាច់រឿងយ៉ាងដូចម្តេចខ្លះ? អាស្រ័យលើអាជីព និងកាលៈទេសៈទស្សនិកជនរបស់អ្នក។

គ្រូអាចជ្រើសរើសសាច់រឿងមកធ្វើជាមេរៀនតូចៗដែលនិយាយអំពីប្រវត្តិសាស្ត្រ និងអាចផ្តល់បទបង្ហាញអំពីប្រវត្តិសាស្ត្រនៃតំបន់អន្លង់វែងបន្ទាប់មកនិយាយរឿងខ្លីមួយប្រាប់សិស្ស សម្រាប់ធ្វើឆ្លុះបញ្ចាំង និងការពិភាក្សាពីប្រវត្តិសាស្ត្រ។ គ្រូអាចអានសាច់រឿងឮៗ និងឲ្យសិស្សសរសេរសាច់រឿង បន្ទាប់មកឲ្យធ្វើការជាក្រុម ដើម្បីពិភាក្សាអំពីមូលហេតុដែលសាច់រឿងមានសារៈសំខាន់សម្រាប់ការយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ឬប្រវត្តិសាស្ត្រកម្ពុជា។ ឱកាសដើម្បីធ្វើការត្រិះរិះពិចារណា ការឆ្លុះបញ្ចាំង និងការអប់រំសីលធម៌ គឺគ្មានដែនកំណត់ទេ។

មគ្គុទ្ទេសក៍ទេសចរណ៍ អាចជ្រើសយកសាច់រឿងដើម្បីធ្វើបទបង្ហាញខ្លីៗទេសចរ និងអាចប្រើប្រាស់ជាសេចក្តីផ្តើមសម្រាប់ទីតាំងប្រវត្តិសាស្ត្រជាក់លាក់ឬអាចប្រើប្រាស់សាច់រឿងជាការសន្ទនាខ្លីៗ។ទេសចរឲ្យតម្លៃលើការទស្សនកិច្ចដែលមានលក្ខណៈបែបផ្ទាល់ខ្លួននិងសាច់រឿងខ្លីៗអាចជាវិធីសាស្ត្រមួយក្នុងការធ្វើឲ្យទស្សនកិច្ចមានទម្រង់ផ្ទាល់ខ្លួនតាមរយៈសំណួរជាក់លាក់ ចំណាប់អារម្មណ៍ និងសាវតាររបស់សមាជិកក្រុម ក៏ដូចជាផ្តល់ឲ្យក្រុមទេសចរជារួមនូវឱកាសមួយដើម្បីចូលទៅមើលក្នុងពិភពលោករបស់មនុស្សម្នាក់ផ្សេងទៀត។ សរុបមក សាច់រឿងធ្វើឲ្យប្រវត្តិសាស្ត្រក្លាយជារឿងផ្ទាល់ខ្លួន។



រូបចម្លាក់នៅប្រាសាទបាយ័ន។ ថតដោយ ជី ទេវិទ្ធិ, បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

អ្វីដែលគួរកត់សម្គាល់គឺ សាច់រឿងជាទស្សនៈ ដែលអាចនឹងមានភាពខុសគ្នា។ ហេតុនេះនៅពេលដែលយើងមើលសាច់រឿងយើងត្រូវតែគិតក្នុងចិត្តថា ទស្សនៈផ្សេងៗទៅលើព្រឹត្តិការណ៍ មនុស្ស និងកាលៈទេសៈ អាចនឹងមានភាពខុសពីគ្នា។ យើងបានធ្វើបទបង្ហាញអំពីសាច់រឿងដោយគិតរំពឹងទុកជាមុនថា នឹងមានទស្សនៈផ្សេងៗពីគ្នាទៅលើទិដ្ឋភាព ដែលអាចបង្កឲ្យមានការខ្វែងគំនិតគ្នានៃប្រវត្តិសាស្ត្រខ្មែរក្រហម និងសហគមន៍អន្លង់វែង។

ក្នុងគោលបំណងដើម្បីបង្កើនភាពបន្សាំទៅនឹងសាច់រឿងទាំងឡាយ អ្នកអានជំរុញឲ្យអានសាច់រឿងនីមួយៗយ៉ាងហោចណាស់ម្តង បន្ទាប់មកសង្ខេបសាច់រឿងទៅជា មួយ ឬពីរប្រយោគ ក្នុងចន្លោះសម្រាប់សេចក្តីសង្ខេបដែលបានផ្តល់ឲ្យ។ រឿងខ្លះវែងជាងរឿងខ្លះទៀត និងមិនងាយស្រួលក្នុងការសង្ខេបឲ្យទៅជាមួយឬពីរប្រយោគទេ ក្នុងករណីនេះអ្នកអានអាចពង្រីកសេចក្តីសង្ខេបរបស់ខ្លួនឲ្យបានវែង។ ក៏ប៉ុន្តែ គោលបំណងមួយសំខាន់នៅក្នុងសកម្មភាពអាន និងសង្ខេប គឺដើម្បីព្យាយាមធ្វើឲ្យអ្នកអានអាចរៀបរាប់សាច់រឿងដោយប្រើពាក្យផ្ទាល់ខ្លួនបាន។ មូលហេតុនេះ អ្នកអាននឹងតម្រូវ (ប្រសិនបើនៅក្នុងសិក្ខាសាលា) ឲ្យរៀបរាប់ចាប់ពីមួយរឿងឡើងទៅដោយប្រើប្រាស់ពាក្យផ្ទាល់ខ្លួនទៅកាន់ដៃគូ ឬក្រុមរបស់ខ្លួន។ បន្ទាប់ពីអ្នកបានអានសាច់រឿង អ្នកនឹងអាចចងចាំបានយ៉ាងហោចណាស់ពីរ ឬបីរឿងដែលអ្នកអាចរៀបរាប់សាជាថ្មីឡើងវិញទៅកាន់អ្នកដទៃនៅក្នុងមជ្ឈដ្ឋានការងាររបស់អ្នក (នៅក្នុងថ្នាក់រៀន ឬក្នុងក្រុមអ្នកធ្វើទស្សនកិច្ច)។ ប្រសិនបើអ្នកមានបញ្ហាក្នុងការចងចាំ សូមអានរឿងម្តងទៀត រួចបិទសៀវភៅ និងព្យាយាមរៀបរាប់សាច់រឿងឲ្យឮៗ។ អនុវត្តន៍ការរៀបរាប់សាច់រឿង នឹងមិនត្រឹមតែជួយឲ្យអ្នកចងចាំសាច់រឿងទេ វាក៏នឹងជួយពង្រឹងជំនាញនិទានរឿងរបស់អ្នក។

## ផ្នែកទី២៖ សាច់រឿងស្តីពីអន្លង់វែង មុនពេលនៃការងើបឡើងរបស់ខ្មែរក្រហម

ការណែនាំ៖ ចូរអានសាច់រឿងខាងក្រោម។ បន្ទាប់ពីបានអានរឿងនីមួយៗ សូមសង្ខេបសាច់រឿងនៅក្នុងចន្លោះដែលបានផ្តល់ឲ្យ។ សូមព្យាយាមធ្វើឲ្យសេចក្តីសង្ខេបរបស់អ្នកមិនលើសពី មួយ ឬពីរប្រយោគ។ នៅពេលដែលអ្នកបានធ្វើការសង្ខេបរួចរាល់ អ្នកនឹងត្រូវបានហៅឲ្យរៀបរាប់សាច់រឿងមួយ ឬពីរទៅកាន់ដៃគូរបស់អ្នក។

សាច់រឿងទី១៖ នៅខែវិច្ឆិកា ឆ្នាំ១៩០៧ អាជ្ញាធរកម្ពុជាបានចាប់ខ្លួនចោរព្រៃម្នាក់ឈ្មោះ «អាឃួន» ដែលបានចូលរួមក្នុងសកម្មភាពប្លន់នៅតំបន់នោះ។ ឃួន បានគេចខ្លួនរួច បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេលពីរបីថ្ងៃ។ ប៉ុន្តែ មុនពេលរត់គេចខ្លួន ឃួន បានទទួលព័ត៌មានខ្លះៗអំពីក្រុមចោរព្រៃ ដោយបានបញ្ជាក់កាន់តែច្បាស់ពីការសង្ស័យរបស់អាជ្ញាធរបារាំង ទៅលើការជាប់ពាក់ព័ន្ធរបស់ប្រជាជនសៀមនៅក្នុងសកម្មភាពប្លន់។ ឃួន គឺជាជនជាតិខ្មែរដែលរស់នៅភូមិធ្នង់នៃខេត្តចុងកាល់។ កាលពីដើមខែតុលា ឆ្នាំ១៩០៨ ចោរព្រៃមួយក្រុមធំ (ប្រហែលជា៦០នាក់) បានចូលក្នុងភូមិរបស់គាត់ ដោយមានកាន់កាំភ្លើងវែងនិងដាវ។ មេចោរព្រៃបានបញ្ជាឲ្យកូនចៅចំនួន៣០នាក់ប្រមូលអ្នកភូមិ ហើយនាំអ្នកទាំងនោះទៅកាន់ឃុំកូល នៅសង់គាក(សៀម)។ ឃួន ក៏ជាមនុស្សម្នាក់ក្នុងចំណោមអ្នកភូមិ ដែលត្រូវប្រមូលផ្តុំដែរ។ ចោរព្រៃបានដកហូត និងបំផ្លាញចោលប័ណ្ណបង់ពន្ធរបស់អ្នកភូមិ ដោយនិយាយថា ខ្លួននឹងមិនអនុញ្ញាតឲ្យអ្នកភូមិទាំងនោះរស់នៅក្រោមការគ្រប់គ្រងរបស់បារាំងឡើយ។ ចោរព្រៃបានព្យាយាមប្រមូលយកសត្វគោ និងសត្វចិញ្ចឹមដទៃទៀត។ ប៉ុន្តែក្រោយមក ចោរព្រៃយល់ឃើញថា ការធ្វើបែបនេះអាចធ្វើឲ្យយឺតដំណើររបស់ខ្លួន។ ចោរព្រៃបានបង្ខំឲ្យឃួនធ្វើជាអ្នកនាំផ្លូវ ដើម្បីវាយប្រហារភូមិដទៃទៀតនៅក្នុងប្រទេសកម្ពុជា។ ចោរព្រៃបានបញ្ជាឲ្យឃួននាំផ្លូវទៅកាន់ភូមិដុនឡុក ដែលក្រុមចោរព្រៃបានធ្វើសកម្មភាពប្លន់។ ចោរព្រៃក៏បានប្លន់ភូមិតុងនិងខេត្តចុងកាល់ដែរ។ នៅក្នុងភូមិទាំងពីរនេះ មេចោរព្រៃបានបញ្ជាឲ្យកូនចៅ



ក្រុមកងឈ្លបខ្មែរក្រហមនៅតំបន់គ្រប់គ្រងដោយខ្មែរក្រហមក្បែរព្រំដែនថៃ នៅឆ្នាំ១៩៨០។ ក្រុមឈ្លបខ្មែរក្រហមនេះត្រូវបានទទួលការគាំទ្រពីបរទេស ដែលជំនួយសេដ្ឋកិច្ចភាគច្រើនត្រូវបានផ្តល់ឲ្យដោយប្រទេសចិន។ ថតដោយ ដេ ខោហ្វមិន, បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

របស់ខ្លួនជម្លៀសអ្នកភូមិទៅកាន់ប្រទេសសៀម។ កូនចៅដែលសេសសល់បានបន្តដំណើរទៅអន្លង់វែងទៀត។ ទោះយ៉ាងណាក៏ដោយ ដោយសារតែមានភ្លៀងធំ ចោរព្រៃមិនបានទៅដល់តំបន់នោះទេ។ មូលហេតុចម្បងគឺដោយសារតែចោរព្រៃជាច្រើនមិនចេះហែលទឹក។ ចោរព្រៃទាំងនោះក៏សម្រេចចិត្តវិលត្រឡប់ទៅប្រទេសសៀមវិញ។

## សេចក្តីសង្ខេបរបស់អ្នក៖

---

---

---

---

**សាច់រឿងទី២៖** ឆាន់ បៃ ប្រជាជននៅអន្លង់វែង ពិពណ៌នាអំពីជីវិតនៅក្នុងភូមិខ្នុល មុនពេលរបបកម្ពុជាប្រជាធិបតេយ្យឡើងកាន់អំណាចនៅក្នុងឆ្នាំ១៩៧៥។

«នៅពេលនោះ មានតែប្រជាជន៦គ្រួសារប៉ុណ្ណោះដែលចូលមករស់នៅក្នុងតំបន់នេះ។ ប្រជាជនទាំងនេះមិនបានរៀនសូត្រទេ ហើយជីកត្រាវ និងដំឡូងដើម្បីចិញ្ចឹមជីវិត។ ប្រជាជនទាំងអស់មិនដែលពាក់អាវ ឬស្លៀកសម្លៀកបំពាក់ស្អាតៗ ដូចសព្វថ្ងៃនេះទេ។ យើងមិនមានប្រាក់ហើយ។ យើងស្លៀកសម្លៀកបំពាក់កខ្វក់។ យើងក៏គ្មានប្រាក់សម្រាប់ទិញគ្រឿងទេសដែរ។ យើងទិញតែអំបិល។ យើងទិញគ្រឿងទេសទាំងនេះនៅក្នុងភូមិខ្នារ ប្រទេសថៃ។ យើងត្រូវចំណាយពេល១០ថ្ងៃក្នុងការធ្វើដំណើរឆ្លងកាត់ជួរភ្នំដើម្បីទៅទីផ្សាររបស់ខ្មែរ។ ដើម្បីទិញអំបិល យើងគ្រាន់តែត្រូវដើរចូលទៅប្រទេសថៃ ហើយស្នាក់នៅទីនោះមួយយប់ ហើយត្រឡប់មកវិញនៅថ្ងៃបន្ទាប់។»

## សេចក្តីសង្ខេបរបស់អ្នក៖

---

---

---

---

**សាច់រឿងទី៣៖** អ៊ុក សុខ រៀបរាប់សាច់រឿងទាក់ទងនឹងរបៀបគណនាអាយុចូលរៀននៅសម័យមុន។ ដោយសារតែពិបាកចាំ និងមិនបានកត់ត្រាទុកថ្ងៃកំណើតនិងអាយុពិតប្រាកដ ប្រជាជននៅសម័យនោះបានប្រើប្រាស់វិធីសាស្ត្រថ្មីដើម្បីកំណត់អំពីពេលវេលាដែលកុមារអាចចូលរៀន។

«នៅពេលខ្ញុំចូលរៀននៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ (នៅខេត្តតាកែវ) អាយុដែលអាចចូលរៀនបាន មានភាពខុសគ្នាពីអាយុរបស់កុមារ នាពេលសព្វថ្ងៃ។ ពេលខ្ញុំនៅក្មេង យើងត្រូវបោះដៃឡើងលើក្បាល ហើយឈោងឲ្យដល់ត្រចៀកម្ខាងទៀត។ ប្រសិនបើដៃយើងមិនប៉ះត្រចៀកម្ខាងទៀតទេ យើងមិនទទួលបានការអនុញ្ញាតឲ្យចូលរៀនឡើយ។ ជាធម្មតា កុមារៗស្ទើរតែមានអាយុ១០ឆ្នាំទៅហើយ ទម្រាំតែទទួលបានការអនុញ្ញាតឲ្យចូលរៀន។»

## សេចក្តីសង្ខេបរបស់អ្នក៖

---

---

---

---

**សាច់រឿងទី៤៖** មុី ឆេង ពិពណ៌នាអំពីភាពខ្វះខាតនៃមធ្យោបាយធ្វើដំណើរ ការដោះដូរទំនិញ និងភាពក្រីក្រ នៅក្នុងតំបន់នោះកាលពីសម័យមុនឆ្នាំ១៩៧៥៖

«ប្រជាជនម្នាក់ៗបានធ្វើដំណើរដោយថ្មើរជើង។ ប្រជាជនត្រូវចំណាយពេលមួយថ្ងៃ ដើម្បីដើរពីអន្លង់វែងទៅរំចេក។ យើងអាចទៅដល់រំចេក នៅពេលថ្ងៃត្រង់។ ប្រជាជនខ្លះមានរទេះ។ ប៉ុន្តែ ប្រជនជនផ្សេងទៀតបានដើរនិងដេកនៅតាមផ្លូវតែម្តងដោយសារតែគ្មានរទេះ ប្រសិនបើខ្លួនត្រូវធ្វើដំណើរទៅកន្លែងឆ្ងាយៗ ដូចជា ស្រែណូយ ជាដើម។ ... ប្រជាជនក្នុងភូមិរំចេកក្រីក្រតោកយ៉ាកណាស់ ហើយប្រជាជនទាំងនោះមានត្រឹមតែក្រណាត់សម្រាប់រុំខ្លួនតែប៉ុណ្ណោះ។ បុរសជាច្រើនមិនមានអាវពាក់ទេ បុរសខ្លះទៀតមិនមានខោស្លៀកទៀតផង។ នៅទីនេះ មិនមានទីផ្សារសម្រាប់ទិញសម្លៀកបំពាក់ទេ។ ជនជាតិថៃធ្វើដំណើរមកកាន់ទីនេះក្នុងរយៈពេល១០ខែម្តងប៉ុណ្ណោះ ដើម្បីធ្វើជំនួញ។»

## សេចក្តីសង្ខេបរបស់អ្នក៖

---

---

---

---

**សាច់រឿងទី៥៖** មីន ម្យ៉ាម រៀបរាប់សាច់រឿងអំពីជីវិតរបស់ប្រជាជនរស់នៅតាមព្រំដែន។

ក្នុងនាមជាប្រជាជនថៃម្នាក់ មីន ម្យ៉ាម អាយុ១៤ឆ្នាំ មិនចង់ចូលបម្រើក្នុងជួរកងទ័ពកម្ពុជាទេ។ ប៉ុន្តែដោយសារតែព្រហ្មលិខិតនៅឆ្នាំ១៩៦៣ ម្យ៉ាមគ្មានជម្រើសផ្សេងឡើយ។

ម្យ៉ាម មានកំណើតនៅភូមិណូឡូហាន ដែលជាភូមិតូចមួយនៅប្រទេសថៃ។ ម៉្យាមរស់នៅដូចក្មេងប្រុសៗដទៃទៀតនៅទីជនបទនៃប្រទេសថៃ។ ម៉្យាមជួយឪពុកម្តាយលើការងារស្រែចម្ការនិងការងារផ្ទះ ពេលខ្លះគាត់ក៏ធ្វើដំណើរជាមួយឪពុកម្តាយ ដើម្បីទិញឥវ៉ាន់នៅតាមទីផ្សារនៅព្រំដែនកម្ពុជា។

ដូចប្រជាជនដទៃទៀតនៅក្នុងតំបន់ដែរ ឪពុកម្តាយរបស់ ម្យ៉ាម ដែលចេះនិយាយតែភាសាខ្មែរគឺជាកសិករ។ អ្នកទាំងពីរទំនងជាធ្វើចំណាកស្រុកមកពីតំបន់ខ្ពង់រាបប្រទេសថៃ មុនពេលដែលម្យ៉ាមចាប់កំណើត។ ប៉ុន្តែម្យ៉ាមមិនដែលសួរថាឪពុកម្តាយគាត់មកពីណា ឬជួបគ្នាដោយរបៀបណានោះទេ។ ព័ត៌មានទាំងនេះ មិនសូវជាសំខាន់ឡើយនៅសម័យនោះ។ កាលពី ម្យ៉ាម នៅវ័យក្មេង រាជរដ្ឋាភិបាលថៃបានបញ្ជាឲ្យគាត់ និងក្រុមគ្រួសារផ្លាស់ទីពីភូមិណូឡូហានទៅកាន់ភូមិណុនចូរៈ ដែលជាសហគមន៍មួយស្ថិតនៅជាប់នឹងព្រំប្រទល់ប្រទេសកម្ពុជា។

មន្ត្រីរដ្ឋាភិបាលតម្រូវឲ្យគ្រួសារ ម្យ៉ាម ផ្លាស់ទី ដើម្បីការពារព្រៃឈើតំបន់នោះ។ គ្រួសារ ម្យ៉ាម មានជម្រើសមួយ គឺផ្លាស់ទីទៅជិតក្រុងនៃខេត្តស៊ីសាកេតឬផ្លាស់ទៅទិសខាងត្បូង។ ទឹកដីនៃខ្ពង់រាបខេត្តស៊ីសាកេតមានលក្ខណៈស្ងួត និងមិនសូវមានជីជាតិទេ។ ហេតុនេះគ្រួសារ ម្យ៉ាម ក៏បានសម្រេចចិត្តផ្លាស់ទីទៅទិសខាងត្បូង។ ភូមិណុនចូរៈនេះហើយដែល ម្យ៉ាម និងគ្រួសារអាចធ្វើដំណើរឆ្លងព្រំដែនកម្ពុជាទៅកាន់អន្លង់វែង ដើម្បីទិញទំនិញ។ ការធ្វើដំណើរមកទិញទំនិញឆ្លងព្រំដែននេះ បានធ្វើឲ្យជីវិត ម្យ៉ាម ផ្លាស់ប្តូរយ៉ាងខ្លាំង។ មន្ត្រីយោធាកម្ពុជាបានប្រកាសប្រាប់ប្រជាជនក្នុងតំបន់អន្លង់វែងថា គ្រួសារនីមួយៗត្រូវតែប្រគល់បុរសពេញវ័យម្នាក់ឲ្យស្ម័គ្រចិត្តធ្វើជាកងទ័ពកម្ពុជា។ ម្យ៉ាម បានប្រាប់ឪពុកម្តាយថា ខ្លួនខ្លាចសង្គ្រាម ប៉ុន្តែម្តាយបានព្យាយាមបញ្ចុះបញ្ចូល ម្យ៉ាម។ ម្តាយ ម្យ៉ាម បាននិយាយថា វាគ្រាន់តែមួយរយៈពេលខ្លីប៉ុណ្ណោះ ហើយប្រាក់បៀវត្សរ៍របស់ទាហានក៏អាចជួយគ្រួសារបានទៀតផង។

ម្យ៉ាមដឹងច្បាស់ថា ខ្លួនមានជម្រើសតិចតួចណាស់។ ដោយសារតែគ្មានលិខិតបញ្ជាក់អត្តសញ្ញាណ ម្យ៉ាមគ្មានភស្តុតាងដែលបញ្ជាក់ថាគាត់ជាជនជាតិថៃទេ។ បើទោះជា ម្យ៉ាម មានរបស់សំអាងពីអត្តសញ្ញាណក៏ដោយ ក៏ ម្យ៉ាម យល់ថា គាត់មិនគួរនិយាយអ្វីឡើយ។ សហគមន៍កម្ពុជា និងថៃបានរស់នៅជាមួយគ្នាអស់ជាច្រើនជំនាន់មកហើយ តាមរយៈការរៀបការឆ្លងសាសន៍ និងការដោះដូរទំនិញឆ្លងកាត់ព្រំដែន។ ដូច្នេះហើយសញ្ជាតិគឺជាប្រធានបទដ៏រសើបមួយ។ ម្យ៉ាម បានលើកឡើងថា «ប្រសិនបើខ្ញុំបានប្រាប់គេថាខ្ញុំគឺជាជនជាតិថៃ គេប្រហែលជាបានសម្លាប់ខ្ញុំចោលបាត់ទៅហើយ។»

ម្យ៉ាម ត្រូវបានកេណ្ឌឲ្យចូលបម្រើកងទ័ពកម្ពុជា ហើយគាត់បានក្លាយជាទាហានថ្មើរជើង។ ជំរំនោះមានទំហំតូចទេ ហើយមានកងទ័ពប្រមាណមួយរយនាក់ប៉ុណ្ណោះដែលត្រូវបានបញ្ចូលទៅក្នុងអង្គភាពនោះ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៦០ មុខងាររបស់អង្គភាពនោះគឺត្រូវការពារសន្តិសុខក្នុងតំបន់ ដែលធ្លាប់ជាទីតាំងឆ្លងកាត់របស់ចោរព្រៃ ក្រុមកុម្មុយនីស្ត និងក្រុមប្រដាប់អាវុធដទៃទៀត។

## សេចក្តីសង្ខេបរបស់អ្នក៖

## លំហាត់គោល៖

ការណែនាំ៖ ចូរបិទសៀវភៅ ចំណាយពេលមួយនាទីដើម្បីគិតអំពីសាច់រឿងដែលអ្នកអាចចាំបាន។ សូមធ្វើការជាមួយដៃគូម្នាក់ រៀបរាប់សាច់រឿងក្នុងផ្នែកនេះឡើងវិញ យ៉ាងហោចណាស់ឲ្យបានចំនួនមួយ។ ដៃគូរបស់អ្នកត្រូវបើកសៀវភៅ កត់ត្រាផ្នែកនៃសាច់រឿងដែលអ្នកភ្លេចនិយាយខុស ឬគួរតែកែលម្អ។ នៅពេលអ្នករៀបរាប់ចប់ ចូរប្តូរតួនាទីគ្នា៖ ដៃគូរបស់អ្នករៀបរាប់សាច់រឿង អ្នកធ្វើការកត់ត្រានូវអ្វីដែលគួរកែលម្អនៅក្នុងសាច់រឿងដែលគាត់រៀបរាប់។



## ផ្នែកទី៣៖ សាច់រឿងស្តីពីអន្លង់វែងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ

ការណែនាំ៖ ចូរអានសាច់រឿងខាងក្រោម។ បន្ទាប់ពីបានអានរឿងនីមួយៗ សូមសង្ខេបសាច់រឿងនៅក្នុងចន្លោះដែលបានផ្តល់ឲ្យ។ សូមព្យាយាមធ្វើឲ្យសេចក្តីសង្ខេបរបស់អ្នកមិនលើសពីមួយ ឬពីរប្រយោគ។ នៅពេលដែលអ្នកបានធ្វើការសង្ខេបរួចរាល់ អ្នកនឹងត្រូវបានហៅឲ្យរៀបរាប់សាច់រឿងមួយឬពីរទៅកាន់ដៃគូរបស់អ្នក។

សាច់រឿងទី១៖ ស្ត្រីម្នាក់រៀបរាប់អំពីបទពិសោធន៍មួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

«នៅក្នុងអំឡុងរបបខ្មែរក្រហម ខ្ញុំធ្លាប់បានឃើញអំពីការចាប់ខ្លួនស្ត្រីម្នាក់នៅក្នុងកងកុមារ។ ខ្ញុំស្ថិតនៅទីនោះផ្ទាល់។ ស្ត្រីនោះប្រើពាក្យគំរាមកំហែង ហើយអត្តចរិតរបស់គាត់មានលក្ខណៈពាក់កណ្តាលបុរស ពាក់កណ្តាលស្ត្រី។ យើងមិនទុកចិត្តស្ត្រីនោះទេ។ យប់មួយ ស្ត្រីនោះនិយាយពីអ្វីដែលខ្លួនចង់ហូប...ហើយចង់ហូបអាហារជាច្រើនមុខទៀតផង។ ខ្ញុំមិនដឹងថាស្ត្រីនោះចង់ហូបអ្វីទេ។ ប៉ុន្តែបន្ទាប់ពីខ្ញុំឮគាត់និយាយយ៉ាងដូច្នោះ ខ្ញុំក៏រាយការណ៍ទៅមេបញ្ជាការ។ ក្រោយមក ក្រុមយោធាបានចូលមកយាមកាមស្ត្រីនោះ។ លុះស្អែកឡើង ខ្ញុំបានទទួលបញ្ជាឲ្យនាំខ្លួនស្ត្រីនោះចេញមកក្រៅ ហើយស្ត្រីនោះត្រូវបាននាំទៅបាត់ និងមិនបានត្រឡប់មកវិញទេ។ កម្មាភិបាលខ្មែរក្រហមតែងតែចង់ឲ្យយើងប្រុងប្រយ័ត្នចំពោះមនុស្សដែលមិនស្មោះត្រង់។ កម្មាភិបាលខ្មែរក្រហមក៏បានប្រាប់ខ្ញុំឲ្យបន្តឃ្លាំមើល និងស្វែងរកជនក្បត់ ឬអ្នកដទៃទៀតដែលមិនស្មោះត្រង់។»

## សេចក្តីសង្ខេបរបស់អ្នក៖

សាច់រឿងទី២៖ យែម ហ៊ុន ប្រាប់អំពីជីវិតរបស់គាត់ ក្នុងនាមជាយោធាម្នាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

«ខ្ញុំធ្វើការនៅក្នុងអង្គភាពយោធាខ្មែរក្រហមដែលប្រចាំការនៅតាមព្រំដែនវៀតណាម។ យោធាក៏ត្រូវបានចាប់ខ្លួន និងសម្លាប់ដូចគ្នាទៅនឹងប្រជាជនដែរ។ ខ្ញុំចាំបានថា ថ្ងៃមួយ មេកងរបស់ខ្ញុំត្រូវបានចាប់ខ្លួន។ ខ្ញុំមានកាតព្វកិច្ចយាមគាត់។ មេវរៈសេនាតូចចង្អុលមុខខ្ញុំ ហើយនិយាយថា៖ «មកយាមមាន់អញ។» គាត់និយាយសំដៅទៅមេកងរបស់ខ្ញុំ។ នៅពេលដែលខ្ញុំទៅដល់ផ្ទះនោះ ខ្ញុំបានឃើញមេកងរបស់ខ្ញុំឈ្មោះ ភ័ក្រ ជាប់ចំណង។ ខ្ញុំពិតជាពិបាកចិត្តណាស់។ យើងធ្លាប់រស់នៅជាមួយគ្នា ហើយធ្លាប់ជាមិត្តភក្តិស្និទ្ធស្នាលទៀតផង។ ខ្ញុំបានបន្ធូរចំណងដែលចងដៃគាត់ ហើយឲ្យបារីគាត់មួយដើម។ ខ្ញុំប្រាប់គាត់កុំឲ្យរត់ ព្រោះខ្ញុំក៏ត្រូវស្លាប់ដែរ។ យើងបាននិយាយគ្នាបន្តិចបន្តួច។ គាត់និយាយថា គាត់មិនចង់ឲ្យខ្ញុំស្លាប់ជាមួយគាត់ទេ។ គាត់បានត្រៀមខ្លួនស្លាប់រួចហើយ។ ក្រោយមក ខ្ញុំចម្អិនសាច់ខ្លះឲ្យគាត់និងឲ្យបារីទៀត។ នៅម៉ោង៦ល្ងាច ពេជ្ឈឃាតមកដល់ ហើយនាំគាត់ចេញទៅប្រហែល២០០ម៉ែត្រពីភូមិ។ ពេជ្ឈឃាតបានបាញ់គាត់បីគ្រាប់នៅចំខ្នង។ ប្រហែលមួយម៉ោងក្រោយមក ខ្ញុំដើរទៅកាន់ទីតាំងដែលគាត់ត្រូវបានសម្លាប់និងបានឃើញសាកសព។ ពេជ្ឈឃាតមិនបានស្រាយចំណងទេ។ ខ្ញុំបានកាត់ខ្សែចេញពីកដៃគាត់។ ខ្ញុំពិតជាមានអារម្មណ៍សោកស្តាយចំពោះគាត់ណាស់។»

សេចក្តីសង្ខេបរបស់អ្នក៖

សាច់រឿងទី៣៖ ស៊ីន ហួង រំឭកអំពីជីវិតរបស់គាត់នៅក្នុងសហករណ៍តាដេវក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ

«យើងត្រូវបានចាត់តាំងឲ្យធ្វើការដាច់ដោយឡែកពីគ្នា។ ឪពុកខ្ញុំធ្វើការនៅរោងម៉ាស៊ីនកិនស្រូវ។ ខ្ញុំឃ្វាលគោ។ ម្តាយខ្ញុំធ្វើការនៅវាលស្រែ។ ប្អូនប្រុសខ្ញុំកាត់ស្មៅដើម្បីធ្វើជី។ បងប្រុសខ្ញុំធ្វើការនៅសហករណ៍រោងម៉ាស៊ីនកិនស្រូវជាមួយឪពុកខ្ញុំ។ យើងធ្វើការតាំងពីព្រឹករហូតដល់ល្ងាច ហើយអាចសម្រាកនៅពេលបាយថ្ងៃត្រង់ប៉ុណ្ណោះ។ យើងហូបតែបបរមួយចានតូចក្នុងមួយពេល (ពីរពេលក្នុងមួយថ្ងៃ)។ យើងត្រូវស្វែងរកបន្លែបន្ថែម ហើយហូបជាមួយអំបិល។»

សេចក្តីសង្ខេបរបស់អ្នក៖

សាច់រឿងទី៤៖ សាក្សីម្នាក់ពណ៌នាហេតុការណ៍ ដែលមេបញ្ជាការនៃមន្ទីរយោធាឫស្សីសុខចាប់ខ្លួនប្រជាជនដែលព្យាយាមឆ្លងដែន។

«ខ្ញុំបានឃើញយោធាចាប់ខ្លួនប្រជាជន ៥នាក់ ដែលព្យាយាមរត់ទៅប្រទេសថៃ។ មេបញ្ជាការបានមកដល់ទីនោះ រួមជាមួយអង្គរក្សប្អូនប្រាំនាក់។ គាត់បានវាយប្រជាជន ៥នាក់នោះ។ ម្នាក់ៗត្រូវវាយយ៉ាងតិច៣០រំពាត់។ គាត់សួរថាតើប្រជាជនទាំងនេះមកពីខាងណា ហើយចង់ទៅណា។ ប្រជាជនបាននិយាយថា ខ្លួនមកពីកំពង់ធំនិងសៀមរាប ហើយចង់ទៅប្រទេសថៃ។ មេបញ្ជាការរូបនោះបានវាយប្រជាជនរហូតបែកខ្នងចេញឈាម ហើយក្រោយមក បាននាំប្រជាជនទាំងនោះចេញទៅបាត់។ ខ្ញុំមិនប្រាកដទេថា ប្រជាជនទាំងនោះអាចរស់រានមានជីវិតទេ។»

សេចក្តីសង្ខេបរបស់អ្នក៖



សាច់រឿងទី៥៖ យិន ឡាហៀ យោធាម្នាក់ការពារព្រំដែននៅអន្លង់វែងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ រំឭកអំពីការភ្ញាក់ផ្អើលរបស់ខ្លួននៅពេលដែលខ្លួនធ្វើដំណើរទៅសួរសុខទុក្ខក្រុមគ្រួសារ។ ផ្ទះរបស់ខ្លួនមានភាពស្ងាត់ជ្រងំនិងគ្មានមនុស្សរស់នៅ បន្ទាប់ពីសហគមន៍អន្លង់វែងត្រូវបានជម្លៀសដោយបង្ខំទៅកាន់ស្រុកក្រឡាញ់និងសហករណ៍ដទៃទៀត។

«នៅពេលខ្ញុំទៅដល់ផ្ទះ ខ្ញុំឃើញផ្ទាំងបាយរបស់យាយខ្ញុំព្យួរចោល។ ភូមិនោះស្ងាត់ជ្រងំ។ ប្រជាជនត្រូវបានជម្លៀសទៅក្រឡាញ់។ បន្ទាប់ពីបានឃើញទិដ្ឋភាពភូមិបែបនេះ ខ្ញុំអស់សង្ឃឹមយ៉ាងខ្លាំង។ ខ្ញុំបានខិតខំបម្រើប្រទេសដើម្បីអ្វី? ខ្ញុំបាត់បង់អ្វីៗគ្រប់យ៉ាង។ ខ្ញុំបាត់បង់ជំនឿចិត្ត។ ខ្ញុំមិនអាចធ្វើអ្វីបានទាំងអស់ គឺបានត្រឹមតែបំភ្លេចស្ថានភាពនោះចោល ហើយបន្តរស់នៅតទៅទៀត។»

សេចក្តីសង្ខេបរបស់អ្នក៖

## លំហាត់គោល៖

ការណែនាំ៖ ចូរបិទសៀវភៅ ចំណាយពេលមួយនាទីដើម្បីគិតអំពីសាច់រឿងដែលអ្នកអាចចាំបាន។ សូមធ្វើការជាមួយដៃគូម្នាក់ រៀបរាប់សាច់រឿងក្នុងផ្នែកនេះឡើងវិញយ៉ាងហោចណាស់ឲ្យបានចំនួនមួយ។ ដៃគូរបស់អ្នកត្រូវបើកសៀវភៅ កត់ត្រាផ្នែកនៃសាច់រឿងដែលអ្នកភ្លេចនិយាយខុស ឬគួរតែកែលម្អ។ នៅពេលអ្នករៀបរាប់ចប់ ចូរប្តូរតួនាទីគ្នា៖ ដៃគូរបស់អ្នករៀបរាប់សាច់រឿង អ្នកធ្វើការកត់ត្រានូវអ្វីដែលគួរកែលម្អនៅក្នុងសាច់រឿងដែលគាត់រៀបរាប់។

## ផ្នែកទី៤៖ សាច់រឿងស្តីពីការរត់គេច បន្លាស់ទី និងការរស់រានមានជីវិត ក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ

ការណែនាំ៖ ចូរអានសាច់រឿងខាងក្រោម។ បន្ទាប់ពីបានអានរឿងនីមួយៗ សូមសង្ខេបសាច់រឿងនៅក្នុងចន្លោះដែលបានផ្តល់ឲ្យ។ សូមព្យាយាមធ្វើឲ្យសេចក្តីសង្ខេបរបស់អ្នកមិនលើសពី មួយ ឬពីរប្រយោគ។ នៅពេលដែលអ្នកបានធ្វើការសង្ខេបរួចរាល់ អ្នកនឹងត្រូវបានហៅឲ្យរៀបរាប់សាច់រឿងមួយ ឬពីរទៅកាន់ដៃគូរបស់អ្នក។

សាច់រឿងទី១៖ សាំង ថាញ់ គឺជាអតីតនីរសារកងពល២៨០របស់ខ្មែរក្រហម ដែលមានទីតាំងនៅភូមិភាគបូព៌ា។ ថាញ់ បានរៀបរាប់ពីបទពិសោធន៍របស់ខ្លួននៅពេលរត់ឡើងភ្នំ១០០១ ថា៖

"នៅឆ្នាំ១៩៨០ ខ្ញុំបានដឹកនាំកងទ័ព៧នាក់រត់ទៅមុំបី។ នៅតាមផ្លូវ ខ្ញុំបានជួបជាមួយកងទ័ពខ្មែរក្រហមនិងប្រជាជន

ជាច្រើនក្រុមដែលកំពុងធ្វើដំណើរទៅម៉ុំបីដែរ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមនីមួយៗត្រូវមានភាពឯករាជ្យ ពោលគឺធ្វើយ៉ាងណាឲ្យទៅដល់ម៉ុំបី ដើម្បីជួបជុំជាមួយអង្គការ។ ខ្ញុំបានយកមាសទៅដូរយកអង្ករ និងអំបិលពីអ្នកភូមិ។ យើងបានរំលែកអំបិលដាក់ទៅក្នុងថង់តូចៗ ហើយរក្សាទុកក្នុងកាបូបរៀងៗខ្លួន។ ខ្ញុំបានឃើញមនុស្សជាច្រើនស្លាប់ ហើយសាកសពហើមស្អុយនៅតាមផ្លូវ។ ស្ត្រីមួយចំនួនបានដេកស្លាប់ក្នុងអង្រឹង ស្ត្រីមួយចំនួនទៀតបានស្រែកហៅឲ្យខ្ញុំជួយ «សមមិត្ត! ជួយខ្ញុំផង! ជួយយកខ្ញុំទៅជាមួយផង!» ខ្ញុំបានសួរខ្លួនឯងថា «តើខ្ញុំអាចជួយអ្នកទាំងនោះយ៉ាងម៉េច បើខ្ញុំជួយខ្លួនឯងមិនបានផង?»។ ជាងនេះទៅទៀត កងទ័ពវៀតណាមបានដេញតាមយើងជាប់ពីក្រោយរហូត ហើយសម្លាប់អ្នកជិតស្លាប់។ ពេលមកដល់ស្រុកឆែប យើងបានកាប់ដើមចេក ហើយបេះចេកខ្ចីយកមកហូបដូចដំរី។ យើងបានចំណាយពេលមួយខែកន្លះទើបបានមកដល់ម៉ុំបី។ នៅទីនោះ យើងរកបានអង្ករជាច្រើន។ ដោយសារម្នាក់ៗកំពុងតែឃ្លានខ្លាំង យើងហូបច្រើនទាល់តែហល់។ មនុស្សជាច្រើនបានស្លាប់ដោយសារតែហូបអង្ករឆៅច្រើនជ្រុល។ ដូច្នេះ យើងទទួលបានការណែនាំឲ្យហូបបាយដំណើបជំនួសវិញ។»

## សេចក្ដីសង្ខេបរបស់អ្នក៖

**សាច់រឿងទី២៖** ឃឹម ផាន់ណា យោធាម្នាក់ក្នុងកងពល៨០១ បានរត់ទៅព្រំដែនថៃជាមួយកងទ័ពនិងកម្មាភិបាលខ្មែរក្រហមដទៃទៀត។ ផាន់ណា បានរំឭកពីដំណើរដ៏វែងឆ្ងាយនិងលំបាកលំបិនដូចខាងក្រោម៖

«យើងចាប់ផ្ដើមធ្វើដំណើរពីខែមីនា ឆ្នាំ១៩៧៩។ នៅពេលនោះ អាកាសធាតុក្ដៅខ្លាំងណាស់។ តំបន់ដែលមានទឹកត្រូវបានកងទ័ពវៀតណាមគ្រប់គ្រង។ ជារឿយៗ ការប្រយុទ្ធគ្នាតែងតែកើតឡើងនៅតាមតំបន់ទាំងនោះ។ មនុស្សជាច្រើនបានស្លាប់និងរបួស។ ដៃជើងរបស់ខ្ញុំចាប់ផ្ដើមហើម ដែលធ្វើឲ្យខ្ញុំមិនអាចដើរទៅមុខបាន។ ខ្ញុំបានវង្វេងជាមួយក្រុមរបស់ខ្ញុំ នៅពេលរត់គេចពីខ្មែរក្រហម។ នៅទីបំផុត ខ្ញុំត្រូវផឹកទឹកនោមខ្លួនឯងដើម្បីរស់។ នៅពេលខ្លះ កងទ័ពវៀតណាមវាយប្រហារយើងនៅពេលពួកយើងកំពុងដាំបាយ។ យើងត្រូវរត់បែកផ្លូវគ្នា ដោយទុកបាយចោល។ ពីមួយពេលទៅមួយពេល ក្រុមរបស់យើងកាន់តែតូចទៅៗ។ នៅពេលនោះ ឌី ធិន គឺជាមេក្រុមរបស់យើង។ នៅពេលយើងធ្វើដំណើរមកដល់ស្រុកឆែប ខ្ញុំបង្ខំចិត្តចូលក្នុងភូមិ ដើម្បីទទួលការព្យាបាល។ ដៃជើងរបស់ខ្ញុំកាន់តែហើមឡើងៗ ហើយខ្ញុំកាន់តែគ្រុនក្ដៅទៀត។ ប្រសិនបើខ្ញុំបន្តរស់នៅជាមួយក្រុមទៀត ដំណើរផ្លូវដ៏វែងឆ្ងាយរបស់យើងនឹងត្រូវយឺតយ៉ាវដោយសារជំងឺរបស់ខ្ញុំជាមិនខាន។ ដូច្នេះ ក្រុមរបស់ខ្ញុំក៏បានសម្រេចចិត្តដកហូតកាំភ្លើងរបស់ខ្ញុំ ហើយបង្ខំឲ្យខ្ញុំចូលសារភាពជាមួយសត្រូវ។ ខ្ញុំមិនចង់ទៅទេ ប៉ុន្តែគ្មានជម្រើស។ ពេលមកដល់ក្នុងភូមិ ខ្ញុំត្រូវបានកងទ័ពវៀតណាមចាប់ខ្លួន ហើយបញ្ជូនទៅក្នុងគុក។ នៅទីនោះ ខ្ញុំបានជួបជាមួយមិត្តភក្តិរបស់ខ្ញុំជាច្រើន។"



## សេចក្ដីសង្ខេបរបស់អ្នក៖

**សាច់រឿងទី៣៖** គឹម ណន ដែលជាអតីតយោធាខ្មែរក្រហមប្រចាំនៅតំបន់សៀមរាប-ឧត្តរមានជ័យ (តំបន់ ១០៦) ស្ថិតនៅក្នុងកងកាំភ្លើងធំនៃតំបន់នោះ។ នៅឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមវាយចូលប្រទេសកម្ពុជា ណន និងកងរបស់ខ្លួន ត្រូវបានបញ្ជូនទៅស្រុកថាឡាបរិវ៉ាត់ (ខេត្តស្ទឹងត្រែង) ដើម្បីជួយប្រយុទ្ធក្នុងសមរភូមិនៅទីនោះ។ ណន បានរៀបរាប់អំពីដំណើរភៀសខ្លួនដ៏លំបាកទៅកាន់ព្រំដែនថៃ ថា៖

«នៅពេលមកដល់ស្រុកថាឡាបរិវ៉ាត់ ខ្ញុំមិនអាចបែងចែកបានថាតើនរណាជាខ្មែរហើយនរណាជាយួនទេ។ ព្រឹកឡើង ខ្ញុំបានឃើញកងទ័ពវៀតណាមជាច្រើន ដូចផ្សិតដែលផុសចេញពីដី។ ការប្រយុទ្ធគ្នាបានផ្ទុះឡើងជាច្រើនថ្ងៃ។ យើងបានចាញ់កងទ័ពវៀតណាម ហើយបានរត់ចូលទៅក្នុងព្រៃ ដែលនៅទីនោះមានសត្វព្រៃជាច្រើនដូចជាដំរីនិងខ្លា។ ខ្ញុំគិតថា ខ្ញុំប្រាកដជាស្លាប់មិនខាន។ នៅពេលយប់ ខ្ញុំមិនហ៊ានដេកនៅលើដីទេ។ ខ្ញុំដេកនៅលើដើមឈើ។ លុះដល់ព្រឹកឡើងខ្ញុំបានវង្វេងទិស។ ខ្ញុំបានឮសំឡេងកាំភ្លើង ហើយក៏សម្រេចដើរតាមទិសដៅរបស់សំឡេងនោះ។ នៅពេលដើរទៅដល់ទីវាលមួយ ខ្ញុំបានឃើញមនុស្សមួយក្រុមអត់ពាក់អាវ ប៉ុន្តែមិនអាចមើលស្គាល់ថាជានរណា។ ខ្ញុំបានស្រែកហៅអ្នកទាំងនោះ។ ដោយសារមនុស្សមួយក្រុមនោះជាកងទ័ពវៀតណាម កងទ័ពទាំងនោះមិនអាចស្ដាប់ខ្ញុំយល់ទេ។ កងទ័ពទាំងនោះបានបក់ដៃឲ្យខ្ញុំដើរចូល។ ខ្ញុំក៏ដើរចូល។ ប៉ុន្តែនៅពេលដែលខ្ញុំដឹងថាកងទ័ពនោះគឺជាកងទ័ពវៀតណាម។ ខ្ញុំក៏រត់គេចចេញ។ ខ្ញុំបានវង្វេងនៅក្នុងព្រៃអស់រយៈពេលពីរថ្ងៃ ដោយគ្មានអាហារ។ ពេលដើរតាមផ្លូវ ខ្ញុំបានឮសំឡេងឡានមួយ។ ខ្ញុំបានដឹងថា ឡាននោះជារបស់ខ្មែរក្រហម។ ខ្ញុំក៏រត់សំដៅទៅរកឡាននោះ ហើយសុំជិះទៅជាមួយ។ កងទ័ពខ្មែរក្រហមបានយល់ព្រមឲ្យខ្ញុំជិះទៅជាមួយ។ កងទ័ពវៀតណាមនៅតែបន្តដេញយើងពីក្រោយរហូតដល់ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។»

## សេចក្ដីសង្ខេបរបស់អ្នក៖

**សាច់រឿងទី៤៖** ឡេង ផេង ដែលជាអតីតយោធានៅកងពល៨០១ បានរំឭកពីការគេចខ្លួនរបស់គាត់ពីខេត្តរតនគិរីទៅកាន់ទន្លេរពៅ ថា៖

«នៅពេលដែលវៀតណាមចូលមកកម្ពុជានៅឆ្នាំ១៩៧៩ ខ្ញុំបានរត់ចូលព្រៃខេត្តរតនគិរី។ បន្ទាប់មក នៅក្នុងឆ្នាំ១៩៨១ ខ្ញុំបានរត់ទៅភ្នំដងរែក ដោយសារតែមានការលំបាកផ្នែកសេដ្ឋកិច្ច។ យើងបានធ្វើដំណើរចេញពីខេត្តរតនគិរីដោយឆ្លងកាត់តាម

ប្រទេសឡាវ។ នេះក៏ដោយសារតែកងទ័ពវៀតណាមបានឈរជើងនៅតាមព្រំដែនក្នុងទឹកដីកម្ពុជា។ ពេលមកដល់ខេត្តស្ទឹងត្រែង យើងបានធ្វើក្បូនឫស្សី ដើម្បីឆ្លងទន្លេមេគង្គទៅខេត្តព្រះវិហារ។ នៅពេលដែលខ្ញុំហែលឆ្លងទន្លេ ជើងរបស់ខ្ញុំបានរមួលក្រពើ។ ខ្ញុំក៏អង្គុយសម្រាកនៅច្រាំងទន្លេដោយសារតែខ្ញុំមិនអាចដើរទៅមុខទៀត។ សមាជិកដទៃទៀតនៅក្នុងកងរបស់ខ្ញុំបានឆ្លងទន្លេ និងបានបន្តដំណើរទៅមុំបី។ ខ្ញុំបានចំណាយពេលអស់៩ថ្ងៃ ដើម្បីធ្វើដំណើរទៅដល់ទន្លេរពៅឬមុំបី។ ចំណែកឯគ្នីគ្នារបស់ខ្ញុំចំណាយពេលតែបីថ្ងៃតែប៉ុណ្ណោះ។»

## សេចក្តីសង្ខេបរបស់អ្នក៖

សាច់រឿងទី៥៖ ប៉ុក តឿក និយាយរៀបរាប់ពីរឿងរ៉ាវនៃការបាត់បង់ប្តី និងកូនរបស់គាត់ ក្នុងស្ថានភាពវឹកវរក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ៖

«ប្តីរបស់ខ្ញុំជាអ្នកយាមម្នាក់នៅចម្ការដូង។ គាត់មានតួនាទីមើលការខុសត្រូវលើក្មេងៗនៅទីនោះ។ នៅឆ្នាំ១៩៧៩ យើងបានបែកគ្នាដោយសារតែស្ថានភាពចលាចល។ យើងកំពុងរត់គេចពីការឈ្លានពានរបស់វៀតណាម។ បន្ទាប់ពីយើងបានជួបគ្នា យើងបានរត់គេចខ្លួនទៅកន្ទួត ត្រពាំងជង។ នៅទីនោះ ខ្មែរក្រហមបានបញ្ជូនស្ត្រីទាំងអស់ទៅកាន់ភូមិថ្មី។ តាម៉ុក បានបញ្ជូនប្តីរបស់ខ្ញុំទៅកាន់តំបន់ផ្សេង។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យខ្ញុំទៅតាមប្តីទេ។ ចាប់តាំងពីពេលនោះមក យើងបានបែកគ្នា។ ខ្ញុំមិនដែលបានឮដំណឹងពីគាត់ទៀតឡើយ។

នៅពេលដែលខ្ញុំបានជួបសាច់ញាតិរបស់ខ្ញុំ ខ្ញុំបានទទួលដំណឹងថា ប្តីរបស់ខ្ញុំបានមករកខ្ញុំ។ ប៉ុន្តែយើងអាចរកគ្នាឃើញដោយរបៀបណា បើម្នាក់កំពុងតែរត់គេចខ្លួន ហើយម្នាក់ទៀតកំពុងតែដើរស្វែងរក។ ជាលទ្ធផល យើងទាំងពីរបានបែកគ្នាជារៀងរហូត។

ខ្ញុំជឿថា ប្តីរបស់ខ្ញុំប្រហែលជាស្លាប់ជាយូរមកហើយ ដោយសារអត់អាហារ។ គាត់ជាមនុស្សពិការជើងម្ខាង ហើយមិនអាចយកអាហារតាមខ្លួនបានទេ។ ខ្ញុំបានឮប្រជាជនដែលបានស្គាល់គាត់ប្រាប់ថា ប្តីរបស់ខ្ញុំហូបតែផ្លែឈើប៉ុណ្ណោះ។ នៅក្នុងព្រៃមិនមានបាយហូបទេ។ កូនក្មេងក៏ត្រូវស្លាយអង្ករនិងដាំបាយដែរ។ យើងហូបជុំគ្នា។ ក្រោយមក ប្តីរបស់ខ្ញុំក៏ត្រូវបានបំបែកចេញពីកុមារទាំងនោះ។ មិនមាននរណាម្នាក់ជួយស្លាយនិងចម្អិនអាហារឲ្យគាត់ទៀតទេ។ ដូច្នេះ គាត់ប្រហែលជាគ្មានអីហូបទេ។ ខ្ញុំបានឮប្រជាជនមួយចំនួនដែលបានជួបគាត់និយាយថា គាត់បានអនុញ្ញាតឲ្យប្តីរបស់ខ្ញុំរស់នៅជាមួយ។ ប៉ុន្តែ ប្តីរបស់ខ្ញុំមិនព្រម ព្រោះគាត់ចង់ដើរស្វែងរកខ្ញុំ។

នៅពេលនោះ ខ្ញុំមានផ្ទៃពោះកូនដំបូង។ ខ្ញុំពុំមានអាហារហូបគ្រប់គ្រាន់ទេ។ ប៉ុន្តែ ខ្ញុំនៅមានកម្លាំងនៅឡើយ។ ទោះបីជាខ្ញុំមិនមានអ្វីហូប និងមានផ្ទៃពោះក៏ដោយ ក៏ខ្ញុំអាចបន្តដំណើរទៅព្រំដែនថៃ និងឡើងភ្នំចុះភ្នំ។ ប៉ុន្តែ នៅពេលទៅដល់ត្រាងក្នុងខែកក្កដា ឆ្នាំ១៩៧៩ ខ្ញុំបានសម្រាលកូន ដែលទើបតែមានអាយុ៦ខែក្នុងផ្ទៃ។ បន្ទាប់ពីសម្រាលបាន ២ ម៉ោង កូនរបស់ខ្ញុំក៏បានស្លាប់។ កូននោះយំដូចកង្កែប ហើយមិនមានរូបរាងពេញលក្ខណៈទេ។ ដៃជើងរបស់វាខ្លីៗ ហើយវាកើតអត់គ្រប់ខែទៀត។ ប្រសិនបើកូនហ្នឹងវា៧ខែទើបកើត នោះវាប្រហែលជាមិនស្លាប់ទេ។»



## សេចក្តីសង្ខេបរបស់អ្នក៖

សាច់រឿងទី៦៖ អ៊ុក សុខ និយាយរៀបរាប់ពីរឿងរ៉ាវនៅពេលដែលគាត់បានទៅដល់ជំរំភៀសខ្លួនមួយកន្លែងនៅលើទឹកដីថៃ៖

«នៅក្នុងឆ្នាំ១៩៧៩ ខ្ញុំបានធ្វើដំណើរទៅដល់ជំរំភៀសខ្លួនមួយនៅលើទឹកដីថៃ។ មិនយូរប៉ុន្មាន សក់របស់ខ្ញុំក៏ចាប់ផ្តើមជ្រុះអស់។ ខ្ញុំជឿជាក់ថា សក់របស់ខ្ញុំជ្រុះអស់ ដោយសារខ្ញុំឈឺនិងទទួលរងការលំបាកជាច្រើននៅតាមផ្លូវ។ នៅក្នុងជំរំ បុគ្គលិកជនជាតិបារាំងមិនអនុញ្ញាតឲ្យយើងហូបច្រើនទេ។ ពីដំបូង បុគ្គលិកទាំងនោះអនុញ្ញាតឲ្យយើងហូបតែត្រីផ្លាធូជាមួយខ្លាញ់និងបាយ។ ដោយសារតែឃ្លានខ្លាំងពេក អ្វីក៏ឆ្ងាញ់ដែរ។ យើងអាចរកអាហារបន្ថែមបាននៅមន្ទីរពេទ្យ។ គ្រប់គ្នាមានជំងឺរាក។ ប្រជាជនទាំងប្រុសទាំងស្រីបន្ទោបង់នៅមុខគ្នាដោយមិនមានការអៀនខ្មាស់ឡើយ។ តាមពិតទៅ ការទទួលទានអាហារទាំងនោះអាចជួយបញ្ចេញជាតិពុលចេញពីរាងកាយរបស់យើង។ មួយខែក្រោយមក យើងលែងកើតជំងឺរាកទៀតហើយ។ យើងចាប់ផ្តើមឡើងទម្ងន់។ ប្រសិនបើយើងក្រឡេកទៅមើលអតីតកាលវិញ មនុស្សរាប់រយនាក់បានស្លាប់ជារៀងរាល់ថ្ងៃនៅជំរំស្រះកែវ។ បុគ្គលិកអន្តរជាតិជាច្រើនដែលបម្រើការនៅទីនោះនាំគ្នាយំ ដោយសារតែឃើញមនុស្សជាច្រើនបានស្លាប់ជាបន្តបន្ទាប់។ ត្រាក់ទ័រដែលប្រើសម្រាប់ជីករណ្តៅកប់សាកសព ក៏មិនអាចជីកទាន់ចំនួនមនុស្សដែលស្លាប់ក្នុងមួយថ្ងៃៗបានទេ។ យើងមិនមានប្រារព្ធពិធីបុណ្យអ្វីនោះទេ។ នៅពេលមានមនុស្សស្លាប់ យើងជីករណ្តៅ ហើយប្រើរទេះដឹកសាកសពយកមកទម្លាក់ចូលក្នុងរណ្តៅ។»

## សេចក្តីសង្ខេបរបស់អ្នក៖

## លំហាត់គោល៖

ការណែនាំ៖ ចូរបិទសៀវភៅចំណាយពេលមួយនាទីដើម្បីគិតអំពីសាច់រឿងដែលអ្នកអាចចាំបាន។ សូមធ្វើការជាមួយដៃគូម្នាក់ រៀបរាប់សាច់រឿងក្នុងផ្នែកនេះឡើងវិញយ៉ាងហោចណាស់ឲ្យបានចំនួនពីរ។ ដៃគូរបស់អ្នកត្រូវបើកសៀវភៅ កត់ត្រាផ្នែកនៃសាច់រឿងដែលអ្នកភ្លេច និយាយខុស ឬគួរតែកែលម្អ។ នៅពេលអ្នករៀបរាប់ចប់ ចូរប្តូរតួនាទីគ្នា៖ ដៃគូរបស់អ្នករៀបរាប់សាច់រឿង អ្នកធ្វើការកត់ត្រានូវអ្វីដែលគួរកែលម្អនៅក្នុងសាច់រឿងដែលគាត់រៀបរាប់។

## ផ្នែកទី៥៖ សាច់រឿងស្ដីពីជម្លោះ និងការរស់រានមានជីវិត ( ១៩៧៩ ~ ១៩៨៩ )

ការណែនាំ៖ ចូរអានសាច់រឿងខាងក្រោម។ បន្ទាប់ពីបានអានរឿងនីមួយៗ សូមសង្ខេបសាច់រឿងនៅក្នុងចន្លោះដែលបានផ្ដល់ឲ្យ។ សូមព្យាយាមធ្វើឲ្យសេចក្ដីសង្ខេបរបស់អ្នកមិនលើសពី មួយ ឬពីរ ប្រយោគ នៅពេលដែលធ្វើការសង្ខេបរួចរាល់ នឹងត្រូវហៅឲ្យរៀបរាប់សាច់រឿងមួយ ឬពីរទៅដៃគូរបស់អ្នក។



សមមិត្ត ហេង សំរិន កំពុងនិយាយជាមួយទ័ពរណសិរ្សរួបរួមនៅចម្ការកៅស៊ូមួយ នៅដើមទសវត្ស៍ឆ្នាំ ១៩៨០។ ឈរពីស្ដាំទៅឆ្វេងមាន ៖ ហ៊ុន សែន, ជ័យ កញ្ញា, ចាន់ វ៉ែន, ម៉ាត់ លី និង ហេង សំរិន។ ប្រភពព័ត៌មាន ៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

សាច់រឿងទី១៖ យឹម ឡាហៀ បាននិយាយថា គាត់និងប្រជាជនប្រមាណ៧០នាក់ បានវិលត្រឡប់ទៅអន្លង់វែងដើម្បីស្វែងរកសាច់ញាតិ ប៉ុន្តែត្រូវបានកងទ័ពវៀតណាមចាប់ខ្លួននៅភូមិលំទង។ ប្រជាជនដែលត្រូវបានចាប់ខ្លួន ត្រូវបានសួរចម្លើយនិងធ្វើទារុណកម្ម។ ឡាហៀ រំឭកឡើងពីបទពិសោធន៍របស់ខ្លួនដូចខាងក្រោម៖

«ខ្ញុំបានរត់ត្រឡប់មកផ្ទះ ហើយកងទ័ពវៀតណាមចាប់ខ្លួននៅភូមិលំទង។ កងទ័ពវៀតណាមបានឆែកឆេរខ្លួនខ្ញុំ ហើយសម្លឹងមើលសម្លៀកបំពាក់ ភ្នែក និងមុខមាត់របស់ខ្ញុំទៀត។ បន្ទាប់មក កងទ័ពវៀតណាមបានជ្រើសរើសគ្នារបស់ខ្ញុំចំនួនប្រាំនាក់ ហើយបានសួរយើងថាធ្លាប់ធ្វើការអ្វីកាលពីជំនាន់សីហនុ។ ខ្ញុំឆ្លើយថា ខ្ញុំមិនបានធ្វើអ្វីទេកាលណោះ គ្រាន់តែបានរៀនសូត្របន្តិចបន្តួច។ «ចុះឯងធ្វើអីកាលពីជំនាន់ លន់ នល់?» ខ្ញុំបានឆ្លើយថា ខ្ញុំឃ្វាលគោ។ «ចុះឯងធ្វើអីក្រោយឆ្នាំ១៩៧០?» ខ្ញុំឆ្លើយថា ខ្ញុំអត់បានធ្វើអីទេ ព្រោះខ្ញុំនៅតូច។ ខ្ញុំត្រូវបានខ្មែរក្រហមបង្រៀនឲ្យចេះរាំ។ នៅពេលកងទ័ពវៀតណាម សួរខ្ញុំថាធ្វើអីកាលពីជំនាន់ខ្មែរក្រហម ខ្ញុំបានឆ្លើយត្រង់ថា ខ្ញុំជាយោធារបស់ ប៉ុល ពត។ «តើឯងការពារនៅព្រំដែនណា?» ខ្ញុំឆ្លើយថា ខ្ញុំឈរជើងនៅព្រំដែនថៃ។ «តើឯងធ្លាប់ប្រយុទ្ធនៅព្រំដែនវៀតណាមអត់?» ខ្ញុំឆ្លើយថា «ខ្ញុំមិនដែលស្គាល់ព្រំដែនហ្នឹងទេ។ ខ្ញុំក៏មិនដឹងថាវៀតណាមមានរូបរាងយ៉ាងម៉េចផង»។ បន្ទាប់ពីសួរសំណួរនេះរួច កងទ័ពវៀតណាមនិយាយថា ខ្លួននឹង«សម្លាប់យើងទាំងអស់គ្នានៅពេលក្រោយ»។ បន្ទាប់ពីសួរចម្លើយរួច កងទ័ពវៀតណាមក៏បានអនុញ្ញាតឲ្យយើងត្រឡប់មកភូមិវិញ។ ខ្ញុំបានធ្វើដំណើរទៅភូមិតាដេវ។ នៅទីនោះ ខ្ញុំបានជួបឪពុកម្ដាយរបស់ខ្ញុំ និងអ្នកភូមិផ្សេងទៀតដែលទើបតែត្រឡប់មកពីស្រុកក្រឡាញ់វិញ។»

### សេចក្ដីសង្ខេបរបស់អ្នក៖

សាច់រឿងទី២៖ ប៉ុក តឿក រំឭកឡើងវិញនូវភាពលំបាកលំបិនដែលគាត់ជួបប្រទះ នៅពេលយោធាខ្មែរក្រហមចាប់ខ្លួននៅក្នុងឆ្នាំ១៩៨៣។

«តឿក ធ្វើការក្នុងកងចល័តស្រុករហូតដល់ថ្ងៃ ដែលកងទ័ពវៀតណាមវាយចូលដល់ទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៩។ តឿក បានវិលត្រឡប់មកស្រុកកំណើត ហើយបានជួបជុំជាមួយក្រុមគ្រួសារ តឿក វិញ។ ជាសំណាងល្អ តឿក អាចមករស់នៅក្នុងផ្ទះរបស់គាត់វិញ។ កងទ័ពវៀតណាមជាច្រើនកំពុងឈរជើងនៅក្នុងឃុំ។ តឿក បានចូលបម្រើការជាឈ្លបឃុំ រហូតដល់ឆ្នាំ១៩៨៣។ នៅពេល តឿក កំពុងច្រូតស្រូវ ខ្មែរក្រហមបានចាប់គាត់។ តាម៉ុន នៃកងពល៩៨០ ជាអ្នកចាប់ខ្លួន តឿក ហើយបានចោទប្រកាន់ថាជាមនុស្ស «ក្បាលយួនខ្លួនខ្មែរ»។ តឿក ត្រូវបានបញ្ជូនទៅភ្នំ១០០៣ ដើម្បីដឹកជញ្ជូនសព្វាវុធឲ្យកងទ័ពខ្មែរក្រហម ដែលប្រចាំការនៅភ្នំគូលែន ស្រុកសូត្រនិគម។ តឿក រស់នៅជាមួយខ្មែរក្រហមអស់រយៈពេលកន្លះខែ មុនពេលខ្មែរក្រហមដោះលែង និងអនុញ្ញាតឲ្យត្រឡប់មកផ្ទះវិញ។ ពេលត្រឡប់មកដល់ផ្ទះវិញ កងទ័ពវៀតណាមបានចាប់ តឿក ដោយចោទថាគាត់ជាគិញរបស់ខ្មែរក្រហម។ តឿក បានរត់គេចពីការចាប់ខ្លួននោះ ហើយបានចុះចូលជាមួយខ្មែរក្រហមវិញ។ កងទ័ពវៀតណាមសាហាវណាស់។ ប្រជាជនមួយចំនួនត្រូវបានកងទ័ពវៀតណាមចាប់ខ្លួន ហើយត្រូវបានបញ្ជូនទៅឃុំឃាំងក្នុងគុកមួយក្នុងឃុំទឹកវិល។ តឿក បានចូលបម្រើនៅក្នុងអង្គភាពរបស់ តា ថេន។ ជាក់ស្ដែង ខ្មែរក្រហមបានធ្វើឲ្យគាត់ក្លាយជាជនរងគ្រោះ ដោយសារតែវៀតណាមសង្ស័យថាគាត់ជាគិញខ្មែរក្រហម។ ដោយសារពុំមានជម្រើស តឿក ត្រូវតែចូលរួមជាមួយខ្មែរក្រហម។ នៅពេលនោះ វៀតណាមបានសម្លាប់មនុស្សជាច្រើន ដែលត្រូវបានចោទប្រកាន់ថាជាគិញខ្មែរក្រហម។»

### សេចក្ដីសង្ខេបរបស់អ្នក៖

សាច់រឿងទី៣៖ ធៀប ថេន អតីតយោធានៃកងពល៩២០ បានរៀបរាប់ពីបទពិសោធន៍របស់គាត់ក្នុងការដឹកជញ្ជូនសព្វាវុធពីភ្នំ១០០១ ទៅឲ្យកងទ័ពរបស់ខ្មែរក្រហមដែលមានទីតាំងនៅខេត្តក្រចេះ៖

«ខ្ញុំបានដឹកនាំកងទ័ពមួយក្រុមដែលមានសមាជិក៧០នាក់ ដើម្បីដឹកជញ្ជូនអាវុធទៅកាន់សមរភូមិនៅខេត្តក្រចេះ។ យើងបានដើរចុះពីភ្នំដងរែកទៅកាន់ឃុំស្រអែម ហើយធ្វើដំណើរបន្តទៅខេត្តកំពង់ធំ។ នៅពេលរសៀលម៉ោង ១ យើងបានឈប់សម្រាកនៅតាមដងផ្លូវ ដើម្បីដាំបាយហូបថ្ងៃត្រង់។ បន្ទាប់ពីបាយថ្ងៃត្រង់រួច យើងបន្តដំណើរបានប្រហែលមួយគីឡូម៉ែត្រ កងទ័ពវៀតណាមបានកន្ទ្រាក់គ្រាប់បែកចង្កោម។ យោធាម្នាក់នៅខាងមុខខ្ញុំបានដួល។ ពេលខ្ញុំក្រឡេកមកក្រោយ ខ្ញុំឃើញយោធាពីរនាក់ទៀតបានដួលដែរ។ ខ្ញុំបានបាញ់គ្រាប់បែកបួនប្រាំគ្រាប់ពីកាំភ្លើងបាញ់គ្រាប់បែក ដែលប្រហែលជាត្រូវចំកងទ័ពវៀតណាមមួយចំនួន។ យើងប្រមូលបានមួកកងទ័ពវៀតណាមចំនួន១០ បន្ទាប់ពីការប៉ះទង្គិចនោះ។ ខ្ញុំក៏រងរបួសនិងត្រូវបានសែងត្រឡប់មកក្រោយវិញដើម្បីព្យាបាល។″

សេចក្តីសង្ខេបរបស់អ្នកៈ

សាច់រឿងទី៤ៈ យោធានៅភ្នំ១០០៣ត្រូវបានបញ្ជូនទៅធ្វើប្រតិបត្តិការប្រចាំឆ្នាំនៅក្នុងប្រទេស។ យោធាខ្មែរក្រហម បានចេះពីរបៀបបង្កើតឲ្យមានភាពភ័យខ្លាច និងបង្កើតមិត្តភាពជាមួយប្រជាជននៅក្នុងប្រទេស។ មាស អេន អ្នកភូមិម្នាក់ក្នុងស្រុកអន្លង់វែង បានរំឭកឡើងវិញពីបទពិសោធន៍របស់ខ្លួនកាលពីទសវត្សរ៍ឆ្នាំ១៩៨០ៈ

«ខ្ញុំបានចូលរួមជាមួយខ្មែរក្រហមតាំងពីឆ្នាំ១៩៨៥ ដោយសារតែខ្ញុំមានបញ្ហានៅក្នុងគ្រួសារ។ ខ្មែរក្រហមមានទំនាក់ទំនងល្អជាមួយប្រជាជននៅក្នុងភូមិ (ភូមិរូង ឃុំល្វែងឫស្សី ស្រុកជីក្រែង ខេត្តសៀមរាប)។ អ្នកភូមិបានជួយរៀបចំដំណើររបស់ខ្ញុំទៅកាន់ភ្នំដងរែក។ ខ្មែរក្រហមមានក្រុមគិញរបស់ខ្លួននៅក្នុងភូមិ។ ប្រសិនបើកងទ័ពវៀតណាមចុះមកត្រួតពិនិត្យនៅក្នុងភូមិនៅម៉ោង១រសៀល អ្នកភូមិនឹងរាយការណ៍ទៅខ្មែរក្រហមឲ្យចាកចេញពីភូមិនៅម៉ោង១២ថ្ងៃត្រង់ ដើម្បីចៀសវាងការប្រឈមមុខដាក់គ្នាជាមួយកងទ័ពវៀតណាម។ ប្រសិនជាកងទ័ពខ្មែរក្រហមចាកចេញពីភូមិមិនទាន់ពេលទេ ការប្រយុទ្ធរវាងកងទ័ពវៀតណាម និងកងទ័ពខ្មែរក្រហមនឹងផ្ទុះឡើង។ ខ្ញុំបានធ្វើដំណើរនិងដេកជាមួយកងទ័ពខ្មែរក្រហមអស់រយៈពេលកន្លះខែ មុននឹងទៅដល់មូលដ្ឋានរបស់ខ្មែរក្រហមនៅលើភ្នំដងរែក។ យើងបានធ្វើដំណើរឆ្លងកាត់ចម្ការមីន។ ខ្ញុំត្រូវតោងវល្លិ៍ឡើងចំណោតភ្នំ។ ក្រោយមក ខ្ញុំបានក្លាយជាកងទ័ពខ្មែរក្រហមក្នុងកងពល៧៨៥ និងក្រោយមកទៀត នៅក្នុងកងពល៩៨០។»

សេចក្តីសង្ខេបរបស់អ្នកៈ

សាច់រឿងទី៥ៈ ព្រុំ យឹម អតីតយោធានៃកងពល៨០១ បានរៀបរាប់ពីបទពិសោធន៍ដែលគាត់បានរៀនសូត្រពីមេបញ្ជាការរបស់គាត់ក្នុងការធ្វើ «សង្គ្រាមប្រជាជន» ថាៈ

"ដំបូង យើងកសាងបុគ្គល ហើយបន្ទាប់មក កសាងគ្រួសារទាំងមូល។ ដំបូង យើងត្រូវកសាងប្តីដែលអាចឈានទៅកសាងប្រពន្ធរបស់គាត់បន្ត។ នៅពេលដែលប្តីប្រពន្ធមានគោលជំហរស្នេហាជាតិដូចគ្នា ប្តីប្រពន្ធនឹងបន្តកសាងកូនៗរបស់ខ្លួន។ កូនៗទាំងនោះនឹងបន្តកសាងមិត្តភក្តិរបស់ខ្លួនបន្តទៀត។ ដំណើរការនៃការកសាងកម្លាំង ប្រៀបបានទៅនឹងសត្វកណ្តៀរដែលស៊ីឈើបន្តិចម្តងៗ។ សត្វកណ្តៀរនឹងបំផ្លាញឈើពីខាងក្នុងមកវិញ។ សំបកក្រៅរបស់ឈើមើលទៅហាក់ដូចជាល្អ។ ប៉ុន្តែ ដោយសារតែប្រតិបត្តិការផ្ទៃក្នុងនេះដែលចាំបាច់ត្រូវតែលាក់ការណ៍សម្ងាត់ កងកម្លាំងទាំងអស់នឹងត្រូវរត់ចូលព្រៃ ដើម្បីគេចពីការចាប់ខ្លួន និងការធ្វើទុក្ខបុកម្នេញ។»

សេចក្តីសង្ខេបរបស់អ្នកៈ

សាច់រឿងទី៦ៈ ប៊ួ ចាន់ណា បានរៀបរាប់ពីការសង្ស័យរបស់អ្នកភូមិមកលើរូបគាត់ ដែលបន្តរហូតមកដល់បច្ចុប្បន្ន ទោះបីជារយៈពេលប៉ុន្មានឆ្នាំក្រោយរបបខ្មែរក្រហមយ៉ាងណាក៏ដោយៈ

«ខ្ញុំរស់នៅក្នុងភូមិ ហើយបានរៀនសូត្ររហូតដល់ឆ្នាំ១៩៧២។ នៅក្នុងឆ្នាំនោះ ខ្ញុំឈប់រៀនដោយសារតែខ្ញុំបានធំដឹងក្តីល្មមដែលអាចក្លាយជាយោធាសម្រាប់ខ្មែរក្រហម។ ប៉ុន្តែ ខ្ញុំនៅធ្វើការឲ្យកងចល័តសហករណ៍រហូតដល់ឆ្នាំ១៩៧៧សិន មុនពេលខ្ញុំអាចក្លាយជាយោធា។ នៅឆ្នាំ១៩៧៩ ខ្ញុំបានឈប់ធ្វើទាហាន ហើយបានត្រឡប់មករស់នៅក្នុងភូមិវិញ ក្នុងនាមជាយោធាបម្រុង។ ខ្ញុំបានរៀបការក្នុងឆ្នាំ១៩៨៤ និងមានកូន។ ប៉ុន្តែ នៅឆ្នាំ១៩៨៧ ប្រជាជននៅក្នុងភូមិបានចោទប្រកាន់ខ្ញុំថាជាគិញរបស់ ប៉ុល ពត។ ដោយសាររឿងនេះ ខ្ញុំមានការភ័យខ្លាចណាស់។ ខ្ញុំមានតែម្នាក់ឯង ហើយព្យាយាមបង្ហាញពីភាពស្អាតស្អំរបស់ខ្ញុំ។ ប៉ុន្តែ អ្នកភូមិនៅតែមិនជឿខ្ញុំ។ ខ្ញុំគិតថា ប្រសិនបើខ្ញុំបន្តរស់នៅក្នុងភូមិតទៅទៀតនោះ ខ្ញុំមុខជាស្លាប់មិនខាន។ ដូច្នេះ ខ្ញុំក៏សម្រេចចិត្តចាកចេញពីប្រពន្ធកូននិងសាច់ញាតិ ហើយធ្វើដំណើរទៅព្រំដែនថៃ ហើយចុះចូលជាមួយ តាម៉ុក ក្នុងឆ្នាំ១៩៨៧។ នៅពេលនោះ ខ្ញុំមានកូន៤នាក់។ ខ្ញុំគ្មានជម្រើសអ្វីក្រៅពីចាកចេញពីភូមិឡើយ។ ខ្ញុំមិនដែលបានជួបជុំជាមួយគ្រួសារខ្ញុំវិញនោះទេ រហូតដល់មានការផ្តាច់ខ្លួនចុះចូលជាមួយរដ្ឋាភិបាលថ្មី។"

សេចក្តីសង្ខេបរបស់អ្នកៈ

## លំហាត់គោលៈ

ការណែនាំៈ ចូរបិទសៀវភៅចំណាយពេលមួយនាទីដើម្បីគិតអំពីសាច់រឿងដែលអ្នកអាចចាំបាន។ សូមធ្វើការជាមួយដៃគូម្នាក់ រៀបរាប់សាច់រឿងឡើងវិញយ៉ាងហោចណាស់ឲ្យបានចំនួនពីរ។ ដៃគូរបស់អ្នកត្រូវបើកសៀវភៅ កត់ត្រាផ្នែកនៃសាច់រឿងដែលអ្នកភ្លេច និយាយខុស ឬគួរតែកែលម្អ។ នៅពេលអ្នករៀបរាប់ចប់ ចូរប្តូរតួនាទីគ្នាៈ ដៃគូរបស់អ្នករៀបរាប់សាច់រឿង អ្នកធ្វើការកត់ត្រានូវអ្វីដែលគួរកែលម្អនៅក្នុងសាច់រឿងដែលគាត់រៀបរាប់។

## ផ្នែកទី៦ៈ សាច់រឿងស្តីពីជីវិតនៅក្នុងមូលដ្ឋានយោធាខ្មែរក្រហម (១៩៧៩ ~ ១៩៨៩)

ការណែនាំៈ ចូរអានសាច់រឿងខាងក្រោម។ បន្ទាប់ពីបានអានរឿងនីមួយៗ សូមសង្ខេបសាច់រឿងនៅក្នុងចន្លោះដែលបានផ្តល់ឲ្យ។ សូមព្យាយាមធ្វើឲ្យសេចក្តីសង្ខេបរបស់អ្នកមិនលើសពីមួយ ឬពីរប្រយោគ នៅពេលដែលធ្វើការសង្ខេបរួចរាល់ នឹងហៅឲ្យរៀបរាប់សាច់រឿងមួយ ឬពីរទៅកាន់ដៃគូរបស់អ្នក។

សាច់រឿងទី១ៈ កងទ័ពវៀតណាមបានបាញ់គ្រាប់ផ្លោងចូលទៅក្នុងភូមិនៅលើភ្នំ ដោយបង្កឲ្យមានការស្លាប់មនុស្សជាច្រើន។ សំ ភីន គឺជាអតីតអ្នកកាន់ឃ្លាំង តាម៉ុក និងជាជនពិការដោយសារគ្រាប់មីន។ សំ ភីន ដែលធ្លាប់រស់នៅលើភ្នំ ១០០៣ បានរៀបរាប់ពីជីវិតរស់នៅបែបចល័តរបស់គាត់ថាៈ

> «កងទ័ពវៀតណាមវាយប្រហារយើង នៅពេលដែលកងទ័ពវៀតណាមស៊ើបដឹងពីទីតាំងរបស់យើង។ មនុស្សស្លាប់ត្រូវទុកចោល ហើយអ្នកនៅរស់បន្តធ្វើដំណើរទៅមុខទៀតដើម្បីស្វែងរកទីតាំងថ្មី។ យើងតែងតែទុកចានឆ្នាំងនៅក្នុងបង្វេចរបស់យើងជាប្រចាំ ហើយយើងតែងតែប្រុងប្រយ័ត្នជាប់ជានិច្ច។ យើងមិនអនុញ្ញាតឲ្យកូនចៅទៅឆ្ងាយពីយើងទេ ដោយសារតែខ្លាចបែកគ្នានៅពេលមានការប្រយុទ្ធកើតឡើង។ ការធ្វើបែបនេះបានក្លាយទៅជាទម្លាប់របស់យើងទៅហើយ។ បន្ទាប់ពីហូបបាយរួច យើងតែងតែរៀបចំឆ្នាំងចានចូលក្នុងបង្វេចវិញ។ ជាទូទៅ ការវាយប្រហារកើតមានឡើងស្ទើររាល់ថ្ងៃ។»

### សេចក្តីសង្ខេបរបស់អ្នកៈ

សាច់រឿងទី២ៈ កងដឹកជញ្ជូននារីបានចូលរួមចំណែកយ៉ាងច្រើននៅក្នុងកិច្ចខំប្រឹងប្រែងផ្នែកយោធារបស់ខ្មែរ ក្រហម។ កងនារីទាំងនោះត្រូវបានបញ្ជូនទៅកាន់តំបន់ផ្សេងៗនៅតាមព្រំដែន ដើម្បីចាត់ចែងការដឹកជញ្ជូនស្បៀងអាហារ គ្រាប់មីន និងគ្រឿងសព្វាវុធទៅឲ្យកងទ័ពនៅសមរភូមិមុខ។ ឡាច ថៃ ដែលជាអតីតនារីម្នាក់រូបនៅក្នុងកងដឹកជញ្ជូននារី បានរំឭកពីបទពិសោធន៍របស់គាត់ នៅក្នុងការដឹកជញ្ជូនគ្រឿងសព្វាវុធទៅឲ្យកងទ័ពនៅសមរភូមិមុខថាៈ

> «កម្លាំងរបស់យើងស្ថិតនៅក្នុងមូលដ្ឋានដាំស្លានៃទឹកដីថៃ។ នៅពេលមានកិច្ចការអ្វីមួយ យើងធ្វើដំណើរទៅព្រំដែន។ ក្រុមរបស់ខ្ញុំមានសមាជិកពី៥០ទៅ១០០នាក់ ដើម្បីដឹកជញ្ជូនគ្រឿងសព្វាវុធទៅឲ្យកងទ័ពនៅសមរភូមិមុខ។ មេកងរបស់ខ្ញុំឈ្មោះ ភួន និងផាត។ នៅក្នុងអំឡុងពេលនៃការដឹកជញ្ជូនគ្រឿងសព្វាវុធ យើងតែងតែពើបប្រទះជាមួយកងទ័ពវៀតណាម ដែលយាមល្បាតនៅតាមព្រំដែន។ យើងរត់គេចខ្លួនពីកងទ័ពវៀតណាម។ យើងអាចដើរតាមធម្មតាវិញ នៅពេលចេញឆ្ងាយពីកងយាមល្បាតរបស់វៀតណាម។ នេះគឺជាការងារដ៏លំបាក។ នៅពេលមួយនោះ កងទ័ពវៀតណាមបានបំផ្ទុះមីនចង្កោម សម្លាប់កងនារីដឹកជញ្ជូនអស់១២នាក់។ យើងបានរត់បែកផ្លូវគ្នាទៅគ្រប់ទិស។ យើងបានចំណាយពេលពីរអាទិត្យទម្រាំរកគ្នាឃើញវិញ។ មនុស្សមួយចំនួនទៀតបានស្លាប់ដោយសារគ្រុនបួស និងដាច់បាយ។ នៅពេលនោះ យើងមិនអាចរកអាហារហូបបានទេ។ ជីវិតនៅពេលនោះពោរពេញទៅដោយទុក្ខវេទនា។»

### សេចក្តីសង្ខេបរបស់អ្នកៈ

សាច់រឿងទី៣ៈ ប្រជាជននៅក្នុងជំរំយោធាធ្វើចម្រូង។ ប៉ិល សារ៉ាត់ ដែលជាអតីតខ្មែរក្រហមនៅភ្នំ១០០៣ បានរំឭកពីបទពិសោធន៍នៅពេលធ្វើការក្រោមការគ្រប់គ្រងផ្ទាល់ពី តាម៉ុក ក្នុងការធ្វើចម្រូងនិងដាក់មីនៈ

> «ខ្ញុំធ្វើការនៅក្នុងកងនារី។ សមមិត្តនារី ស៊ុប ជាប្រធានកង។ ក្រុមរបស់ខ្ញុំដែលត្រូវបានស្គាល់ថាជាកងរបស់យាយ តុង ត្រូវបានបញ្ជូនឲ្យទៅច្រកជប់រុន។ ក្រុមរបស់ខ្ញុំមានគ្នាប្រមាណ៣០នាក់ ដែលសុទ្ធតែនៅលីវ។ បន្ទាប់ពីខ្ញុំរៀបការនៅឆ្នាំ១៩៨៦ ខ្ញុំបានចេញពីកងនេះ ហើយទៅរស់នៅជាមួយប្តីនៅកងពល៧៨៥។ ប្រពន្ធរបស់កងពលធ្វើការងារបិតចម្រូង និងដឹកចម្រូងដាក់រទេះទៅឲ្យកងទ័ពនៅសមរភូមិមុខ។ ចម្រូងមួយដើមមានប្រវែងប្រហែលមួយហត្ថ។ ខ្ញុំក៏ធ្លាប់លាបថ្នាំពុលនៅចុងចម្រូងដែរ។ កងទ័ពបានផ្តល់ឲ្យយើងនូវសារធាតុពុលទាំងនោះ។ខ្ញុំពេញចិត្តខ្លាំងណាស់ក្នុងការធ្វើជាយុទ្ធនារី។ខ្ញុំពិតជាពេញចិត្តក្នុងការដឹកជញ្ជូនមីន។ ខ្ញុំមិនខ្លាចមីនទេ។ យើងបានរាយមីននៅតាមតំបន់ដែលយើងឃើញមានពួកចារកម្មយួនឆ្លងកាត់។»

### សេចក្តីសង្ខេបរបស់អ្នកៈ

សាច់រឿងទី៤៖ ឱ សារ៉ាត បានដើរជាន់មីន និងបានបាត់បង់ជើងម្ខាង នៅពេលដែលគាត់ដឹកជញ្ជូនគ្រាប់ទៅឲ្យកងទ័ពនៅសមរភូមិមុខ នៅឆ្នាំ១៩៨៧។ សារ៉ាត បានរំឭកពីបទពិសោធន៍របស់គាត់ថា៖

«ផ្លូវធ្វើដំណើរនៅលើភ្នំដើម្បីដឹកជញ្ជូនគ្រាប់ទៅសមរភូមិមុខ មានសភាពតូចចង្អៀតណាស់។ ផ្លូវនេះមានទទឹងតែកន្លះម៉ែត្រតែប៉ុណ្ណោះ ហើយជាផ្លូវតែមួយគត់ទៅកាន់សមរភូមិមុខ។ នៅពេលខ្ញុំទៅដល់សមរភូមិ ហើយប្រគល់គ្រាប់ឲ្យកងទ័ពចប់សព្វគ្រប់ ខ្ញុំក៏ត្រឡប់មកវិញ។ នៅតាមផ្លូវត្រឡប់មកវិញ ខ្ញុំបានឃើញស្ត្រីចំណាស់ៗ ស្ពាយគ្រាប់ធំៗ ហើយធ្ងន់ៗនៅលើខ្នង។ ខ្ញុំបានជៀសទៅម្ខាង ដើម្បីទុកផ្លូវឲ្យស្ត្រីចំណាស់ៗទាំងនោះដើរ។ ជាអកុសល មួយជំហានរបស់ខ្ញុំចេញពីផ្លូវ ជាន់ចំគ្រាប់មីន។ នៅពេលដែលគ្រាប់មីននោះផ្ទុះឡើង មិនត្រឹមតែជើងម្ខាងរបស់ខ្ញុំត្រូវដាច់នោះទេ ក្បាលប្រុសរបស់ខ្ញុំក៏រងរបួសដោយសារអំបែងតូចៗដែរ។ ខ្ញុំចាំថា ខ្ញុំបានប្រាប់ស្ត្រីចំណាស់ៗទាំងនោះកុំឲ្យដើរទៅក្នុងព្រៃ ប្រយ័ត្នជាន់ត្រូវគ្រាប់មីន។ ប៉ុន្តែខ្ញុំនឹកស្មានមិនដល់ថា មីនត្រូវបានកប់នៅក្បែរផ្លូវដើរដ៏តូចនោះសោះ។ មិនតែប៉ុណ្ណោះ ខ្មែរក្រហមគ្នាឯងជាអ្នកដាក់មីននោះទៅទៀត។ នៅពេលដែលខ្ញុំដួលនៅលើដី ខ្ញុំបានក្រឡេកមើលជុំវិញខ្លួនខ្ញុំ ហើយបានឃើញមីនជាច្រើនគ្រាប់ទៀត។ ជាសំណាងល្អ ខ្ញុំបានដួលនៅលើផ្លូវដើរ។ បើមិនដូច្នោះទេ ខ្លួនរបស់ខ្ញុំទាំងមូលប្រហែលជាត្រូវមីនកម្ទេចអស់ទៅហើយ។ ខ្ញុំត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យនៅលើភ្នំដងរែក។»

## សេចក្តីសង្ខេបរបស់អ្នក៖

សាច់រឿងទី៥៖ ពិធីមង្គលការច្រើនគូ ដែលជារឿងធម្មតានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានបន្តប្រារព្ធ ឡើងមួយរយៈនៅលើភ្នំ ១០០៣។ ដោយធ្លាប់បានរៀបការនៅលើភ្នំ១០០៣ ហាប់ ហេន បាននិយាយថា «នៅពេលនោះយើងមិនដឹងថាស្នេហាមានន័យយ៉ាងម៉េចទេ។ យើងមិនដែលចាប់អារម្មណ៍លើប្រុសៗទេ»។ ហាប់ ហេន បានរំឭកឡើងវិញពីថ្ងៃរៀបមង្គលការរបស់គាត់ថា ៖

«តាញឹម គឺជាចាស់ទុំដែលបានរៀបមង្គលការឲ្យយើង។ ពិធីនេះត្រូវបានរៀបចំធ្វើឡើងនៅប្រហែលម៉ោងបីរសៀល។ នៅថ្ងៃដែលខ្ញុំរៀបការនោះ មាន១១គូ។ នៅពេលនោះ យើងពុំមានតុឬកៅអីទេ។ ទាំងប្រុសទាំងស្រីនាំគ្នាអង្គុយនៅលើអង្កត់ឈើ ដែលអាចរកបាននៅក្បែរនោះ។ នៅក្នុងពិធីមង្គលការ ប្រធានកងបានប្រកាសថា យើងទាំងពីរនាក់បានក្លាយទៅជាប្តីប្រពន្ធនិងបានណែនាំយើងឲ្យប្រឹងប្រែងធ្វើការងារ និងមិនត្រូវរត់ចោលចលនាខ្មែរក្រហមឡើយ។ យើងបានទះដៃអបអរសាទរ។ បន្ទាប់មក មានការរៀបចំពិធីជប់លៀងតូចមួយ ដោយមានម្ហូបអាហារដូចជា គុយទាវ ត្រីខកំប៉ុង ទឹកដោះគោ និងនំចិនជាដើម។ នេះគឺជាពិធីរៀបមង្គលការរបស់យើងនៅពេលនោះ។»

## សេចក្តីសង្ខេបរបស់អ្នក៖

## លំហាត់គោល៖

ការណែនាំ៖ ចូរបិទសៀវភៅចំណាយពេលមួយនាទីដើម្បីគិតអំពីសាច់រឿងដែលអ្នកអាចចាំបាន។ សូមធ្វើការជាមួយដៃគូម្នាក់ រៀបរាប់សាច់រឿងឡើងវិញយ៉ាងហោចណាស់ឲ្យបានចំនួនពីរ។ ដៃគូរបស់អ្នកត្រូវបើកសៀវភៅ កត់ត្រាផ្នែកនៃសាច់រឿងដែលអ្នកភ្លេច និយាយខុស ឬគួរតែកែលម្អ។ នៅពេលអ្នករៀបរាប់ចប់ ចូរប្តូរតួនាទីគ្នា៖ ដៃគូរបស់អ្នករៀបរាប់សាច់រឿង អ្នកធ្វើការកត់ត្រានូវអ្វីដែលគួរកែលម្អនៅក្នុងសាច់រឿងដែលគាត់រៀបរាប់។

## ផ្នែកទី៧៖ សាច់រឿងស្តីពីការវិលត្រឡប់របស់ខ្មែរក្រហមមកអន្លង់វែង

ការណែនាំ៖ ចូរអានសាច់រឿងខាងក្រោម។ បន្ទាប់ពីបានអានរឿងនីមួយៗ សូមសង្ខេបសាច់រឿងនៅក្នុងចន្លោះដែលបានផ្តល់ឲ្យ។ សូមព្យាយាមធ្វើឲ្យសេចក្តីសង្ខេបរបស់អ្នកមិនលើសពីមួយ ឬពីរប្រយោគ។ នៅពេលដែលអ្នកបានធ្វើការសង្ខេបរួចរាល់ អ្នកនឹងត្រូវបានហៅឲ្យរៀបរាប់សាច់រឿងមួយ ឬពីរទៅកាន់ដៃគូរបស់អ្នក។

សាច់រឿងទី១៖ នៅពេលដែលវៀតណាមបញ្ចប់ការដកទ័ពរបស់ខ្លួនចេញពីកម្ពុជា កងកម្លាំងខ្មែរក្រហមចាប់ផ្តើមយុទ្ធនាការវាយកាន់កាប់ប្រទេសឡើងវិញ។ កងទ័ពខ្មែរក្រហមបានដណ្តើមកាន់កាប់តំបន់អន្លង់វែងនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៨៩ រយៈពេលពីរខែបន្ទាប់ពីការដណ្តើមកាន់កាប់តំបន់ប៉ៃលិន។ ឌុច សារិត ដែលជាអតីតទាហាននៃកងពល៦១២ បានរំឭកអំពីជ័យជម្នះរបស់ខ្មែរក្រហមទៅលើកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជានៅតំបន់អន្លង់វែងដូចតទៅ៖

«នៅឆ្នាំ១៩៨៥ កងទ័ពវៀតណាមបានវាយកាន់កាប់តំបន់តស៊ូរបស់ខ្មែរក្រហមទាំងអស់នៅលើភ្នំដងរែក។ ខ្មែរក្រហមបានចល័តប្រជាជននិងកងទ័ពទាំងអស់ពីតំបន់តស៊ូរបស់ខ្លួនទៅក្នុងទឹកដីថៃ នៅតំបន់ក្បែរសមរភូមិ។ ខ្មែរក្រហមត្រូវការកងទ័ពដើម្បីវាយរុញច្រានកងទ័ពវៀតណាមឲ្យចេញពីតំបន់ព្រំដែន។ ការប្រយុទ្ធបានកើតឡើងអស់រយៈពេលជាង៤ឆ្នាំ គឺពីឆ្នាំ១៩៨៥ ដល់ ឆ្នាំ១៩៨៩។ នៅចុងឆ្នាំ១៩៨៨ យើងបានរុញច្រានកងទ័ពវៀតណាមចុះពីលើភ្នំដងរែក។ បន្ទាប់ពីបានកាន់កាប់ភ្នំដងរែក យើងចាប់ផ្តើមធ្វើប្រតិបត្តិការនៅតាមបណ្តោយផ្លូវបារាំង (ផ្លូវពីតំបន់អន្លង់វែងទៅកាន់ខេត្តព្រះវិហារ)។ យើងបានវាយប្រហារជាប់ជានិច្ចចាប់ពីឆ្នាំ១៩៨៨ ដល់ឆ្នាំ១៩៨៩។ នៅទីបញ្ចប់ (ឆ្នាំ១៩៨៩) យើងអាចកាន់កាប់តំបន់អន្លង់វែងនិងបានបញ្ជូនប្រជាជនមកតាំងទីលំនៅនៅក្នុងតំបន់នេះ។»

សេចក្តីសង្ខេបរបស់អ្នក៖

សាច់រឿងទី២៖ កែវ ភ័ក្រ បានរំឭកឡើងវិញពីបទពិសោធន៍របស់គាត់នៅអន្លង់វែង បន្ទាប់ពីគាត់ចុះពីជំរំជប់ម្លូនៅដើមឆ្នាំ១៩៩០ ថា៖

«ខ្ញុំខ្លាចគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះខ្លាំងណាស់ ដោយសារតែអន្លង់វែងជាអតីតបន្ទាយកងទ័ពវៀតណាម។ ខ្ញុំបានឃើញការផ្ទុះគ្រាប់ជាច្រើនលើក ដោយបានសម្លាប់មនុស្សអស់ជាច្រើន។ ខ្ញុំមិនហ៊ានធ្វើដំណើរចេញទៅណាក្រៅភូមិរបស់ខ្ញុំឡើយ។ ប្រជាជនខ្លះដីករណ្តៅដាំចេក តែបែរជាជីកប៉ះចំគ្រាប់មីនស្លាប់ចោលកូនទៅវិញ។ នៅអំឡុងពេលនោះ យើងមិនហ៊ានភ្ជួរដីធ្វើស្រែទេ។ ទើបតែប៉ុន្មានឆ្នាំក្រោយមកនេះទេ យើងអាចធ្វើស្រែវិញ។។

សេចក្តីសង្ខេបរបស់អ្នក៖

សាច់រឿងទី៣៖ ទោះបីជាខ្មែរក្រហមបានដណ្តើមកាន់កាប់តំបន់អន្លង់វែងក៏ដោយ ការវាយប្រហារគំរាមកំហែង ពីសំណាក់កងរាជអាវុធហត្ថរបស់រាជរដ្ឋាភិបាលនៅតែបន្តកើតមាន។ ពេលខ្លះ កងរាជអាវុធហត្ថបានវាយចូលតំបន់អន្លង់វែង ហើយកាន់កាប់តំបន់នោះរយៈពេលខ្លី។ ជីវ ចាន់ ដែលជាអតីតនីរសាររបស់ វន វេត(ឧបនាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច) បាននិយាយថា ជីវិតគឺពោរពេញទៅដោយភាពលំបាកវេទនានៅក្នុងជម្លោះឆ្នាំ១៩៩៣ និងឆ្នាំ១៩៩៤ ៖

«ខ្ញុំបានស្ពាយកូននៅពីក្រោយខ្នង ហើយរត់ឡើងភ្នំដងរែក។ ផ្ទះដែលទើបតែសង់ថ្មីរបស់ខ្ញុំ ត្រូវបានដុតបំផ្លាញចោលរាបដល់ដី(ដោយសារខ្មែរក្រហមដែលកំពុងភៀសខ្លួន)។ ផ្ទះនោះនៅសល់តែសំបក។ យើងបានរត់ភៀសខ្លួនទៅប្រទេសថៃ។ ដោយសារតែគ្មានមធ្យោបាយដឹកជញ្ជូន ប្រពន្ធខ្ញុំនិងខ្ញុំបានដឹកគោ និងបានជញ្ជូនកូន និងសម្ភារផ្សេងៗឡើងលើភ្នំ។»

សេចក្តីសង្ខេបរបស់អ្នក៖



លំហាត់គោល (ខេបស្លូន)៖

ការណែនាំ៖ ចូរបិទសៀវភៅចំណាយពេលមួយនាទីដើម្បីគិតអំពីសាច់រឿងដែលអ្នកអាចចាំបាន។ សូមធ្វើការជាមួយដៃគូម្នាក់រៀបរាប់សាច់រឿងឡើងវិញយ៉ាងហោចណាស់ឲ្យបានចំនួនមួយ។ ដៃគូរបស់អ្នកត្រូវបើកសៀវភៅ កត់ត្រាផ្នែកនៃសាច់រឿងដែលអ្នកភ្លេច និយាយខុស ឬគួរតែកែលម្អ។ នៅពេលអ្នករៀបរាប់ចប់ ចូរប្តូរតួនាទីគ្នា៖ ដៃគូរបស់អ្នករៀបរាប់សាច់រឿង អ្នកធ្វើការកត់ត្រានូវអ្វីដែលគួរកែលម្អនៅក្នុងសាច់រឿងដែលគាត់រៀបរាប់។

## ផ្នែកទី៨៖ សាច់រឿងស្តីពី តាម៉ុក នៅតំបន់អន្លង់វែង

ការណែនាំ៖ ចូរអានសាច់រឿងខាងក្រោម។ បន្ទាប់ពីបានអានរឿងនីមួយៗ សូមសង្ខេបសាច់រឿងនៅក្នុងចន្លោះដែលបានផ្តល់ឲ្យ។ សូមព្យាយាមធ្វើឲ្យសេចក្តីសង្ខេបរបស់អ្នកមិនលើសពីមួយ ឬពីរប្រយោគ។ នៅពេលដែលអ្នកបានធ្វើការសង្ខេបរួចរាល់ អ្នកនឹងហៅឲ្យរៀបរាប់សាច់រឿងមួយ ឬពីរទៅកាន់ដៃគូរបស់អ្នក។

សាច់រឿងទី១៖ គឹម ណន អតីតទាហាននៃកងពល៧៨៥ យល់ឃើញថា តាម៉ុក គឺជាមនុស្សម្នាក់ដែលពិបាកក្នុងការពណ៌នា៖

«ការរៀបរាប់ពីចរិតលក្ខណៈរបស់ តា ម៉ុកគឺជារឿងលំបាកណាស់។ តាម៉ុក មិនដែលធ្វើខ្លួនឲ្យខុសពីប្រជាជនសាមញ្ញទេ។ នៅពេល តាម៉ុក ជួបជាមួយនរណាម្នាក់ គាត់ជេរស្តីគេយ៉ាងខ្លាំង។ ក្រោយមក តាម៉ុក នឹងឲ្យរបស់របរដែលគាត់មានទៅឲ្យអ្នកនោះ។ ថ្ងៃមួយ ខ្ញុំនិងមិត្តរបស់ខ្ញុំបានទៅបើកអង្ករនិងអាហារនៅឃ្លាំង។ យើងបានយកកាំភ្លើងទៅជាមួយដែរ។ នៅពេលដែលយើងកំពុងបើករបបអាហារ ឡានហ្ស៊ីបរបស់តាម៉ុក បានមកដល់។ តាម៉ុក បានសួរយើងថា «សុខសប្បាយទេ អាក្មេងៗ? ពួកហ្អែងទៅណា?» ខ្ញុំបានឆ្លើយថា «បាទ តា! ពួកខ្ញុំមកបើកអង្ករនិងអាហារ»។ គាត់បានសួរថា «យ៉ាងម៉េចហើយការប្រយុទ្ធនៅសមរភូមិមុខ? ប្រសិនបើខ្មាំងចូលមកបាន អញនឹងសម្លាប់ពួកហ្អែងចោល។ ពួកហ្អែងនេះដូចអាចម៍អីចឹង»។ បន្ទាប់មក តាម៉ុក បានយកឈើច្រត់មកវាយក្បាលខ្ញុំ។ ក្រោយមក តាម៉ុក បានដើរចូលទៅក្នុងឃ្លាំងបាត់ ហើយបានស្តីឲ្យអ្នកយាមឃ្លាំងទៀត។ តាម៉ុក បានបញ្ជាអ្នកយាមឃ្លាំងបន្ថែមរបបអាហារឲ្យយើងថែមទៀត។ តាម៉ុក បាននិយាយថា យើងហូបមិនឆ្អែតទេ សម្រាប់របបអាហារដូចរាល់ដងនេះ។»

សេចក្តីសង្ខេបរបស់អ្នក៖

សាច់រឿងទី២៖ ឯម អឿន ប្រជាជនមួយរូបនៅស្រុកអន្លង់វែង ពណ៌នាចរិតលក្ខណៈរបស់ តាម៉ុក ថា ៖

«តាម៉ុក គឺជាមនុស្សល្អ។ តាម៉ុក មិនមានកម្មសិទ្ធិផ្ទាល់ខ្លួនទេ។ តាម៉ុក មិនដែលអនុញ្ញាតឲ្យសាច់ញាតិឬកូនចៅរបស់គាត់យកទ្រព្យសម្បត្តិរបស់សហគមន៍ឡើយ។ តាម៉ុក រស់នៅសាមញ្ញដូចប្រជាជនដែរ។ តាម៉ុក ជាមនុស្សមាត់ឆៅ ស្មោះត្រង់ និង

ស្រឡាញ់ប្រជាជនណាស់។ តាម៉ុក បែងចែករបបអង្ករដល់ប្រជាជនស្មើៗគ្នា ដោយមិនប្រកាន់ឋានៈ ឬតួនាទីឡើយ។ ប្រសិនបើគ្មានតាម៉ុក ប្រជាជនទាំងអស់ប្រហែលជាស្លាប់ និងគ្មានអាហារហូបទេ។ មេដឹកនាំខ្មែរក្រហមដទៃមិនអនុញ្ញាតឲ្យយើងដឹង សូម្បីតែដំណើរនិងទីតាំងដែលមេដឹកនាំទាំងនោះរស់នៅ ។»

## សេចក្ដីសង្ខេបរបស់អ្នក៖

សាច់រឿងទី៣៖ លី បាននិយាយរៀបរាប់ពីបទពិសោធន៍របស់គាត់នៅក្រោមការដឹកនាំរបស់ តាម៉ុក ថា៖

«ខ្ញុំមិនកាន់ជើងខាងណាទេ។ ខ្ញុំនិយាយតាមតែអ្វីដែលខ្ញុំបានមើលឃើញ។ រាល់ពេលដែលយើងខ្វះអង្ករ លុយ ឬថ្នាំសង្កូវ តាម៉ុក ជាអ្នកជួយយើង។ ខ្ញុំមិនដឹងថា ខ្ញុំខឹងនឹង តាម៉ុក យ៉ាងម៉េចកើត។ តាម៉ុក មិនដែលធ្វើបាបខ្ញុំផង។ គាត់ថែមទាំងធ្លាប់ឲ្យខ្ញុំ ២០០០បាត ដើម្បីទិញជ្រូកនិងមាន់មកចិញ្ចឹមទៀតផង។»

## សេចក្ដីសង្ខេបរបស់អ្នក៖

សាច់រឿងទី៤៖ តឿក, សុខ, ធួន និងចាន់ណា បានរៀបរាប់ពីការយល់ឃើញរបស់ខ្លួនចំពោះ តា ម៉ុក ថា៖

តឿក៖ «តាម៉ុក មិនចាត់ទុកមនុស្សស្មើនឹងសត្វឆ្កែរបស់គាត់ផង។ ការពិតនោះគឺថាឆ្កែមានរបស់ស៊ីឆ្ងាញ់ជាងមនុស្សទៅទៀត»។

សុខ៖ «តាម៉ុក មានចរិតពីរ ពេលខ្លះគាត់ស្លូតបូត ពេលខ្លះទៀតគាត់កាច។ តាម៉ុក ហ្នឹងកាចមែន។ តែ តាម៉ុក ឲ្យរបស់យើងហូប។ ប្រសិនបើយើងសុំអីពី តាម៉ុក គាត់នឹងឲ្យរបស់នោះមកយើង។ អ្នកផ្សេងគ្មាននរណាឲ្យអីយើងហូបទេ»។

ធួន៖ «ប្រជាជនមិនដាច់បាយហូបនោះទេ។ តាម៉ុក ជួយប្រជាជន។ ប្រជាជនមិនខ្វះអីហូបទេ ... តែប្រសិនបើយើងនិយាយពីការអភិវឌ្ឍវិញ បច្ចុប្បន្ននេះមានលក្ខណៈប្រសើរជាងកាលពីជំនាន់នោះ»។

ចាន់ណា៖ «កាលពីមុន តាម៉ុក គឺជាអ្នកផ្គត់ផ្គង់យើង។ ប៉ុន្តែ ការទំនុកបម្រុងបែបនោះមិនអាចមាននិរន្តរភាពបានឡើយ»។

## សេចក្ដីសង្ខេបរបស់អ្នក៖

## ផ្នែកទី៩៖ សាច់រឿងស្ដីពីការពិនិត្យមើលតំបន់អន្លង់វែងឡើងវិញ

ការណែនាំ៖ ចូរអានសាច់រឿងខាងក្រោម។ បន្ទាប់ពីបានអានរឿងនីមួយៗ សូមសង្ខេបសាច់រឿងនៅក្នុងចន្លោះដែលបានផ្ដល់ឲ្យ។ សូមព្យាយាមធ្វើឲ្យសេចក្ដីសង្ខេបរបស់អ្នក មិនលើសពី មួយ ឬពីរប្រយោគ នៅពេលដែលធ្វើការសង្ខេបរួចរាល់ នឹងហៅឲ្យរៀបរាប់សាច់រឿងមួយ ឬពីរទៅកាន់ដៃគូរបស់អ្នក។



អ៊ំស្រី ច្រឹង យៀង ជាអតីតជនរងគ្រោះក្នុងរបបខ្មែរក្រហម ដែលសព្វថ្ងៃគាត់មាន ទីលំនៅនៅជ្រោយតាកែវ ស្រុកកោះធំ។ នៅពេលដែលគាត់កំពុងធ្វើទស្សនកិច្ចនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១១ គាត់មានការរំជួលចិត្តយ៉ាងខ្លាំងដោយសាររូបថតនៅទីនោះ។ នៅពេលដែលអ៊ំស្រីបានឃើញរូបថតរបស់បងប្រុសរបស់គាត់ អ៊ំស្រី យៀង បានយំនិងមានអារម្មណ៍ពិបាកចិត្តជាទម្ងន់ ដោយសារបងប្រុសរបស់អ៊ំស្រីត្រូវបានខ្មែរក្រហមធ្វើទារុណកម្មនិងសម្លាប់ដោយការជ្រមុជទឹក។ កម្មាភិបាលខ្មែរក្រហមដែលនៅទីនោះ បានដកក្រចកដៃក្រចកជើងនិងចាក់ទម្លុះបំពង់ករបស់គាត់។ អ៊ំស្រី យៀង នៅតែមានកំហឹងចំពោះអ្នកដែលបានសម្លាប់បងប្រុសរបស់គាត់។ គាត់ចង់ឲ្យតុលាការខ្មែរក្រហមដាក់ទោសប្រហារជីវិតដល់មេដឹកនាំខ្មែរក្រហមទាំងអស់។
ថតដោយ ម៉ម កល្យាណី, បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ទស្សនៈទី១៖ អ៊ឹម ឡុត «ក្រឡេកមើលក្រោយវិញនូវអ្វីដែលបានកើតឡើងនៅពេលនោះ ខ្ញុំគិតថា ខ្ញុំដើរតាមអង្គការ។ ក្រោយមកខ្ញុំបានគិតដល់ការផ្សះផ្សា។ ខ្ញុំបានដឹងថា អ្វីៗដែលបានកើតឡើងកន្លងមកគឺមិនត្រឹមត្រូវទេ។ ទីមួយ វាបានបំផ្លាញប្រទេសជាតិរបស់ខ្ញុំ ហើយទីពីរ វាបានបំផ្លាញខ្លួនខ្ញុំផ្ទាល់។ ចុងបញ្ចប់ ខ្ញុំបានក្លាយជាជនពិការ និងធ្វើស្រែចម្ការ។ នេះគឺជាការយល់ឃើញរបស់ខ្ញុំ។ នៅពេលយើងដឹកនាំ យើងគិតថាការដឹកនាំនោះគឺជាទង្វើត្រឹមត្រូវ។ ប៉ុន្តែ បន្ទាប់ពីសមាហរណកម្ម ខ្ញុំបានគិតពីរឿងនេះម្ដងទៀត។ ខ្ញុំមានការសោកស្ដាយយ៉ាងខ្លាំង។មនុស្សមួយចំនួនបានប្រព្រឹត្តអំពើមិនល្អប៉ុន្តែមនុស្សទាំងនោះអាចកែខ្លួនបាន (មនុស្សទាំងនោះអាចក្លាយជាមនុស្សថ្មី)។ ប៉ុន្តែ សម្រាប់ជនពិការដូចរូបខ្ញុំ ខ្ញុំមិនមានអ្វីនៅសេសសល់ទៀតទេ។ អ្វីដែលខ្ញុំបានធ្វើកន្លងមក គឺដើម្បីការពារប្រទេសជាតិរបស់ខ្ញុំ។ ប៉ុន្តែ ឥឡូវ ខ្ញុំបានភ្ញាក់ខ្លួន និងយល់ឃើញថាខ្ញុំគឺជាជនរងគ្រោះ»។

## សេចក្ដីសង្ខេបរបស់អ្នក៖

ទស្សនៈទី២៖ រឿម រ៉ែម «ការធ្វើជំនួញនាពេលបច្ចុប្បន្នខុសប្លែកឆ្ងាយណាស់ពីជំនាន់តាម៉ុក។ នៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក យើងរស់នៅជាសហគមន៍។ យើងជួយគ្នាទៅវិញទៅមកទោះបីជាយើងឈឺក៏ដោយ។ យើងកម្រឈ្លោះប្រកែកគ្នាណាស់។ បច្ចុប្បន្ន នៅពេលដែលប្រជាជនធ្វើជំនួញ ប្រជាជនទាំងនោះគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួនជាមុន»។

## សេចក្តីសង្ខេបរបស់អ្នក៖

ទស្សនៈទី៣៖ កង សារ៉ាយ «ខ្ញុំសោកស្តាយណាស់ នៅពេលដែលរឿងរ៉ាវគ្រប់យ៉ាងបានបញ្ចប់ទៅ។ ខ្ញុំគ្មានអ្វីទាំងអស់។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ឲ្យខ្ញុំនូវទឹកប្រាក់ចំនួនបីលានរៀល នៅពេលខ្ញុំចូលនិវត្តន៍។ ខ្ញុំបានយកប្រាក់នោះទៅសងបំណុលអស់។ ចំណែកឯប្រាក់នៅសល់មួយចំនួន ខ្ញុំបានចំណាយទៅលើការព្យាបាលជំងឺ។ មន្ត្រីផ្នែកសង្គមកិច្ចបានសន្យាថា រដ្ឋនឹងចែកដីឲ្យខ្ញុំ។ ប៉ុន្តែ តើដីនោះនៅឯណា? ខ្ញុំមិនមានអ្វីទាំងអស់។ ខ្ញុំមិនខុសពីលោកសង្ឃដែលទើបនឹងសឹកឡើយ»។

## សេចក្តីសង្ខេបរបស់អ្នក៖

ទស្សនៈទី៤៖ ប៊ូចាន់ណា «ខ្ញុំមិនដែលបានជួបសាច់ញាតិរបស់ខ្ញុំនៅខេត្តរតនគីរីតាំងពីខ្ញុំអាយុ១២ឆ្នាំមកម្ល៉េះ។ ឥឡូវនេះ ខ្ញុំមានអាយុ៥៥ឆ្នាំហើយ។ ខ្ញុំមិនចាំមុខសាច់ញាតិរបស់ខ្ញុំនោះទេ នៅពេលដែលខ្ញុំជួបសាច់ញាតិនៅឆ្នាំ២០១០។ សាច់ញាតិរបស់ខ្ញុំបានដុតជ្រូកមួយក្បាល ដើម្បីទទួលស្វាគមន៍ខ្ញុំ។ សាច់ញាតិថែមទាំងឲ្យលុយ មួយចំនួនថែមទៀតផង។ ខ្ញុំមិនអាចចាំបានថា នរណាជានរណានោះទេ។ ប៉ុន្តែសាច់ញាតិបានរៀបរាប់សាច់រឿងកាលពីកុមារភាព ដើម្បីជួយឲ្យខ្ញុំនឹកឃើញឡើងវិញថាសាច់ញាតិទាំងនោះត្រូវជាអ្វីនឹងខ្ញុំ។ ខ្ញុំបានសុំទោសសាច់ញាតិចាស់ទុំរបស់ខ្ញុំ ព្រោះខ្ញុំមិនអាចចំណាំគាត់បាន។ ប៉ុន្តែ សាច់ញាតិយល់ឃើញថា នេះគឺដោយសារតែខ្ញុំចាកចេញពីភូមិតាំងពីនៅតូចពេក។ ម្តាយរបស់ខ្ញុំបានជួយរំឭកឲ្យខ្ញុំចាំពូ មីង និងជីដូនជីតារបស់ខ្ញុំ។ ខ្ញុំបានចំណាយពេលពីរបីថ្ងៃ ស្នាក់នៅផ្ទះរបស់គាត់ម្នាក់ម្តងៗ។ នៅពេលខ្ញុំបានជួបមុខគាត់ ខ្ញុំទប់ទឹកភ្នែកមិនបាន។ ខ្ញុំមានអារម្មណ៍មិនដាច់អាល័យផង និងអាណិតខ្លួនឯងផង។ ខ្ញុំទទួលរងការឈឺចាប់អស់ជាច្រើនឆ្នាំ ដោយមិនទទួលបានភាពកក់ក្តៅពីឪពុកម្តាយសោះ»។

## សេចក្តីសង្ខេបរបស់អ្នក៖



## លំហាត់គោល៖

ការណែនាំ៖ ចូរបិទសៀវភៅចំណាយពេលមួយនាទីដើម្បីគិតអំពីសាច់រឿងដែលអ្នកអាចចាំបាន។ សូមធ្វើការជាមួយដៃគូម្នាក់រៀបរាប់សាច់រឿងឡើងវិញយ៉ាងហោចណាស់ឲ្យបានចំនួនមួយ។ ដៃគូរបស់អ្នកត្រូវបើកសៀវភៅ កត់ត្រាផ្នែកនៃសាច់រឿងដែលអ្នកភ្លេច និយាយខុស ឬគួរតែកែលម្អ។ នៅពេលអ្នករៀបរាប់ចប់ ចូរប្តូរតួនាទីគ្នា៖ ដៃគូរបស់អ្នករៀបរាប់សាច់រឿង អ្នកធ្វើការកត់ត្រានូវអ្វីដែលគួរកែលម្អនៅក្នុងសាច់រឿងដែលគាត់រៀបរាប់។




ទំព័រមួយនៅក្នុងសៀវភៅពុម្ពរបស់ខ្មែរក្រហម ដែលបង្ហាញពីកងធ្វើចម្រូងរបស់ខ្មែរក្រហមនៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។



ពន្លាមួយ ដែលនៅក្បែរផ្ទះមាត់បឹងរបស់ តាម៉ុក។ ថតដោយ គ្រីស្តូហ្វ័រ ឌៀរីង, បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

# ជំពូកទី៣
# ទីតាំងប្រវត្តិសាស្ត្រ

## ផ្នែកទី១៖ សេចក្តីផ្តើម

ផ្នែកមួយដ៏សំខាន់នៃដំណើរទស្សនកិច្ច គឺបទពិសោធន៍ក្នុងការសិក្សាស្វែងយល់។ តួនាទីរបស់មគ្គុទ្ទេសក៍ ឬគ្រូបង្រៀន គឺជួយសម្របសម្រួលក្នុងការទទួលបានបទពិសោធន៍ ប៉ុន្តែមិនមែនដាក់កំហិតឡើយ។ ដូច្នេះ ខណៈពេលដែលការផ្តល់ព័ត៌មានទៅកាន់ភ្ញៀវទេសចរ និងសិស្សានុសិស្សមានសារៈសំខាន់ ការផ្តល់ពេលវេលាឲ្យភ្ញៀវនិងសិស្សស្វែងយល់ពីទិដ្ឋភាពជុំវិញ ក៏មានសារៈសំខាន់ដូចគ្នា។ ផ្នែកមួយនៃដំណើរទស្សនកិច្ចមិនបានរៀបរាប់នៅក្នុងសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ប៉ុន្តែទោះជាយ៉ាងណាក្តី វានៅតែជាផ្នែកមួយ ដែលសង្កត់ធ្ងន់ក្នុងកម្មវិធីសិក្សារបស់គ្រូបង្រៀន ឬមគ្គុទ្ទេសក៍ទេសចរណ៍។

ជំពូកទី៣ នឹងផ្តល់នូវព័ត៌មានសង្ខេបជាមូលដ្ឋាន ដែលអ្នកសម្របសម្រួលអាចជម្រាបជូនភ្ញៀវរបស់ខ្លួនបាន មិនបានដាក់បញ្ចូលនូវបញ្ជីរាយទីតាំងប្រវត្តិសាស្ត្រទាំងអស់ ដែលភ្ញៀវអាចមកទស្សនាបាននៅតំបន់អន្លង់វែងទេ ប៉ុន្តែវាផ្តល់ជាចំណុចចាប់ផ្តើមដ៏ល្អមួយសម្រាប់មគ្គុទេសក៍ ឬគ្រូបង្រៀនដែលមិនស្គាល់ទីតាំង។ សកម្មភាពដែលរៀបរាប់នៅជំពូកទី៣ មានបំណងជួយអ្នកសម្របសម្រួលឲ្យយល់ដឹងកាន់តែច្បាស់ពីទីតាំងប្រវត្តិសាស្ត្រនីមួយៗ។ យើងសូមលើកទឹកចិត្តឲ្យមានការអនុវត្ត ក៏ដូចជាការសិក្សាស្រាវជ្រាវបន្ថែមពីទីតាំងប្រវត្តិសាស្ត្រនៅអន្លង់វែង។

## ផ្នែកទី២៖ ទីតាំងប្រវត្តិសាស្ត្រ

### សកម្មភាពទី១៖ ការអាន និងកត់ត្រា

ការណែនាំ៖ ចូរអានការពិពណ៌នានិងប្រវត្តិស្តីពីទីតាំងខាងក្រោម។ បន្ទាប់ពីអានព័ត៌មានខាងក្រោមរួច ចូរអ្នកគូសពីក្រោមឬកត់ត្រាទុកនូវចំណុច ឬព្រឹត្តិការណ៍ដែលសំខាន់និងគួរឲ្យចាប់អារម្មណ៍ នៅចន្លោះដែលបានផ្តល់ឲ្យខាងក្រោម។

### ១. កន្លែងបូជាសព ប៉ុល ពត

ទីតាំងបូជាសពប៉ុល ពត ស្ថិតនៅលើផ្ទៃដីទំហំ១,២០៧ហិកតា ដែលមានចម្ងាយ១៣គីឡូម៉ែត្រពីរង្វង់មូលស្រុកអន្លង់វែង នៅតាមបណ្តោយផ្លូវជាតិ៦៧ នៅជាប់ច្រកព្រំដែនកម្ពុជា-ថៃ នៅជាំសាងាំ។ ទីតាំងបូជាសពនេះស្ថិតនៅលើភ្នំដងរែក ក្នុងភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

ប៉ុល ពត ស្លាប់នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ដោយជំងឺគាំងបេះដូង។ អ្នកកាសែតអាមេរិកឈ្មោះ ណេត ថាយើរ៍ បានផ្តល់ថ្នាំសម្រាប់ចាក់ដើម្បីរក្សាសាកសពរយៈពេលពីរបីថ្ងៃ។ អ្នកកាសែតអន្តរជាតិជាច្រើនបានធ្វើដំណើរទៅដល់ទីនោះដើម្បីថតរូបសព និងធ្វើសេចក្តីរាយការណ៍ពីការស្លាប់របស់មេដឹកនាំខ្មែរក្រហមរូបនេះ។ ក្រុមអ្នកកាសែតមានចម្ងល់ថាហេតុអ្វីបានជាសាកសពរបស់ ប៉ុល ពត មានសក់ពណ៌ខ្មៅ។ នៅពេលដែល ប៉ុល ពត ត្រូវបានកាត់ទោសកាលពីមួយឆ្នាំមុន នាខែមីនា ឆ្នាំ១៩៩៧ ប៉ុល ពត មានសក់ស្កូវ។ ប្រពន្ធ ប៉ុល ពត បានឆ្លើយប្រាប់ទៅអ្នកកាសែតវិញថា៖ «ខ្ញុំបានលាបសក់ឲ្យគាត់ ដើម្បីក្លែងបន្លំភៀសខ្លួនទៅជំរំភូណយក្នុងដីថៃ ដែលជាជំរំចុងក្រោយរបស់ខ្មែរក្រហមនៅក្នុងខេត្តស៊ីសាកេត»។

បន្ទាប់មក អ្នកកាសែតបានយកសក់ ប៉ុល ពត ដើម្បីធ្វើកោសល្យវិច្ច័យ។ លទ្ធផលគឺដូចអ្វីដែលប្រពន្ធរបស់ ប៉ុល ពត បាននិយាយមែន។ សពរបស់ ប៉ុល ពត ត្រូវបានបូជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៨ នៅវេលាម៉ោង១០ព្រឹក ដែលស្ថិតនៅចម្ងាយប្រហែល១០ម៉ែត្រពីផ្ទះខ្ទមរបស់គាត់។ គ្មាននរណាម្នាក់ចូលរួម ក្រៅតែពីយោធាខ្មែរក្រហមឡើយ។ ដោយសារនាពេលនោះ កងកម្លាំងរាជរដ្ឋាភិបាលកំពុងវាយសម្រុកចូលយ៉ាងខ្លាំង ហើយយោធាខ្មែរក្រហមភាគច្រើនរត់គេចពីតំបន់នោះ។ យោធាដែលនៅសេសសល់មិនអាចរកអុសឲ្យបានគ្រប់គ្រាន់ដើម្បីបូជាសពបាននោះទេ។ យោធាទាំងនោះបានប្រមូលកៅអីឫស្សី សាឡុង និងកៅអីធ្វើពីផ្តៅ ព្រមទាំងកង់ឡានចាស់ៗ ដាក់ដុតជាមួយគ្នា។ យោធាខ្មែរក្រហមទាំងនោះមិនបានរើសឆ្អឹងទុកនោះទេ។ ឆ្អឹងទាំងអស់ត្រូវទុកចោលនៅកន្លែងដុតសពនោះតែម្តង។

ព្រឹត្តិការណ៍សំខាន់៖



សាកសពរបស់ ប៉ុល ពត ត្រូវបានបូជានៅទីកន្លែងនេះ ក្នុងខែមេសា ឆ្នាំ១៩៩៨ មានទីតាំងស្ថិតនៅបណ្តោយផ្លូវជាតិលេខ៦៧ ក្បែរព្រំដែនកម្ពុជា-ថៃ និងមានចម្ងាយ១៣គីឡូម៉ែត្រពីរង្វង់មូលអន្លង់វែង។ ប៉ុល ពត ស្លាប់ដោយជំងឺបេះដូងក្នុងពេលជាប់ឃុំ។ នៅខែមីនា ឆ្នាំ១៩៩៧ តាម៉ុក កាត់ទោសឲ្យ ប៉ុល ពត ជាប់ឃុំអស់មួយជីវិត ដោយចោទពីបទសម្លាប់ សុន សេន និងគ្រួសារ។ សាកសព ប៉ុល ពត បូជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៨ ដែលត្រូវជាខួបលើកទី២៣នៃការទទួលជ័យជម្នះរបស់ខ្មែរក្រហមលើរបប លន់ នល់។ ពិធីបុណ្យសព ប៉ុល ពត មិនបានរៀបចំឲ្យជិតដល់ទេ ហើយយកកង់ឡាន និងសំរាម ប្រើប្រាស់សម្រាប់ធ្វើជាមឈូស និងបូជាសព។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

## ២. កន្លែងកាត់ទោស ប៉ុល ពត

ទីតាំងកាត់ទោស ប៉ុល ពត ស្ថិតនៅលើផ្ទៃដីទំហំ០.៤៤៨ហិកតានៃភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលមានចម្ងាយ១៤គីឡូម៉ែត្រពីរង្វង់មូលទីរួមស្រុកអន្លង់វែង នៅជិតច្រកព្រំដែនកម្ពុជា-ថៃ (ច្រកជាំសាង៉ាំ)។ ពីមុន ទីតាំងនេះគឺជារោងមួយដែល តា ម៉ុក សាងសង់ឡើងសម្រាប់ចតរថយន្ត មុននឹងដឹកសម្ភារចេញចូលឆ្លងកាត់ទៅប្រទេសថៃនិងជាកន្លែងសម្រាកបណ្តោះអាសន្នសម្រាប់អ្នកដំណើរ។

ក្រោយពីបានសម្លាប់ក្រុមគ្រួសារ សុន សេន រួចហើយ ប៉ុល ពត ត្រូវបាននាំខ្លួនមកកាត់ទោសនៅចំពោះមុខតុលាការប្រជាជននៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៩៧។ ខឹម ង៉ុន, កោ ប៊ុនហេង, ម៉ក់ ប៉ែន, ចាន់ យូរ៉ាន់, ទេព យុនណាល់, អាចារ្យនៅ និងលោកសេង បានធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំនោះ។ អ្នកកាសែតបរទេស រួមមានអ្នកកាសែតជនជាតិថៃមួយចំនួន ក៏មានវត្តមាននៅទីនោះជាមួយ ណេត ថាយើរ៍ ដែលជាអ្នកកាសែតជនជាតិអាមេរិកាំង។ ប្រជាពលរដ្ឋប្រហែល៤០០ទៅ៥០០នាក់ក្នុងស្រុកអន្លង់វែងបានតាមដានដំណើរកាត់ទោសនេះដែរ។ ខឹម ង៉ុន បានអានសុន្ទរកថាជូនប្រជាពលរដ្ឋ ក៏ដូចជាគ្រួសារយោធាខ្មែរក្រហម ដែលបានចូលរួមការជំនុំជម្រះក្តី។ ប៉ុល ពត បានបាត់បង់អំណាចដឹកនាំក្នុងជួរខ្មែរក្រហមចាប់ពីពេលនោះមក។ ប៉ុល ពត និងបក្សពួកត្រូវបានកាត់ឲ្យជាប់គុកអស់មួយជីវិត។

ព្រឹត្តិការណ៍សំខាន់៖




សសរបាក់បែកដែលជាសំណល់នៃរោងប្រើប្រាស់ការកាត់ទោស ប៉ុល ពត។ រោងនោះមានតែដំបូល និងសសរតែប៉ុណ្ណោះគ្មានជញ្ជាំងទេ ដែលពីមុនគឺជាចំណតរថយន្ត និងជាកន្លែងសម្រាករបស់ប្រជាជនពេលធ្វើដំណើរចេញចូលប្រទេសថៃ។ នៅទីនេះ តាម៉ុក កាត់ទោសឲ្យ ប៉ុល ពត ជាប់ឃុំអស់មួយជីវិត ដោយមូលហេតុចម្បងគឺពីបទសម្លាប់ សុន សេន និងគ្រួសារ មុនការកាត់ទោសរយៈពេលមួយខែ។ សព្វថ្ងៃនេះ នៅសល់តែសសរទេ ដំបូលខូចបាត់អស់ និងមានទីតាំងស្ថិតនៅក្បែរព្រំដែនថៃ ហើយក៏ជានិមិត្តរូបនៃយុត្តិធម៌សម្រាប់ក្រុមគ្រួសារ សុន សេន ដែលបានបាត់បង់ជីវិតដោយស្នាដៃ ប៉ុល ពត។ អ្នកភូមិដែលចូលរួមសវនាការក្នុងតុលាការប្រជាជន ធ្វើឡើងនៅចុងខែមីនា ឆ្នាំ១៩៩៧ បាននាំគ្នាហៅ ប៉ុល ពត ថាជនក្បត់។ មន្ត្រី និងមេទ័ពខ្មែរក្រហមមួយចំនួនដែលចូលរួមក្នុងការកាត់ទោសនេះរួមមាន ខឹម ង៉ុន, ចាន់ យូរ៉ាន់ និង ទេព យុនណាល់។ ក្រោយមក ទេព យុនណាល់ បានរៀបការជាមួយប្រពន្ធ ប៉ុល ពត។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។



មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា មានទីតាំងស្ថិតនៅពយដ៏ស្រស់ស្អាតមួយនៃភ្នំដងរែក ដែលបានស្គាល់ថា ពយតាវួន។ មជ្ឈមណ្ឌលនេះក្លាយជាបណ្ណាល័យ និងកន្លែងសាកសួរព័ត៌មានសម្រាប់ភ្ញៀវជាតិនិងអន្តរជាតិ ក៏ដូចជាការិយាល័យសម្រាប់ការសិក្សា និងស្រាវជ្រាវសម្រាប់អ្នកស្រាវជ្រាវទាំងក្នុងនិងក្រៅប្រទេស។ ទីកន្លែងនេះធ្លាប់ជាអតីតផ្ទះប្រជុំមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ រួមមាន ប៉ុល ពត និងមេបញ្ជាការខ្មែរក្រហមដទៃទៀត។ ដោយមានការសហការគ្នាជាមួយក្រសួងទេសចរណ៍ និងការផ្ដល់ជំនួយសេដ្ឋកិច្ចពីសេវាសន្តិភាពស៊ីវិលរបស់ GIZ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមជាមួយនឹងនិស្សិតស្ថាបត្យកម្ម មកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានជួសជុលកែលម្អផ្ទះប្រជុំនោះឡើងវិញ សម្រាប់ការប្រើប្រាស់ជាសាធារណៈ និងដាំកូនឈើ៤០០ដើម។ ប្រភពព័ត៌មានៈបណ្ណសាររបស់មជ្ឈមណ្ឌល ឯកសារកម្ពុជា។

## ៣. ផ្ទះតាម៉ុក (បរិវេណលើខ្នងភ្នំដងរែក)

ផ្ទះតាម៉ុក ត្រូវបានសាងសង់នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៥។ ផ្ទះតាម៉ុកស្ថិតនៅលើផ្ទៃដីទំហំ ៣,០២៥ ហិកតា ដែលមានចម្ងាយប្រហែល ១៦,៥ គីឡូម៉ែត្រ ពីរង្វង់មូលស្រុកអន្លង់វែង។ ផ្ទះតាម៉ុកស្ថិតនៅក្នុងភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

បន្ទាប់ពីយើងធ្វើដំណើរពីច្រកព្រំដែនសព្វថ្ងៃឆ្ពោះទៅទិសខាងកើត ហើយកាត់លើបណ្ដោយខ្នងភ្នំដងរែកប្រហែល៣គីឡូម៉ែត្រ យើងនឹងទៅដល់ផ្ទះតាម៉ុកលើខ្នងភ្នំដងរែកនេះ។ ផ្ទះនេះគឺជាទីតាំងដែលតាម៉ុក ស្នាក់នៅជាប្រចាំនិងជាទីកន្លែងជួបប្រជុំគ្នាជាមួយមេដឹកនាំកំពូលៗរបស់ខ្មែរក្រហម ដូចជា ប៉ុល ពត, ខៀវ សំផន, នួន ជា, សុន សេន និងមេបញ្ជាការកងពលមួយចំនួនទៀត។ នៅលើទីតាំងផ្ទះ តាម៉ុក កណ្ដាលលើខ្នងភ្នំដងរែកនេះមានរាប់បញ្ចូលផ្ទះ នួន ជា, សុន សេន និងតាម៉ុក ព្រមទាំងក្រុមគ្រួសារដែលរស់នៅជាមួយគ្នា។ នៅខាងមុខផ្ទះ មានផ្ទះប្រជុំសម្រាប់ទទួលភ្ញៀវមួយ ដែលធ្វើអំពីឈើប្រក់ក្បឿងស្រកានាគ។ នៅក្នុងផ្ទះ មានតុធ្វើពីដើមគគីរទាំងមូលមួយ តែសព្វថ្ងៃនេះត្រូវបានភ្លើងឆេះអស់ហើយ។ នៅបរិវេណខាងមុខផ្ទះ មានដាំលម្អទៅដោយដើមផ្កា ដើមប្រទាល ដែលនាំមកពីប្រទេសថៃ និងមានថូផ្កាធំៗ ដែលមានចម្លាក់រូបនាគ។ តាម៉ុកតែងតែបញ្ជាឲ្យអ្នកបើកបរស្រោចទឹកផ្កាជារៀងរាល់ព្រឹក។ ក្រោយមកទៀត តាម៉ុកបានសង់ផ្ទះមួយទៀត ដែលមានសសរធំៗ និងជញ្ជាំងបេតុង។ ជញ្ជាំងបេតុង និងសំណាញ់ដែកសរសៃត្រូវបានសាងសង់ឡើងដើម្បីការពារគ្រាប់កាំភ្លើងគ្រប់ប្រភេទ។ ផ្ទះនេះគឺជាទីបញ្ជាការកងទ័ពតាមរយៈវិទ្យុទាក់ទងទៅសមរភូមិផ្សេងៗទៀត។

## ព្រឹត្តិការណ៍សំខាន់៖

## ៤. កន្លែងកែច្នៃគ្រាប់កាំភ្លើងលើភ្នំ២០០

ក្រោយពីកាត់ផ្ដាច់ទំនាក់ទំនងការទូតនិងជំនួយពីបរទេស តាម៉ុក បានប្រែក្លាយ«ភ្នំ២០០»ឲ្យទៅជាទីតាំងកែច្នៃគ្រាប់កាំភ្លើង។ទីតាំងកែច្នៃគ្រាប់កាំភ្លើងភ្នំ២០០ ត្រូវបានសាងសង់ឡើងនៅលើផ្ទៃដីទំហំ ១.១៤២ហិកតា នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៤។ ទីតាំងនេះមានចម្ងាយ ១៤,៩ គីឡូម៉ែត្រពីរង្វង់មូលស្រុកអន្លង់វែងស្ថិតនៅក្នុងភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

មុនឆ្នាំ១៩៩០«ភ្នំ២០០»ធ្លាប់ជាមូលដ្ឋានយោធារបស់រដ្ឋកម្ពុជា។ក្រោយមកទៀត នៅឆ្នាំ១៩៩៣ តាម៉ុក បានសម្រេចប្រើប្រាស់ «ភ្នំ២០០» ជាកន្លែងកែច្នៃគ្រាប់កាំភ្លើង។ កម្មករទាំងឡាយមានតួនាទីផលិតគ្រាប់កាំភ្លើង ហើយទីតាំងនេះមានបំពាក់អាវុធពាក់កណ្ដាលស្វ័យប្រវត្តិទៀតផង។ នៅលើទីតាំងនេះ មានផ្ទះ១ខ្នងសម្រាប់ច្នៃគ្រាប់ ដែលមានទទឹង ១០ ម៉ែត្រ និងបណ្ដោយ ៣០ ម៉ែត្រ ដែលប្រើប្រាស់សម្រាប់ផលិតគ្រាប់កាំភ្លើងតែប៉ុណ្ណោះ។ មានឃ្លាំងមួយទៀតសម្រាប់ដាក់ម៉ាស៊ីន។

លោក សាន់ រឿង អតីតយោធាខ្មែរក្រហម និងជាមន្ត្រីការិយាល័យទេសចរណ៍ស្រុកអន្លង់វែង (ស្លាប់) បានបញ្ជាក់ប្រាប់ថា «ពេលនោះ កម្មាភិបាលខ្មែរក្រហមរៀបចំកន្លែងកែច្នៃគ្រាប់កាំភ្លើង AK៤៧ និង AK៥៧។ កម្លាំងមនុស្សប្រហែល១២នាក់ បានធ្វើការរួមគ្នាដើម្បីកែច្នៃគ្រាប់ចំនួន ៥០០០ ទៅ ៦០០០ គ្រាប់ក្នុងមួយថ្ងៃ»។



ភ្នំ២០០ ធ្លាប់ជាកន្លែងផលិតគ្រាប់កាំភ្លើង។ តាម៉ុក បានបង្កើតកន្លែងផលិតគ្រាប់កាំភ្លើងនេះនៅឆ្នាំ១៩៩៤ក្រោយពេលដែលជំនួយនិងទំនាក់ទំនងការទូតជាមួយនឹងបរទេសត្រូវបានកាត់ផ្ដាច់។ មានការរាយការណ៍ថា ធ្លាប់មានមនុស្ស១២នាក់បានធ្វើការនៅកន្លែងនេះ ដែលអ្នកទាំងនោះអាចផលិតគ្រាប់កាំភ្លើងចាប់ពី៥០០០ទៅ៦០០០គ្រាប់ក្នុងមួយថ្ងៃ។ មុនពេលនោះ ភ្នំនេះធ្លាប់ជាអតីតបន្ទាយទាហានរបស់កងទ័ពរដ្ឋាភិបាលកម្ពុជា។
ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

## ព្រឹត្តិការណ៍សំខាន់៖

## ៥. ផ្ទះ ប៉ុល ពត និង ខៀវ សំផន

ផ្ទះ ប៉ុល ពត និង ខៀវ សំផន ស្ថិតនៅចម្ងាយ ២៤គីឡូម៉ែត្រ ពីរង្វង់មូលទីរួមស្រុកអន្លង់វែង នៅក្នុងភូមិអូរក្រញូង ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ផ្ទះនេះត្រូវបានសាងសង់ឡើង នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៩៣ នៅលើផ្ទៃដី១១៧,០៦១ហិកតា។

ផ្ទះកំពស់មួយជាន់របស់ ប៉ុល ពត សង់ពីឥដ្ឋ បេតុង និងប្រក់ហ្វីប្រូស៊ីម៉ង់ត៍។ ផ្ទះនេះមានបន្ទប់ក្រោមដីសម្រាប់ទុកឯកសារ និងសម្ភារមានតម្លៃមួយចំនួនទៀត។

ផ្ទះ ខៀវ សំផន សង់ពីឥដ្ឋ បេតុង និងប្រក់ហ្វីប្រូស៊ីម៉ង់ត៍ដែរ នៅក្នុងផ្ទះនោះ ខៀវ សំផន មានការិយាល័យមួយនិងមានស្រះចិញ្ចឹមត្រីមួយ។

តាម៉ុក បានសាងសង់ផ្ទះនេះសម្រាប់ ប៉ុល ពត ដែលបានផ្លាស់ពីតំបន់ប៉ៃលិនមករស់នៅកន្លែងនេះ។ ទីតាំង ត្រូវបានហៅថា«ក្បាលទន្សោង» និងជាទីបញ្ជាការជំរបស់ខ្លួន។

### ព្រឹត្តិការណ៍សំខាន់៖



អតីតផ្ទះ ប៉ុល ពត និងខៀវ សំផន ដែលស្ថិតនៅចម្ងាយ ២៤គីឡូម៉ែត្រពីរង្វង់មូលអន្លង់វែង។ ផ្ទះនោះត្រូវបានសាងសង់ឡើងនៅឆ្នាំ១៩៩៣ ពីស៊ីម៉ង់ត៍និងឥដ្ឋ ដែលមានដំបូលស៊ីម៉ង់ត៍។ ផ្ទះនោះក៏មានជាន់ក្រោមដីដែលអាចប្រើប្រាស់ជាឃ្លាំងដាក់វត្ថុមានតម្លៃនិងជាកន្លែងលាក់ខ្លួន។ មានការរាយការណ៍ថា តាម៉ុក បានសាងសង់ផ្ទះនេះឲ្យ ប៉ុល ពត និង ខៀវ សំផន នៅក្រោយពេលដែលអ្នកទាំងពីរបានភៀសខ្លួនពីប៉ៃលិនមកអន្លង់វែង។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

## ៦. ឃ្លាំងដាក់សម្ភារជើងភ្នំ

ឃ្លាំងដាក់សម្ភារជើងភ្នំត្រូវបានសាងសង់ឡើងនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្ថិតនៅលើផ្ទៃដីទំហំ ១,៧៥២ ហិកតា។ ទីតាំងនេះមានចម្ងាយ ១១,៩ គីឡូម៉ែត្រ នៅតាមបណ្ដោយផ្លូវជាតិលេខ ៦៧ ទៅដល់ប៉ុស្ដិ៍ត្រួតពិនិត្យជើងភ្នំ។ យើងនឹងឃើញផ្លូវលំមួយ ហើយបត់ស្ដាំប្រហែល ៥០០ ម៉ែត្រ។ ទីតាំងនេះស្ថិតនៅក្នុងភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងពិភាក្សាពីប្រវត្តិរបស់ឃ្លាំងជើងភ្នំជាមួយលោក សាន់ រឿង។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ក្នុងអំឡុងរបបខ្មែរក្រហម ឃ្លាំងសម្ភារនេះមានអគារចំនួន៤ខ្នង ដែលមួយខ្នងៗមានទទឹង៦ ម៉ែត្រ និងបណ្ដោយ៨ម៉ែត្រ។ អគារទាំងនេះត្រូវបានប្រើប្រាស់ក្នុងគោលបំណងដូចខាងក្រោម៖

- អគារទី១ សម្រាប់ដាក់ឡុតមីន
- អគារទី២ សម្រាប់ដាក់កឹបមីន
- អគារទី៣ សម្រាប់ដាក់កឹបមិនទាន់ច្នៃហើយ
- អគារទី៤ សម្រាប់ដាក់ខោអាវ មួក មុង អង្រឹង និងស៊ីទែនប្រេងពីរចំណុះ ១០,០០០ លីត្រទៀត។

ក្នុងអំឡុងពេលនោះ គ្មាននរណាអាចចេញចូលឃ្លាំងនេះបានទេ ក្រៅពីអ្នកយាមមួយក្រុមប៉ុណ្ណោះ។ លោក ចាប ប៊ុនធឿន ដែលជាអតីតអ្នករថយន្តដឹកស្បៀង និងបច្ចុប្បន្នជាជំទប់ទី១នៃឃុំត្រពាំងប្រីយ៍ ចងចាំយ៉ាងច្បាស់នូវរាល់សំណង់ទាំងអស់នេះ ដែលត្រូវបានប្រើប្រាស់សម្រាប់ធ្វើជាឃ្លាំង។

### ព្រឹត្តិការណ៍សំខាន់៖

## ៧. កន្លែងបូជាសព សុន សេន

ទីតាំងផុតសពរបស់ សុន សេន និងក្រុមគ្រួសារស្ថិតនៅក្នុងភូមិស្រះឈូក ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដោយមានចម្ងាយ៨,៩ គីឡូម៉ែត្រពីរង្វង់មូលស្រុកអន្លង់វែង។ សុន សេន និងក្រុមគ្រួសារត្រូវបានសម្លាប់នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៧។ ទីតាំងនេះមានផ្ទៃដីទំហំ០,០៦២ហិកតា។

ទីតាំងផុតសព សុន សេន មិនមែនបូជាតែសាកសព សុន សេន តែម្នាក់ប៉ុណ្ណោះទេ។ សាកសពសមាជិកក្រុមគ្រួសាររបស់ សុន សេន ១០ នាក់ទៀត ត្រូវបានបូជារួមគ្នាតែម្តង។ សមាជិកក្រុមគ្រួសារទាំងនោះរួមមាន នីរសារ អ្នកបើកឡាន កូនស្រី២នាក់របស់ សុន សេន។ កូនស្រី២នាក់របស់ សុន សេន ត្រូវបានអូសយកទៅរំលោភនៅមាត់អូរ ដោយឈ្មោះ រ៉ន ដែលជាកូនប្រសាររបស់តាសារឿន (ហៅ០៥)។ បន្ទាប់មក យោធារបស់ប៉ុលពតបានកាត់ក្បាលនិងសម្លាប់ស្ត្រីទាំងពីរនាក់នេះយ៉ាងព្រៃផ្សៃបំផុត។ក្រោយមកតាម៉ុកនិងមេទ័ពមួយចំនួនក្រោមឱវាទរបស់ខ្លួនបានដណ្តើមសាកសពទាំងអស់ពីក្រុមយោធារបស់ប៉ុល ពត ដើម្បីយកមកបូជារួមគ្នា។ ក្រោយពីការស្លាប់របស់សុន សេន និងក្រុមគ្រួសារ តា ម៉ុក បានបញ្ជាឲ្យថតរូបសាកសព និងបង្ហាញទៅប្រជាជនស្រុកអន្លង់វែង។ ប្រជាជនមានភាពរន្ធត់ចិត្តយ៉ាងខ្លាំង នៅពេលដែលខ្លួនដឹងថា ប៉ុល ពត បានចេញបញ្ជាឲ្យសម្លាប់ថ្នាក់ដឹកនាំកំពូលដែលធ្លាប់បានតស៊ូជាមួយគ្នា។ កំហឹងបានផ្ទុះឡើង និងបែកបាក់គ្នាជាពីរក្រុម។ ក្រុមមួយស្ថិតនៅក្រោមគ្រប់គ្រងរបស់ប៉ុល ពត ហើយក្រុមមួយទៀតនៅក្រោមការគ្រប់គ្រងរបស់ តា ម៉ុក ។ ការផ្ទុះអាវុធរវាងក្រុមទាំងពីរនេះចាប់ផ្តើម។ បន្ទាប់មក តា ម៉ុក បានប្រកាសទៅភាគីម្ខាងទៀតថា «សូមវិលត្រឡប់មកផ្ទះវិញ និងដាក់អាវុធចុះដោយសារតែយើងនៅសល់មនុស្សតិចតួចណាស់។ យើងត្រូវចេះសាមគ្គីគ្នា»។ ក្រោយពីភាគីម្ខាងទៀតបានដាក់អាវុធចុះចូលជាមួយ តា ម៉ុក។ តាម៉ុកបានចាប់ខ្លួនមេទ័ពរបស់ ប៉ុល ពត មួយចំនួន ដូចជា តា សារឿន (ហៅ០៥) តា សាន, តាយ៉ន, តាងួន, ខេមរា និង តា សេន និងយកមកដាក់ក្នុងទ្រុងដែក។ ទ្រុងដែកនេះស្ថិតនៅផ្ទះតាម៉ុក ក្បែរបឹងអូរជីក។ តា ម៉ុក បានបញ្ជាឲ្យយោធារបស់គាត់កសាងផ្ទះតូចល្មមមួយសម្រាប់ប៉ុលពត ដែលបានរស់នៅដូចប្រជាជនធម្មតា។



នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៩៧ សុន សេន ព្រមទាំងភរិយា កូនស្រី នីរសារ និងអ្នកបើកឡានគាត់ ត្រូវបានបាញ់សម្លាប់យ៉ាងសាហាវឃោរឃៅនៅកន្លែងនេះ។ លើកលែងតែកូនស្រីទាំងពីររបស់ សុន សេន ត្រូវបានអូសទៅរំលោភនិងសម្លាប់នៅអូរក្បែរនោះ។ តាម៉ុក បានបញ្ជាឲ្យថតរូបសាកសព បង្ហាញឲ្យប្រជាជនអន្លង់វែងមើលពីភាពសាហាវឃោរឃៅនៅកន្លែងកើតហេតុនេះ។ ប្រជាជនមានការតក់ស្លុតយ៉ាងខ្លាំង និងបានធ្វើការរិះគន់ ប៉ុល ពត អំពីអំពើឃោរឃៅរបស់កងទ័ពក្រោមឱវាទ។ ប្រជាជនដែលស្រលាញ់គាំទ្រ ប៉ុល ពត មិនអាចទទួលយកការពិតពីអំពើរបស់ ប៉ុល ពត ក៏បានភៀសខ្លួនទៅរស់នៅតំបន់ផ្សេង។ ហេតុការណ៍នេះធ្វើឲ្យមានការបែងចែកចលនាខ្មែរក្រហមជាពីរក្រុមរវាងអ្នកគាំទ្រ តាម៉ុក និងអ្នកគាំទ្រ ប៉ុល ពត។ តាម៉ុក បានប្រាប់ក្រុមអ្នកគាំទ្រ ប៉ុល ពត ឲ្យសុំចុះចាញ់។ ក្រោយការប្រកាសរបស់ តាម៉ុក មេបញ្ជាការកងទ័ពមួយចំនួនរួមមាន តាសារឿន តាសាន និងមេបញ្ជាការដទៃទៀតបានចុះចាញ់។ តាម៉ុក បានចាប់ខ្លួនមេទ័ពមួយចំនួនដាក់នៅក្នុងទ្រុងដែក ដែលសព្វថ្ងៃនេះបានដាក់តាំងបង្ហាញនៅផ្ទះមាត់បឹងរបស់ តាម៉ុក។ ចំណែកឯ ប៉ុល ពត ត្រូវបានដាក់ទោសឲ្យជាប់ឃុំអស់មួយជីវិត។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។



### ព្រឹត្តិការណ៍សំខាន់៖

## ៨. ស្រែគំរូ

ស្រែគំរូស្ថិតនៅចម្ងាយ ១៣,៥ គីឡូម៉ែត្រពីរង្វង់មូលស្រុកអន្លង់វែង នៅក្នុងភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ តាម៉ុក បានបង្កើតស្រែគំរូឡើងនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៤ នៅលើផ្ទៃដី ៤,៤១២ ហិកតា។ ដើមឡើយ ស្រែគំរូជាកន្លែងលាក់ខ្លួនរបស់ ប៉ុល ពត និងក្រុមមេដឹកនាំមួយចំនួនទៀត សម្រាប់រយៈពេលខ្លី ដោយមានផ្ទះចំនួន ៥ខ្នងសង់ នៅខាងក្រោមដើមឈើធំៗ។ មូលហេតុនៃការសាងសង់ផ្ទះទាំងនេះ គឺដោយសារមានការគាបសង្កត់ ពីប្រទេសជិតខាង។ មានតែមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ទេ ទើបស្គាល់ពីកន្លែងនេះ។ ក្រោយពេលដែល ប៉ុល ពត ចាកចេញពីផ្ទះនេះ ទីតាំងទាំងមូលត្រូវបានប្រែក្លាយទៅជាទីវាលសម្រាប់ធ្វើស្រែចម្ការ ហៅថា «ស្រែគំរូ»។



តាម៉ុក បានបង្កើតស្រែ«គំរូ»មួយឡើងនៅខែសីហា ឆ្នាំ១៩៩៤ ដែលគ្របដណ្តប់លើផ្ទៃដីជាង៤ហិកតា នៅក្នុងសហគមន៍ត្រពាំងប្រីយ៍ ស្រុកអន្លង់វែង។ ស្រែគំរូនេះធ្លាប់ជាអតីតកន្លែងលាក់ខ្លួនរបស់ ប៉ុល ពត និងមេដឹកនាំដទៃទៀត។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

### ព្រឹត្តិការណ៍សំខាន់៖

## ៩. ទីតាំងការដ្ឋានដឹកជញ្ជូនតាម៉ុក (ហៅថា ឃ្លាំងកណ្តាល)

ឃ្លាំងកណ្តាលស្ថិតនៅចម្ងាយ ៤,១ គីឡូម៉ែត្រ ពីរង្វង់មូលស្រុកអន្លង់វែង នៅក្នុងភូមិឃ្លាំងកណ្តាល ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ទីតាំងការដ្ឋានដឹកជញ្ជូនរបស់តាម៉ុកត្រូវបានសាងសង់ឡើងនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៩២ នៅលើផ្ទៃដីទំហំ០,១២២ ហិកតា។

លោកឃុនលីដែលធ្លាប់នាំអ្នកជំងឺទៅមន្ទីរពេទ្យហើយបច្ចុប្បន្នជាសមាជិកក្រុមប្រឹក្សាស្រុកអន្លង់វែងបានបញ្ជាក់ប្រាប់ថា៖«ឃ្លាំងនេះធ្វើអំពីឈើនិងរៀបឥដ្ឋ ដោយមានរាងជារោងសម្រាប់ដាក់ឡាន»។

លោក សាន់ រឿង ដែលជាអតីតយោធាខ្មែរក្រហម និងជាមន្ត្រីការិយាល័យទេសចរណ៍ស្រុកអន្លង់វែង (ស្លាប់)បានបញ្ជាក់ថា៖ «ឃ្លាំងនេះត្រូវបានប្រើប្រាស់ជាបញ្ជាការចែកចាយសម្ភារ»។

### ព្រឹត្តិការណ៍សំខាន់៖



កន្លែងនេះត្រូវបានស្គាល់ថាជាទីតាំងការដ្ឋានដឹកជញ្ជូនរបស់ តាម៉ុក ដែលបានសាងសង់នៅពាក់កណ្តាលឆ្នាំ១៩៩២ ជាឃ្លាំងកណ្តាលសម្រាប់ចែកចាយ ស្បៀង និងសម្ភារនានា។ កាលពីដើមឃ្លាំងនេះជាសាលធំមួយ ដែលសាងសង់ពីឈើនិងប្រក់ក្បឿង។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

## ១០. បឹងអន្លង់វែង

បឹងអន្លង់វែងស្ថិតនៅខាងកើតស្ពានតាម៉ុកនិងមានចម្ងាយ២០០ម៉ែត្រពីរង្វង់មូលស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ផ្ទៃបឹងមានទំហំ៤១៧ហិកតា ដែលមានព្រំប្រទល់ខាងកើតទល់នឹងឃុំថ្លាត ខាងលិចទល់នឹងឃុំអន្លង់វែង ខាងជើងទល់នឹងឃុំត្រពាំងប្រីយ៍ និងខាងត្បូងទល់នឹងឃុំអន្លង់វែង។ កាលពីដើមឡើយ បឹងអន្លង់វែងនេះជាអូរធម្មជាតិ ដែលមានទឹកថ្លា សម្បូរទៅដោយដើមឈើនិងត្រីតូចធំជាច្រើន។ អតីតសមាជិកខ្មែរក្រហមពឹងផ្អែកលើត្រីនៅក្នុងបឹងដើម្បីធ្វើជាអាហារ កាលពីទសវត្សរ៍ឆ្នាំ១៩៩០។ នៅរដូវប្រាំង នៅពេលដែលប្រជាជននិងក្រុមគ្រួសារយោធាខ្មែរក្រហមខ្វះខាតទឹកប្រើប្រាស់ តាម៉ុក ក៏បានទប់ទំនប់ជាបីដំណាក់កាល។ ដំណាក់កាលទីមួយចាប់ផ្តើមពីឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩១។ ទំនប់បង្ហៀរទឹកត្រូវបានសាងសង់ឡើង។ លុះក្រោយមកនៅឆ្នាំ១៩៩២ ទំនប់បង្ហៀរទឹកនោះត្រូវបានសាងសង់ខ្ពស់ជាងមុន ដើម្បីរក្សាទឹកឲ្យបានច្រើន។ លុះដល់ឆ្នាំ១៩៩៤ តាម៉ុកបានរៀបចំសាងសង់ស្ពានមួយ និងពង្រីកទំនប់ឲ្យធំជាងមុន។ ក្រោយពី តាម៉ុក សាងសង់ទំនប់ និងស្ពានរួចមក ទឹកនៅក្នុងបឹងកាន់តែកើនឡើង រហូតក្លាយទៅជាបឹង។ ចាប់តាំងពីពេលនោះមក ប្រជាជនបានហៅបឹងនេះថាជា «បឹងអូរជីក» ឬ «បឹងអន្លង់វែង»។

### ព្រឹត្តិការណ៍សំខាន់៖



រូបភាពដែលបានថតនៅបឹងមួយហៅថា បឹងទំនប់ថ្មី។ បឹងទំនប់ថ្មីត្រូវបានស្គាល់ថា ជាបឹងសិប្បនិម្មិត និងបានសាងសង់ក្នុងសម័យកាលដែល តាម៉ុក គ្រប់គ្រងអន្លង់វែង (១៩៨៩-១៩៩៨)។ ប្រជាជនក្នុងតំបន់យល់ឃើញថាបឹងនេះមានទំហំធំជាងបឹងអូរជីក និងមានសារៈសំខាន់ក្នុងការធ្វើកសិកម្មពេញមួយឆ្នាំនៅតំបន់ជុំវិញ។ ជាក់ស្តែងណាស់ ខ្មែរក្រហមផ្តល់តម្លៃឲ្យប្រព័ន្ធធារាសាស្ត្រយ៉ាងខ្លាំង ព្រោះខ្មែរក្រហមដឹងថានឹងផ្តល់សារប្រយោជន៍ដល់សហគមន៍ជាច្រើនជំនាន់តទៅមុខទៀត។ អ្វីដែលខ្មែរក្រហមមិនបានពិចារណានោះ គឺការបាត់បង់ជីវិតមនុស្ស និងភាពអមនុស្សធម៌ដែលកើតឡើងក្នុងការអនុវត្តគម្រោងនេះ។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

## ១១. ផ្ទះតាម៉ុក ៖ សារមន្ទីរតាម៉ុក

ផ្ទះតាម៉ុកត្រូវបានសាងសង់ឡើងនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៣ នៅលើផ្ទៃដី ១,៦១៤ហិកតា។ ផ្ទះនេះមានចម្ងាយ២គីឡូម៉ែត្រពីរង្វង់មូលស្រុកអន្លង់វែង រួចបត់ស្តាំតាមស្លាកសញ្ញាពីផ្លូវជាតិប្រហែល៥០០ម៉ែត្រ។ ផ្ទះតាម៉ុកស្ថិតនៅក្នុងភូមិអភិវឌ្ឍន៍ ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

កាលពីដើមឡើយ ទីតាំងផ្ទះតាម៉ុក ជាកូនភ្នំមួយមានរាងតូចហើយវែង។ ប៉ុន្តែ ប្រជាជនបាននាំគ្នាគាស់កកាយថ្មក្នុងកូនភ្នំនោះ ដើម្បីសាងសង់ទំនប់ និងស្ពានអូរជីក រហូតនៅសល់តែបាតក្រោមដែលមានសណ្ឋានដីរាបបន្តិច។ នៅទីនោះ តាម៉ុក បានសម្រេចចិត្តសាងសង់ផ្ទះរបស់គាត់ជាបន្តបន្ទាប់។

ក. ផ្ទះទី១៖ ផ្ទះនេះត្រូវបានសាងសង់ឡើងនៅឆ្នាំ១៩៩៣ ធ្វើអំពីឈើ ប្រក់ហ្វីប្រូស៊ីម៉ង់ត៍ និងក្រាលបេតុង។ តាម៉ុកប្រើប្រាស់ផ្ទះនេះសម្រាប់ធ្វើជាទីស្នាក់ការរបស់គាត់ ដើម្បីងាយស្រួលក្នុងការមើលការខុសត្រូវលើកម្មករ ដែលកំពុងសាងសង់ទំនប់អូរជីក និងជាកន្លែងសម្រាប់ដាក់ឡានធំតូចផង។

ខ. ផ្ទះទី២៖ ផ្ទះនេះត្រូវបានសាងសង់ឡើងនៅឆ្នាំ១៩៩៤ ហើយបញ្ចប់នៅឆ្នាំ១៩៩៦។ ផ្ទះនេះមានបីជាន់៖

- ជាន់លើជាកន្លែងស្នាក់នៅរបស់ តាម៉ុក
- ជាន់កណ្តាលជាកន្លែងទទួលភ្ញៀវរបស់ តាម៉ុក។ នៅតាមជញ្ជាំងមានផ្ទាំងគំនូរពីរផ្ទាំង ប្រាសាទអង្គរវត្តមួយផ្ទាំង និងប្រាសាទព្រះវិហារមួយផ្ទាំង ព្រមទាំងផែនទី កម្ពុជាប្រជាធិបតេយ្យ។
- ជាន់ក្រោមមានច្រកចេញចូលតែមួយគត់ ដែលមានទំហំ៤ម៉ែត្រ។ គ្មានបងប្អូនឬកូនចៅណាអាចចេញចូលបានឡើយ ក្រៅពី តាម៉ុក។ បន្ទប់នេះបិទជិតរហូតហាក់ដូចជាមានអាថ៌កំបាំងអ្វីមួយ។

តាមការសាកសួរពីលោក សាន់ សារឿន (អតីតកម្មករដែលបានធ្វើផ្ទះ តាម៉ុក) បានឲ្យដឹងថា ផ្ទះជាន់ក្រោមនេះ គឺសម្រាប់ដាក់សម្ភារសំខាន់ៗដូចជា រូបចម្លាក់ វត្ថុបុរាណ ហើយមានព្រះពុទ្ធរូបតូចធំជាច្រើនអង្គ ដែលជាទីសក្ការបូជារបស់ តាម៉ុក។ តាម៉ុក តែងតែចេញចូល ដើម្បី



រថយន្តវិទ្យុចល័ត នៅក្បែរផ្ទះតាម៉ុក។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។



ដុតធូបបួងសួង នៅរៀងរាល់ថ្ងៃសីល។

គ. ផ្ទះទី៣៖ ផ្ទះនេះមានទំហំធំ ដោយសារតែត្រូវបានធ្វើឡើងសម្រាប់ក្រុមគ្រួសាររបស់ តាម៉ុក និងអ្នកធ្វើដំណើរមកពីចម្ងាយ ដូចជាប្រជាជនដែលមកសុំគោ ក្របី ស្រូវ អង្ករ និងសម្រាប់អ្នកមកទទួលអំណោយ ផ្សេងៗ។

ឃ. ផ្ទះទី៤៖ ផ្ទះនេះត្រូវបានសាងសង់ឡើងនៅឆ្នាំ១៩៩៣។ ផ្ទះនេះគឺជារោងបាយសម្រាប់បុគ្គលិកនិងចុងភៅដើម្បីស្នាក់នៅ។ ផ្ទះមានកម្ពស់បីជាន់ដែលជាន់ក្រោមគឺជាលេណដ្ឋាន។ ជាន់ទីពីរជាកន្លែងហូបបាយរបស់បុគ្គលិករបស់តាម៉ុក។ ជាន់ទីបី គឺជាបន្ទប់សម្រាប់ស្នាក់នៅរបស់ចុងភៅ។

## ព្រឹត្តិការណ៍សំខាន់៖



ផ្ទះតាម៉ុក ឬសារមន្ទីរតាម៉ុក បានសាងសង់បួនដំណាក់កាល។ ផ្ទះទីមួយសាងសង់ឡើងពីឈើ ប្រក់ហ្វីប្រូស៊ីម៉ង់ត៍ និងក្រាលបេតុង ដោយប្រើប្រាស់ជាទីស្នាក់ការ កន្លែងចតរថយន្ត និងកន្លែងមើលការខុសត្រូវលើការដ្ឋានទំនប់អូរជីក។ ផ្ទះទីពីរសាងសង់អស់រយៈពេលមួយឆ្នាំ រួចរាល់ក្នុងឆ្នាំ១៩៩៦ ជាកន្លែងស្នាក់នៅរបស់ តាម៉ុក។ ជាន់លើជាបន្ទប់គេង។ ជាន់កណ្តាលជាបន្ទប់ទទួលភ្ញៀវ មានរូបគំនូរប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ និងផែនទីកម្ពុជាប្រជាធិបតេយ្យគូរលើជញ្ជាំង។ ជាន់ក្រោមជាកន្លែងសម្ងាត់ដែលមានតែ តាម៉ុក ម្នាក់គត់ដែលអាចចេញចូលបាន។ ផ្ទះទីបីមានទំហំធំជាងគេ ដោយប្រើប្រាស់ជាកន្លែងសម្រាករបស់ក្រុមគ្រួសារ តាម៉ុក និងប្រជាជនដែលតែងតែមកសូមជំនួយដូចជា អាហារ អង្ករ គោ និងរបស់របរប្រើប្រាស់ផ្សេងៗពីតាម៉ុក។ ផ្ទះទីបួនជាចង្ក្រានបាយ និងជាកន្លែងស្នាក់នៅសម្រាប់ចុងភៅ និងអ្នកបម្រើ។ ប្រភពព័ត៌មាន ៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

## ១២. អតីតមន្ទីរពេទ្យតាម៉ុក

មន្ទីរពេទ្យតាម៉ុកត្រូវបានសាងសង់ឡើងនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៣ នៅលើផ្ទៃដី១,៦១៤ហិកតា ហើយស្ថិតនៅចម្ងាយ២០០ម៉ែត្រពីរង្វង់មូលស្រុកអន្លង់វែង។ មន្ទីរពេទ្យនេះស្ថិតនៅក្នុងភូមិអូរចិញ្ចៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ មន្ទីរពេទ្យនេះមានអគារមួយខ្នងដែលមានកម្ពស់បីជាន់។ តាលន ដែលធ្លាប់បានសិក្សានៅប្រទេសចិន និងតាលាវ ដែលជាមេជាងមកពីប្រទេសថៃ មានភារកិច្ចគ្រប់គ្រងការសាងសង់មន្ទីរពេទ្យ។ មន្ទីរពេទ្យនេះត្រូវបានកសាងឡើងសម្រាប់ព្យាបាលជំងឺប្រជាជននិងយោធាខ្មែរក្រហម នៅសម័យនោះ។ អ្នកជំងឺភាគច្រើនដែលទទួលបានការព្យាបាល គឺជាអ្នកជំងឺគ្រុនចាញ់និងអ្នករបួសនៅតាមសមរភូមិ។ ប្រសិនបើជំងឺមានសភាពធ្ងន់ធ្ងរនិងមិនអាចព្យាបាលបានអ្នកជំងឺទាំងនោះនឹងត្រូវបញ្ជូនទៅព្យាបាលនៅប្រទេសថៃ។ ចំណែកឯថ្នាំពេទ្យសម្រាប់ប្រើប្រាស់ក្នុងមន្ទីរពេទ្យត្រូវបាននាំចូលមកពីប្រទេសថៃ។ នៅពេលនោះ សម្ភារ ពេទ្យមិនសូវទំនើបទេ។ ប្រដាប់ប្រដាសម្រាប់ព្យាបាលមានត្រឹមតែឧបករណ៍សម្រាប់ពិនិត្យជំងឺគ្រុនចាញ់ និងឧបករណ៍សម្រាប់វះកាត់មួយចំនួនតែប៉ុណ្ណោះ។ ក្រោយឆ្នាំ១៩៩៨ មន្ទីរពេទ្យតា ម៉ុក បានក្លាយទៅជាមន្ទីរពេទ្យបង្អែក ប្រចាំស្រុកអន្លង់វែង រហូតមកដល់បច្ចុប្បន្ន។

### ព្រឹត្តិការណ៍សំខាន់៖



មន្ទីរពេទ្យតាម៉ុក សាងសង់នៅចុងឆ្នាំ១៩៩៣ មានកម្ពស់បីជាន់ ដើម្បីព្យាបាលប្រជាជន និងកងទ័ពខ្មែរក្រហមរងរបួស។ ដោយសារតែអន្លង់វែងមានទីតាំងក្បែរតំបន់ព្រៃភ្នំ ជារឿយៗប្រជាជនតែងតែកើតជំងឺគ្រុនចាញ់។ តាលន ដែលបានសិក្សានៅប្រទេសចិន និង តាលាវ ជាមេជាងមកពីប្រទេសថៃ គឺជាអ្នកដែលគ្រប់គ្រងការសាងសង់អគារនេះ។ មន្ទីរពេទ្យនេះប្រើប្រាស់ជាចម្បងក្នុងការព្យាបាលអ្នកដែលមានបញ្ហាសុខភាពកម្រិតមធ្យម។ អ្នកជំងឺដែលមានសភាពធ្ងន់ត្រូវបញ្ជូនទៅព្យាបាលនៅប្រទេសថៃ។ សព្វថ្ងៃ មន្ទីរពេទ្យតាម៉ុក ជាមន្ទីរពេទ្យបង្អែកប្រចាំស្រុកអន្លង់វែង។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

## ១៣. អតីតសាលារៀនតាម៉ុក

អតីតសាលារៀនតាម៉ុកស្ថិតនៅចម្ងាយ៧០០ម៉ែត្រពីរង្វង់មូលស្រុកអន្លង់វែង នៅតាមបណ្តោយផ្លូវពីអន្លង់វែងទៅខេត្តព្រះវិហារ។ សាលានេះត្រូវបានសាងសង់ឡើងនៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៩៣ នៅលើផ្ទៃដី ៤,៨៣០ហិកតា។ សាលាមានទីតាំងស្ថិតនៅក្នុងភូមិថ្មល់កែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សាលាត្រូវបានសាងសង់ពីឥដ្ឋ ដែលមានកម្ពស់៣ជាន់និង១២បន្ទប់ ដែលអាចទទួលសិស្សចំនួនប្រមាណជា ៣០០ ទៅ៤០០នាក់។ ប៉ុន្តែសាលានេះមានត្រឹមតែពីថ្នាក់ទី១ ដល់ថ្នាក់ទី៥ តែប៉ុណ្ណោះ។

នៅពេលនោះ កម្មវិធីបង្រៀនមានត្រឹមតែគណិតវិទ្យានិងអក្សរខ្មែរ។ សៀវភៅរៀនអានច្រើនតែពណ៌នាអំពីសង្គ្រាមឈ្លប និងសមរភូមិវាយខ្មាំងយួនឈ្លានពានតែប៉ុណ្ណោះ។ សម្ភារសិក្សាមានដូចជា ប៊ិច សៀវភៅ ដីស ក្តារខៀន ត្រូវបាននាំចូលមកពីប្រទេសថៃ។ ចំណែកឯ សៀវភៅរៀនអានគឺត្រូវបានខ្មែរក្រហមបោះពុម្ពដោយខ្លួនឯង ដែលមានចំណងជើងថា «កម្ពុជាប្រជាធិបតេយ្យ»។ គ្រូបង្រៀនទាំងប្រុសទាំងស្រីពុំមានប្រាក់ខែទេ។ បច្ចុប្បន្ន សាលានេះមានឈ្មោះថា «វិទ្យាល័យអន្លង់វែង»។

### ព្រឹត្តិការណ៍សំខាន់៖



អគារកម្ពស់បីជាន់ មានដប់ពីរបន្ទប់ បានសាងសង់នៅឆ្នាំ១៩៩៣ អាចផ្ទុកសិស្សបានពី៣០០ទៅ៤០០នាក់។ កាលពីដំបូងឡើយអាគារនេះជាសាលាបឋមសិក្សាសម្រាប់សិស្សថ្នាក់ទី១ដល់ថ្នាក់ទី៥ ដោយរៀនតែគណិតវិទ្យា និងភាសាខ្មែរតែប៉ុណ្ណោះ។ សិស្សទាំងអស់ក៏ត្រូវរៀនអំពីសង្គ្រាមឈ្លបរវាងវៀតណាម និងខ្មែរក្រហម។ សៀវភៅពុម្ព ប៊ិច សៀវភៅសរសេរ ដីស ក្តារខៀន និងសម្ភារសិក្សាផ្សេងៗគឺនាំចូលពីប្រទេសថៃ។ ក្រោយមកសាលានេះត្រូវបានពង្រីក សព្វថ្ងៃក្លាយជាវិទ្យាល័យអន្លង់វែង។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

## ១៤. ស្ពានតាម៉ុក

ស្ពាន តាម៉ុក ឬ ស្ពានអូរជីក ត្រូវបានសាងសង់ឡើងនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៦។ ស្ពាននេះស្ថិតនៅក្នុងភូមិអូរចិញ្ចៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅតាមបណ្ដោយផ្លូវពីអន្លង់វែងទៅព្រំដែនខ្មែរថៃ (ច្រកជាំសាង៉ាំ)។ ស្ពានមានចម្ងាយ២០០ម៉ែត្រពីរង្វង់មូលទីរួមស្រុកអន្លង់វែង។ ស្ពានត្រូវបានចំណាយអស់រយៈពេល២ឆ្នាំដើម្បីសាងសង់ ដោយប្រើគ្រឿងចក្រនិងបច្ចេកវិទ្យាពីប្រទេសថៃ។ មូលហេតុនៃការសាងសង់ស្ពានអូរជីកគឺដោយសារមានការលំបាកក្នុងការធ្វើដំណើរ និងដឹកជញ្ជូនវត្ថុផ្សេងៗ ដូចជាស្បៀងអាហារ និងគ្រាប់រំសេវកាត់អូរជីកនេះ។ ដូច្នេះ តាម៉ុកក៏បានរៀបចំសាងសង់ទំនប់ និងស្ពាននេះឡើង ដើម្បីសម្រួលដល់ការធ្វើចរាចរ។



តាម៉ុក បានបញ្ជាឲ្យសាងសង់ស្ពាននៅឆ្នាំ១៩៩៥ ដោយប្រើប្រាស់គ្រឿងចក្រដែលនាំចូលពីប្រទេសថៃ ដើម្បីសម្របសម្រួលការធ្វើដំណើរទៅមករវាងស្រុកអន្លង់វែង និងប្រទេសថៃ។ ស្ពាននេះស្ថិតនៅតាមបណ្ដោយផ្លូវទៅប៉ុស្តិ៍ត្រួតពិនិត្យជាំសាង៉ាំ ព្រំដែនថៃ ។ ប្រភពព័ត៌មានៈ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

### ព្រឹត្តិការណ៍សំខាន់៖

## ទីតាំងប្រវត្តិសាស្ត្របន្ថែម

### ១. រោងអារឈើ

នៅក្នុងឆ្នាំ១៩៩១ តាម៉ុក បានបង្កើតរោងចក្រអារឈើមួយ ដើម្បីផ្គត់ផ្គង់ឈើឲ្យកងទ័ពធ្វើផ្ទះ និង ជួញដូរជាមួយថៃ។ រោងអារឈើមានទីតាំងនៅក្នុងវត្តស្រះឈូក(បច្ចុប្បន្ន)។ ចេតិយរបស់ តាម៉ុក ត្រូវបានសាងសង់នៅក្នុងវត្តនេះដែរ។ រោងចក្រដ៏តូចនេះមិនអាចផ្គត់ផ្គង់ឈើបានគ្រប់គ្រាន់ទៅឲ្យប្រជាជនរាប់ម៉ឺននាក់ ដែលបានចុះពីជំរំ និងពីលើភ្នំមក ដើម្បីសាងសង់ផ្ទះទេ។ ដូច្នេះហើយ ប្រជាជនជាច្រើនបាននាំគ្នាកាប់ឈើដោយខ្លួនឯង។ កម្មាភិបាលខ្មែរក្រហមដែលធ្លាប់ធ្វើការនៅរោងអារឈើរួមមាន ហែម មាន, រ៉ែន, ទៀ, សុខ, និង មឿន។ ហែម គឺជាប្រធានរោងចក្រ។ រ៉ែនគឺជាអនុប្រធាន។ រោងចក្រនេះមានម៉ាស៊ីនអារឈើចំនួន២៤គ្រឿង ហើយឈើត្រូវបានកាប់មកពីព្រៃស្អាក។ សុខ គឺជាប្រធានកងកាប់ឈើ ហើយ មឿន ជាសមាជិកម្នាក់នៅក្នុងកងនោះ។ រោងចក្រអារឈើមានដំណើរការរហូតដល់ពេលដែលមានការប្រយុទ្ធគ្នានៅដើមឆ្នាំ១៩៩៨។ ក្រោយមកទៀត ម៉ាស៊ីននិងសម្ភារផ្សេងៗនៅក្នុងរោងចក្រត្រូវបានកងទ័ពយកទៅលក់។

### ព្រឹត្តិការណ៍សំខាន់៖

### ២. ចេតិយតាម៉ុក

ចេតិយនេះមានទីតាំងនៅក្នុងបរិវេណវត្ត និងមានស្រះទឹកមួយនៅចំខាងមុខ។ បើយោងទៅតាមព្រះចៅអធិការវត្ត ចេតិយមួយទៀតដែលនៅក្បែរគ្នានោះ គឺជាចេតិយរបស់មេជាងរបស់តាម៉ុក។ មេជាងនេះប្រហែលជាមិត្តភក្តិជិតស្និទ្ធរបស់គ្រួសារ តាម៉ុក។

### ព្រឹត្តិការណ៍សំខាន់៖

### ៣. ច្រកព្រំដែនដាំសាង៉ាំ

យោងតាមចាស់ៗជនជាតិថៃ ទីតាំងនេះត្រូវបានកំណត់ថាជាទីកន្លែងដែលភូមិសាង៉ាំធ្លាប់មានរួចមកហើយកាលពីជាង៧៥ឆ្នាំមុន។ ភូមិសាង៉ាំនេះ ត្រូវបានកត់ត្រាទុកដោយអ្នកគូរផែនទីជនជាតិបារាំង ដែលនៅពេលនោះកំពុងបង្កើតខ្សែបន្ទាត់ព្រំដែនរវាងកម្ពុជា-ថៃនៅចន្លោះឆ្នាំ១៩០៧ និងឆ្នាំ១៩០៩។ មានការជឿជាក់ថា ភូមិនេះត្រូវបានរាតត្បាតដោយសារជំងឺអាសន្នរោគ កាលពី៧៥ឆ្នាំមុន។ ក្រោយមកទៀត នៅពេលដែលតំបន់នេះបានធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ភូមិថ្កាមរមាសដែលនៅក្បែរនោះគឺជាទីតាំងសមរភូមិមុខភ្នំ៨០៨។ ច្រកព្រំដែនដាំសាង៉ាំត្រូវបានបើកឲ្យដំណើរការនៅឆ្នាំ២០០៤។ រៀងរាល់ព្រឹក នៅម៉ោង៧ ប្រជាជនកម្ពុជានាំគ្នាប្រញាប់ប្រញាល់ធ្វើដំណើរទៅផ្សារថៃនៅក្បែរច្រកព្រំដែន ដើម្បីទិញទំនិញល្អៗសម្រាប់ក្រុមគ្រួសាររបស់ខ្លួន និងសម្រាប់ប្រើប្រាស់ ឬលក់បន្តក្នុងរបររកស៊ីលក់ដូរផ្សេងៗ។ ផ្សារដែលមានជាច្រើនឆ្នាំមកហើយនេះ បានក្លាយជាគំរូដ៏គួរឲ្យចាប់អារម្មណ៍នៃការដោះដូរឆ្លងដែន។ ការដោះដូរបែបនេះមានតាំងពីយូរ ណាស់មកហើយ នៅក្នុងតំបន់នេះ។

### ព្រឹត្តិការណ៍សំខាន់៖

________________________________________

________________________________________

________________________________________

________________________________________



### សកម្មភាពទី២៖ ការសួរឆ្លើយជាមួយដៃគូ (កម្រិតងាយស្រួល)

**ការណែនាំ៖** អ្នកតម្រូវឲ្យមានដៃគូម្នាក់ក្នុងការធ្វើសកម្មភាព។ នៅពេលដែលអ្នកមានដៃគូ ម្នាក់ក្នុងចំណោមអ្នកទាំងពីរត្រូវបើកសៀវភៅ ម្នាក់ទៀតបិទសៀវភៅ។ អ្នកដែលបើកសៀវភៅ ត្រូវជ្រើសរើសទីតាំងប្រវត្តិសាស្ត្រមួយ ធ្វើការពណ៌នាពីទីតាំងទៅកាន់ដៃគូដែលបិទសៀវភៅវិញ ដោយមិនប្រាប់ពីឈ្មោះទីតាំង។ បន្ទាប់មក អ្នកដែលបិទសៀវភៅត្រូវទាយឈ្មោះរបស់ទីតាំង។ អនុវត្តសកម្មភាពលើទីតាំងប្រវត្តិសាស្ត្រ១ ទៅ២កន្លែងបន្ទាប់មកត្រូវផ្លាស់ប្តូរវេនគ្នាម្តង។

រូបខាងលើ៖ ក្បួនដង្ហែបុណ្យសពរបស់ តាម៉ុក នៅឆ្នាំ២០០៦។
រូបខាងស្តាំ៖ ចេតិយរបស់ តាម៉ុក នៅអន្លង់វែង។
ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។



### សកម្មភាពទី៣៖ ការសួរឆ្លើយជាមួយដៃគូ (កម្រិតពិបាក)

**ការណែនាំ៖** អ្នកតម្រូវឲ្យមានដៃគូម្នាក់ក្នុងការធ្វើសកម្មភាព។ នៅពេលដែលអ្នកមានដៃគូ ម្នាក់ក្នុងចំណោមអ្នកទាំងពីរត្រូវបើកសៀវភៅ ម្នាក់ទៀតបិទសៀវភៅ។ អ្នកដែលបើកសៀវភៅត្រូវជ្រើសរើសទីតាំងប្រវត្តិសាស្ត្រមួយកន្លែង ប្រាប់ឈ្មោះទីតាំងទៅកាន់អ្នកដែលបិទសៀវភៅ។ អ្នកដែលបិទសៀវភៅត្រូវនិយាយរៀបរាប់ពីព័ត៌មានទាំងឡាយ ដែលខ្លួនបានដឹងស្តីពីទីតាំងប្រវត្តិសាស្ត្រ។ អ្នកបើកសៀវភៅអាចបន្ថែម ឬកែតម្រូវព័ត៌មានដែលខ្វះខាត។ ផ្លាស់ប្តូរវេនគ្នាក្នុងការអនុវត្តរហូតដល់បានអនុវត្តលើគ្រប់ទីតាំងប្រវត្តិសាស្ត្រ។



ទេសភាពអមដោយរូបចម្លាក់អ្នកតាព្រាហ្មណ៍នៅលើចំណោទភ្នំពយតារួន។
ថតដោយ គ្រីស្តូហ្វ័រ ឌៀរីង ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

# ជំពូកទី៤
# ផែនការបង្រៀន

## ផ្នែកទី១៖ សេចក្តីណែនាំ

ផែនការបង្រៀនខាងក្រោម គួរតែប្រើប្រាស់ជាមួយខ្លឹមសារសង្ខេបនៃជំពូកមុនៗក្នុងសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ (ការរៀបរាប់ពីប្រវត្តិសាស្ត្រ និងសាច់រឿង)។ គ្រូបង្រៀនលើកទឹកចិត្តឲ្យប្រើប្រាស់ផែនការបង្រៀនខាងក្រោមប្រសិនបើយល់ថាចាំបាច់ និងអាចជ្រើសរើសប្រើប្រាស់ផែនការបង្រៀនទាំងមូល ឬមួយផ្នែកនៃផែនការបង្រៀនក៏បាន និងធ្វើការកែសម្រួលផែនការបង្រៀនដើម្បីបំពេញតម្រូវការ ក៏ដូចជាទាក់ទាញចំណាប់អារម្មណ៍របស់សិស្សានុសិស្ស។ ជារួមផែនការបង្រៀនគ្រាន់តែជាចំណុចចាប់ផ្តើម ដែលយើងស្នើឡើងសម្រាប់គ្រូបង្រៀនតែប៉ុណ្ណោះនិងធ្វើការពិនិត្យលើផែនការឡើងវិញ ដើម្បីមានគំនិតក្នុងការរៀបចំកម្មវិធីសិក្សាឲ្យស្របទៅតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ផ្នែកទី២៖ ផែនការបង្រៀន

### ប្រធានបទទី១៖ ប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា

### មេរៀនទី១៖ ការស្វែងយល់ពីប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា

គោលបំណង៖

១. សិស្សនឹងយល់ដឹងពីព្រឹត្តិការណ៍សំខាន់ៗនៃប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា។
២. សិស្សនឹងអាចរៀបចំព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទៅជាគម្រោងសិក្សាស្តីពីចលនាកុម្មុយនីស្តកម្ពុជា។
៣. សិស្សនឹងពិនិត្យឡើងវិញនូវគម្រោងសិក្សារបស់ខ្លួនស្តីពីប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា។

សកម្មភាព៖ ការអាន ការកត់ត្រា និងការប្រៀបធៀបគម្រោងសិក្សា

បរិក្ខារសិក្សាសម្រាប់សិស្ស៖ ក្រដាសកត់ត្រា ប៊ិច ឬខ្មៅដៃ

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូពន្យល់ទៅកាន់សិស្សថា គាត់នឹងអានអត្ថបទស្តីពីប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា។ គ្រូគួរតែប្រាប់សិស្សឲ្យយកចិត្តទុកដាក់ និងកត់ត្រាទុកពីព្រោះគ្រូនឹងសួរសំណួរអំពីអត្ថបទ។
២. គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹកចេញ ដើម្បីត្រៀមកត់ត្រាព័ត៌មាន។
៣. គ្រូចាប់ផ្តើមអានអត្ថបទដំបូង ដែលមាននៅក្នុងសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ស្តីពីប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា ខណៈពេលដែលសិស្សធ្វើការកត់ត្រាទុក។
៤. នៅពេលដែលគ្រូបញ្ចប់ការអាន គ្រូនឹងផ្តល់រយៈពេល១០នាទីឲ្យសិស្សពិនិត្យឡើងវិញនូវអ្វីដែលខ្លួនបានកត់ត្រាទុក។
៥. ១០នាទីក្រោយមក គ្រូប្រាប់ឲ្យសិស្សរកដៃគូម្នាក់ ដើម្បីប្តូរវេនគ្នាក្នុងការសាកសួរពីកំណត់ត្រារបស់គ្នាទៅវិញទៅមក។
៦. ១០នាទីក្រោយមកទៀត គ្រូសួរទៅកាន់សិស្សថា តើសិស្សទាំងអស់មានសំណួរអ្វីទៀតឬទេ។

### មេរៀនទី២៖ ការវាយតម្លៃរបស់សិស្សដោយខ្លួនឯងស្តីពីការយល់ដឹងចំពោះប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា

គោលបំណង៖

១. សិស្សនឹងពិចារណាពីប្រភេទសំណួរ ដែលខ្លួនអាចប្រើប្រាស់បាន ដើម្បីធ្វើការវាយតម្លៃពីការយល់ដឹងរបស់ខ្លួនឯង ស្តីពីប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា។

២. សិស្សនឹងវាយតម្លៃពីការយល់ដឹងរបស់គ្នាទៅវិញទៅមកស្តីពីប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា។

៣. សិស្សនឹងធ្វើការវាយតម្លៃពីការយល់ដឹងអំពីប្រវត្តិចលនាកុម្មុយនីស្តកម្ពុជារបស់ខ្លួនឯង។

សកម្មភាព៖ ការបង្កើតកម្រងសំណួរ សំណួរនិងចម្លើយ

បរិក្ខារសិក្សាសម្រាប់សិស្ស៖ ក្រដាសកត់ត្រា ប៊ិច ឬខ្មៅដៃ

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូប្រាប់ទៅកាន់សិស្សថា ម្នាក់ៗនឹងមានពេល១០នាទី ដើម្បីបង្កើតសំណួរអំពីប្រវត្តិកុម្មុយនីស្តកម្ពុជា ដែលខ្លួនគិតថាមានសារៈសំខាន់ឲ្យបានយ៉ាងតិច១០។ សិស្សត្រូវសរសេរសំណួរនៅលើក្រដាសមួយសន្លឹក ហើយសរសេរចម្លើយលើក្រដាសមួយសន្លឹកទៀត។ ១០នាទីក្រោយ សិស្សនឹងស្វែងរកដៃគូម្នាក់ដើម្បីផ្លាសប្តូរកម្រងសំណួរគ្នាទៅវិញទៅមក។

២. សិស្សធ្វើការបង្កើតសំណួររៀងៗខ្លួន។

៣. ១០នាទីក្រោយមក គ្រូប្រាប់សិស្សឲ្យរើសដៃគូម្នាក់ ផ្លាសប្តូរកម្រងសំណួរគ្នាទៅវិញទៅមក។ សិស្សមានពេលវេលាតែ៥ ទៅ១០នាទីតែប៉ុណ្ណោះក្នុងការឆ្លើយសំណួរ។

៤. ១០នាទីក្រោយមក សិស្សឲ្យកម្រងសំណួរដែលឆ្លើយរួចទៅគ្នាវិញ ចាប់ផ្តើមកែ និងដាក់ពិន្ទុឲ្យគ្នាទៅវិញទៅមក។

៥. គ្រូប្រាប់សិស្សឲ្យរាយការណ៍ពីសំណួរ ដែលខ្លួនឆ្លើយខុស។



កញ្ញា ស្រីល័ក្ខ ជាសិស្សមកពីវិទ្យាល័យឫស្សីកែវ ក្រុងភ្នំពេញ កំពុងទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។ ស្រីល័ក្ខ និយាយថា «ឪពុកម្តាយខ្ញុំធ្លាប់ប្រាប់ថា ខ្មែរក្រហមបានបង្ខំគាត់ឲ្យហូបជីដែលធ្វើពីលាមកសត្វនិងមនុស្ស និងធ្វើទារុណកម្ម ប៉ុន្តែខ្ញុំជឿតែពាក់កណ្តាលប៉ុណ្ណោះ ព្រោះខ្ញុំមិនបានកើតនៅសម័យនោះ។ ខ្ញុំស្មានមិនដល់ថារឿងបែបនេះអាចកើតឡើងបានសោះ។» ថតដោយ ម៉ម កល្យាណី, បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។



### សកម្មភាពទី៣៖ ការវាយតម្លៃ និងការវាស់ស្ទង់ការយល់ដឹងរបស់សិស្ស

បរិក្ខារសិក្សាសម្រាប់សិស្ស៖ កម្រងសំណួរខាងក្រោម

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូសរសេរសំណួរខាងក្រោមនៅលើក្តារខៀន បន្ទាប់មកប្រាប់ឲ្យសិស្សកត់ត្រាតាម។

២. នៅពេលដែលសិស្សបានកត់សំណួររួចរាល់ គ្រូប្រាប់សិស្សឲ្យចំណាយពេល១០នាទី ដើម្បីឆ្លើយសំណួរ។

៣. ១០នាទីក្រោយមក គ្រូប្រាប់សិស្សឲ្យប្តូរក្រដាសសំណួរ ដែលបានឆ្លើយរួចជាមួយអ្នកដែលនៅក្បែរ បន្ទាប់មកឲ្យសិស្សកែ និងដាក់ពិន្ទុលើក្រដាសសំណួរនោះ។

៤. គ្រូអានចម្លើយ ឬសួររកចម្លើយពីសិស្ស។

៥. នៅពេលកែ និងដាក់ពិន្ទុលើក្រដាសសំណួររួច គ្រូនិងប្រាប់សិស្សឲ្យកត់ពិន្ទុដាក់នៅលើក្រដាសសំណួរ។ គ្រូអាចប្រមូលក្រដាស ឬឲ្យសិស្សជាអ្នកទុក។

## ប្រធានបទទី២៖ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

### មេរៀនទី១៖ ការស្វែងយល់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

គោលបំណង៖

១. សិស្សនឹងយល់ដឹងពីព្រឹត្តិការណ៍សំខាន់ៗ ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។

២. សិស្សនឹងអាចរៀបចំព្រឹត្តិការណ៍ដែលកើតមានឡើង ទៅជាគម្រោងសិក្សាស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។

៣. សិស្សនឹងរំឭកឡើងវិញនូវគម្រោងសិក្សារបស់ខ្លួន ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។

សកម្មភាព៖ ការអាន ការកត់ត្រា និងការប្រៀបធៀបគម្រោងសិក្សា

បរិក្ខារសិក្សាសម្រាប់សិស្ស៖ ក្រដាសកត់ត្រា ប៊ិច ឬខ្មៅដៃ

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូពន្យល់ទៅកាន់សិស្សថា គ្រូនឹងអានអត្ថបទស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ គ្រូគួរតែប្រាប់សិស្សឲ្យយកចិត្តទុកដាក់ និងកត់ត្រាទុក ពីព្រោះគ្រូនឹងសួរសំណួរអំពីអត្ថបទ។

២. គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹកចេញ ដើម្បីត្រៀមកត់ត្រាព័ត៌មាន។

៣. គ្រូចាប់ផ្តើមអានអត្ថបទដំបូងដែលមាននៅក្នុងសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យខណៈពេលដែលសិស្សធ្វើការកត់ត្រាទុក។

៤. នៅពេលដែលគ្រូបញ្ចប់ការអាន គ្រូនឹងផ្តល់រយៈពេល១០នាទីឲ្យសិស្សពិនិត្យឡើងវិញ នូវអ្វីដែលខ្លួនបានកត់ត្រាទុក។



លោកគ្រូ ឈឹម ឌីណា កំពុងបង្រៀនគំរូអំពីមេរៀនមួយ ក្នុង«សៀវភៅណែនាំសម្រាប់គ្រូបង្រៀន»។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

៥. ១០នាទីក្រោយមក គ្រូប្រាប់ឲ្យសិស្សរកដៃគូម្នាក់ ដើម្បីប្តូរវេនគ្នាក្នុងការសាកសួរ ពីកំណត់ត្រារបស់គ្នាទៅវិញទៅមក។
៦. ១០នាទីក្រោយមកទៀត គ្រូសួរទៅកាន់សិស្សថា តើសិស្សទាំងអស់មានសំណួរអ្វីទៀតឬទេ។

## មេរៀនទី២៖ ការវិភាគអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

គោលបំណង៖

១. សិស្សនឹងធ្វើការស្វែងយល់ពីបទពិសោធន៍របស់បុគ្គលម្នាក់មួយចំនួន ដែលធ្លាប់រស់នៅឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ។
២. សិស្សនឹងធ្វើការវាយតម្លៃពីបទពិសោធន៍របស់បុគ្គលម្នាក់ៗ ដែលរស់នៅឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ។
៣. សិស្សនឹងធ្វើការពន្យល់ពីមូលហេតុ ដែលធ្វើអោយសាច់រឿងមានសារៈសំខាន់។

សកម្មភាព៖ ការកត់ត្រា ការសរសេរ និងការធ្វើបទបង្ហាញ

បរិក្ខារសិក្សាសម្រាប់សិស្ស៖ ក្រដាសកត់ត្រា ប៊ិច ឬខ្មៅដៃ

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូពន្យល់ទៅកាន់សិស្សថា គ្រូនឹងឲ្យសិស្សម្នាក់ៗអានសាច់រឿងខុសៗគ្នា ស្តីពីប្រវត្តិរបស់បុគ្គល ដែលធ្លាប់រស់នៅឆ្លងកាត់របបខ្មែរក្រហមឲ្យឮៗ ម្នាក់ម្តងៗ។ គ្រូគួរប្រាប់សិស្សដទៃឲ្យធ្វើការកត់ត្រាឲ្យបានល្អ នៅពេលដែលសិស្សម្នាក់កំពុងអាន ព្រោះខ្លួននឹងត្រូវប្រើប្រាស់កំណត់ត្រា សម្រាប់ធ្វើកិច្ចការក្រោយៗទៀត។
២. គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹកចេញដើម្បីត្រៀមកត់ត្រាព័ត៌មាន។
៣. គ្រូជ្រើសរើសសិស្សម្នាក់ ឲ្យអានសាច់រឿងនៅក្នុងជំពូក២ ផ្នែកទី៣។ គ្រូឲ្យសៀវភៅណែនាំសម្រាប់មគ្គុទេសក៍ទេសចរណ៍ទៅសិស្សម្នាក់ដើម្បីអានសាច់រឿងនៅក្នុងជំពូកទី៣ទៅកាន់សិស្សដទៃទៀត សិស្សដទៃទៀតត្រូវព្យាយាមកត់ត្រា។
៤. ក្រោយពីអានសាច់រឿងមួយចប់ គ្រូហៅសិស្សម្នាក់ទៀតដើម្បីសង្ខេបសាច់រឿងដែលបានអាន។
៥. នៅពេលដែលសិស្សបានអានសាច់រឿងចប់ គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹកដើម្បីសរសេរអំពីចំណាប់អារម្មណ៍របស់ខ្លួន ដែលមានប្រវែងមួយទំព័រ អំពីសាច់រឿងណាមួយដែលខ្លួនគិតថាមានសារៈសំខាន់ និងអំពីមូលហេតុដែលខ្លួនគិតដូច្នោះ។ សិស្សមានពេល ១៥នាទីដើម្បីសរសេរចំណាប់អារម្មណ៍។
៦. ១៥នាទីក្រោយមក គ្រូអាចប្រាប់ឲ្យសិស្សចំនួនពីរ ឬបីនាក់អានចំណាប់អារម្មណ៍របស់ខ្លួនទៅកាន់សិស្សគ្នា។
៧. គ្រូប្រាប់ឲ្យសិស្សរក្សាទុកក្រដាសកត់ត្រារបស់ខ្លួន សម្រាប់ប្រើប្រាស់ក្នុងកិច្ចការក្រោយទៀត។



យុទ្ធភណ្ឌមិនទាន់ផ្ទុះ ដែលត្រូវបានរកឃើញនៅតំបន់ជនបទ។
ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

## មេរៀនទី៣៖ សេចក្តីរាយការណ៍អំស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

គោលបំណង៖

១. សិស្សនឹងរំឭកឡើងវិញនូវប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។
២. សិស្សនឹងវាយតម្លៃពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។
៣. សិស្សនឹងពន្យល់ពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។

សកម្មភាព៖ ការកត់ត្រា ការសរសេរ និងការធ្វើបទបង្ហាញ

បរិក្ខារសិក្សាសម្រាប់សិស្ស៖ ក្រដាសកត់ត្រា ប៊ិច ឬខ្មៅដៃ

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូពន្យល់ទៅកាន់សិស្សថា គ្រូនឹងអានអត្ថបទស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ គ្រូគួរតែប្រាប់សិស្សឲ្យយកចិត្តទុកដាក់ និងកត់ត្រាទុក ពីព្រោះសិស្សនឹងត្រូវការព័ត៌មាន ដើម្បីសរសេរអត្ថបទមួយរាយការណ៍ពីព្រឹត្តិការណ៍ ដែលកើតមានឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។
២. គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹកចេញមកក្រៅ ដើម្បីកត់ត្រាពេលគ្រូអាន។
៣. គ្រូអានអត្ថបទអំពីប្រវត្តិកម្ពុជាប្រជាធិបតេយ្យ ដែលមាននៅក្នុងសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ខណៈពេលដែលសិស្សកត់ត្រាទុក។
៤. នៅពេលដែលគ្រូអានចប់ គ្រូប្រាប់សិស្សឲ្យយកក្រដាសថ្មីមួយសន្លឹកទៀតចេញមក។ គ្រូប្រាប់សិស្សឲ្យយកក្រដាស ដែលសរសេរពីចំណាប់អារម្មណ៍លើសាច់រឿងកាលពីមេរៀនមុនចេញមកក្រៅ។ គ្រូពន្យល់ទៅសិស្សថា សិស្សគួរសន្មតថាខ្លួនជាអ្នករាយការណ៍ព័ត៌មានឲ្យកាសែតក្នុងស្រុកម្នាក់ ខ្លួនមានតួនាទីសរសេរអត្ថបទមួយស្តីពីអ្វីដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សិស្សមានពេល១៥ទៅ២០នាទី ដើម្បីសរសេរអត្ថបទ។ សិស្សលើកទឹកចិត្តឲ្យប្រើប្រាស់សាច់រឿង ដែលខ្លួនបានរៀនកាលពីមេរៀនមុនយកមកប្រើប្រាស់នៅក្នុងអត្ថបទ។
៥. បន្ទាប់ពី១៥ទៅ២០នាទីក្រោយមក គ្រូប្រាប់សិស្សឲ្យអានអត្ថបទទៅកាន់សិស្សដទៃទៀត។

## សកម្មភាពទី៤៖ ការវាយតម្លៃ និងវាស់ស្ទង់ពីការយល់ដឹងរបស់សិស្ស

បរិក្ខារសម្រាប់សិស្ស៖ កម្រងសំណួរខាងក្រោម

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ប្រាប់ឲ្យសិស្សកត់ត្រាតាម។
២. នៅពេលដែលសិស្សបានកត់សំណួររួចរាល់ គ្រូប្រាប់សិស្សឲ្យចំណាយពេល១០នាទី ដើម្បីឆ្លើយសំណួរ។
៣. ១០នាទីក្រោយមក គ្រូប្រាប់សិស្សឲ្យប្តូរក្រដាសសំណួរ ដែលបានឆ្លើយរួចជាមួយអ្នកដែលនៅក្បែរខ្លួន ឲ្យសិស្សកែ និងដាក់ពិន្ទុលើក្រដាសសំណួរ។
៤. គ្រូអានចម្លើយ ឬសួររកចម្លើយពីសិស្ស។
៥. នៅពេលដែលកែ និងដាក់ពិន្ទុលើក្រដាសសំណួររួច គ្រូប្រាប់សិស្សឲ្យកត់ពិន្ទុដាក់នៅលើក្រដាសសំណួរ។ គ្រូអាចប្រមូលក្រដាស ឬឲ្យសិស្សជាអ្នកទុក។

## ប្រធានបទទី៣៖ ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី១)

### មេរៀនទី១៖ ការស្វែងយល់ពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង

គោលបំណង៖

១. សិស្សនឹងយល់ដឹងពីព្រឹត្តិការណ៍សំខាន់ៗ ស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី១)។
២. សិស្សនឹងអាចរៀបចំព្រឹត្តិការណ៍ទៅជាគម្រោងសម្រាប់សិក្សាស្តីពីប្រវត្តិសហគមន៍អន្លង់វែង (ផ្នែកទី១)។
៣. សិស្សនឹងរំឭកឡើងវិញនូវគម្រោងសម្រាប់សិក្សាពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី១)។

សកម្មភាព៖ ការអាន ការកត់ត្រា និងការប្រៀបធៀបគម្រោងសិក្សា

បរិក្ខារសម្រាប់សិស្ស៖ ក្រដាសកត់ត្រា ប៊ិច ឬខ្មៅដៃ

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូពន្យល់ទៅកាន់សិស្សថា គ្រូនឹងអានអត្ថបទស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី១)។ គ្រូគួរតែប្រាប់សិស្សឲ្យយកចិត្តទុកដាក់និងកត់ត្រាទុកពីព្រោះគ្រូនឹងសួរសំណួរអំពីអត្ថបទ។
២. គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹកចេញ ដើម្បីត្រៀមកត់ត្រាព័ត៌មាន។
៣. គ្រូចាប់ផ្តើមអានអត្ថបទដំបូង ដែលមាននៅក្នុងសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ស្តីពីប្រវត្តិកម្ពុជាប្រជាធិបតេយ្យ ខណៈពេលដែលសិស្សធ្វើការកត់ត្រាទុក។
៤. នៅពេលដែលគ្រូបញ្ចប់ការអាន គ្រូនឹងផ្តល់រយៈពេល១០នាទីឲ្យសិស្សពិនិត្យឡើងវិញនូវអ្វីដែលខ្លួនបានកត់ត្រាទុក។
៥. ១០នាទីក្រោយមក គ្រូប្រាប់ឲ្យសិស្សរកដៃគូម្នាក់ ដើម្បីប្តូរវេនគ្នាក្នុងការសាកសួរពីកំណត់ត្រារបស់គ្នាទៅវិញទៅមក។
៦. ១០នាទីក្រោយមកទៀត គ្រូសួរទៅកាន់សិស្សថា តើសិស្សទាំងអស់មានសំណួរអ្វីទៀតឬទេ។

### មេរៀនទី២៖ ការវិភាគស្តីអំពីការរត់គេច បន្លាស់ទី និងការរួចរស់រានមានជីវិតរបស់ប្រជាជន នៅភ្លាមៗក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ

គោលបំណង៖

១. សិស្សនឹងធ្វើការស្វែងយល់ពីបទពិសោធន៍របស់បុគ្គលមួយចំនួន ដែលរស់នៅក្នុងអំឡុងពេលនៃការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។
២. សិស្សនឹងធ្វើការវាយតម្លៃពីបទពិសោធន៍របស់បុគ្គលម្នាក់ៗដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។
៣. សិស្សនឹងធ្វើការពន្យល់ពីមូលហេតុ ដែលធ្វើឲ្យសាច់រឿងមានសារៈសំខាន់។

សកម្មភាព៖ ការកត់ត្រា ការសរសេរ និងការធ្វើបទបង្ហាញ

បរិក្ខារសម្រាប់សិស្ស៖ ក្រដាសកត់ត្រា ប៊ិច ឬខ្មៅដៃ

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូពន្យល់ទៅកាន់សិស្សថា គាត់នឹងឲ្យសិស្សម្នាក់ៗអានសាច់រឿងខុសៗគ្នាស្តីពីប្រវត្តិរបស់បុគ្គលដែលធ្លាប់រស់នៅឆ្លងកាត់ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យឲ្យឮៗម្នាក់ម្តងៗ។ គ្រូគួរប្រាប់សិស្សដទៃឲ្យធ្វើការកត់ត្រាឲ្យបានល្អនៅពេលដែលសិស្សម្នាក់កំពុងអានព្រោះខ្លួននឹងត្រូវប្រើប្រាស់កំណត់ត្រា សម្រាប់ធ្វើកិច្ចការក្រោយៗទៀត។
២. គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹកចេញ ដើម្បីត្រៀមកត់ត្រាព័ត៌មាន។
៣. គ្រូជ្រើសរើសសិស្សម្នាក់ឲ្យអានសាច់រឿងនៅក្នុងជំពូក២ ផ្នែកទី៤។ គ្រូឲ្យសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ទៅសិស្សម្នាក់ ដើម្បីអានសាច់រឿងនៅក្នុងជំពូកទៅកាន់សិស្សដទៃទៀត សិស្សដទៃទៀតត្រូវព្យាយាមកត់ត្រា។
៤. ក្រោយពីអានសាច់រឿងមួយចប់ គ្រូហៅសិស្សម្នាក់ទៀត ដើម្បីសង្ខេបសាច់រឿងដែលបានអាន។
៥. នៅពេលដែលសិស្សបានអានសាច់រឿងចប់ គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹកចេញ ដើម្បីសរសេរពីចំណាប់អារម្មណ៍របស់ខ្លួនប្រវែងមួយទំព័រ អំពីសាច់រឿងណាមួយដែលគិតថាមានសារៈសំខាន់និងអំពីមូលហេតុដែលខ្លួនគិតដូច្នោះ។ សិស្សមានពេល១៥នាទីដើម្បីសរសេរចំណាប់អារម្មណ៍។
៦. ១៥នាទីក្រោយមក គ្រូអាចប្រាប់ឲ្យសិស្សចំនួនពីរ ឬបីនាក់អានចំណាប់អារម្មណ៍របស់ខ្លួន ទៅកាន់សិស្ស។
៧. គ្រូបាប្រ់ឲ្យសិស្សរក្សាទុកក្រដាសកត់ត្រារបស់ខ្លួន សម្រាប់ប្រើប្រាស់ក្នុងកិច្ចការក្រោយទៀត។


អ្នកស្រី មុំ ម៉េត ដែលជាគ្រូបង្រៀនជំនាន់មុន កំពុងនិយាយជាមួយសិក្ខាកាមដែលជាគ្រូបង្រៀនដូចគ្នា នៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានធ្វើឡើងនៅឆ្នាំ២០១៦។
ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

### មេរៀនទី៣៖ ការវាយតម្លៃដោយខ្លួនឯងរបស់សិស្ស ស្តីពីការយល់ដឹងពីប្រវត្តិសហគមន៍អន្លង់វែង (ផ្នែកទី១)

គោលបំណង៖

១. សិស្សនឹងពិចារណាពីប្រភេទសំណួរ ដែលខ្លួនអាចប្រើប្រាស់បាន ដើម្បីធ្វើការវាយតម្លៃពីការយល់ដឹងរបស់ខ្លួន ស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី១)។
២. សិស្សនឹងវាយតម្លៃពីការយល់ដឹងរបស់គ្នាទៅវិញទៅមក ស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង(ផ្នែកទី១)។
៣. សិស្សនឹងវាយតម្លៃពីការយល់ដឹងរបស់ខ្លួន ស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី១)។

សកម្មភាព៖ ការបង្កើតសំណួរ ការសួរ និងការឆ្លើយ

បរិក្ខារសម្រាប់សិស្ស៖ ក្រដាសកត់ត្រា ប៊ិច ឬខ្មៅដៃ

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូពន្យល់ទៅកាន់សិស្សថា គ្រូនឹងអានអត្ថបទស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី១)។ គ្រូគួរតែប្រាប់សិស្សឲ្យយកចិត្តទុកដាក់ និងកត់ត្រាពីព្រោះគ្រូនឹងសួរសំណួរអំពីអត្ថបទ។

២. គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹកចេញ ដើម្បីត្រៀមកត់ត្រាព័ត៌មានដែលគ្រូបានអាន។

៣. គ្រូប្រាប់ទៅកាន់សិស្សថា ម្នាក់ៗនឹងមានពេល១០នាទី ដើម្បីបង្កើតសំណួរពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី១) ដែលខ្លួនគិតថាមានសារៈសំខាន់ឲ្យបានយ៉ាងតិច១០។ សិស្សត្រូវសរសេរសំណួរនៅលើក្រដាសមួយសន្លឹក ចម្លើយលើក្រដាសមួយសន្លឹកទៀត។ ១០នាទីក្រោយមក សិស្សនឹងស្វែងរកដៃគូម្នាក់ ដើម្បីផ្លាសប្តូរកម្រងសំណួរគ្នាទៅវិញទៅមក។



កម្មវិធីចែកសៀវភៅ «អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជូនដល់សិស្សានុសិស្ស គ្រូបង្រៀន និងសមាជិកសហគមន៍អន្លង់វែង ដែលប្រព្រឹត្តឡើងនៅឆ្នាំ២០១២។
ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

៤. សិស្សបង្កើតសំណួររៀងៗខ្លួន។

៥. ១០នាទីក្រោយមក គ្រូប្រាប់សិស្សឲ្យរើសដៃគូម្នាក់ ផ្លាស់ប្តូរកម្រងសំណួរគ្នាទៅវិញទៅមក។ សិស្សមានពេលវេលាតែ៥ ទៅ១០នាទីតែប៉ុណ្ណោះក្នុងការឆ្លើយសំណួរ។

៦. ១០នាទីក្រោយមក សិស្សឲ្យកម្រងសំណួរដែលឆ្លើយរួចទៅគ្នាវិញ ចាប់ផ្តើមកែ និងដាក់ពិន្ទុឲ្យគ្នាទៅវិញទៅមក។

៧. គ្រូអាចប្រាប់សិស្សឲ្យរាយការណ៍ពីសំណួរដែលខ្លួនឆ្លើយខុស។

## សកម្មភាពទី៤៖ ការវាយតម្លៃ និងការវាស់ស្ទង់ពីការយល់ដឹងរបស់សិស្ស

បរិក្ខារសម្រាប់សិស្ស៖ តារាងសំណួរខាងក្រោម

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូសរសេរសំណួរខាងក្រោមនៅលើក្តារខៀន បន្ទាប់មកប្រាប់ឲ្យសិស្សកត់ត្រាតាម។

២. នៅពេលដែលសិស្សបានកត់សំណួររួចរាល់ គ្រូប្រាប់សិស្សឲ្យចំណាយពេល១០នាទីដើម្បីឆ្លើយសំណួរ។

៣. ១០នាទីក្រោយមក គ្រូប្រាប់សិស្សឲ្យប្តូរក្រដាសសំណួរ ដែលបានឆ្លើយរួចជាមួយអ្នកដែលនៅក្បែរខ្លួន ឲ្យសិស្សកែនិងដាក់ពិន្ទុលើក្រដាសសំណួរ។

៤. គ្រូអានចម្លើយ ឬសួររកចម្លើយពីសិស្ស។

៥. នៅពេលដែលកែ និងដាក់ពិន្ទុលើក្រដាសសំណួររួច គ្រូប្រាប់សិស្សឲ្យកត់ពិន្ទុដាក់នៅលើក្រដាសសំណួរ។ គ្រូអាចប្រមូលក្រដាសឬឲ្យសិស្សជាអ្នកទុក។

# ប្រធានបទទី៤៖ ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី២)

## មេរៀនទី១៖ ការស្វែងយល់ពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី២)

គោលបំណង៖

១. សិស្សនឹងយល់ដឹងពីព្រឹត្តិការណ៍សំខាន់ៗ ស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី២)។

២. សិស្សនឹងអាចរៀបចំព្រឹត្តិការណ៍ ទៅជាគម្រោងសម្រាប់សិក្សាស្តីពីប្រវត្តិសហគមន៍អន្លង់វែង (ផ្នែកទី២)។

៣. សិស្សនឹងរំឭកឡើងវិញនូវគម្រោងសម្រាប់សិក្សាពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី២)។

សកម្មភាព៖ ការអាន ការកត់ត្រា និងការប្រៀបធៀបគម្រោងសិក្សា

បរិក្ខារសិក្សាសម្រាប់សិស្ស៖ ក្រដាសកត់ត្រា ប៊ិច ឬខ្មៅដៃ

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូពន្យល់ទៅកាន់សិស្សថា គ្រូនឹងអានអត្ថបទស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង(ផ្នែកទី២)។ គ្រូគួរតែប្រាប់សិស្សឲ្យយកចិត្តទុកដាក់ និងកត់ត្រាទុក ពីព្រោះគ្រូនឹងសួរសំណួរអំពីអត្ថបទ។

២. គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹកចេញដើម្បីត្រៀមកត់ត្រាព័ត៌មាន។

៣. គ្រូចាប់ផ្តើមអានអត្ថបទដំបូង ដែលមាននៅក្នុងសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ខណៈពេលដែលសិស្សធ្វើការកត់ត្រាទុក។

៤. នៅពេលដែលគ្រូបញ្ចប់ការអាន គ្រូនឹងផ្តល់រយៈពេល១០នាទីឲ្យសិស្សពិនិត្យឡើងវិញនូវអ្វីដែលខ្លួនបានកត់ត្រាទុក។

៥. ១០នាទីក្រោយមក គ្រូប្រាប់ឲ្យសិស្សរកដៃគូម្នាក់ដើម្បីប្តូរវេនគ្នាក្នុងការសាកសួរពីកំណត់ត្រារបស់គ្នាទៅវិញទៅមក។

៦. ១០នាទីក្រោយមកទៀត គ្រូសួរទៅកាន់សិស្សថា តើសិស្សទាំងអស់មានសំណួរអ្វីទៀតឬទេ។

## មេរៀនទី២៖ ការវិភាគស្តីពីសាច់រឿងទាក់ទងនឹងជម្លោះ ការរួចរស់មានជីវិត និងជីវិតរស់នៅក្នុងជំរំឃោជាខ្មែរក្រហម

គោលបំណង៖

១. សិស្សនឹងធ្វើការស្វែងយល់ពីបទពិសោធន៍បុគ្គលមួយចំនួនដែលរស់នៅក្នុងអំឡុងពេលនៃការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។

២. សិស្សនឹងធ្វើការវាយតម្លៃពីបទពិសោធន៍របស់បុគ្គលម្នាក់ៗ ដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

៣. សិស្សនឹងធ្វើការពន្យល់ពីមូលហេតុដែលធ្វើឲ្យសាច់រឿងមានសារៈសំខាន់។

សកម្មភាព៖ ការកត់ត្រា ការសរសេរ និងការធ្វើបទបង្ហាញ

បរិក្ខារសម្រាប់សិស្ស៖ ក្រដាសកត់ត្រា ប៊ិច ឬខ្មៅដៃ

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូពន្យល់ទៅកាន់សិស្សថា គ្រូនឹងឲ្យសិស្សម្នាក់ៗអានសាច់រឿងខុសៗគ្នាស្តីពីប្រវត្តិរបស់ប្រជាជនអន្លង់វែង ដែលបានតស៊ូនៅចន្លោះឆ្នាំ១៩៧៩ និងឆ្នាំ១៩៨៩ ឲ្យឮៗ ម្នាក់ម្តងៗ។ គ្រូគួរប្រាប់សិស្សដទៃឲ្យធ្វើការកត់ត្រាឲ្យបានល្អនៅពេលដែលសិស្សម្នាក់កំពុងអាន ព្រោះខ្លួននឹងត្រូវប្រើប្រាស់កំណត់ត្រា សម្រាប់ធ្វើកិច្ចការក្រោយៗទៀត។

២. គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹកចេញ ដើម្បីត្រៀមកត់ត្រាព័ត៌មាន។

៣. គ្រូជ្រើសរើសសិស្សមួយចំនួនឲ្យអានសាច់រឿងពី២ ទៅ៤រឿងនៅក្នុងជំពូកទី២ ផ្នែកទី៥ និងពី២ ទៅ៤ សាច់រឿងទៀតនៅក្នុងជំពូកទី២ ផ្នែកទី៦។ គ្រូឲ្យសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ទៅសិស្សម្នាក់ ដើម្បីអានសាច់រឿងនៅក្នុងជំពូកទៅកាន់សិស្សដទៃទៀត សិស្សដទៃទៀតត្រូវព្យាយាមកត់ត្រា។

៤. ក្រោយពីអានសាច់រឿងមួយចប់ គ្រូហៅសិស្សម្នាក់ទៀត ដើម្បីសង្ខេបសាច់រឿងដែលបានអាន។

៥. នៅពេលដែលសិស្សបានអានសាច់រឿងចប់ គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹក ដើម្បីសរសេរពីចំណាប់អារម្មណ៍របស់ខ្លួនប្រវែងមួយទំព័រអំពីសាច់រឿងណាមួយ ដែលខ្លួនគិតថាមានសារៈសំខាន់ និងអំពីមូលហេតុដែលខ្លួនគិតដូច្នោះ។ សិស្សមានពេល១៥នាទីដើម្បីសរសេរចំណាប់អារម្មណ៍។

៦. ១៥នាទីក្រោយមក គ្រូអាចប្រាប់ឲ្យសិស្សចំនួនពីរឬបីនាក់អានចំណាប់អារម្មណ៍របស់ខ្លួនទៅកាន់សិស្ស។

៧. គ្រូប្រាប់ឲ្យសិស្សរក្សាទុកក្រដាសកត់ត្រារបស់ខ្លួនសម្រាប់ប្រើប្រាស់ក្នុងកិច្ចការក្រោយទៀត។

### មេរៀនទី៣៖ ការវិភាគស្តីពីការយល់ឃើញ ឬសាច់រឿងរបស់ខ្មែរក្រហមដែលត្រឡប់មករស់នៅតំបន់អន្លង់វែង និងចរិតលក្ខណៈសម្បត្តិរបស់ តាម៉ុក

គោលបំណង៖

១. សិស្សនឹងធ្វើការស្វែងយល់ពីបទពិសោធន៍បុគ្គលមួយចំនួន ដែលរស់នៅក្នុងអំឡុងពេលនៃការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។

២. សិស្សនឹងធ្វើការវាយតម្លៃពីបទពិសោធន៍បុគ្គលម្នាក់ៗ ដែលរស់នៅក្នុងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

៣. សិស្សនឹងធ្វើការពន្យល់ពីមូលហេតុ ដែលធ្វើឲ្យសាច់រឿងមានសារៈសំខាន់។

សកម្មភាព៖ ការកត់ត្រា ការសរសេរ និងការធ្វើបទបង្ហាញ

បរិក្ខារសម្រាប់សិស្ស៖ ក្រដាសកត់ត្រា ប៊ិច ឬខ្មៅដៃ

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូពន្យល់ទៅកាន់សិស្សថា គ្រូនឹងឲ្យសិស្សម្នាក់ៗអានសាច់រឿងខុសៗគ្នា ស្តីពីប្រវត្តិរបស់ប្រជាជន ដែលបានត្រឡប់មកអន្លង់វែងវិញនៅឆ្នាំ១៩៨៩ ឲ្យឮៗ ម្នាក់ម្តងៗ។ គ្រូគួរប្រាប់សិស្សដទៃឲ្យធ្វើការកត់ត្រា ឲ្យបានល្អនៅពេលដែលសិស្សម្នាក់កំពុងអាន ព្រោះខ្លួននឹងត្រូវប្រើប្រាស់កំណត់ត្រាសម្រាប់ធ្វើកិច្ចការក្រោយទៀត។

២. គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹកចេញ ដើម្បីត្រៀមកត់ត្រាព័ត៌មាន។

៣. គ្រូជ្រើសរើសសិស្សមួយចំនួនឲ្យអានសាច់រឿងនៅក្នុងជំពូកទី២ ផ្នែកទី៧ និងពី២ ទៅ៤រឿងទៀត នៅក្នុងជំពូកទី២ ផ្នែកទី៨។ គ្រូឲ្យសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ទៅសិស្សម្នាក់ ដើម្បីអាសាច់រឿងនៅក្នុងជំពូកទៅកាន់សិស្សដទៃទៀត សិស្សដទៃទៀតត្រូវព្យាយាមកត់ត្រា។

៤. ក្រោយពីអានសាច់រឿងមួយចប់ គ្រូហៅសិស្សម្នាក់ទៀតដើម្បីសង្ខេបសាច់រឿងដែលបានអាន។

៥. នៅពេលដែលសិស្សបានអានសាច់រឿងចប់ គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹក ដើម្បីសរសេរពីចំណាប់អារម្មណ៍របស់ខ្លួនប្រវែងមួយទំព័រអំពីសាច់រឿងណាមួយដែលខ្លួនគិតថាមានសារៈសំខាន់ និងអំពីមូលហេតុដែលគិតដូច្នោះ។ សិស្សមានពេល១៥នាទីដើម្បីសរសេរចំណាប់អារម្មណ៍។

៦. ១៥នាទីក្រោយមក គ្រូអាចប្រាប់ឲ្យសិស្សចំនួនពីរ ឬបីនាក់អានចំណាប់អារម្មណ៍របស់ខ្លួនទៅកាន់សិស្ស។

៧. គ្រូប្រាប់ឲ្យសិស្សរក្សាទុកក្រដាសកត់ត្រារបស់ខ្លួនសម្រាប់ប្រើប្រាស់ក្នុងកិច្ចការក្រោយទៀត។

### មេរៀនទី៤៖ ការវិភាគពីការយល់ឃើញ ឬសាច់រឿងស្តីពីការពិនិត្យមើលតំបន់អន្លង់វែងឡើងវិញ

គោលបំណង៖

១. សិស្សនឹងធ្វើការស្វែងយល់ពីបទពិសោធន៍បុគ្គលមួយចំនួន ដែលរស់នៅក្នុងអំឡុងពេលនៃការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។

២. សិស្សនឹងធ្វើការវាយតម្លៃពីបទពិសោធន៍របស់បុគ្គលម្នាក់ៗ ដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

៣. សិស្សនឹងធ្វើការពន្យល់ពីមូលហេតុ ដែលធ្វើឲ្យសាច់រឿងមានសារៈសំខាន់។

សកម្មភាព៖ ការកត់ត្រា ការសរសេរ និងការធ្វើបទបង្ហាញ

បរិក្ខារសម្រាប់សិស្ស៖ ក្រដាសកត់ត្រា ប៊ិច ឬខ្មៅដៃ

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូពន្យល់ទៅកាន់សិស្សថា គ្រូនឹងឲ្យសិស្សម្នាក់ៗអានសាច់រឿងខុសៗគ្នា ស្តីពីប្រវត្តិរបស់ប្រជាជនដែលបានត្រឡប់មកអន្លង់វែងវិញនៅឆ្នាំ១៩៨៩ ឲ្យឮៗម្នាក់ម្តងៗ។ គ្រូគួរប្រាប់សិស្សដទៃឲ្យធ្វើការកត់ត្រាឲ្យបានល្អនៅពេលដែលសិស្សម្នាក់កំពុងអាន ព្រោះខ្លួននឹងត្រូវប្រើប្រាស់កំណត់ត្រាសម្រាប់ធ្វើកិច្ចការក្រោយៗទៀត។

២. គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹកចេញដើម្បីត្រៀមកត់ត្រាព័ត៌មាន។

៣. គ្រូជ្រើសរើសសិស្សមួយចំនួនឲ្យអានការយល់ឃើញឬសាច់រឿងនៅក្នុងជំពូកទី២ ផ្នែកទី៩។ គ្រូឲ្យសៀវភៅណែនាំសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ទៅសិស្សម្នាក់ ដើម្បីអានសាច់រឿងនៅក្នុងជំពូកទៅកាន់សិស្សដទៃទៀត សិស្សដទៃទៀតត្រូវព្យាយាមកត់ត្រា។

៤. ក្រោយពីអានសាច់រឿងមួយចប់ គ្រូហៅសិស្សម្នាក់ទៀត ដើម្បីសង្ខេបសាច់រឿងដែលបានអាន។

៥. នៅពេលដែលសិស្សបានអានសាច់រឿងចប់ គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹក ដើម្បីសរសេរពីចំណាប់អារម្មណ៍របស់ខ្លួនប្រវែងមួយទំព័រអំពីសាច់រឿងណាមួយដែលខ្លួនគិតថាមានសារៈសំខាន់ និងអំពីមូលហេតុដែលខ្លួនគិតដូច្នោះ។ សិស្សមានពេល១៥នាទី ដើម្បីសរសេរចំណាប់អារម្មណ៍។

៦. ១៥នាទីក្រោយមក គ្រូអាចប្រាប់ឲ្យសិស្សចំនួនពីរឬបីនាក់អានចំណាប់អារម្មណ៍របស់ខ្លួនទៅកាន់សិស្ស។

៧. គ្រូបាប្រ់ឲ្យសិស្សរក្សាទុកក្រដាសកត់ត្រារបស់ខ្លួន សម្រាប់ប្រើប្រាស់ក្នុងកិច្ចការក្រោយទៀត។

### មេរៀនទី៥៖ ស្វ័យវាយតម្លៃរបស់សិស្សស្តីពីការយល់ដឹងពីប្រវត្តិសហគមន៍អន្លង់វែង (ផ្នែកទី ២)

គោលបំណង៖

១. សិស្សនឹងពិចារណាពីប្រភេទសំណួរដែលខ្លួនអាចប្រើប្រាស់បាន ដើម្បីធ្វើការវាយតម្លៃពីការយល់ដឹងរបស់ខ្លួនឯង ស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី២)។

២. សិស្សនឹងវាយតម្លៃពីការយល់ដឹងរបស់គ្នាទៅវិញទៅមក ស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង(ផ្នែកទី២)។

៣. សិស្សនឹងវាយតម្លៃពីការយល់ដឹងរបស់ខ្លួនឯង ស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី២)។

សកម្មភាព៖ ការបង្កើតសំណួរ ការសួរ និងការឆ្លើយ

បរិក្ខារសម្រាប់សិស្ស៖ ក្រដាសកត់ត្រា ប៊ិច ឬខ្មៅដៃ

របៀបវារៈសម្រាប់គ្រូបង្រៀន៖

១. គ្រូពន្យល់ទៅកាន់សិស្សថា គ្រូនឹងអានអត្ថបទស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង(ផ្នែកទី២)។ គ្រូគួរតែប្រាប់សិស្សឲ្យយកចិត្តទុកដាក់ និងកត់ត្រាទុកពីព្រោះគ្រូនឹងសួរសំណួរអំពីអត្ថបទ។

២. គ្រូប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹកចេញ ដើម្បីត្រៀមកត់ត្រានូវព័ត៌មានដែលគ្រូបានអាន។
៣. គ្រូប្រាប់ទៅកាន់សិស្សថា ម្នាក់ៗនឹងមានពេល១០នាទី ដើម្បីបង្កើតសំណួរអំពី ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង (ផ្នែកទី២) ដែលខ្លួនគិតថាមានសារៈសំខាន់ឲ្យបានយ៉ាងតិច១០។ សិស្សត្រូវសរសេរសំណួរនៅលើក្រដាសមួយសន្លឹក ចម្លើយលើក្រដាសមួយសន្លឹកទៀត។ ១០នាទីក្រោយមក សិស្សនឹងស្វែងរកដៃគូម្នាក់ ដើម្បីផ្លាសប្តូរកម្រងសំណួរគ្នាទៅវិញទៅមក។
៤. សិស្សបង្កើតសំណួររៀងៗខ្លួន។
៥. ១០នាទីក្រោយមក គ្រូប្រាប់សិស្សឲ្យរើសដៃគូម្នាក់ ផ្លាស់ប្តូរកម្រងសំណួរគ្នាទៅវិញទៅមក។ សិស្សមានពេលវេលាតែ៥ទៅ១០នាទីតែប៉ុណ្ណោះក្នុងការឆ្លើយសំណួរ។
៦. ១០នាទីក្រោយមក សិស្សឲ្យកម្រងសំណួរដែលឆ្លើយរួចទៅគ្នាវិញ ចាប់ផ្តើមកែនិងដាក់ពិន្ទុឲ្យគ្នាទៅវិញទៅមក។
៧. គ្រូអាចប្រាប់សិស្សឲ្យរាយការណ៍ពីសំណួរដែលខ្លួនឆ្លើយខុស។

## សកម្មភាពទី៦៖ ការវាយតម្លៃ និងការវាស់ស្ទង់អំពីការយល់ដឹងរបស់សិស្ស

បរិក្ខារសម្រាប់សិស្ស៖ តារាងសំណួរខាងក្រោម
របៀបវារៈសម្រាប់គ្រូបង្រៀន៖
១. គ្រូសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ប្រាប់ឲ្យសិស្សកត់ត្រាតាម។
២. នៅពេលដែលសិស្សបានកត់សំណួររួចរាល់ គ្រូប្រាប់សិស្សឲ្យចំណាយពេល១០នាទី ដើម្បីឆ្លើយសំណួរ។
៣. ១០នាទីក្រោយមក គ្រូប្រាប់សិស្សឲ្យប្តូរក្រដាសសំណួរ ដែលបានឆ្លើយរួចជាមួយអ្នកដែលនៅក្បែរខ្លួន បន្ទាប់មកឲ្យសិស្សកែ និងដាក់ពិន្ទុលើក្រដាសសំណួរ។
៤. គ្រូអានចម្លើយ ឬសួររកចម្លើយពីសិស្ស។
៥. នៅពេលដែលកែនិងដាក់ពិន្ទុលើក្រដាសសំណួររួច គ្រូប្រាប់សិស្សឲ្យកត់ពិន្ទុដាក់នៅលើក្រដាសសំណួរ។ គ្រូអាចប្រមូលក្រដាស ឬឲ្យសិស្សជាអ្នកទុក។
៦. នៅពេលដែលសិស្សបានកត់សំណួររួចរាល់ គ្រូប្រាប់សិស្សឲ្យចំណាយពេល ១០ នាទីដើម្បីឆ្លើយសំណួរ។
៧. ១០នាទីក្រោយមក គ្រូប្រាប់សិស្សឲ្យប្តូរក្រដាសសំណួរដែលបានឆ្លើយរួចរបស់ខ្លួនជាមួយអ្នកដែលនៅក្បែរខ្លួន បន្ទាប់មកឲ្យសិស្សកែ និងដាក់ពិន្ទុលើក្រដាសសំណួរ។


សន្តិសុខម្នាក់កំពុងតែឈរនៅក្នុងបរិវេណសារមន្ទីរតាម៉ុក ដែលជាទីតាំងដ៏ទាក់ទាញមួយសម្រាប់អ្នកមកទស្សនានៅសហគមន៍អន្លង់វែង។ នៅពេលអ្នកទស្សនាគិតអំពីអន្លង់វែង គេតែងតែគិតអំពីសារមន្ទីរក្បែរមាត់បឹងមួយនេះ។
ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។



រូបភាពដែលថតបាននៅបឹងមួយដែលមានឈ្មោះថាបឹងទំនប់ថ្មី។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

# ជំពូកទី៥
# កម្រងសំណួរចម្លើយ

## សំណួរ និងចម្លើយ នៅក្នុងមេរៀនស្តីពីប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា

១. តើពាក្យថា «ខ្មែរក្រហម» មានដើមកំណើតចេញមកពីណា?

ចម្លើយ៖ ពាក្យថា «ខ្មែរក្រហម» គឺជាឈ្មោះដែលសម្តេចព្រះ នរោត្តម សីហនុ ហៅពួកកុម្មុយនីស្តដែលប្រឆាំងនឹងទ្រង់នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ ឈ្មោះជាផ្លូវការរបស់ក្រុមគឺ បក្សកុម្មុយនីស្តកម្ពុជា។ ដើមកំណើតនៃរបបខ្មែរក្រហមគឺ ចាប់ផ្តើមចេញពីការតស៊ូប្រឆាំងនឹងអាណា និគមបារាំង។

២. តើវៀតណាមបានដឹកនាំឲ្យមានការបង្កើតបក្សកុម្មុយនីស្តអ្វីនៅក្នុងឆ្នាំ១៩៥១?

ចម្លើយ៖ បក្សកុម្មុយនីស្តវៀតណាមបានដឹកនាំបង្កើត ជាបក្សប្រជាជនបដិវត្តន៍ខ្មែរនៅឆ្នាំ១៩៥១ ដែលក្រោយមកបានក្លាយទៅជាបក្សកុម្មុយនីស្តកម្ពុជា។

៣. នៅក្នុងឆ្នាំ១៩៦០ តើបក្សប្រជាជនបដិវត្តន៍ខ្មែរប្តូរទៅជាបក្សអ្វី?

ចម្លើយ៖ នៅខែកញ្ញា ឆ្នាំ១៩៦០ បក្សប្រជាជនបដិវត្តន៍ខ្មែរបានរៀបចំបក្សរបស់ខ្លួនឡើងវិញ បង្កើតមាគ៌ានយោបាយថ្មី និងផ្លាស់ប្តូរឈ្មោះទៅជាបក្សពលករកម្ពុជា។

៤. តើមេដឹកនាំសំខាន់ៗទាំង៣របស់បក្សពលករកម្ពុជាមាននរណាខ្លះ?

ក. ទូ សាមុត លេខាបក្ស

ខ. នួន ជា អនុលេខាបក្ស

គ. ប៉ុល ពត មានឋានៈទី៣ និងជឿថា បានក្លាយទៅជាអនុលេខាបក្សទី២ នៅឆ្នាំ១៩៦១។

៥. នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៦៣ បក្សពលករកម្ពុជាបានជ្រើសតាំង ប៉ុល ពត ជាលេខាបក្ស និង នួន ជា ជាអនុលេខាបក្ស។

៦. នៅឆ្នាំ១៩៦៣ ប៉ុល ពត បានប្តូរឈ្មោះបក្សពលករកម្ពុជាទៅជា បក្សកុម្មុយនីស្តកម្ពុជា។

៧. គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជារួមមានបុគ្គល ៥រូបដូចខាងក្រោម៖

ចម្លើយ៖ ក. ប៉ុល ពត

ខ. នួន ជា

គ. អៀង សារី

ឃ. វន វ៉េត

ង. សុន សេន

៨. ចូរអ្នករៀបរាប់ពីព្រឹត្តិការណ៍ចំនួន៣ ដែលកើតឡើងនៅចន្លោះឆ្នាំ១៩៧០ និងឆ្នាំ១៩៧៥ ដែលបានជួយជំរុញឲ្យបក្សកុម្មុយនីស្តកម្ពុជាទទួលបានជោគជ័យក្នុងការតស៊ូដណ្តើមអំណាច។

ចម្លើយ៖ ក. រដ្ឋសភាកម្ពុជាបានបោះឆ្នោតទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងជាព្រះប្រមុខរដ្ឋ។

ខ. របប លន់ នល់ ដែលគាំទ្រដោយសហរដ្ឋអាមេរិក ធ្វើសង្គ្រាមប្រឆាំងនឹងកងកម្លាំងកុម្មុយនីស្តវៀតណាម ក្នុងបរិបទមួយដែលហៅថាជាសង្គ្រាមឥណ្ឌូចិនលើកទី២។

គ. កងកម្លាំងកុម្មុយនីស្តវៀតណាមបានរំកិលចូលជ្រៅក្នុងប្រទេសកម្ពុជាធ្វើការប្រយុទ្ធជាមួយកងកម្លាំង លន់ នល់ ជួយបង្វឹក និងជ្រើសរើសទ័ពឲ្យខ្មែរក្រហម។

ឃ. សម្តេចព្រះ នរោត្តម សីហនុ បានក្លាយជាសម្ព័ន្ធមិត្តជាមួយខ្មែរក្រហម។

៩. ចូរអ្នករៀបរាប់ឈ្មោះប្រទេសអន្តរជាតិមួយដែលគាំទ្ររបបខ្មែរក្រហមក្នុងការតស៊ូប្រឆាំងនឹងរបប លន់ នល់។

ចម្លើយ៖ ចិន ឬវៀតណាមខាងជើង។

១០. តើកងទ័ពខ្មែរក្រហមមានចំនួនប៉ុន្មាននៅឆ្នាំ១៩៧០?

ចម្លើយ៖ ប្រហែល ៣ពាន់នាក់។

១១. តើកងទ័ពខ្មែរក្រហមមានចំនួនប៉ុន្មាននៅឆ្នាំ១៩៧៣?

ចម្លើយ៖ ប្រហែល ៤ម៉ឺននាក់។

១២. តើខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញបាននៅពេលណា?

ចម្លើយ ៖ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។



## សំណួរ និងចម្លើយ នៅក្នុងមេរៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

១. តើគោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជាគឺជាអ្វី?

ចម្លើយ៖ គោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជា គឺទៅធ្វើបដិវត្តន៍សង្គមនិយមទាន់ហាន់នៅក្នុងប្រទេស កម្ពុជាតាមរយៈការប្រើប្រាស់កម្មវិធីកែទម្រង់ទាំងស្រុងតាមបែបលទ្ធិម៉ៅនិយម និងម៉ាក្ស-លេនីននិយម។

២. តើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រជាជនតែងតែជម្លៀសដោយបង្ខំពីផ្ទះរបស់ខ្លួនទៅកន្លែងណា?

ចម្លើយ៖ ចេញទៅទីតាំងមួយចំនួននៅតាមទីជនបទ ដើម្បីស្នាក់នៅ និងធ្វើការនៅក្នុងសហករណ៍ ឬអនុវត្តន៍ការងាររបស់អង្គការបក្សផ្សេងៗ។

៣. ចូរអ្នករៀបរាប់ពីរបស់ឲ្យបានយ៉ាងតិច ៣យ៉ាង ដែលហាមឃាត់នៅក្នុងរបបខ្មែរក្រហម។

ចម្លើយ៖ លុយកាក់ ទំនិញលក់ដូរ និងទ្រព្យសម្បត្តិឯកជនបានលុបបំបាត់។ របស់ដែលទាក់ទងនឹងលោកខាងលិចតែងតែបង្កើតឲ្យមានការសង្ស័យ និងហាមឃាត់។ ទ្រព្យសម្បត្តិឯកជនអាចនឹងដកហូត ឬកម្ទេចចោល។

៤. ចូរអ្នករៀបរាប់ពីសកម្មភាពឲ្យបានយ៉ាងតិច ៣យ៉ាងដែលហាមឃាត់នៅក្នុងរបបខ្មែរក្រហម។

ចម្លើយ៖ ក. ការប្រតិបត្តិសាសនា និងវប្បធម៌ត្រូវបានហាមឃាត់។ ខ. គ្មានមធ្យោបាយធ្វើដំណើរឯកជន និងសាធារណៈផ្សេងៗ។

គ. សកម្មភាពកម្សាន្តផ្សេងៗត្រូវបានហាមឃាត់ជាដាច់ខាត។

៥. ខុស ឬត្រូវ៖ ប្រជាជនមានសេរីភាពក្នុងការដើរហើរនៅក្នុងរបបខ្មែរក្រហម។

ចម្លើយ៖ ខុស

៦. ខុស ឬត្រូវ៖ របបខ្មែរក្រហមគោរពសិទ្ធិមនុស្ស។

ចម្លើយ៖ ខុស

៧. ចូរអ្នករៀបរាប់ពីក្រុមមនុស្សឲ្យបានយ៉ាងតិច ៣ប្រភេទក្នុងរបបខ្មែរក្រហម ដែលកំណត់ជាមុខសញ្ញាសម្រាប់ធ្វើទុក្ខបុកម្នេញ៖

ចម្លើយ៖ ក. ជនជាតិភាគតិច និងអ្នកគោរពសាសនា ខ. ជនទាំងឡាយណាដែលមានទំនាក់ទំនងជាមួយរដ្ឋអំណាចចាស់ (លន់ នល់)

គ. អ្នកមានចំណេះដឹង ឃ. អ្នកមានទ្រព្យសម្បត្តិ ង. ជនទាំងឡាយណាដែលសង្ស័យថាជាខ្មាំង

៨. តើមនុស្សចំនួនប៉ុន្មាននាក់ ដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម?

ចម្លើយ៖ មានការជឿជាក់ថាមនុស្សជាង២លាននាក់ស្លាប់នៅក្នុងរបបខ្មែរក្រហម។

៩. តើមូលហេតុចម្បងមួយ ដែលបណ្តាលឲ្យវៀតណាមវាយប្រហារមកលើខ្មែរក្រហមគឺជាអ្វី?

ចម្លើយ៖ កងកម្លាំងខ្មែរក្រហមតែងតែវាយប្រហារវៀតណាម ដែលបង្កឲ្យមានការសងសឹកពីសំណាក់វៀតណាមមកវិញ។

១០. តើនៅក្នុងឆ្នាំណាដែលវៀតណាមបង្កើនការវាយប្រហារយ៉ាងខ្លាំងក្លាមកលើខ្មែរក្រហម?
ចម្លើយ៖ នៅខែមិថុនា ឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានចាប់ផ្តើមទម្លាក់គ្រាប់បែកលើកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ នៅចុងខែធ្នូ ឆ្នាំ១៩៧៨ វៀតណាមបានចាប់បើកការវាយប្រហារទ្រង់ទ្រាយធំមកលើខ្មែរក្រហម។ កងទ័ពវៀតណាម និងកងកម្លាំងប្រឆាំងដែលមានឈ្មោះថា រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា មានកម្លាំងលើសលប់លើកម្លាំងខ្មែរក្រហម។

## សំណួរ និងចម្លើយ នៅក្នុងមេរៀនស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ ផ្នែកទី១

១. នៅចន្លោះឆ្នាំ១៨៦៧ និងឆ្នាំ១៩០៧ តើតំបន់អន្លង់វែងស្ថិតនៅក្នុងផ្នែកមួយរបស់ខេត្តថៃមួយណា?
ចម្លើយ៖ សៀមណាខន។

២. តើប្រទេសកម្ពុជាធ្លាក់ក្រោមអាណាព្យាបាលរបស់បារាំងនៅពេលណា?
ចម្លើយ៖ ឆ្នាំ១៨៦៣។

៣. នៅចន្លោះឆ្នាំ១៩០៧ និងឆ្នាំ១៩៤១ តើអន្លង់វែងស្ថិតនៅក្នុងទឹកដីរបស់ប្រទេសមួយណា?
ចម្លើយ៖ ប្រទេសកម្ពុជា គឺជាប្រទេសស្ថិតនៅក្រោមការគ្រប់គ្រងរបស់បារាំង។

៤. នៅក្នុងឆ្នាំ១៩៤១ តើតំបន់អន្លង់វែងស្ថិតនៅក្នុងខេត្តណាមួយរបស់ប្រទេសថៃ?
ចម្លើយ៖ ប្លែកគីប៊ុនសង់ក្រោម។

៥. តើនៅក្នុងឆ្នាំណាដែលថៃប្រគល់ទឹកដីខេត្តសៀមរាប និងបាត់ដំបងឲ្យមកកម្ពុជាវិញ?
ចម្លើយ៖ ឆ្នាំ១៩៤៦។

៦. អន្លង់វែងជាតំបន់ដាច់ស្រយាល និងអំណោយផលដល់ការកើតមានឧក្រិដ្ឋកម្មអ្វី?
ចម្លើយ៖ ចោរព្រៃ។

៧. តើពេលណាដែលខ្មែរក្រហមកាន់កាប់តំបន់អន្លង់វែង?
ចម្លើយ៖ ឆ្នាំ១៩៧០។

៨. នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសប្រជាជនអន្លង់វែងឲ្យទៅរស់នៅតាមសហករណ៍ ដែលភាគច្រើនមានទីតាំងនៅឯណា?
ចម្លើយ៖ ស្រុកត្រពាំងប្រាសាទ ខេត្តសៀមរាប។ តែមានប្រជាជនមួយចំនួនត្រូវបានជម្លៀសទៅខាងស្រុកវ៉ារិន ស្រីស្នំ សំពេង និងចុងកាល់។

៩. ខុស ឬត្រូវ៖ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អាហារមានភាពសម្បូរបែប កុមារអាចចូលរៀន និងជីវិតរស់នៅមានភាពល្អប្រសើរសម្រាប់ប្រជាជននៅអន្លង់វែង។
ចម្លើយ ៖ ខុស

១០. មានការជឿជាក់ថា នៅស្រុកត្រពាំងប្រាសាទមានវាលពិឃាតមួយកន្លែង តើវាស្ថិតនៅឯណា?
ចម្លើយ៖ ឡពិឃាតភ្នំទ្រង់បាត ក្នុងស្រុកត្រពាំងប្រាសាទ។ ក៏មានការជឿជាក់ថា ស្រុកត្រពាំងប្រាសាទមានវាលពិឃាតមួយទៀត ដែលមានទីតាំងនៅក្បែរឡមួយនៅភ្នំទ្រង់បាត។

១១. នៅពេលដែលកងទ័ពវៀតណាមនិងកងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជា បានផ្តួលរំលំរបបដឹកនាំខ្មែរក្រហម មានប្រជាជនជាច្រើនបានរត់ភៀសខ្លួនទៅប្រទេសថៃ។ ចូរអ្នករៀបរាប់ពីមូលហេតុ ២យ៉ាង ដែលធ្វើឲ្យប្រជាជនរត់ភៀសខ្លួន។
ចម្លើយ៖ ប្រជាជនជាច្រើនភៀសខ្លួនទៅព្រំដែនថៃ ដោយសារហេតុផលច្រើន ដូចជា ទី១ អ្នកខ្លះជឿថា វៀតណាមគឺជាបិសាច។ ទី២ អ្នកខ្លះទៀតជឿថា ជម្រើសតែមួយគត់របស់ខ្លួន គឺចាប់ផ្តើមជីវិតថ្មីនៅប្រទេសក្រៅ។ ចំណែកឯអ្នកផ្សេងទៀតបានជ្រើសរើសយកការភៀសខ្លួនចេញពីប្រទេសកម្ពុជា ដោយសារតែខ្លួនដឹងថាអង្គការសហប្រជាជាតិកំពុងផ្តល់អាហារដល់ជនភៀសខ្លួននៅប្រទេសថៃ អ្នកខ្លះទៀតក៏ធ្លាប់ជាអ្នកធ្វើការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

## សំណួរ និងចម្លើយ នៅក្នុងមេរៀនស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ ផ្នែកទី២

១. នៅចន្លោះឆ្នាំ១៩៧៩ និងឆ្នាំ១៩៨៩ ខ្មែរក្រហមនៅតំបន់អន្លង់វែងភាគច្រើនរស់នៅជំរំជនភៀសខ្លួន ឬនៅក្នុងមូលដ្ឋានយោធាដែលមានឈ្មោះថា ៖
ចម្លើយ៖ ក. ភ្នំ១០០១ ខ. ភ្នំ១០០៣

២. ខ្មែរក្រហមបានកាន់កាប់តំបន់អន្លង់វែងឡើងវិញនៅក្នុងឆ្នាំណា?
ចម្លើយ៖ ឆ្នាំ១៩៨៩

៣. មានប្រទេសចំនួន២ ដែលកំណត់ការស្លាប់រស់របស់ខ្មែរក្រហម។ ប្រទេសទាំងពីរឈ្មោះ៖
ចម្លើយ៖ ក. ថៃ ខ. ចិន

៤. តើសង្គ្រាមប្រភេទណាដែលកងទ័ពខ្មែរក្រហមប្រើប្រាស់ ដើម្បីតស៊ូប្រឆាំងនឹងកងកម្លាំងវៀតណាម និងកម្ពុជា?
ចម្លើយ៖ ក. សង្គ្រាមប្រជាជន ខ. សង្គ្រាមឈ្លប

៥. ចូរអ្នករៀបរាប់ពីការងារចំនួន២ ដែលស្ត្រី ពេលខ្លះជាកុមារ តែងតែធ្វើនៅក្នុងតំបន់អន្លង់វែង?
ចម្លើយ៖ ដាក់អង្គប់ ដឹកជញ្ជូនសម្ភារ ឬផលិតអាវុធ

៦. ខុស ឬត្រូវ៖ ប៉ុល ពត ជាអ្នកគ្រប់គ្រងតំបន់អន្លង់វែង។
ចម្លើយ ៖ ខុស

៧. ខុស ឬត្រូវ៖ ខ្មែរក្រហមយល់ព្រមតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។
ចម្លើយ ៖ ត្រូវ

៨. ខុស ឬត្រូវ៖ ខ្មែរក្រហមបានចូលរួមនៅក្នុងការបោះឆ្នោតជាតិឆ្នាំ១៩៩៣។
ចម្លើយ ៖ ខុស

៩. នៅក្នុងឆ្នាំ១៩៩៧ ប៉ុល ពត បានបញ្ជាឲ្យកូនចៅក្រោមបង្គាប់របស់ខ្លួនសម្លាប់មេបញ្ជាការខ្មែរក្រហមជាន់ខ្ពស់ម្នាក់ចោល។ តើមេបញ្ជាការឈ្មោះអ្វី?
ចម្លើយ ៖ សុន សេន

១០. នៅក្នុងឆ្នាំ១៩៩៧ កងកម្លាំងរបស់ តាម៉ុក និងកងកម្លាំងរបស់ ប៉ុល ពត បានវាយប្រហារគ្នា។ តើនរណាជាអ្នកឈ្នះ?
ចម្លើយ ៖ តាម៉ុក

១១. តើនៅក្នុងខែឆ្នាំណា ដែលកងកម្លាំងខ្មែរក្រហមចុងក្រោយយល់ព្រមចុះចាញ់?
ចម្លើយ ៖ ខែធ្នូ ឆ្នាំ១៩៩៨

១២. តើ តាម៉ុក ស្លាប់នៅពេលណា?
ចម្លើយ ៖ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦



បឹងសិប្បនិម្មិតដែលមានទំហំ៤១៧ហិកតានេះធ្លាប់ជាប្រភពទឹក និងជាអាហារចម្បងសម្រាប់កម្មាភិបាលខ្មែរក្រហមដែលរស់នៅតំបន់។ នៅពេលបច្ចុប្បន្ន បឹងសិប្បនិម្មិតកំពុងបន្តដើរតួជាធនធានយ៉ាងសំខាន់ សម្រាប់ប្រជាជនក្នុងតំបន់អន្លង់វែង។ កាលពីមុន បឹងមានទឹកថ្លា និងសម្បូរត្រី ដើមឈើ រុក្ខជាតិ និងសត្វធំតូចនានា មានចម្ងាយ ២០០ ឬ៣០០ម៉ែត្រពីរង្វង់មូលស្រុកអន្លង់វែងតែប៉ុណ្ណោះ។ នៅរដូវប្រាំងទឹកក្នុងបឹងរីងស្ងួតអស់ ដូច្នេះ តាម៉ុក បានកសាងទំនប់ឡើងដើម្បីទប់ទឹកទុកប្រើប្រាស់ដែលសាងសង់ឡើងតាមដំណាក់កាលជាច្រើនចាប់ផ្តើមពីឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩៤។ ក្រោយមក តាម៉ុក ក៏បានសាងសង់ស្ពានមួយ ដូចដែលយើងឃើញនៅសព្វថ្ងៃ។បឹងនេះត្រូវបានហៅថា បឹងអូរជីក។ ប្រភពព័ត៌មាន៖ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។





ចាប់តាំងពីសម្ពោធនៅឆ្នាំ២០១៤មក មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង តែងតែបានរួមបញ្ចូលនូវការពិចារណាអំពីបរិស្ថានទៅក្នុងផែនការយុទ្ធសាស្ត្រ និងសកម្មភាពរបស់ខ្លួន។ មកដល់ថ្ងៃនេះ បុគ្គលិករបស់មជ្ឈមណ្ឌលបានចំណាយពេលវេលាជាច្រើន ក្នុងការដាំដើមឈើដើម្បីស្តារព្រៃទឹកភ្លៀងក្នុងសហគមន៍ ក៏ដូចជាក្នុងតំបន់ដែលកំពុងតែជួបប្រទះការថយចុះនៃព្រៃឈើ។ តាំងពីការចាប់ផ្តើមរបស់គម្រោងនេះមក មានសិស្សចំនួនជាងមួយរយនាក់មក ដែលបានស្ម័គ្រចិត្តជាមួយនឹងបុគ្គលិករបស់មជ្ឈមណ្ឌល ដើម្បីដាំកូនឈើលើបរិវេណរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងដែលមានទំហំ៣ហិកតា។ សិស្សស្ម័គ្រចិត្តទាំងនោះ ក៏បានចូលរួមកម្មវិធីទស្សនកិច្ចសន្តិភាពរបស់មជ្ឈមណ្ឌល។ ក្នុងឆ្នាំ២០១៦ មានដើមឈើសរុបចំនួន១១០០ដើមត្រូវបានដាំនៅតាមសាលារៀននិងវត្តអារាមនានា។

# ជីវប្រវត្តិអ្នកនិពន្ធ

## បណ្ឌិត លី សុខឃាង

បណ្ឌិត លី សុខឃាង គឺជានាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ជាកូនប្រុសច្បងក្នុងចំណោមបងប្អូនបួននាក់ បណ្ឌិត លី សុខឃាង មានស្រុកកំណើតនៅខេត្តកណ្តាល ហើយឪពុកម្តាយរបស់លោកប្រកបរបរជាអ្នកចម្ការ។ នៅឆ្នាំ២០០២ បណ្ឌិត លី សុខឃាង បានចូលធ្វើការងារស្ម័គ្រចិត្ត និងក្លាយជាបុគ្គលិកពេញសិទ្ធិនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងខណៈដែលលោកកំពុងបន្តការសិក្សាថ្នាក់កម្រិតបរិញ្ញាប័ត្រ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ក្នុងនាមជាបុគ្គលិកដ៏មានសមត្ថភាពម្នាក់ បណ្ឌិត លី សុខឃាង បានទទួលអាហារូបករណ៍ទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិតនៅសាកលវិទ្យាល័យខូវិនទ្រី ចក្រភពអង់គ្លេស នៅឆ្នាំ២០០៥។ នៅពេលដែលលោកបានបញ្ចប់ការសិក្សានៅឆ្នាំ២០០៦ លោកបានត្រលប់មកបំពេញការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាវិញ ជាអ្នកដឹកនាំគម្រោងឯកសាររស់ និងឃ្លាំមើលយុត្តិធម៌។ ចាប់តាំងពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៤ បណ្ឌិត លី សុខឃាង បានចូលសិក្សាថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យខូវិនទ្រី ដែលលោកបានចំណាយពេលប្រាំពីរឆ្នាំ ដើម្បីសរសេរសៀវភៅស្រាវជ្រាវរបស់លោកមានចំណងជើងថា «ដំណើរការនៃការផ្សះផ្សានៅប្រទេសកម្ពុជាពីឆ្នាំ១៩៧៩ដល់ឆ្នាំ២០០៧ មុនពេលមានតុលាការខ្មែរក្រហម»។ លោកក៏បានទទួលការបណ្តុះបណ្តាលពីវិទ្យាស្ថានសម្រាប់ការស៊ើបអង្កេតឧក្រិដ្ឋកម្មអន្តរជាតិ។ បណ្ឌិត លី សុខឃាង គឺជាសហអ្នកនិពន្ធនៃជំពូក «តួនាទីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការផ្សះផ្សា» នៅក្នុងសៀវភៅដែលមានចំណងជើងថា «ការកាត់សេចក្តី៖ ដំណើរការនៃការទទួលខុសត្រូវរបស់ខ្មែរក្រហម»។

## គ្រីស្តូហ្វ័រ ឌៀរីង

គ្រីស្តូហ្វ័រ ឌៀរីង បានបម្រើការនៅវិទ្យាស្ថានស្លឹករឹត និងមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងនាមជាទីប្រឹក្សាផ្នែកច្បាប់ និងអប់រំ និងជាអ្នកស្រាវជ្រាវតាំងពីឆ្នាំ២០០៧។ ក្នុងនាមជាទីប្រឹក្សាផ្នែកអប់រំ គ្រីស្តូហ្វ័រ (ជាមួយសហអ្នកនិពន្ធ បណ្ឌិត ជា ផល្លា) បានបោះពុម្ពសៀវភៅណែនាំសម្រាប់គ្រូបង្រៀន៖ វិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលផ្តល់វិធីសាស្ត្របង្រៀនជាច្រើនដល់លោកគ្រូអ្នកគ្រូនៅទូទាំងប្រទេស ដើម្បីបង្រៀនពីអំពើប្រល័យពូជសាសន៍។ ក្រោមការឧបត្ថម្ភគាំទ្រពីមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានតាក់តែងជំពូកមួយស្តីពីឧក្រិដ្ឋកម្មនៃការជម្លៀសដោយបង្ខំ និងព្រឹត្តិការណ៍ដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ។ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសាលក្រមកាត់ទោសជនជាប់ចោទនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ ដោយបានយល់ស្របដាក់ជំពូកនេះជាគម្រោងសំណងមួយ។

ក្រៅពីបម្រើការងារនៅក្នុងប្រទេសកម្ពុជា លោក គ្រីស្តូហ្វ័រ ក៏បានធ្វើការនៅក្នុងវិស័យជាច្រើន ដូចជា វិស័យវេជ្ជាភិបាល យោធា មនុស្សធម៌ និងការវិនិយោគអន្តរជាតិ។ លោកសូមឧទ្ទិសសៀវភៅនេះជូនចំពោះម្តាយរបស់លោក គឺអ្នកស្រី អេនទ្រេ ឌៀរីង។



រយៈពេល២៥ឆ្នាំបានកន្លងផុតទៅហើយ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀង សន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស។ សន្តិភាពនៅតែមានភាពផុយស្រួយនៅឡើយនៅក្នុងប្រទេសកម្ពុជា។ ក្នុងនាមជាអ្នកទទួលផលប្រយោជន៍ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសម្នាក់ និងក្នុងនាមជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំសូមធ្វើការបញ្ជាក់ និងគាំទ្រអំពីការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងការចូលរួមរបស់មជ្ឈមណ្ឌលនេះ ចំពោះដំណើរការនៃការព្យាយាមសម្រេចឱ្យបាននូវសន្តិភាព។ សន្តិភាពនៅតែជាផ្លូវដ៏វែងឆ្ងាយសម្រាប់ប្រជាជនកម្ពុជា ប្រសិនបើយើងមិនដើររួមគ្នាទេនោះ។

-ឆាំង យុ

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានខិតខំប្រឹងប្រែងក្នុងការកសាងការចងចាំ ការផ្សះផ្សា និងសន្តិភាព ហើយមជ្ឈមណ្ឌលអាចសម្រេចគោលដៅទាំងនេះបានតាមរយៈការសិក្សាអំពីសន្តិភាព និងការអប់រំពីអំពើប្រល័យពូជសាសន៍។ ការសិក្សាអំពីសន្តិភាព បង្ហាញពីការព្យាយាមរបស់មជ្ឈមណ្ឌលក្នុងការកត់សម្គាល់ និងវិភាគអំពីអាកប្បកិរិយាហិង្សា និងអហិង្សា ក៏ដូចជាយន្តការបែបប្រព័ន្ធដែលបង្កឱ្យជម្លោះផ្ទុះឡើង។ចំណែកឯការអប់រំពីអំពើប្រល័យពូជសាសន៍វិញបានតំណាងឲ្យការព្យាយាមរបស់មជ្ឈមណ្ឌល ក្នុងការរៀបរៀងកម្មវិធីសិក្សា ដែលពិភាក្សាអំពីសំណួរមូលដ្ឋានដែលសួរថា តើនៅសម័យខ្មែរក្រហមមានរឿងអ្វីកើតឡើងខ្លះ ហើយហេតុអ្វីបានជារឿងទាំងនោះកើតឡើង។ វិធីសាស្ត្រក្នុងការអប់រំទាំងពីរនេះត្រូវបានអនុវត្តជាមួយនឹងទស្សនៈដែលជំរុញឲ្យមានសន្តិភាព ការអប់រំ និងនីតិរដ្ឋ។

ទីស្នាក់ការថ្មីរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានទីតាំងស្ថិតនៅស្រុកអន្លង់វែងដែលជាតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហម។ មជ្ឈមណ្ឌល មានគោលបំណងផ្សះផ្សាការបែកបាក់រវាងអតីតកម្មាភិបាលខ្មែរក្រហម និងយុវជនកម្ពុជាជំនាន់ក្រោយ តាមរយៈការធ្វើការយ៉ាងជិតស្និតជាមួយសហគមន៍ក្នុងតំបន់ សាលារៀន និងមន្ត្រីទេសចរណ៍នានា។ គោលបំណងរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនេះ គឺជាការផ្តល់នូវកម្មវិធីទាក់ទងនឹងការអប់រំក៏ដូចជាទេសចរណ៍ជាច្រើនដែលជួយថែរក្សាទុករឿងរ៉ាវ វត្ថុ និងទីតាំងប្រវត្តិសាស្ត្រនៅក្នុងតំបន់ ព្រមទាំងកសាងសន្តិភាព និងការផ្សះផ្សារវាងមនុស្សគ្រប់ជំនាន់ និងវណ្ណៈសង្គម។

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មិនត្រឹមតែមានគោលដៅក្នុងការផ្តល់ការយល់ដឹងស៊ីជម្រៅអំពីប្រវត្តិសាស្ត្រហិង្សារបស់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ មជ្ឈមណ្ឌលថែមទាំងមានបំណងផ្សព្វផ្សាយការយល់ដឹងស្តីពីទ្រឹស្តីនានាទាក់ទងនឹងការដោះស្រាយនិងប្រែក្លាយជម្លោះទៀតផង។ ដោយប្រើប្រាស់ទីស្នាក់ការថ្មីនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនឹងសម្រេចគោលដៅរបស់ខ្លួន តាមរយៈកម្មវិធីនានានៅពេលអនាគតដែលផ្តោតសំខាន់ទៅលើការពិភាក្សា ការធ្វើទស្សនកិច្ចនៅតាមទីតាំងប្រវត្តិសាស្ត្រក្នុងតំបន់ និងកម្មវិធីសិក្សាដែលប្រើប្រាស់រឿងរ៉ាវផ្ទាល់ខ្លួនដើម្បីបង្ហាញពីអត្ថន័យអប់រំ និងអត្ថន័យប្រវត្តិសាស្ត្រ។ ការធ្វើទស្សនកិច្ចនឹងជួយឲ្យជនរងគ្រោះ ក៏ដូចជាអតីតកម្មាភិបាលខ្មែរក្រហមទទួលការសះស្បើយផ្លូវអារម្មណ៍ ព្រោះថា ទស្សនកិច្ចទាំងនោះនឹងផ្តល់ឱកាសឲ្យជនរងគ្រោះ និងអតីតកម្មាភិបាល ធ្វើការឆ្លុះបញ្ចាំងព្រមទាំងបញ្ចេញទស្សនៈ យល់ឃើញអំពីបទពិសោធន៍របស់ខ្លួននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និងសម័យសង្គ្រាមស៊ីវិល (១៩៧៩-១៩៩៨) ដែលកើតឡើងបន្តបន្ទាប់។

តាមរយៈការពិភាក្សាទល់មុខគ្នាជាមួយនឹងជនរងគ្រោះ ក៏ដូចជាអតីតកម្មាភិបាលខ្មែរក្រហម កម្មវិធីនេះនឹងជំរុញឱ្យសិក្ខាកាមគិតពិចារណាអំពីភាពទីទៃពីគ្នានៃបទពិសោធន៍របស់មនុស្ស (ទាំងក្នុងឧទាហរណ៍នៃភាពមានមនុស្សធម៌និងភាពអមនុស្សធម៌)នៅក្នុងសម័យកាលនៃជម្លោះនិងចលាចលសង្គម។ រឿងរ៉ាវទាំងនោះបញ្ជាក់អំពីសារសំខាន់នៃមនុស្សម្នាក់ៗ និងជួយជំរុញឱ្យមនុស្សម្នាក់ៗមានមូលដ្ឋានក្នុងការប្រែក្លាយជម្លោះ និងជំនាញពលរដ្ឋ។ គំនិតដូចជា សមត្ថភាពនៃការឆ្លុះបញ្ចាំងការគិតស៊ីជម្រៅ និងការយល់ពីអ្នកដទៃ គឺជាមូលដ្ឋានគ្រឹះសម្រាប់សង្គមប្រជាធិបតេយ្យដែលប្រកបដោយសុខសន្តិភាពទាំងឡាយ។ គម្រោងនេះ ផ្តោតទៅលើប្រវត្តិសាស្ត្រដែលផ្តល់ភាពអាណិតអាសូរដល់គ្នាទៅវិញទៅមក ហើយសិស្សានុសិស្ស គ្រូបង្រៀន និងមគ្គុទ្ទេសក៍ទេសចរណ៍ដែលចូលរួមក្នុងកម្មវិធីនេះ នឹងមានតួនាទីជាអ្នកតំណាងនៅសហគមន៍របស់ខ្លួនក្នុងការចែករំលែកចំណេះដឹង និងការយល់ដឹងរបស់ខ្លួន។

ការបង្កើតមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៅស្រុកអន្លង់វែង តំណាងឱ្យការចាប់ផ្តើមនៃការងាររបស់មជ្ឈមណ្ឌលដែលឆ្ពោះទៅកាន់ការពង្រឹងគោលដៅនៃការកសាងសន្តិភាព ការអប់រំ និងទេសចរណ៍ប្រកបដោយនិរន្តភាព។ តាមរយៈគោលដៅស្នូលទាំងនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបាននិងកំពុងក្លាយទៅជា ស្ថាប័នឈានមុខ សម្រាប់ការអភិវឌ្ឍន៍វិធីសាស្ត្រប្រកបដោយនិរន្តភាពដើម្បីសម្រេចបាននូវការផ្សះផ្សា និងសន្តិភាពក្នុងតំបន់ក៏ដូចជាក្នុងប្រទេសកម្ពុជាទាំងមូល។

២០១៧

9 789924 907817 >

ក្របមុខ៖ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងសមាជិកគណៈអចិន្ត្រៃយ៍របស់គណៈមជ្ឈិម នៃបក្សកុម្មុយនីស្តកម្ពុជា នៅឆ្នាំ១៩៧៥-១៩៧៩។ ឈរបែរទៅមុខពីខាងឆ្វេងមាន ប៉ុល ពត (លេខាបក្សកុម្មុយនីស្តកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ) នួន ជា (អនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ) អៀង សារី (ឧបនាយករដ្ឋមន្ត្រីការបរទេស) សុន សេន (ឧបនាយករដ្ឋមន្ត្រីការពារជាតិ) វ៉ន វេត (ឧបនាយករដ្ឋមន្ត្រីសេដ្ឋកិច្ច)។ អ្នកទាំងនោះកំពុងរង់ចាំទទួលគណៈប្រតិភូចិននៅអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង។ ប្រភពព័ត៌មានៈ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។